# ការពារកុមារកម្ពុជា?

## តួនាទីរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងយន្តការក្រៅផ្លូវការ នៅតាមសហគមន៍ សម្រាប់ការការពារកុមារនៅប្រទេសកម្ពុជា

ខែមីនា ឆ្នាំ២០១៦



unicef
PLAN INTERNATIONAL
Save the Children
ChildFund Cambodia
World Vision

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ៤

**សេចក្តីសង្ខេប** ៥
លទ្ធផលរកឃើញបឋមអំពីការប្រព្រឹត្តទៅរបស់គ.ក.ន.ក ៦
កត្តាដែលរារាំង ឬជំរុញប្រសិទ្ធភាពរបស់គ.ក.ន.ក ៧
អនុសាសន ៩
អក្សរកាត់និងវាក្យសព្ទ ១២
អក្សរកាត់ ១២
វាក្យសព ១២

**សាវតារ និងបរិបទ** ១៤
១.១ ការគំរាមកំហែងចំពោះសុវត្ថិភាពកុមារនៅកម្ពុជា ១៤
១.២ ប្រព័ន្ធការពារកុមារផ្លូវការ និងតួនាទីរបស់ គ.ក.ន.ក ១៦

**វិធីសាស្ត្រនៃការស្រាវជ្រាវ** ២០
២.១ ហេតុផលសម្រាប់ការស្រាវជ្រាវ និងសំណួរស្រាវជ្រាវ ២០
២.២ វិធីសាស្ត្រ ២១
២.៣ លក្ខខណ្ឌរឹតត្បិត ២៥

**ការរំឭកឡើវិញ** ២៦
៣.១ ប្រសិទ្ធភាពរបស់ គ.ក.ន.ក. ២៦
៣.២របាយការណ៍ស្រាវជ្រាវដែលទាក់ទងនឹងអាកប្បកិរិយារបស់សហគមន៍និងអាជ្ញាធរមូលដ្ឋានចំពោះកុមារនិងកិច្ចការពារកុមារ ២៨

**ការរកឃើញ** ៣០
ការអនុវត្តមុខងារ គ.ក.ន.ក. ពាក់ព័ន្ធបញ្ហាការពារកុមារ ៣០
៤.១ ការទទួលខុសត្រូវក្នុងការរាយការណ៍របស់ គ.ក.ន.ក.៖ ចំណាត់ថ្នាក់នៃសំណួរបើក និងការចាត់លំដាប ៣០
៤.២ ការវាយតម្លៃទំនួលខុសត្រូវរបស់ គ.ក.ន.ក ដែលបាន រាយការណ ៣២
៤.២.១ ការលើកកម្ពស់ការយល់ដឹងអំពីចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរកុមារ និងពលកម្មកុមារ ៣២
៤.២.២ ការប្រមូលព័ត៌មានអំពីស្ត្រី និងកុមារ ដើម្បីផ្តល់ជាព័ត៌មាន សម្រាប់ការបែងចែកសេវា ៣៣
៤.២.៣ ការបញ្ជូនទៅរក និងការផ្តល់សេវាការពារកុមារពីសំណាក់ គ.ក.ន.ក. ៣៥
៤.២.៤ ការរៀបចំផែនការការងារ និងថវិកាប្រចាំឆ្នាំ ៤៣
៤.២.៥ ការចូលរួមរបស់កុមារនៅក្នុង គ.ក.ន.ក. ៤៤
ទម្លាប់នៃការការពារកុមារតាមសហគមន៍ (CBCPP) ៤៦

**៥.១ CBCPP ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹង គ.ក.ន.ក** ៤៧
**៥.២ ការពង្រឹងប្រព័ន្ធ CBCPPs ដែលពាក់ព័ន្ធនឹង គ.ក.ន.ក** ៤៧

៥.២.១ ការគាំទ្រសមត្ថភាពចាត់ចែង ៤៧
៥.២.២ ការគាំទ្រសម្រាប់ការអនុវត្តមុខងាររបស់ គ.ក.ន.ក ៤៨
៥.២.៣ ការគាំទ្រដល់ គ.ក.ន.ក ដើម្បីផ្សារភ្ជាប់ទៅរកសេវា ឬផ្តល់ សេវា ៤៩
៥.២.៤ ការគាំទ្រសម្រាប់ការធ្វើផែនទី និងការតាមដានដោយ គ.ក.ន.ក ៥០
៥.២.៥ ការបង្កើតក្រុមកុមារ ៥០
៥.២.៦ ការបង្កើតក្រុមឪពុកម្តាយ ៥១

៥.២.៧ ការបង្កើតក្រុមសម្រាប់គ្រួសារដែលមានប្រវត្តិមានអំពើ ហិង្សា ៥១
៥.២.៨ ការផ្តល់បុគ្គលិកសង្គមកិច្ចដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីធ្វើការជាមួយគ.ក.ន.ក ៥២
CBCPPs និង Non-CBCPPs ៥២

**៦.១ ទម្លាប់ការពារកុមារនៅតាមសហគមន៍បែបប្រពៃណី** ៥២

៦.១.១ ការថែទាំតាមវត្តអារាម ៥២
៦.១.២ ការថែទាំដោយញាតិសន្តាន ៥៣

**៦.១ ទម្លាប់ការពារកុមារមិនមែននៅតាមសហគមន៍** (Non-CBCPPs) ៥៣

៦.២.១ ស្ថាប័នថែទាំបែបគ្រួសារ (RCIs) ៥៣
កត្តារាំងស្ទះឬជំរុញដល់មុខងារនិងប្រសិទ្ធភាពរបស់ គ.ក.ន.ក ៥៥
៧.១ ឥទ្ធិពលនៃគណនេយ្យភាពសាំញ៉ាំ ៥៦
៧.២ ឥទ្ធិពលនៃមូលនិធិ ៥៦
៧.៣ ឥទ្ធិពលនៃការទទួលសេវាការពារកុមារ ៥៧
៧.៤ ឥទ្ធិពលនៃសមត្ថភាពសមាជិក គ.ក.ន.ក ៥៧
៧.៥ ឥទ្ធិពលនៃកង្វះខាតការជឿជាក់លើប្រព័ន្ធយុត្តិធម៌ ៥៨
៧.៦ ឥទ្ធិពលនៃវត្តមាន និងការចូលរួមនៅ គ.ក.ន.ក ៥៩
៧.៧ ឥទ្ធិពលរបស់កុមារ យុវជន និងក្រុមគ្រួសារ ៦០
៧.៨ ឥទ្ធិពលនៃបុគ្គលិកសង្គម ៦១

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៦២

**ឯកសារយោង** ៦៦


## ក្រាហ្វ


ក្រាហ្វ ១៖ ភារកិច្ចស្នូលរបស់ គ.ក.ន.ក. ដែលបានរាយការណ៍ ៣០
ក្រាហ្វ ២៖ ចំណេះដឹងរបស់កុមារអំពី គ.ក.ន.ក ដែលបានរាយការណ៍ ៣៤
ក្រាហ្វ ៣៖ ចំនួន គ.ក.ន.ក ដែលបានជួយកុមារ តាមអ្វីដែល គ.ក.ន.ក បានរាយការណ ៣៥
ក្រាហ្វ ៤៖ ដៃគូរបស់ គ.ក.ន.ក ដូចដែលរាយការណ៍ដោយសមាជិក គ.ក.ន.ក ៤៦
ក្រាហ្វ ៥៖ ភាពប្រឈមរបស់ គ.ក.ន.ក ក្នុងការបំពេញការងារ ដូចដែលរាយការណ៍ដោយសមាជិក គ.ក.ន.ក ៥៥

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សូឡា ហ៊ុយ (Sola Huy) ដែលបានលះបង់ និងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ព្រមទាំងបានបំពេញការងារ ប្រកបដោយវិជ្ជាជីវៈ។ ជាងនេះទៅទៀត អ្នកនិពន្ធក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិកគណៈកម្មាធិការដឹកនាំការសិក្សានេះ និងអ្នកចូលរួមទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ព័ត៌មានសម្រាប់របាយការណ៍នេះ។

មូលនិធិសម្រាប់ការស្រាវជ្រាវនេះមួយចំណែកបានមកពីក្រសួងការងារសហរដ្ឋអាមេរិច (United States Department of Labor) និង មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)។

## ការបដិសេធទំនួលខុសត្រូវ

ខ្លឹមសារនៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីទស្សនៈ ឬគោលនយោបាយរបស់ក្រសួងការងារសហរដ្ឋអាមេរិកឡើយ ហើយការបរិយាយទាក់ទងនឹងឈ្មោះពាណិជ្ជកម្ម ផលិតផលពាណិជ្ជកម្ម ឬអង្គភាពនានាក៏មិនមានន័យថាទទួលបាន ការអនុម័តពីរដ្ឋាភិបាលសហរដ្ឋអាមេរិកដែរ។

Jordanwood, M., 2016. Protecting Cambodia's Children? Phnom Penh: World Vision Cambodia.

# សេចក្ដីសង្ខេប

កុមារនៅក្នុងប្រទេសកម្ពុជា ប្រឈមនឹងការគំរាមកំហែងមួយចំនួនដែលរារាំងដល់ការ ការពាររបស់ពួកគេ។ ការសិក្សានានាពេលកន្លងទៅបានបង្ហាញថា៖

- អំពើហិង្សាលើកុមារគឺជាបញ្ហារាលដាល។ កុមារច្រើនជាង ៥០ ភាគរយបានរាយការណ៍ថាធ្លាប់ទទួលរងនូវអំពើហិង្សា នៅមុនពេលមានអាយុ ១៨ឆ្នាំហើយ កុមារជាង១ភាគ៣ ដែលមានអាយុចាប់ពី ១៣ ដល់ ១៧ឆ្នាំ រាយការណ៍ថាធ្លាប់បានឃើញអំពើហិង្សាលើរាងកាយកើតឡើងនៅក្នុងផ្ទះ របស់ពួកគេក្នុង រយៈពេល១២ខែ ចុងក្រោយ។
- ការរំលោភបំពានផ្លូវភេទក៏ជាបញ្ហាគួរឲ្យបារម្ភផងដែរ៖ កុមារ និងយុវជនម្នាក់ក្នុងចំណោមកុមារ និងយុវជន២០នាក់បានរាយការណ៍ថាយ៉ាងហោចណាស់ត្រូវបានរំលោភបំពានផ្លូវភេទម្ដងនៅមុនពេលពេញវ័យ។
- ជាងនេះទៅទៀត កុមារប្រឈមនឹងហានិភ័យកាន់តែខ្លាំងឡើងដោយសារតែការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច៖ ១៩,១ ភាគរយនៃកុមារដែលមានអាយុ ពី៥ ដល់ ១៧ឆ្នាំ ចូលរួមសកម្មនៅក្នុងសកម្មភាពសេដ្ឋកិច្ច ហើយក្នុងចំណោមកុមារទាំងនោះ មានកុមារ៥៦,៩ភាគរយ ត្រូវបានចាត់ចំណាត់ថ្នាក់ ជាពលករកុមារ ខណៈដែល កុមារ៣១,៣ភាគរយក្នុងចំណោមនោះស្ថិតក្នុងពលកម្មដែលមានភាពគ្រោះថ្នាក់។
- ចំណុចចុងក្រោយគឺ ប្រព័ន្ធយុត្តិធម៌ អាចនឹងបរាជ័យក្នុងការផ្ដន្ទាទោសករណីចោទប្រកាន់ពីបទរំលោភបំពានលើកុមារ ហើយនៅពេលដែលករណីបែបនេះត្រូវបានផ្ដន្ទាទោស ជារឿយៗកុមារមិនត្រូវបានទទួលការគាំទ្រ និងការការពារគ្រប់គ្រាន់នៅក្នុងដំណើរការនេះឡើយ។

ទោះបីជាមានយុទ្ធសាស្ត្រ ផែនការសកម្មភាព និងច្បាប់ជាតិក្នុងការដោះស្រាយបញ្ហាទាំងនេះក៏ពិតមែន ប៉ុន្តែការអនុវត្ត និងការគោរពតាមគោលនយោបាយទាំងនេះ ជារឿយៗ គឺពឹងផ្អែកទៅលើការផ្ដល់សេវាថ្នាក់មូលដ្ឋាននៅកម្រិតឃុំ ឬសង្កាត់តែប៉ុណ្ណោះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ជាក្រសួងដែលទទួលបន្ទុកក្នុងកិច្ចការពារកុមារនៅថ្នាក់ជាតិ ប៉ុន្តែក្រសួងនេះពុំទាន់មានយន្តការក្នុងការផ្ដល់សេវាសង្គមនៅថ្នាក់ឃុំសង្កាត់ ឬមូលនិធិចាំបាច់ដើម្បីគាំទ្រយន្តការបែបនេះនៅឡើយ។ ផ្ទុយទៅវិញ ជារឿយៗ សេវាទាំងនេះត្រូវបានផ្ដល់ដោយអង្គការមិនមែនរដ្ឋាភិបាលនានា ដែលនាំឲ្យការគ្របដណ្ដប់ការផ្ដល់សេវានៅមានកម្រិត និងមានការផ្លាស់ប្ដូរ ទៅតាមចំណុចអាទិភាពរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនោះ។

នៅក្នុងឆ្នាំ២០០៤ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (គ.ក.ន.ក) ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធ្វើជាស្ថាប័នប្រឹក្សារបស់ក្រុមប្រឹក្សាឃុំសង្កាត់។ គ.ក.ន.ក ផ្ដោតទៅលើនារី និងកុមារ និងទទួលបន្ទុកក្នុងការរៀបចំផែនការការគាំទ្រ ការតស៊ូមតិ ការលើកកម្ពស់ការយល់ដឹង ព្រមទាំងការតាមដានបញ្ហាទាំងអស់នោះផងដែរ។ដែលមានទំនាក់ទំនងជាមួយនឹង គ.ក.ន.ក នៅថ្នាក់ភូមិ។ ការសិក្សា ស្រាវជ្រាវនេះ បានកំណត់រកកត្តានានា ដែលបានជំរុញ ឬបន្ទច់បង្អាក់ភាពជោគជ័យរបស់ គ.ក.ន.ក ដែលនឹងជួយផ្ដល់ព័ត៌មានគ្រប់ជ្រុងជ្រោយដល់ទាំងការធ្វើកម្មវិធី និងការធ្វើគោលនយោបាយ។ ឆ្លើយតបទៅនឹងរបាយការណ៍ស្ដីពីការរំលោភបំពានលើកុមារនៅក្នុងសហគមន៍ គ.ក.ន.ក ក៏ដើរតួនាទីជាយន្តការបញ្ជូនបន្តទៅរកសេវាការពារកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងជាអ្នកផ្ដល់សេវាដោយខ្លួនឯងផងដែរ។

ចាប់តាំងពី គ.ក.ន.ក ត្រូវបានបង្កើតមក ការពិនិត្យមើលឡើងវិញ ឬការស្រាវជ្រាវមានតិចតួចប៉ុណ្ណោះពាក់ព័ន្ធនឹង គ.ក.ន.ក។ ការសិក្សានេះមានគោលបំណងដើម្បីបំពេញចន្លោះ ខ្វះខាតក្នុងការផ្ដល់ព័ត៌មានអំពីការប្រព្រឹត្តទៅរបស់ គ.ក.ន.ក ដោយធ្វើការពិនិត្យមើលទាំងលើភាពជោគជ័យក្នុងការបំពេញកិច្ចការនៅក្នុងអាណត្តិដែលមានកំណត់នៅក្នុង គោលនយោបាយ និងតួនាទីដែល គ.ក.ន.ក បានបំពេញក្នុងការផ្ដល់សេវា ឬការផ្សារភ្ជាប់កុមារ និងគ្រួសារ ទៅនឹងសេវាការពារកុមារនានា។ ការសិក្សានេះ ក៏បានវាយតម្លៃទៅលើទម្លាប់នៃការការពារកុមារតាមបែបប្រពៃណីនៅតាមសហគមន៍ និងទម្លាប់នៃការការពារ កុមារដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល ដែលមានទំនាក់ទំនង ជាមួយនឹង គ.ក.ន.ក នៅថ្នាក់ភូមិ។ ការសិក្សា ស្រាវជ្រាវ នេះ បានកំណត់រកកត្តានានា ដែលបានជំរុញ ឬបន្ទច់បង្អាក់ភាពជោគជ័យរបស់ គ.ក.ន.ក ដែលនឹងជួយផ្ដល់ព័ត៌មានគ្រប់ជ្រុងជ្រោយដល់ទាំងការ ធ្វើកម្មវិធី និងការធ្វើ គោលនយោបាយ។

ការសិក្សានេះ ធ្វើឡើងជាចម្បងតាមរយៈវិធីសាស្ត្រលក្ខណៈគុណភាព រួមទាំងតាមរយៈ ការធ្វើសម្ភាសន៍តាមបែបពាក់កណ្ដាលគម្រោងទុក ជាមួយនឹងអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ចំនួន១២៩នាក់នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ និងកិច្ចពិភាក្សាក្រុមគោលដៅជាមួយក្រុមសហគមន៍ចំនួន ១២៧ក្រុម នៅក្នុងឃុំសង្កាត់ចំនួន ៣២ ក្នុងខេត្តចំនួន ១០ និងនៅក្នុងរាជធានីភ្នំពេញ។ ទីកន្លែងត្រូវបានជ្រើសរើសចេញពីក្នុងតំបន់គោលដៅរបស់អង្គការមិនមែន រដ្ឋាភិបាលអន្តរជាតិចំនួន ៤ និងអង្គការពហុភាគីដែលជាអ្នកឧបត្ថម្ភដល់ការសិក្សានេះ។ បន្ថែមលើនេះ ការសម្ភាសចំនួន១២ ត្រូវបានធ្វើជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ ហើយឯកសារចំនួន៦៥ ត្រូវបានពិនិត្យមើលឡើងវិញ។ ក្រោយពីទទួលបានការគាំ ទ្រពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើងចាប់ពី ខែតុលា រហូតដល់ ខែធ្នូ ឆ្នាំ២០១៥។

## លទ្ធផលរកឃើញបឋមអំពីការអនុវត្តមុខងាររបស់ គ.ក.ន.ក

ការសិក្សាបានរកឃើញថា គ.ក.ន.ក ភាគច្រើនដែលត្រូវបានស្ទង់មតិ យ៉ាងហោចណាស់ក៏បានអនុវត្តមុខងារជាអប្បបរមាដែរ៖ រៀបចំកិច្ចប្រជុំប្រចាំខែ អាចពណ៌នាអំពីតួនាទីរបស់ខ្លួន និងអាចផ្តល់ឧទាហរណ៍អំពីករណីនៅពេលដែល គ.ក.ន.ក បានជួយកុមារណាម្នាក់។ គ.ក.ន.ក ទទួលបានភាពជោគជ័យបង្គួរនៅក្នុងការបំពេញតួនាទីតាមនីតិវិធី។ គ.ក.ន.ក ភាគច្រើនបំផុត បានរាយការណ៍ថាបានតាមដានកុមារងាយរងគ្រោះ។ ចំពោះ គ.ក.ន.ក ជាច្រើន ការងារនេះជាដំណើរការក្រៅផ្លូវការ ប៉ុន្តែ គ.ក.ន.ក មួយចំនួនតូច បានទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ក្នុងការបំពេញការងារតាមដានដែលមានភាពស្មុគស្មាញច្រើន។ គ.ក.ន.ក ភាគច្រើនបំផុត ក៏បានរាយការណ៍ថា បានបំពេញផែនការវិនិយោគឃុំសង្កាត់ និងបានចំណាយថវិកាទាំងអស់ដែលបានបម្រុងទុក។ តាមរយៈការពិនិត្យមើលឯកសារភស្តុតាងបង្ហាញថា ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះ គ.ក.ន.ក នៅក្នុងដំណើរការទាំងនេះ បាននាំឲ្យមានការកើនឡើងនៅក្នុងការបែងចែកថវិកា ពីផែនការវិនិយោគឃុំសង្កាត់សម្រាប់សេវាសង្គម (បើធៀបនឹងការស្រាវជ្រាវផ្សេងទៀតដែលបង្ហាញថា ការវិភាជថវិកាសម្រាប់សេវាសង្គមនៅក្នុងផែនការវិនិយោគឃុំសង្កាត់គឺមានចំនួនត្រឹមតែពី ៣ ទៅ ៤ភាគរយប៉ុណ្ណោះ)។

**គ.ក.ន.ក ភាគច្រើនបំផុត៖**

- រាយការណ៍ថា បានធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដើម្បីផ្សព្វផ្សាយអំពីទិដ្ឋភាពនានានៃការការពារកុមារនៅក្នុងសហគមន៍។
- បានបង្ហាញថាមានចំណេះដឹងខ្ពស់គួរសម អំពីបញ្ហាសិទ្ធិកុមារ លើកលែងតែចំណេះដឹងអំពីការរំលោភបំពានផ្លូវភេទ។
- បានរាយការណ៍ថា ការលើកកម្ពស់ការយល់ដឹង និងកិច្ចប្រឹងប្រែងតស៊ូមតិបានប្រព្រឹត្តទៅ ប្រកបដោយប្រសិទ្ធភាព ប៉ុន្តែភស្តុតាងវាស់វែងបរិមាណបន្ថែមទៀតដើម្បីគាំទ្រអំណះអំណាងនេះ ដូចជាការធ្វើតេស្តមុន និងក្រោយពេលការធ្វើ កិច្ចការនេះ មិនអាចរកបានឡើយ។
- សមាជិកមានការយល់ដឹងទាបអំពីតួនាទីដែលកំណត់សម្រាប់អាណត្តិរបស់ខ្លួន។

**មានភស្តុតាងបង្ហាញថា គ.ក.ន.ក បានរំកិលហួសព្រំដែនអាណត្តិរបស់ខ្លួន នៅក្នុងគោលនយោបាយ និងបានចាប់ផ្តើមផ្តល់សេវាការពារកុមារ**

**មានភស្តុតាងបង្ហាញថា គ.ក.ន.ក បានរំកិលហួសព្រំដែនអាណត្តិរបស់ខ្លួន នៅក្នុងគោល នយោបាយ និងបានចាប់ផ្តើមផ្តល់សេវាការពារកុមារ**។ ការផ្លាស់ប្តូរនេះ ត្រូវបានជំរុញដោយកត្តា ជាច្រើន ដូចជាការស្នើសុំជំនួយជាប់ជាប្រចាំ និងអារម្មណ៍វងសម្ពាធដើម្បីដោះស្រាយបញ្ហា ទាំងនេះ ឬការឆ្លើយតបទៅនឹងការផ្តល់មូលនិធិពីអង្គការក្រៅរដ្ឋាភិបាល សម្រាប់សេវាដែលផ្តល់ តាមរយៈ គ.ក.ន.ក។

ការសិក្សានេះ បានពិនិត្យមើលលើប្រសិទ្ធភាពរបស់ គ.ក.ន.ក នៅការក្នុងការដោះស្រាយបញ្ហាការពារកុមារ។ សមាជិករបស់ គ.ក.ន.ក បានបង្ហាញអំពីតម្រូវការចាំបាច់លើវិស័យធំៗចំនួនបួន ដែលពួកគេបានផ្តល់សេវា៖

**ទីមួយ គ.ក.ន.ក ជាច្រើនបានផ្តល់ការគាំទ្រដល់គ្រួសារ ឬផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ហើយកិច្ចអន្តរាគមន៍នេះត្រូវបានរាយការណ៍ថា មានប្រសិទ្ធភាពបំផុត**

**ទីមួយ គ.ក.ន.ក ជាច្រើន បានផ្តល់ការគាំទ្រដល់គ្រួសារ ឬផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ហើយកិច្ចអន្តរាគមន៍នេះ ត្រូវបានរាយការណ៍ថាមានប្រសិទ្ធភាពបំផុត**។ អ្នកចូលរួមបានជឿជាក់ថា ការចូលរៀនជាប់លាប់នៅសាលារៀនបានទប់ស្កាត់កុមារមិនឲ្យធ្លាក់ចូលទៅក្នុងពលកម្មកុមារ។ គ.ក.ន.ក មួយចំនួន បានជួយធ្វើអន្តរាគមន៍នៅពេលដែលកុមារគិតចង់ឈប់រៀនដើម្បីធ្វើការងារ តាមរយៈការចុះទៅតាមផ្ទះដោយផ្ទាល់ និងការផ្តល់ការប្រឹក្សាដល់គ្រួសាររបស់ពួកគេឲ្យអនុញ្ញាតឲ្យកូនបន្តការសិក្សា។ គ.ក.ន.ក ជាច្រើន បានផ្តល់ការគាំទ្រដោយផ្ទាល់លើថ្លៃចំណាយនៅសាលា សម្ភារៈសិក្សា និងគាំទ្រដល់កម្រិតជីវភាពគ្រួសារ ដែលបានជួយឲ្យកុមារបន្តការសិក្សានៅសាលារៀន។ ការជួយគាំទ្រប្រភេទនេះ ត្រូវគេជឿជាក់ថា កើតមានជាទូទៅ ពីព្រោះវាជាតម្រូវការចាំបាច់ដែលសហគមន៍បានលើកឡើង ហើយក៏ដោយសារតែវាជាទម្រង់នៃការគាំទ្រដែលមានភាពងាយស្រួលបំផុតក្នុងការផ្តល់ពីសំណាក់ គ.ក.ន.ក។

**ទីពីរ គ.ក.ន.ក ជាច្រើនបានផ្តល់ការគាំទ្រដល់គ្រួសារដែលទទួលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ គ.ក.ន.ក ភាគច្រើនបំផុតបានជ្រើសយកការផ្សះផ្សាគ្នាជាជាងការកសាងសំណុំរឿង ប្តឹងទៅតុលាការ**

**ទីពីរ គ.ក.ន.ក ជាច្រើន បានផ្តល់ការគាំទ្រដល់គ្រួសារដែលទទួលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ គ.ក.ន.ក ភាគច្រើនបំផុត បានជ្រើសយកការផ្សះផ្សាគ្នាជាជាងការកសាងសំណុំរឿងប្តឹងទៅតុលាការ** ។ ប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាមានកម្រិតខ្ពស់ ហើយកុមាររងគ្រោះដោយសារអំពើហិង្សាដោយផ្ទាល់ផង និងដោយសារការបានជួប្រទះអំពើហិង្សារវាងឪពុកម្តាយរបស់ពួកគេផង។ ករណីអំពើហិង្សាក្នុងគ្រួសារ ជាញឹកញយ ត្រូវបានបញ្ជូនមក គ.ក.ន.ក ដើម្បីដោះស្រាយ ហើយ គ.ក.ន.ក ជាច្រើន បានរាយការណ៍ថាពួកគាត់បានចំណាយពេលវេលាជាច្រើន ក្នុងការដោះស្រាយបញ្ហានេះ។ ខណៈដែលការផ្សះផ្សា ត្រូវបានការសិក្សារកឃើញថា ជាវិធីនិយមប្រើប្រាស់ដោយ គ.ក.ន.ក ភាគច្រើនបំផុត ដែលបានអនុញ្ញាតឲ្យក្រុមគ្រួសារនៅបន្តរស់នៅជួបជុំគ្នាបាននោះ មិនត្រឹមតែមិនបានទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានដាក់ឲ្យជនរងគ្រោះឲ្យប្រឈមនឹងហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារ នាពេលអនាគតទៀតផង (ទាំងដោយសារអំពើហិង្សាដោយផ្ទាល់ និងទាំងដោយសារការឃើញអំពើហិង្សារវាងឪពុកម្តាយ)។ ខណៈដែលអ្នកចូលរួមបានរាយការណ៍ថា កម្មវិធីរបស់ គ.ក.ន.ក ដែលបានគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល មានឥទ្ធិពលវិជ្ជមានទៅលើឥរិយាបថរំលោភបំពានក្នុងរយៈពេលខ្លី ប៉ុន្តែគេមិនច្បាស់ទេថា តើឥទ្ធិពលវិជ្ជមានទាំងនេះអាចមាននិរន្តរភាពឬយ៉ាងណានោះឡើយ។

**ទីបី គ.ក.ន.ក បានពណ៌នាអំពីការទទួលសំណើសុំជំនួយក្នុងករណីកុមារទទួលរងផលប៉ះពាល់ដោយសារការរំលោភបំពានផ្លូវភេទ ដែលផ្តោតតែទៅលើករណីរំលោភសេពសន្ថវៈ ជាជាងការរំលោភ បំពានផ្លូវភេទក្នុងន័យទូលំទូលាយជាងនេះ នេះអាចដោយសារតែកង្វះការយល់ដឹងអំពីទម្រង់ផ្សេងៗ នៃការរំលោភបំពាន**

**ទីបី គ.ក.ន.ក បានពណ៌នាអំពីការទទួលសំណើសុំជំនួយក្នុងករណីកុមារទទួលរងផលប៉ះពាល់ដោយសារការរំលោភបំពានផ្លូវភេទ ដែលផ្តោតតែទៅលើករណីរំលោភសេពសន្ថវៈ ជាជាងការរំលោភបំពានផ្លូវភេទក្នុងន័យទូលំទូលាយជាងនេះ នេះអាចដោយសារតែកង្វះការយល់ដឹងអំពីទម្រង់ផ្សេងៗនៃការរំលោភបំពាន**។ សមាជិក គ.ក.ន.ក ភាគច្រើនបំផុត បានគាំទ្រយ៉ាងពេញទំហឹងចំពោះការចាប់ខ្លួន និងការកសាងសំណុំរឿងទៅតុលាការប្រឆាំងនឹងជនល្មើស ហើយភាគច្រើនបំផុតនៃករណីរំលោភសេពសន្ថវៈ ត្រូវបានដោះ ស្រាយតាមវិធីនេះ។ ទោះជាយ៉ាងណាក៏ដោយ គេបានរកឃើញថាកង្វះសេវាសម្រាប់ជនរងគ្រោះនៅក្នុងសហគមន៍ ហើយជនរងគ្រោះខ្លះត្រូវបានដាក់នៅក្នុងមណ្ឌលដែលធ្វើឲ្យពួកគេបែកពីក្រុមគ្រួសារក្នុងអំឡុងពេលកំពុងទទួលរងផលប៉ះពាល់ពីស្លាក់ស្នាមទុរយស។ ការសិក្សាបានបង្ហាញថា ការដាក់កុមារ ជាពិសេសកុមារតូចៗនៅក្នុងមណ្ឌល ធ្វើឲ្យកុមាររងផលប៉ះពាល់អវិជ្ជមាន ដូច្នេះហើយរាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការដើម្បីកាត់បន្ថយទម្លាប់អនុវត្តន៍បែបនេះ តាមរយៈការអនុវត្តគោលនយោបាយថែទាំជំនួស។

**ចុងក្រោយ គ.ក.ន.ក បានរាយការណ៍ថា បានធ្វើការងារដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកដោយគ្មាន សុវត្ថិភាព**

**ចុងក្រោយ គ.ក.ន.ក បានរាយការណ៍ថា បានធ្វើការងារដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព។** គ.ក.ន.ក ដែលត្រូវបានសម្ភាស ថ្លែងថា ចំណាកស្រុកបានប៉ះពាល់ដល់កុមារនៅក្នុងសហគមន៍របស់ពួកគេដោយលក្ខណៈពីរយ៉ាងសំខាន់ៗ៖ ទីមួយគឺ កុមារដែលបោះបង់ការសិក្សាដើម្បីធ្វើចំណាកស្រុកទៅរកការងារធ្វើ ចំណែកទីពីរគឺ កុមារដែលត្រូវបានទុកចោលដោយឪពុកម្តាយដែលបានធ្វើចំណាកស្រុក។ គ.ក.ន.ក រាយការណ៍ថា បានធ្វើសកម្មភាពលើកកម្ពស់ការយល់ដឹង ដើម្បីទប់ស្កាត់ចំណាកស្រុកដោយគ្មានសុវត្ថិភាព និងបានផ្សារភ្ជាប់ទំនាក់ទំនងកុមារទៅរកសេវានានា ដែលផ្តល់ការគាំទ្រផ្នែកអប់រំ និងសម្ភារៈផ្សេងទៀត។

## កត្តាដែលរារាំង ឬ
## ជំរុញប្រសិទ្ធភាពរបស់ គ.ក.ន.ក

កត្តាមួយចំនួនត្រូវបានរកឃើញថាបានរារាំង ឬជំរុញប្រសិទ្ធភាពរបស់ គ.ក.ន.ក។

**គ.ក.ន.ក ជួបការ លំបាក ជាមួយនឹងគណនេយ្យភាពដែលមានភាពស្មុគស្មាញ**

**គ.ក.ន.ក ជួបការ លំបាក ជាមួយនឹងគណនេយ្យភាពដែលមានភាពស្មុគស្មាញ**។ គ.ក.ន.ក រួមមានសមាសភាពសមាជិក ដែលបានចាត់តាំងជារចនាសម្ព័ន្ធទៅនឹងរបស់ក្រសួងខុសៗគ្នានៅថ្នាក់ជាតិ។ ប្រការនេះ បង្កឲ្យមានការ លំបាកនៅក្នុងទំនួលខុសត្រូវសម្រាប់សមាជិក ម្នាក់ៗរបស់ គ.ក.ន.ក ក៏ដូចជាគណៈកម្មាធិការទាំងមូល ផងដែរ។ គ.ក.ន.ក ផ្ទាល់ ត្រូវទទួលខុសត្រូវចំពោះក្រសួងមហាផ្ទៃ ដែលផ្តោតជាសំខាន់លើ អភិបាលកិច្ច ចំណែកឯមុខងារជាច្រើនរបស់ គ.ក.ន.ក មានជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយអាណត្តិ របស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលទទួលបន្ទុកកិច្ចការពារកុមារ។ ដូច្នេះ សមាជិករបស់ គ.ក.ន.ក អាចនឹងទទួលខុសត្រូវ ចំពោះក្រសួងជាច្រើន ដែលមិនផ្តោតសំខាន់ជាចម្បងលើការ ការពារកុមារ។

**គ.ក.ន.ក ជួបបញ្ហាខ្វះខាតមូលនិធិ ទាំងសម្រាប់ភារកិច្ចរដ្ឋបាល និងទាំងសេវាការពារកុមារ**

**គ.ក.ន.ក ជួបបញ្ហាខ្វះខាតមូលនិធិ ទាំងសម្រាប់ភារកិច្ចរដ្ឋបាល និងទាំងសេវាការពារកុមារ។** សមាជិកភាគច្រើនបំផុតត្រូវបានចាត់តាំងពីមុខតំណែងផ្សេងៗគ្នា (សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ នគរបាល គ្រូបង្រៀន និងបុគ្គលិកមណ្ឌលសុខភាព) ហើយការបំពេញការងារឲ្យ គ.ក.ន.ក ត្រូវបានចាត់ទុកជាភារកិច្ចបន្ថែមដែលគ្មានប្រាក់បៀវត្សរ៍។ កាលពីមុន គ.ក.ន.ក បានទទួលមូលនិធិតាមរយៈអង្គការមិនមែនរដ្ឋាភិបាលពហុភាគី ប៉ុន្តែ មូលនិធិនេះត្រូវបានដកទៅវិញ ហើយបច្ចុប្បន្ន គ.ក.ន.ក ភាគច្រើនបំផុតមិនមានមូលនិធិគ្រប់គ្រាន់សម្រាប់ការបំពេញមុខងារជាមូលដ្ឋាន ដូចជា ថ្លៃចាក់សាំងសម្រាប់មធ្យោបាយធ្វើដំណើរចុះទៅជួបក្រុមគ្រួសារសម្រាប់ការតាមដាន។

**គ.ក.ន.ក ត្រូវបានរារាំងដោយកង្វះបណ្តាញផ្តល់សេវាសង្គមថ្នាក់ជាតិ និងពឹងផ្អែកទៅលើអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់មូលនិធិ ឬផ្សារភ្ជាប់ទំនាក់ទំនង ទៅនឹងសេវាសង្គមសម្រាប់សមាជិក សហាគមន៍**

**គ.ក.ន.ក ត្រូវបានរារាំងដោយកង្វះបណ្តាញផ្តល់សេវាសង្គមថ្នាក់ជាតិ និងពឹងផ្អែកទៅលើអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់មូលនិធិ ឬផ្សារភ្ជាប់ទំនាក់ទំនង ទៅនឹងសេវាសង្គមសម្រាប់សមាជិកសហាគមន៍។** សេវារបស់អង្គការមិនមែនរដ្ឋាភិបាលគ្របដណ្តប់ត្រឹមតែលើតំបន់ភូមិសាស្ត្រមួយចំនួន ឬក្រុមប្រជាពលរដ្ឋ និងសេវាជាក់លាក់ប៉ុណ្ណោះ ដែលនេះមានន័យថា សមាជិក គ.ក.ន.ក អាចនឹងមិនមានលទ្ធភាពបញ្ជូនសមាជិកសហាគមន៍ទៅរកសេវានានា ដែលចាំបាច់ ដោយសារតែកង្វះអត្ថិភាពសេវា។ ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់គំរូឥទ្ធិពលវិជ្ជមាន ដូចជា កំណើនការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងក្លឹបកុមារ និងបុគ្គលិកសង្គមកិច្ចដែលមានបណ្តាញរឹងមាំតផ្សារភ្ជាប់ជាមួយនឹង គ.ក.ន.ក ប៉ុន្តែ ទាំងនេះមិនមែនជាការអនុវត្ត ឬជាប្រភពមូលនិធិដែលមាននិរន្តរភាពឡើយ។

**ប្រសិទ្ធភាពរបស់ គ.ក.ន.ក បានទទួលរងឥទ្ធិពលអវិជ្ជមាន ដោយសារកង្វះសមត្ថភាពបច្ចេកទេស**

ប្រសិទ្ធភាពរបស់ គ.ក.ន.ក បានទទួលរងឥទ្ធិពលអវិជ្ជមានដោយសារកង្វះសមត្ថភាពបច្ចេកទេស។ សមាជិកជាច្រើនរបស់ គ.ក.ន.ក បានទទួលការបណ្តុះបណ្តាល ប៉ុន្តែពួកគេនៅតែត្អូញត្អែរអំពីកង្វះជំនាញ ឬសមត្ថភាពក្នុងការអនុវត្តដំណោះស្រាយចំពោះបញ្ហាការពារកុមារដែលគេបានរកឃើញ។ នៅក្នុងករណីជាច្រើន សមាជិក គ.ក.ន.ក បាន បំពេញតួនាទីជាបុគ្គលិកសង្គមកិច្ច ទាំងខ្លួនបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈតិចតួច តែប៉ុណ្ណោះ ឬគ្មានទាល់តែសោះ ពាក់ព័ន្ធនឹងការអន្តរាគមន៍ផ្អែកសង្គមកិច្ច។

# អនុសាសន៍

ឆ្លើយតបទៅនឹងការរកឃើញនៃការសិក្សានេះ ការផ្លាស់ប្តូរខាងក្រោមនេះត្រូវបានផ្តល់ជាអនុសាសន៍៖

## មូលនិធិ និងធនធាន

**លទ្ធផល រកឃើញសំខាន់ៗ**

- សេវាការពារកុមារនៅថ្នាក់ភូមិ ពុំមានមូលនិធិគាំទ្រគ្រប់គ្រាន់ ដោយគ្មានមូលនិធិច្បាស់លាស់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងមូលនិធិមិនគ្រប់គ្រាន់សម្រាប់ គ.ក.ន.ក។
- ថវិកាឃុំសង្កាត់ច្រើនតែផ្តល់អាទិភាពទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ជាជាងសេវាសង្គមកិច្ច ហើយដំណើរការនៃការប្រើប្រាស់មូលនិធិសម្រាប់សេវាសង្គមកិច្ច មានភាពស្មុគស្មាញជាងវិស័យ និងគម្រោងដទៃទៀត។ ប្រការនេះ អាចឆ្លុះបញ្ចាំងនូវកង្វះចំណេះដឹងអំពីសេវាដែលអាចផ្តល់មូលនិធិដោយថវិកាឃុំសង្កាត់។
- នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលគាំទ្រដំណើរការធ្វើផែនការ និងថវិកា លទ្ធផលគឺកំណើន នៃការវិភាជថវិកាពីកញ្ចប់ថវិកានៃផែនការអភិវឌ្ឍន៍ឃុំសង្កាត់ (CIP) សម្រាប់សេវាសង្គមកិច្ច។

**អនុសាសន៍ សម្រាប់រដ្ឋាភិបាល**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរអនុម័តយុទ្ធសាស្ត្រច្បាស់លាស់ជាងមុន ដើម្បីបង្កើតប្រព័ន្ធផ្តល់សេវាសង្គមកិច្ចទូលំទូលាយមួយ ដែលនឹងបង្កើនសេវាសង្គមកិច្ចការពារកុមារនៅថ្នាក់ភូមិ និងថ្នាក់ឃុំ សម្រាប់រយៈពេលវែង និងរៀបចំសំណើសុំមូលនិធិច្បាស់លាស់ ទៅរាជរដ្ឋាភិបាលកម្ពុជាដើម្បីបានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តប្រព័ន្ធនេះ។
- ជាផ្នែកមួយនៃយុទ្ធសាស្ត្រនេះ ការផ្តល់មូលនិធិដល់ គ.ក.ន.ក តាមរយៈក្រសួងមហាផ្ទៃ គួរត្រូវបានបង្កើនជាមួយនឹងការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើសកម្មភាពទប់ស្កាត់ ការប្រមូលទិន្នន័យការចំណាយសម្រាប់ការចុះទៅដល់ផ្ទះ និងការឆ្លើយតបទៅនឹងករណីរំលោភបំពានកុមារ ព្រមទាំងអំពើហិង្សាក្នុងគ្រួសារ។
- ដំណើរការឃុំសង្កាត់សម្រាប់ការស្នើសុំ និងទទួលបានមូលនិធិសម្រាប់សេវាសង្គមកិច្ច គួរតែពិនិត្យមើលឡើងវិញ និងធ្វើឲ្យមានលក្ខណៈងាយស្រួល។
- គ.ក.ន.ក គួរអប់រំពលរដ្ឋអំពីសេវាសង្គមកិច្ច ដែលអាចផ្តល់មូលនិធិបានតាមរយៈ CIP។

**អនុសាសន៍ សម្រាប់អង្គការ មិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងដៃគូផ្សេងៗ៖**

- អង្គការមិនមែនរដ្ឋាភិបាល គួរបន្តផ្តល់ការគាំទ្រដល់ គ.ក.ន.ក ដើម្បីបំពេញតួនាទីអាណត្តិរបស់ខ្លួនដោយស្របទៅតាមគោលនយោបាយ របស់រដ្ឋាភិបាល ក្នុងនោះរាប់បញ្ចូលទាំងការគាំទ្រសេវាការពារកុមារនៅថ្នាក់មូលដ្ឋាន និងផ្តល់មតិយោបលសម្រាប់ការបង្កើតប្រព័ន្ធជាតិ មួយសម្រាប់សេវាសង្គមកិច្ច។
- អង្គការមិនមែនរដ្ឋាភិបាលគួរបន្តពង្រីកការគាំទ្រដល់ គ.ក.ន.ក និងក្រុមប្រឹក្សាឃុំសង្កាត់ នៅក្នុងដំណើរការធ្វើផែនការ និងថវិកា ព្រមទាំងការតស៊ូមតិដើម្បីជំរុញការបង្កើនវិភាជន៍ថវិកា សម្រាប់សេវាសង្គមកិច្ច (នៅថ្នាក់ឃុំ ស្រុក និងខេត្ត)។
- អង្គការមិនមែនរដ្ឋាភិបាល គួរគាំទ្រការចូលរួមរបស់ពលរដ្ឋដើម្បីឲ្យមានឥទ្ធិពលទៅលើការរៀបចំថវិកា និងតាមដានថវិកាថ្នាក់ឃុំសង្កាត់។

# សកម្មភាព និងការទទួលខុសត្រូវ (កម្មវិធី)

**លទ្ធផល រកឃើញសំខាន់ៗ**

- គ.ក.ន.ក ជាច្រើនបានធ្វើលើសពីតួនាទីរបស់ខ្លួន ដែលបានកំណត់នៅក្នុងគោលនយោបាយ និងបានផ្តល់សេវាការពារកុមារ។ ជារឿយៗ សេវាទាំងនេះមិនគ្រប់គ្រាន់ឡើយ ហើយក្នុងករណីមួយចំនួន បានដាក់ឲ្យកុមារបន្តប្រឈមនឹងហានិភ័យ។
- សមត្ថភាពបច្ចេកទេសនៅមានកម្រិតរបស់ គ.ក.ន.ក បណ្តាលឲ្យការឆ្លើយតបចំពោះករណីការពារកុមារ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ ឧទាហរណ៍ ការពឹងផ្អែកខ្លាំងពេកទៅលើការផ្សះផ្សា ធ្វើឲ្យជនរងគ្រោះបន្តប្រឈមនឹងហានិភ័យ។ ករណីរំលោភបំពានផ្លូវភេទក្រៅពីការរំលោភសេពសន្ថវៈ ជានិច្ចកាលមិនត្រូវបានកំណត់ និងការពឹងផ្អែកខ្លាំងពេកទៅលើមណ្ឌល និងស្ថាប័នថែទាំតាមផ្ទះ ជាការឆ្លើយតបបឋមសម្រាប់កុមារ ដែលត្រូវបានរំលោភសេពសន្ថវៈ។
- ការចូលរួមរបស់ក្រុមសង្គមស៊ីវិលនៅមូលដ្ឋាន ជាពិសេសក្រុមឪពុកម្តាយ និងក្រុមកុមារ អាចនាំឲ្យមានកំណើនក្នុងការរាយការណ៍អំពីការរំលោភបំពានលើកុមារទៅអាជ្ញាធរ ហើយអាចជះឥទ្ធិពលវិជ្ជមានទៅលើការប្រព្រឹត្តទៅរបស់ គ.ក.ន.ក។
- ជារឿយៗ អង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកផ្តល់សេវាការពារកុមារសំខាន់ជាងគេ ប៉ុន្តែកម្មវិធីទាំងនេះត្រូវបានសម្រេចនៅថ្នាក់ជាតិ ដោយមានការចូលរួមមតិយោបល់តិចតួចប៉ុណ្ណោះពី គ.ក.ន.ក ហើយមិនគ្របដណ្តប់ប្រជាជនទាំងអស់នោះទេ។
- កង្វះការជឿទុកចិត្តលើប្រព័ន្ធតុលាការ បានបន្ទច់បង្អាក់ដល់កិច្ចប្រឹងប្រែងដើម្បីបញ្ជូនជនល្មើសទៅផ្តន្ទាទោស ហើយប្រព័ន្ធយុត្តិធម៌នេះទៀតសោត មិនមានលក្ខណៈកុមារមេត្រី ដែលមិនរក្សាការសម្ងាត់ ឬត្រូវអស់កម្រៃច្រើន។
- ការថែទាំមិនផ្លូវការដោយសាច់ញាតិ គឺជាផ្នែកស្នូលនៃការការពារកុមារនៅតាមសហគមន៍។
កម្មវិធីអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលគាំទ្របុគ្គលិកសង្គមកិច្ច ដែលទទួលជនរងគ្រោះពី គ.ក.ន.ក ដំណើរការ
- ប្រកបដោយប្រសិទ្ធភាព និងភាពជោគជ័យ។

**អនុសាសន៍ សម្រាប់រដ្ឋាភិបាល**

- ក្រសួងមហាផ្ទៃគួរតែពិនិត្យឡើងវិញ និងកែសម្រួលតួនាទីរបស់ គ.ក.ន.ក ដើម្បីឲ្យមានភាពច្បាស់លាស់ជាងនេះ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ពួកគេ ក្នុងនោះរាប់បញ្ចូលទាំងមុខងារតាមដាន និងការចូលរួមរបស់កុមារ នារី បុគ្គលិកសង្គមកិច្ច និងមេដឹកនាំសាសនានៅក្នុងគណៈកម្មាធិការ។
- មុខងារតាមដានរបស់ គ.ក.ន.ក គួរតែត្រូវពង្រឹងបន្ថែម ដោយគាំទ្រ គ.ក.ន.ក ឲ្យប្រើប្រាស់ព័ត៌មានដែលប្រមូលបានដើម្បីផ្សារភ្ជាប់ទំនាក់ទំនង ជាមួយសេវាអង្គការមិនមែនរដ្ឋាភិបាល និងធានាឲ្យបាននូវការសម្របសម្រួលសេវានានាជាមួយអ្នកផ្តល់សេវានៅតាមមូលដ្ឋាន។
- ការផ្តោតយកចិត្តទុកដាក់បន្ថែមទៀត និងគោលការណ៍ណែនាំស្តីពីការចូលរួមរបស់កុមារ និងយុវជននៅក្នុង គ.ក.ន.ក គឺត្រូវការជាចាំបាច់ដែលត្រូវតែមាន និងធានាថាការចូលរួមរបស់ពួកគេស្របទៅនឹងឧត្តមប្រយោជន៍របស់ពួកគេ។
- គ.ក.ន.ក គួរជំរុញការថែទាំនៅតាមសហគមន៍ និងទប់ស្កាត់ការដាក់កុមារឲ្យស្ថិតក្រោមការថែទាំតាមផ្ទះដែលមិនចាំបាច់។
ក្រសួងមហាផ្ទៃគួរសហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់ការបណ្តុះបណ្តាល
- កសាងសមត្ថភាពបន្ថែមទៀតដល់ គ.ក.ន.ក លើប្រធានបទដូច ខាងក្រោម៖
    - ការធ្វើថវិកាសម្រាប់បញ្ហាការពារកុមារ
    - ការកំណត់អត្តសញ្ញាណ និងការតាមដានកុមាររងាយរងគ្រោះ
    - ការធានាឲ្យបាននូវសុវត្ថិភាពកុមារនៅពេលឆ្លើយតបទៅនឹងករណីអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទ
    - អត្ថប្រយោជន៍នៃការផ្សារភ្ជាប់កម្មវិធីថែទាំតាមសហគមន៍ និងផលប៉ះពាល់អវិជ្ជមាននៃការថែទាំតាមផ្ទះទៅលើការអភិវឌ្ឍកុមារ
    - ដំណើរការបញ្ជូនបន្តទៅរកសេវា (សេវារដ្ឋាភិបាលក្តី ឬសេវាអង្គការមិនមែនរដ្ឋាភិបាល)។
- ពង្រឹងការអនុវត្តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ដើម្បីធានាឲ្យបាននូវការផ្តន្ទាទោស (និងការដាក់ពន្ធនាគារ) ជនល្មើស និងធ្វើការកែលម្អការគាំទ្រដល់ជនរងគ្រោះ។
- ពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ សមាជិក គ.ក.ន.ក និងនគរបាល ដើម្បីធានាថាពលរដ្ឋនឹងមិនត្រូវបានតម្រូវឲ្យបង់ប្រាក់ក្រៅផ្លូវការសម្រាប់ដំណើរការនីតិវិធីរឿងក្តី និងធានាថាប្រព័ន្ធយុត្តិធម៌ផ្តល់ការរក្សាការសម្ងាត់ និងលទ្ធភាពដល់កុមារ។

**អនុសាសន៍ សម្រាប់អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងដៃគូផ្សេងៗ៖**

- ក្នុងរយៈពេលមធ្យម អង្គការមិនមែនរដ្ឋាភិបាល គួរតែពង្រីកកម្មវិធីផ្តល់បុគ្គលិក/សេវាសង្គមកិច្ច (សម្រាប់ជនរងគ្រោះ និងកុមារងាយរងគ្រោះ និងក្រុមគ្រួសារ) ដែល គ.ក.ន.ក អាចបញ្ជូនទៅរក និងគាំទ្រការពង្រឹងយន្តការសម្របសម្រួលរវាង គ.ក.ន.ក និងអ្នកផ្តល់សេវា (ក្នុងនោះរាប់បញ្ចូលទាំងការកំណត់ចន្លោះខ្វះខាត់ផ្នែកភូមិសាស្ត្រនៅក្នុងការផ្តល់សេវា)។
- បន្តតស៊ូមតិជំរុញឲ្យមានវិភាជន៍ថវិកាឃុំសង្កាត់សម្រាប់បុគ្គលិកសង្គមកិច្ច។
- ពង្រឹងចំណេះដឹង និង ការយល់ដឹងរបស់បុគ្គលិក អំពីតួនាទីរបស់ គ.ក.ន.ក (ដូចដែលបានកំណត់នៅក្នុង គោលនយោបាយ) ព្រមទាំងធានាឲ្យបានថាដៃគូនានាគាំទ្រដល់សមត្ថភាពរបស់ គ.ក.ន.ក ក្នុងការកំណត់ និងការបញ្ជូន សំណុំរឿងការពារកុមារ។
- បន្តគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយការថែទាំតាមផ្ទះ ដោយធ្វើផែនទីជម្រើសនានាសម្រាប់ការថែទាំតាមសហគមន៍ និងការផ្សារភ្ជាប់ឱកាសថ្មីៗជាមួយនឹង គ.ក.ន.ក។
- គាំទ្រកម្មវិធី និងយន្តការដែលផ្តល់ឱកាសឲ្យពលរដ្ឋបញ្ចេញ មតិយោបល់អំពីតម្រូវការ របស់ពួកគេទៅកាន់ គ.ក.ន.ក និងជះឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្តស្តីពីសេវាការពារកុមារ នៅថ្នាក់មូលដ្ឋាន។
- សហប្រតិបត្តិការជាមួយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ នៅថ្នាក់ស្រុក/ខណ្ឌ និងខេត្ត/ក្រុង ដើម្បីធានាឲ្យបានថា ការបញ្ជូនទៅរកសេវា និងការផ្សារភ្ជាប់បណ្តាញរវាងអង្គការក្រៅរដ្ឋាភិបាល និង គ.ក.ន.ក ត្រូវបានសម្របសម្រួលបានល្អ។
- បន្តវាយតម្លៃ ស្រាវជ្រាវ និងរិះរកឱកាសសម្រាប់ការថែទាំដោយសាច់ញាតិនៅក្នុងប្រទេសកម្ពុជា និងបង្កើតគំរូដែលអាចអនុវត្តបានដោយភាពជោគជ័យ។

## រចនាសម្ព័ន្ធរដ្ឋបាល និងគណនេយ្យភាព

**លទ្ធផលរកឃើញសំខាន់ៗ**

- សមាជិក គ.ក.ន.ក មានបន្ទាត់រាយការណ៍ច្របូកច្របល់គ្នាទៅកាន់ក្រសួងខុសៗគ្នា ដែលនាំឲ្យប៉ះពាល់ដល់ការផ្តោតការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តរបស់សមាជិក (ពីនគរបាល មណ្ឌលសុខភាព សាលារៀន និងជូនកាល ពីក្រុមប្រឹក្សាឃុំសង្កាត់)។
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (WCCC) មិនបានចូលរួមជាមួយ គ.ក.ន.ក ឬគាំទ្រ គ.ក.ន.ក ក្នុងលក្ខណៈដ៏មានអត្ថន័យណាមួយឡើយ។

**អនុសាសន៍សម្រាប់រដ្ឋាភិបាល**

- ក្រសួងមហាផ្ទៃ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវតួនាទី និងទំនួលខុសត្រូវរបស់សមាជិក គ.ក.ន.ក និងកសាងយន្តការដែលមានគណនេយ្យភាព។ បទដ្ឋានថ្មីៗ (ដែលអាចតាមដានបាន) គួរតែកំណត់ឲ្យបានច្បាស់លាស់នៅក្នុងឯកសារគោលនយោបាយ។ បទដ្ឋានថ្មីៗទាំងនេះ ក៏គួរលម្អិតផងដែរអំពីតួនាទី ទំនួលខុសត្រូវ និងការចូលរួមរបស់មន្ត្រីមកពីនគរបាល មណ្ឌលសុខភាព សាលារៀន ក្រុមប្រឹក្សាឃុំសង្កាត់ និងតួអង្គរដ្ឋាភិបាលដទៃទៀត។
- ទំនួលខុសត្រូវសម្រាប់ការចែករំលែកព័ត៌មាន (ដូចជា ការចែករំលែកព័ត៌មានរបស់នគរបាល ស្តីពីករណីរំលោភបំពានលើកុមារ ដែលបានរាយការណ៍) គួរតែកំណត់ឲ្យបានច្បាស់លាស់ជាងមុន និងធានាថាសមាជិក គ.ក.ន.ក ដទៃទៀត ឆ្លើយតបតាមតួនាទីរបស់ខ្លួន នៅពេលដែលទទួលបានព័ត៌មានចែករំលែក។
- ក្រសួងមហាផ្ទៃគួរបញ្ជាក់ឲ្យបានច្បាស់លាស់អំពីវិធីដែល WCCC អាចសម្របសម្រួល និងគាំទ្រ គ.ក.ន.ក បានប្រសើរជាងមុន ដើម្បីបំពេញអាណត្តិរបស់ខ្លួនសម្រាប់ការការពារកុមារ។ ប្រការនេះនឹងតម្រូវឲ្យមានការធ្វើវិសោធនកម្មទៅលើប្រកាសដែលមានស្រាប់ ឬគោលនយោបាយថ្មី ដើម្បីលម្អិតអំពីពេលវេលានៃការប្រាស្រ័យទាក់ទងគ្នា យន្តការតាមដាន និងគណនេយ្យភាព និងការឆ្លើយតបរបស់ WCCC ចំពោះបញ្ហានានាដែលលើកឡើងដោយ គ.ក.ន.ក ដើម្បីសុំការគាំទ្របន្ថែម។

**អនុសាសន៍ សម្រាប់អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងដៃគូផ្សេងៗ៖**

- អង្គការមិនមែនរដ្ឋាភិបាលគួរតែធានាថាកម្មវិធីរបស់ខ្លួនគាំទ្រសមាសភាពចម្រុះរបស់ គ.ក.ន.ក និងបង្កើនការផ្សារភ្ជាប់ទៅនឹងវិស័យផ្សេងទៀតឲ្យបានជាអតិបរមា។

# អក្សរកាត់ និងវាក្យសព្ទ

## អក្សរកាត់

| | |
|---|---|
| CBCPP | ទម្លាប់ការការពារកុមារនៅតាមសហគមន៍ |
| CIP | កម្មវិធីវិនិយោគឃុំ ឬសង្កាត់ |
| CDP | ផែនការអភិវឌ្ឍន៍ឃុំ ឬសង្កាត់ |
| C/S | ឃុំ/សង្កាត់ |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| DOSVY | ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MSACC | បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ |
| OoSVY | ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| PACC | គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ |
| UNICEF VBNK | មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ (អតីតជាមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ អន្តរជាតិ) |
| VBNK | វិទ្យាស្ថានបណ្តុះបណ្តាលអ្នកគ្រប់គ្រងការងារ |
| WCCC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |

## វាក្យសព្ទ

ដើម្បីធ្វើការងារនៅក្នុងក្របខ័ណ្ឌដែលមានស្រាប់ វាក្យសព្ទនៅក្នុងរបាយការណ៍នេះ គឺផ្អែកតាមគោលនយោបាយ របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍គម្រោង។ និយមន័យនៃទម្រង់នៃការថែទាំ គឺផ្អែកតាមគោលនយោបាយ ស្តីពីការថែទាំជំនួសរបស់ប្រទេសកម្ពុជា (ទំព័រ ៩-១១)។

**ការថែទាំតាមសហគមន៍ និងតាមគ្រួសារ**

**ការថែទាំតាមសហគមន៍ និងតាមគ្រួសារ** ត្រូវបានកំណត់និយមន័យថា ជាយុទ្ធសាស្ត្រមួយដែលតាក់តែងឡើងដើម្បីផ្តល់លទ្ធភាពឲ្យកុមារអាចបន្តរស់នៅជាមួយគ្រួសាររបស់ខ្លួន ឬត្រូវគេដាក់ឲ្យរស់នៅជាមួយគ្រួសារចិញ្ចឹម នៅក្នុងសហគមន៍របស់ខ្លួន ប្រសិនបើអាច។ ក្នុងបរិបទនេះ គ្រួសាររួមបញ្ចូលទាំងគ្រួសារ និងសាច់ញាតិ ដែលផ្តល់ការថែទាំជាសាច់ញាតិ គ្រួសារដែលមានកុមារជាមេគ្រួសារ និងគ្រួសារចិញ្ចឹម ដែលមិនជាប់សាច់ញាតិជាមួយកុមារ។

**ការថែទាំដោយសាច់ញាតិ**

**ការថែទាំដោយសាច់ញាតិ** ការថែទាំដោយសាច់ញាតិ គឺជាស្ថានភាពមួយដែលសមាជិកគ្រួសារយកកុមារកំព្រា ឬកុមារផ្សេងទៀតមកចិញ្ចឹម។ អ្នកថែទាំអាចជាជីដូនជីតា ម្តាយមីង ឬម្តាយធំ ឪពុកមា ឬឪពុកធំ ឬសាច់ញាតិដទៃទៀតរបស់កុមារ។ ទម្លាប់ទូទៅនេះបានចាក់ឫសគល់យ៉ាងជ្រៅ នៅក្នុងសង្គមកម្ពុជា។ ប៉ុន្តែការថែទាំប្រភេទនេះ អាចផ្អែកលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងឪពុកម្តាយ គ្រួសារសាច់ញាតិ អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរថ្នាក់ជាតិ និងអង្គការ ណាមួយផងដែរ។

**ការថែទាំក្នុងមណ្ឌល**

**ការថែទាំក្នុងមណ្ឌល** គឺជាការរៀបចំរស់នៅជាក្រុមសម្រាប់កុមារ ដែលក្នុងនោះការថែទាំត្រូវបានផ្តល់ឲ្យ ដោយមនុស្សពេញវ័យដែលទទួលបាក់បៀវត្សរ៍សម្រាប់ការផ្តល់សេវា ដូចជា មណ្ឌលកុមារកំព្រា មណ្ឌលស្តារនីតិសម្បទា មណ្ឌលការពារកុមារ ជាដើម។

**ប្រព័ន្ធការពារកុមារ**

**ប្រព័ន្ធការពារកុមារ** ត្រូវបានឲ្យនិយមន័យថាជាយុទ្ធសាស្ត្រទូលំទូលាយ និងប្រកបដោយនិរន្តរភាពមួយ ដែលទប់ស្កាត់ និងឆ្លើយតបទៅនឹងបញ្ហាការពារកុមារ ដោយរួមមានកម្រងច្បាប់ គោលនយោបាយ បទប្បញ្ញត្តិ និងសេវា ដែលត្រូវការចាំបាច់នៅក្នុងគ្រប់វិស័យសង្គម ជាពិសេស សុខុមាលភាពសង្គម អប់រំ សុខភាព សន្តិសុខ និងយុត្តិធម៌ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះហានិភ័យដែលទាក់ទងនឹងការការពារកុមារ។

**យន្តការការពារកុមារនៅតាមសហគមន**

**យន្តការការពារកុមារនៅតាមសហគមន៍** គឺជាមនុស្សម្នាក់ ឬក្រុមមួយ នៅក្នុងសហគមន៍ ដែលផ្តល់ការការពារដល់កុមារ។ វាអាចជាការងារស្ម័គ្រចិត្ត ឬការងារបានប្រាក់កម្រៃ និងអាចរៀបចំឡើងតាមរយៈការគាំទ្រពីខាងក្រៅ (ឧទាហរណ៍ ពីអង្គការមិនមែនរដ្ឋាភិបាល) ឬរៀបចំដោយឯករាជ្យនៅក្នុងសហគមន៍។

**ការរំលោភបំពានផ្លូវភេទ**

**ការរំលោភបំពានផ្លូវភេទ** ត្រូវបានឲ្យនិយមន័យដូចខាងក្រោម៖

ការប៉ះពាល់ផ្លូវភេទដោយគ្មានការព្រមព្រៀង៖ ប្រសិនបើមនុស្សម្នាក់ មិនថាប្រុសក្តី ឬស្រីក្តី បានប៉ះពាល់មនុស្សម្នាកទៀត ក្នុងលក្ខណៈផ្លូវភេទដោយគ្មានការអនុញ្ញាត ប៉ុន្តែមិនបានព្យាយាមបង្ខំមនុស្សម្នាក់ទៀតនោះ ឲ្យរួមភេទក្នុងលក្ខណៈបែបណាមួយនោះទេ។
ការប៉ុនប៉ងរួមភេទដោយគ្មានការព្រមព្រៀង៖ ប្រសិនបើមនុស្សណាម្នាក់បានព្យាយាមធ្វើឲ្យមនុស្សម្នាក់ទៀតរួមភេទដោយលក្ខណៈណាមួយដោយគ្មានការអនុញ្ញាត ប៉ុន្តែមិនបានសម្រេចដូចបំណង។

ការរួមភេទដោយបង្ខំលើរាងកាយ៖ ប្រសិនបើមនុស្សណាម្នាក់បានបង្ខំរាងកាយលើមនុស្សម្នាក់ទៀត ឲ្យរួមភេទក្នុងលក្ខណៈណាមួយ ទោះជាមនុស្សម្នាក់ទៀតនោះ ប្រឆាំងតបត ឬមិនប្រឆាំងតបតក៏ដោយ។

ការរួមភេទដោយបង្ខំ៖ ប្រសិនបើមនុស្សណាម្នាក់បានបង្ខំមនុស្សម្នាក់ទៀត ដោយមធ្យោបាយមិនពាក់ព័ន្ធនឹងរាងកាយឲ្យមនុស្សម្នាក់ទៀតនោះប្រព្រឹត្តការរួមភេទដោយលក្ខណៈណាមួយ នៅពេលដែលមនុស្សម្នាក់ទៀតនោះ មិនចង់រួមភេទ ហើយការរួមភេទនោះបានកើតឡើង។ នៅពេលដែលមនុស្សម្នាក់បង្ខំមនុស្សម្នាក់ទៀតឲ្យរួមភេទ វាអាចនឹងពាក់ព័ន្ធជាមួយអ្វីៗដូចជា ការគំរាមកំហែង ការបៀតបៀន និងការលួងលោម ឬបោកបញ្ឆោតឲ្យមនុស្សម្នាក់ទៀតនោះរួមភេទ។

**អំពើហិង្សាលើរាងកាយ**

**អំពើហិង្សាលើរាងកាយ** ត្រូវបានឲ្យនិយមន័យថាជាអំពើហិង្សាលើរាងកាយ ដូចជា ត្រូវគេទះកំផ្លៀង រុញ ដាល់ ទាត់ធាក់ វាយនឹងរំពាត់ ឬវាយនឹងវត្ថុអ្វីមួយ ច្របាច់ក ខ្ទប់មុខឲ្យថប់ដង្ហើម ប៉ុនប៉ងជ្រមុជទឹកឲ្យលង់ស្លាប់ ដុតជះទឹកក្តៅដាក់ដោយចេតនា ឬគំរាមកំហែងដោយអាវុធ ដូចជា កាបិត ឬអាវុធផ្សេងទៀត។

**ពលកម្មកុមារ**

**ពលកម្មកុមារ៖** និយមន័យពលកម្មកុមារដែលប្រើប្រាស់នៅក្នុងរបាយការណ៍នេះ ត្រូវបានកំណត់ដូចខាងក្រោម៖
ក) កុមារអាយុចាប់ពី ៥ឆ្នាំ ដល់ ១១ឆ្នាំ ដែលចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចណាមួយក្នុងរយៈពេល០១ម៉ោង ឬច្រើនម៉ោងក្នុងមួយសប្តាហ៍នៃការអង្កេត។
ខ) កុមារអាយុពី១២ឆ្នាំ ដល់ ១៤ឆ្នាំ ដែលចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចដែលអនុញ្ញាតបាន (គ្មានគ្រោះថ្នាក់) ក្នុងរយៈពេលលើសពី១២ម៉ោងនៅក្នុងសប្តាហ៍នៃការអង្កេត។
គ) កុមារអាយុពី ១២ឆ្នាំ ដល់ ១៤ឆ្នាំ ដែលចូលរួមនៅក្នុងការងារតិចជាង ១២ម៉ោងនៅក្នុងសប្តាហ៍នៃការអង្កេត ប៉ុន្តែធ្វើការនៅក្នុងឧស្សាហកម្ម និងមុខរបរដែលចាត់ទុកថាមានគ្រោះថ្នាក់។
ឃ) កុមារអាយុពី ១៥ឆ្នាំ ដល់ ១៧ឆ្នាំ ដែលចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចក្នុង រយៈពេលលើសពី៤៨ម៉ោង នៅក្នុងសប្តាហ៍នៃការអង្កេត។
ង) កុមារអាយុពី ១៥ឆ្នាំ ដល់ ១៧ឆ្នាំ ដែលចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេល ៤៨ម៉ោង ឬតិចជាងនេះនៅក្នុងសប្តាហ៍នៃការអង្កេត ប៉ុន្តែធ្វើការនៅក្នុងឧស្សាហកម្ម និងមុខរបរដែលគេចាត់ថាមានគ្រោះថ្នាក់។
ចំនួនពលករកុមារ គឺជាការបូកសរុបចូលគ្នានូវកុមារទាំងអស់ដែលត្រូវនឹងក្រុមអាយុទាំងបីខាងលើនេះ។

**ពលកម្មកុមារដែលគ្រោះថ្នាក់**

**ពលកម្មកុមារដែលគ្រោះថ្នាក់** ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖
ក) កុមារទាំងអស់អាយុពី ៥ឆ្នាំ ដល់ ១៧ឆ្នាំ ដែលធ្វើការងារនៅក្នុងឧស្សាហកម្មដែលចាត់ទុកថាមានគ្រោះថ្នាក់មុខរបរដែលចាត់ទុកថាគ្រោះថ្នាក់ (និង លក្ខណវិនិច្ឆ័យដទៃទៀតដែលបញ្ជាក់នៅក្នុងច្បាប់ជាតិ ក្នុងនោះមិនរាប់បញ្ចូលបទប្បញ្ញត្តិស្តីពីម៉ោងការងារប្រចាំសប្តាហ៍ឡើយ)។
ខ) កុមារទាំងអស់មានអាយុពី ៥ឆ្នាំ ដល់ ១៧ឆ្នាំ ដែលធ្វើការនៅក្នុងឧស្សាហកម្មគ្មានគ្រោះ ថ្នាក់ មុខរបរមិនមានគ្រោះថ្នាក់ (ធ្វើការនៅក្នុងលក្ខខណ្ឌគ្មានគ្រោះថ្នាក់ ដូចដែល បានកំណត់ដោយច្បាប់ជាតិ) ប៉ុន្តែ ធ្វើការលើស ៤៨ម៉ោងនៅក្នុងសប្តាហ៍នៃការអង្កេត។ ចំនួនកុមារនៅក្នុងស្ថានភាពពលកម្មមានគ្រោះថ្នាក់ គឺជាចំនួនសរុបនៃកុមារដែលត្រូវនឹងលក្ខណវិនិច្ឆ័យទាំងពីរខាងលើនេះ។

## ១.១ ការគំរាមកំហែងចំពោះសុវត្ថិភាពកុមារនៅកម្ពុជា

កុមារតំណាងឲ្យមួយភាគធំនៃប្រជាជនកម្ពុជា ដោយ ៣៥ភាគរយនៃប្រជាជនសរុបមានអាយុក្រោម ១៥ឆ្នាំ។ ទោះបីគ្មានរង្វាស់ស្តង់ដារជាតិនៃចំនួនកុមារងាយរងគ្រោះក៏ដោយ ក៏ប៉ុន្តែមានក្រុមកុមារជាក់លាក់មួយចំនួនដែលអាចប្រឈមនឹងហានិភ័យខ្ពស់។ ជាអន្តរជាតិ កុមារដែលរស់នៅក្រៅរង្វង់នៃការថែទាំរបស់គ្រួសារ ត្រូវបានរកឃើញថា ប្រឈមនឹងហានិភ័យខ្ពស់ (Malhomes et al. 2012)។ កុមារប្រហែល ១១ភាគរយ មិនបានកំពុងរស់នៅជាមួយឪពុកម្តាយឡើយ (CDHS 2014)។ ៩ភាគរយនៃកុមារអាយុក្រោម ១៨ឆ្នាំ រស់នៅតែជាមួយម្តាយ ហើយ ២ភាគរយកំពុងរស់នៅតែជាមួយឪពុក (CHDS 2014)។

**កុមារជាច្រើនរស់នៅក្រៅរង្វង់គ្រួសារ**

**កុមារជាច្រើនរស់នៅក្រៅរង្វង់គ្រួសារ** ត្រូវបានដាក់នៅក្នុងមណ្ឌលថែទាំ (RCI)។ កុមារប្រមាណ ៤៨.៧៧៥នាក់ ត្រូវបានប៉ាន់ស្មានថាកំពុងរស់នៅក្នុង RCIs នៅទូទាំងប្រទេសកម្ពុជា។ នេះបើយោងតាមការប៉ាន់ស្មានថ្នាក់ជាតិថ្មីៗរបស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សាកលវិទ្យាល័យ Columbia និងក្រុមហ៊ុនប្រឹក្សាយោបល់ឯកជនមួយ ដែលធ្វើឡើងនាខែមីនា ឆ្នាំ២០១៦។ ការធ្វើផែនទីកាលពីពេលថ្មីៗនេះដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ UNICEF បានផ្តល់តួលេខនៅក្នុងខេត្តចំនួន ៤ និងរាជធានីភ្នំពេញ ដែលបង្ហាញថា កុមារសរុប ១១.៧៨៨នាក់ អាយុក្រោម ១៨ឆ្នាំ ត្រូវបានរាយការណ៍ថាកំពុងរស់នៅក្នុង RCI ២៦៧កន្លែង ក្នុងនោះ RCIs ៣៧កន្លែង គឺជាស្ថាប័នដែលមិនបានចុះបញ្ជី។ បើយោងតាមការធ្វើផែនទីដដែល ចំនួនស្ថាប័នថែទាំរយៈពេលវែង ត្រូវបានរាយការណ៍ថា កើនឡើងពី ១៣៩កន្លែង (ឆ្នាំ២០១៤) ដល់ ២៦៧កន្លែង (ឆ្នាំ២០១៦)។

**កុមារជាច្រើនរស់នៅក្រៅរង្វង់គ្រួសារ**

**ភាពក្រីក្រ** ក៏ជាកត្តាមួយក្នុងការបង្កើនភាពងាយរងគ្រោះរបស់កុមារផងដែរ។ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឲ្យចាប់អារម្មណ៍ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការសិក្សាមួយរបស់ធនាគារពិភពលោក (ឆ្នាំ២០១៣) បានរកឃើញថា ភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងច្រើនគឺពី ៥៣,២ភាគរយ នៅក្នុងឆ្នាំ២០០៤ មកនៅត្រឹម ២០,៥ភាគរយ នៅក្នុងឆ្នាំ២០១២ ហើយការប៉ាន់ស្មានបច្ចុប្បន្នកំណត់អត្រាភាពក្រីក្រនៅត្រឹម ១៧,៧ ភាគរយ ។ ប៉ុន្តែ ការសិក្សាប៉ាន់ស្មានថា ប្រជាជន ៣លាននាក់ រស់នៅលើខ្សែបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ ហើយ ថាការចំណាយបន្ថែមចំនួន ១.២០០រៀល (0,៣ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ នឹងរុញច្រាន ប្រជាជនមួយក្រុមនេះឲ្យធ្លាក់ចុះក្រោមបន្ទាត់ភាពក្រីក្រ ដែលនឹងរុញកម្រិតនៃភាពក្រីក្រឡើងដល់៤0ភាគរយជាក់ជាមិនខាន។

**អំពើហិង្សាលើកុមារ**

**អំពើហិង្សាលើកុមារ** គឺជាបញ្ហារីករាលដាលនៅក្នុងប្រទេសកម្ពុជា។ អង្គការUNICEF(ឆ្នាំ២០១៤) បានរកឃើញថា ជាង៥0ភាគរយនៃកុមារបានរាយការណ៍បានជួយហេតុការណ៍អំពើហិង្សាលើរាងកាយយ៉ាងហោចមួយលើក នៅមុនពេលមានអាយុ ១៨ឆ្នាំ ហើយជាង ៣ភាគ៤នៃកុមារទាំងនេះ ធ្លាប់ជួបហេតុការណ៍អំពើហិង្សាច្រើនដង។ ការសិក្សាមុនៗបានរាយការណ៍កម្រិតខ្ពស់ប្រហាក់ប្រហែលគ្នានេះនៃអំពើរំលោភបំពានរាងកាយលើកុមារ។ អង្គការទស្សនៈ ពិភពលោក (ឆ្នាំ២០១៥) បានរកឃើញថា កុមារប្រហែល ៧0ភាគរយបាននិយាយថា ឪពុកម្តាយរបស់ពួកគេ ឬអ្នកផ្តល់ការថែទាំពួកគេបានប្រើប្រាស់ទណ្ឌកម្មលើរាងកាយជាវិធីសម្រាប់ការដាក់វិន័យ។ ការសិក្សាមួយកាលពីឆ្នាំ២០០៩ បានរកឃើញថា ៦៤ភាគរយនៃអ្នកចូលរួមជឿជាក់ថា ឪពុកម្តាយគួរតែដាក់វិន័យកូនៗដោយការវាយ ប្រសិនបើកូននោះមិនស្តាប់ដំបូន្មាន ហើយ ៦១ភាគរយ បាននិយាយថាគ្រូបង្រៀនមានសិទ្ធិវាយកូនសិស្សប្រសិនបើកូនសិស្សនោះមិនបានធ្វើលំហាត់ (Gourley ឆ្នាំ២០០៩)។ ការសិក្សានេះ កត់សម្គាល់ថា "វាច្បាស់ណាស់ថា ការដាក់ទណ្ឌកម្មចំពោះរាងកាយ និងការស្តីបន្ទោសដោយពាក្យពេចន៍ធ្ងន់ៗ ត្រូវបានអនុវត្តជាទូទៅ និងទទួលយក នៅក្នុងគ្រួសារកម្ពុជាភាគច្រើនបំផុត"។ មានតែក្នុងករណីដែលការវាយដំនោះបណ្តាលឲ្យកុមាររងរបួសធ្ងន់ធ្ងរប៉ុណ្ណោះ ទើបត្រូវគេរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច (Gourley ឆ្នាំ២០០៩)។

---

[1] http://data.worldbank.org/country/cambodia ចូលមើលនៅថ្ងៃទីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥។

**អំពើហិង្សាក្នុងគ្រួសារ**

**អំពើហិង្សាក្នុងគ្រួសារ** ដែលប្រព្រឹត្តទៅលើភរិយាឬប្តី ហើយកូនបានឃើញផ្ទាល់ភ្នែក អាចប៉ះពាល់មិនល្អដល់កុមារ និងត្រូវបានគេបង្ហាញភស្តុតាងថា បណ្តាលឲ្យកុមារលូតលាស់យឺតយ៉ាវ និងបង្កើនប្រេវ៉ាឡង់នៃបញ្ហាសុខភាពរយៈពេលវែង (Kitzman et al. ឆ្នាំ២០០៣, អង្គការUNICEF ឆ្នាំ២០០៤)។ ការអង្កេតស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា (UNICEF ឆ្នាំ២០១៤) បានរកឃើញថា ជាង ១ភាគ៣ នៃអ្នកឆ្លើយតបដែលមានអាយុពី ១៣ ដល់ ១៧ឆ្នាំ ធ្លាប់បានឃើញផ្ទាល់ភ្នែកនូវអំពើហិង្សាលើរាងកាយនៅក្នុងផ្ទះរបស់ខ្លួនក្នុងរយៈ ពេល០១ឆ្នាំចុងក្រោយនេះ ហើយកុមារ៤នាក់ ក្នុងចំណោម ១០នាក់ ធ្លាប់បានឃើញផ្ទាល់ ភ្នែកនូវអំពើហិង្សានៅក្នុងសហគមន៍របស់ពួកគេ។

**ការរំលោភបំពានផ្លូវភេទ**

**ការរំលោភបំពានផ្លូវភេទ** ក៏ជាបញ្ហាដែលគួរឲ្យព្រួយបារម្ភផងដែរ។ អង្គការ UNICEF បានរកឃើញថា កុមារ និងយុវជនម្នាក់ក្នុងចំណោម ២០នាក់ បានរាយការណ៍អំពីហេតុការណ៍រំលោភបំពានផ្លូវភេទយ៉ាងហោចណាស់ម្តងនៅមុនពេលធំពេញវ័យ (ឆ្នាំ២០១៤)។ ស្ទើរតែពាក់កណ្តាលនៃអ្នកចូលរួមជាស្ត្រី និងជាង៣ភាគ៤នៃអ្នកចូលរួមជាបុរស ដែលមានអាយុពី ១៨ឆ្នាំ ដល់ ២៤ឆ្នាំ មិនបានប្រាប់អ្នកណាម្នាក់អំពីហេតុការណ៍រំលោភបំពានផ្លូវភេទនោះឡើយ។ ខណៈដែលពុំទាន់មានបញ្ជីថ្នាក់ជាតិណាមួយដែលកត់ត្រាហេតុការណ៍រំលោភបំពានផ្លូវភេទនៅឡើយ អង្គការ លីកាដូ (ឆ្នាំ២០០៩) បានរកឃើញថា កម្រិតនៃការរំលោភសេពសន្ថវៈបានកើនឡើង និងថា ៧៨ភាគរយនៃជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈដែលបានស្វែងរកការគាំទ្រពីអង្គការសិទ្ធិមនុស្ស អាដហុក គឺជាកុមារ។ ប្រសិនបើកុមារបញ្ចេញឲ្យដឹងអំពីការរំលោភសេពសន្ថវៈ គេជឿជាក់ថា ជាទូទៅ ពួកគេរាយការណ៍ទៅនគរបាល ពីព្រោះគេយល់ឃើញថា ការរំលោភសេពសន្ថវៈ គឺជាទម្រង់ដ៏ធ្ងន់ធ្ងរបំផុតនៃអំពើរំលោភបំពានលើកុមារ (Gourley ឆ្នាំ២០០៩)។ ជាងនេះទៅទៀត គេអាចគិតថា ការរំលោភសេពសន្ថវៈលើកុមារត្រូវបានរាយការណ៍ទូទៅជាងគេ ពីព្រោះវាងាយស្រួលក្នុងការបង្ហាញភស្តុតាងនៅតុលាការថា វាមិនមែនជាការព្រមព្រៀងគ្នាឡើយ។ Gourley (ឆ្នាំ២០០៩) បានរកឃើញថា ២៩ភាគរយនៃអ្នកឆ្លើយតបបានយល់ស្រប ចំពោះការលើកឡើងថា ជួនកាល ការរំលោភសេពសន្ថវៈគឺជាកំហុសរបស់មនុស្សស្រី។

ការសិក្សានានាក៏បានបង្ហាញផងដែរ អំពីនិន្នាការគួរឲ្យបារម្ភមួយ នៅក្នុងលក្ខណៈដែលករណីរំលោភសេពសន្ថវៈត្រូវបានដោះស្រាយ។ នៅក្នុងឆ្នាំ២០០៩ Gourley (ឆ្នាំ២០០៩) និងអង្គការ លីកាដូ (ឆ្នាំ២០០៩) បានរកឃើញថា ការដោះស្រាយក្រៅប្រព័ន្ធតុលាការ និងការរៀបការជាមួយជនល្មើស គឺជាដំណោះស្រាយទូទៅចំពោះករណីរំលោភសេពសន្ថវៈ ដែលមនុស្សជាច្រើនជឿជាក់ថា ជាដំណោះស្រាយត្រឹមត្រូវពីព្រោះវាបានការពារកិត្តិយសរបស់ជនរងគ្រោះ ព្រមទាំងកិត្តិយសក្រុមគ្រួសារផងដែរ។ ការដោះស្រាយប្រភេទទាំងនេះ ត្រូវគេជឿជាក់ថា ដើម្បីការពារអនាគតក្មេងស្រី ពីព្រោះគេជឿថា ក្មេងស្រីដែលបាត់បង់ភាពបរិសុទ្ធពិបាកនឹងរកប្តីបានណាស់ (Gourely ឆ្នាំ២០០៩, Jordanwood ឆ្នាំ២០១០)។

**ពលកម្មកុមារ**

**ពលកម្មកុមារ** កើតមានជាទូទៅនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្នុងតំបន់ជនបទ និងទាំងនៅ ក្នុងតំបន់ទីក្រុង។ ការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា កាលពីឆ្នាំ២០១២ បានរកឃើញ ថាកុមារប្រមាណ ១៩,១ភាគរយដែលមានអាយុពី ៥ឆ្នាំ ដល់ ១៧ឆ្នាំ បានចូលរួមសកម្មនៅក្នុង សកម្មភាពសេដ្ឋកិច្ច ក្នុងនោះ ៨៦,៧ភាគរយគឺនៅតំបន់ជនបទ និង ១៣,៣ភាគរយ នៅតំបន់ទីក្រុង។ ពលកម្មកុមារគឺជាក្រុមកុមារដែលសកម្មនៅក្នុងសកម្មភាពសេដ្ឋកិច្ច។ ក្នុងចំណោមកុមារសកម្មក្នុងសកម្មភាពសេដ្ឋកិច្ចទាំងនេះ ៥៦,៩ ភាគរយត្រូវបានចាត់ថ្នាក់ជាពលករកុមារ និង ៣១,៣ ភាគរយ ស្ថិតក្នុងស្ថានភាពពលកម្មដែលគ្រោះថ្នាក់។ កម្រិតនៃពលកម្មកុមារ និងកុមារនៅក្នុងស្ថានភាពពលកម្មគ្រោះថ្នាក់ នៅក្នុងតំបន់ជនបទ គឺខ្ពស់ជាងនៅតំបន់ទីក្រុង ដោយកុមារទាំអនោះធ្វើការងារនៅក្នុងវិស័យ កសិកម្ម រុក្ខាប្រមាញ់ ឬនេសាទ ឬការងារបម្រើតាមផ្ទះ។ ជាង៣ភាគ៤នៃពលករកុមារទាំងនោះ គឺជាសិស្សដែលបានបោះបង់ការសិក្សា ឬមិនធ្លាប់ចូលរៀនទាល់តែសោះ។

ប្រទេសកម្ពុជាកំពុងជួបប្រទះការកើនឡើងនូវកម្រិតនៃការធ្វើចំណាកស្រុក។ ការសិក្សារយៈពេលវែងទៅលើការធ្វើចំណាកស្រុកនៅកម្ពុជាដែលធ្វើឡើងដោយ CRUMP របស់ក្រសួងផែនការ (MoP) (ឆ្នាំ២០១២) បានផ្តល់ព័ត៌មានអំពីប្រេវ៉ាឡង់ នៃចំណាកស្រុក និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកលើកុមារ។ ប្រហែល ៨០ភាគរយនៃអ្នកចំណាកស្រុកមានអាយុក្រោម ៣០ឆ្នាំ។ ២,៣ភាគរយនៃអ្នកចំណាកស្រុក ធ្វើដំណើររួមគ្នាជាមួយប្តី ឬប្រពន្ធ។ ក្នុងចំណោមអ្នកចំណាកស្រុក ២,៣ភាគរយនេះ ជាង៣ភាគ៤បានធ្វើចំណាកស្រុកដោយយកកូនៗអាយុក្រោម ១៥ឆ្នាំទៅជាមួយ និង ៨ភាគរយទុកកូនចោល។

ភាគច្រើន នៃកុមារដែលឪពុកម្តាយ ទុកចោល (៨៩ភាគរយ) រស់នៅជាមួយជីដូនជីតា។ ទាំងក្រសួងផែនការ (ឆ្នាំ២០១២) និងទាំងអង្គការ UNICEF (មុនឆ្នាំ២០១៤) បានរកឃើញថា ចំណាកស្រុកមានផលប៉ះពាល់ ទាំងវិជ្ជមាន និងអវិជ្ជមានទៅ លើកុមារ។ ការផ្ញើប្រាក់មកស្រុកកំណើតអាចធ្វើឲ្យជីវភាពគ្រួសារប្រសើរ ឡើង ដោយ ៨០,៥ភាគរយ នៃអ្នកចំណាកស្រុក បានជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រុមគ្រួសាររបស់ពួក គេ។ ប៉ុន្តែកុមារដែលជាកូនៗ របស់អ្នកចំណាកស្រុក គឺច្រើនតែបោះបង់ចោលការសិក្សាដើម្បីធ្វើការ និងមានសុខភាពមិនសូវល្អ ឬខ្វះអាហារូបត្ថម្ភ (Hing et al ឆ្នាំ២០១៤)។

**ប្រព័ន្ធតុលាការកម្ពុជា**

**ប្រព័ន្ធតុលាការកម្ពុជា** មិនបានផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់កុមារដែលរាយការណ៍អំពីបទឧក្រិដ្ឋឡើយ។ Reimer (ឆ្នាំ២០១៥) បានសម្ភាសកុមារចំនួន ៥៩នាក់ ដែលបានប្តឹងទៅតុលាការ ហើយបានរកឃើញថា បទល្មើសប្រឆាំងនឹងកុមារ កម្រត្រូវបានគេរាយការណ៍ភ្លាមៗទៅកាន់សមត្ថកិច្ចនគរបាលណាស់ និងថាជារឿយៗ តុលាការមិនបានផ្តល់នូវការគាំទ្រដែលសមស្របសម្រាប់កុមារឡើយ។ កុមារកម្រត្រូវបានគេសម្ភាសតែម្នាក់ឯង ឬដោយមន្ត្រីនគរបាលស្ត្រីណាស់ (ក្នុងករណីរំលោភសេពសន្ថវៈ ប្រការនេះអាចមានសារសំខាន់ជាពិសេស)។ ក្នុងករណីខ្លះ កុមារត្រូវបានមន្ត្រីនគរបាលចំអកដាក់ ហើយក្នុងករណីភាគច្រើនបំផុត កុមារបានជួបមុខផ្ទាល់ជាមួយជនល្មើសក្នុងអំឡុងពេលនៃដំណើរការនីតិវិធី តុលារ។ ២០ភាគរយនៃកុមារដែលបានសម្ភាស ត្រូវបានតម្រូវឲ្យបង់កម្រៃបន្ថែមលើសពីថ្លៃប្រដាប់ក្តីធម្មតា ហើយចំនួននេះអាចនឹងខ្ពស់ជាងអ្វីដែលបានរាយការណ៍ ពីព្រោះកុមារភាគច្រើនមិនដឹងអំពីនីតិវិធីពាក់ព័ន្ធនឹងហិរញ្ញវត្ថុទេ។ ក្រុមគ្រួសារកុមារ ជួបការលំបាកយ៉ាងខ្លាំងក្នុងការរកប្រាក់បង់ថ្លៃប្រាក់ប្រដាប់ក្តី ហើយពេលខ្លះ គ្រួសារភាគច្រើនត្រូវបង្ខំចិត្តខ្ចីប្រាក់គេដើម្បីបានប្រាក់មកបង់ថ្លៃប្រាក់ប្រដាប់ក្តីទៀតផង។

ខណៈដែលបញ្ហាការមិនអើពើគឺជាបញ្ហាមួយនៃការការពារកុមារ ការសិក្សាមិនបានគ្របដណ្តប់លើប្រធានបទនេះទេ ហើយបញ្ហានេះក៏មិនត្រូវបានគូសបញ្ជាក់ថាជាបញ្ហាមួយដែល គ.ក.ន.ក បានឆ្លើយតបឡើយ។

## ១.២ ប្រព័ន្ធការពារកុមារផ្លូវការ និងតួនាទីរបស់ គ.ក.ន.ក

ក្រសួងមហាផ្ទៃ (MoI) មានភារកិច្ចគ្រប់គ្រងស្ថាប័នរដ្ឋបាល ស្ថាប័ននគរបាល និងការពារប្រជាជនកម្ពុជា។ នៅក្នុងឆ្នាំ២០០២ ជាផ្នែកមួយនៃការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា (RGC) តាមរយៈក្រសួងមហាផ្ទៃ បានបង្កើតក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់ ជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន ដែលជ្រើសតាំងដោយការបោះឆ្នោតដើម្បីតំណាងឲ្យសមាជិកសហគមន៍នៅថ្នាក់ឃុំសង្កាត់។

នៅឆ្នាំ២០០៤ បន្ទាប់ពីការបង្កើតក្រុមប្រឹក្សាឃុំសង្កាត់ គ.ក.ន.ក ក៏ត្រូវបានបង្កើតឡើងផងដែរ។ គ.ក.ន.ក គឺជាគណៈកម្មាធិការថ្នាក់ឃុំសង្កាត់ ដែលមានសមាជិកជ្រើសតាំងតាមការបោះឆ្នោត ឬការតែងតាំងអាស្រ័យទៅតាមតួនាទីរបស់ពួកគេ។

គោលនយោបាយចែងថា សមាសភាពរបស់ គ.ក.ន.ក រួមមានប្រធាន និងអនុប្រធានក្រុមប្រឹក្សាឃុំសង្កាត់ (C/S) អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ នាយ ឬនាយរងប៉ុស្តិ៍នគរបាលមួយរូប សមាជិកមួយរូបមកពី

តារាងសង្ខេប ១. តួនាទី និងភារកិច្ចសំខាន់ៗរបស់ គ.ក.ន.ក

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គណៈកម្មាធិការ និងដាក់ជូនសុំការអនុម័តពីក្រុមប្រឹក្សាឃុំសង្កាត់។
- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំសង្កាត់ និងមេឃុំ ចៅសង្កាត់ ចំពោះការងារពាក់ព័ន្ធនឹងកិច្ចការនារី និងកុមារនៅក្នុងឃុំសង្កាត់។
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋ ពាក់ព័ន្ធនឹងសិទ្ធិនារី និងសិទ្ធិកុមារ នៅឃុំសង្កាត់ និងបំផុសចលនាសហគមន៍លើវិស័យសុខភាព ការអប់រំកិច្ចការពារ និងការអភិវឌ្ឍកុមារ ព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារក និងកុមារ។

- ទាក់ទាញការគាំទ្រដើម្បីឲ្យនារីបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តលើការអភិវឌ្ឍនៅមូលដ្ឋានឃុំង្កាត់។
- បង្កើន និងពង្រឹងការប្រាស្រ័យទាក់ទង កិច្ចសហការ និងការសម្របសម្រួល រវាងក្រុមប្រឹក្សាឃុំសង្កាត់ និងអ្នកផ្ដល់សេវាកម្ម និងអ្នកភូមិ ដែលធ្វើសកម្មភាពជូយនារី និងកុមារ នៅក្នុងឃុំសង្កាត់របស់ខ្លួន។
- ជួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការប្រមូល ការវិភាគព័ត៌មាន ទិន្នន័យ ពាក់ព័ន្ធនឹងបញ្ហា និងតម្រូវការរបស់នារី និងកុមារ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ និងកម្មវិធីវិនិយោគឃុំសង្កាត់។
- ចូលរួមអនុវត្ត ពិនិត្យ តាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំសង្កាត់ ពាក់ព័ន្ធស្ថានភាពនារី និងកុមារ។

  តាមដានស្ថានភាពនារី និងកុមារ ក្នុងឃុំសង្កាត់ និងធ្វើរបាយការណ៍ឲ្យបានទៀងទាត់ ជូនក្រុមប្រឹក្សាឃុំសង្កាត់ ព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍ឃុំសង្កាត់។ ដកស្រង់ចេញពី "ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់" (RGC ឆ្នាំ២០០៨)។

គណៈគ្រប់គ្រងសាលា សមាជិកម្មយរូបមកពីមណ្ឌលសុខភាព និងមេភូមិមកពីគ្រប់ភូមិទាំងអស់ ជាសមាជិក (RGC ឆ្នាំ២០០៨)។

តួនាទី និងភារកិច្ចសំខាន់ៗរបស់ គ.ក.ន.ក ត្រូវបានកំណត់នៅក្នុងមុខងាររបស់ គ.ក.ន.ក (RGC ឆ្នាំ ២០០៨) និងត្រូវបានដាក់បញ្ចូលនៅក្នុងតារាងសង្ខេប ១ ជាទូទៅ ភារកិច្ចទាំងនេះរួមមាន ការធ្វើផែនការ ការសម្របសម្រួល ការគេស៊ូមតិ ការលើកកម្ពស់ការយល់ដឹង និងការតាមដាន។ គ.ក.ន.ក ក៏គាំទ្រការតាមដាន និងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព (SSP) (RGC ឆ្នាំ២០១០)។ គោលនយោបាយនេះ ធ្វើឡើងក្នុងគោលបំណងធានាឲ្យបាននូវសុវត្ថិភាព និងសន្តិសុខនៅក្នុងសហគមន៍នៅទូទាំងប្រទេសកម្ពុជា។ គោលនយោបាយនេះត្រូវបានតាក់តែងឡើងដោយក្រសួងមហាផ្ទៃ ដែលជាក្រសួងអាណាព្យាបាលរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក ហើយផ្ដោតជាសំខាន់ទៅលើការទប់ស្កាត់បទល្មើស និងការផ្ដន្ទាទោសជនល្មើស។ គោលនយោបាយភូមិឃុំមានសុវត្ថិភាព រួមមាន ៩ចំណុច៖

> **គ្មានសកម្មភាពលួចឆក់ប្លន់គ្រប់ប្រភេទ**
> **គ្មានការផលិត និងការចែកចាយគ្រឿងញៀនខុសច្បាប់**
> **គ្មានអំពើអនាចារ ការជួញដូរកុមារ អំពើហិង្សាគ្រួសារ**
> **គ្មានក្មេងទំនើង**
> **គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ គ្មានការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ**
> **គ្មានគ្រោះថ្នាក់ចរាចរណ៍**
> **គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ**
> **មានវិធានការទប់ស្កាត់គ្រប់គ្រងគ្រោះមហន្តរាយ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់**
> **គ្មានប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់**

អាជ្ញាធរមូលដ្ឋានមានកាតព្វកិច្ចក្នុងការធានាឲ្យបាននូវសន្តិសុខ របស់សហគមន៍ទាក់ទង ជាមួយនឹងគោលនយោបាយទាំង៩ចំណុចខាងលើ។ សហគមន៍ដែលរាយការណ៍ថា មានបទល្មើសកើតឡើងតិចជាងគេ ត្រូវបានផ្ដល់រង្វាន់ ហើយការសិក្សាមុនៗ បានរកឃើញថា ការផ្ដល់រង្វាន់បែបនេះជំរុញឲ្យមានការលាក់បាំងមិនរាយការណ៍អំពីបទល្មើស (VBNK ឆ្នាំ២០០៩)។

**មានការកត់សម្គាល់ឃើញថានៅក្នុងគោលនយោបាយទាំងនេះ គ.ក.ន.ក មិនទទួលខុសត្រូវលើការផ្ដល់សេវាការពារកុមារដល់ក្រុមគ្រួសារ និងកុមារឡើយ។** ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្ដែង ដោយសារកត្តាមួយចំនួនដែលនឹងលើកយកមកពិភាក្សានៅផ្នែកបន្តបន្ទាប់ខាងក្រោមនេះ (នៅក្នុងចំណុច ការបញ្ជូនទៅរក និងការផ្ដល់សេវាការពារកុមាររបស់ គ.ក.ន.ក) គ.ក.ន.ក មួយចំនួនបានចាប់ផ្ដើមបំពេញ តួនាទីនេះ។

**មានការកត់សម្គាល់ឃើញថានៅក្នុងគោលនយោបាយទាំងនេះ គ.ក.ន.ក មិនទទួលខុសត្រូវលើការផ្ដល់ សេវាការពារកុមារដល់ក្រុមគ្រួសារ និងកុមារឡើយ**

នៅក្នុងឆ្នាំ២០០៩ គណៈកម្មាធិការប្រឹក្សាយោបល់កិច្ចការស្ត្រី និងកុមារ (WCCC) ត្រូវបានបង្កើតឡើងជាយន្តការមួយដើម្បីបង្កើនសិទ្ធិអំណាចដល់ស្ត្រី និងកុមារនៅថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមយុត្តាធិការរបស់ក្រុមប្រឹក្សាស្រុកខណ្ឌ និងខេត្ត ។

នៅក្នុងប្រកាសលេខ ៩២៧៥ WCCC ត្រូវបានប្រគល់ភារកិច្ចឲ្យផ្តល់យោបល់ដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង និងស្រុក/ខណ្ឌ ជុំវិញបញ្ហានានាដែលទាក់ទងជាមួយនឹងស្ត្រី និងកុមារ។ ជាពិសេសភារកិច្ចដែលជាអាណត្តិរបស់គណៈកម្មាធិការនេះ រួមមាន ការសម្របសម្រួលជាមួយមន្ទីរខេត្តនានា និងភាគីពាក់ព័ន្ធ ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក ក្នុងការអនុវត្តសកម្មភាពនានា ដែលទាក់ទងនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ និងការការពារកុមារ ព្រមទាំងស្វែងរកការគាំទ្រពីក្រុមប្រឹក្សាគណៈអភិបាល ក៏ដូចជា គណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សារាជធានី ខេត្តក្រុង និងស្រុកខណ្ឌ ដើម្បីរួមគ្នាដោះស្រាយបញ្ហាសង្គមនានាដែលទាក់ទងនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សា សហគមន៍ និងការការពារកុមារ (សារាចរណែនាំស្តីពីការប្រព្រឹត្តទៅរបស់ គ.ក.ន.ក ឆ្នាំ២០១០ ទំព័រ៩)។
ប៉ុន្តែការស្រាវជ្រាវ (Harachi ឆ្នាំ២០១៤) បង្ហាញថា ក្រុមប្រឹក្សាទាំងនេះមិនមានសកម្មភាពសកម្មនៅឡើយទេ ដោយពួកគេកម្រជួបប្រជុំគ្នា ហើយជារឿយៗ មិនដឹងអំពីភារកិច្ចរបស់ខ្លួនឡើយ។ អាចសន្មត់បានថា WCCC មិនបានចូលរួមជាមួយ ឬមិនជួយគាំទ្រដល់ គ.ក.ន.ក ក្នុងលក្ខណៈណាមួយប្រកបដោយអត្ថន័យនោះទេ។

**គ.ក.ន.ក ក៏ត្រូវបានបញ្ជាក់នៅក្នុងគោលនយោបាយជាតិ និងក្របខ័ណ្ឌស្ថាប័នដែលបង្កើតឡើង និង ជំរុញដោយក្រសួងផ្សេងៗទៀត ក្រៅពីក្រសួងមហាផ្ទៃផងដែរ**

គ.ក.ន.ក ក៏ត្រូវបានបញ្ជាក់នៅក្នុងគោលនយោបាយជាតិ និងក្របខ័ណ្ឌស្ថាប័នដែលបង្កើតឡើង និងជំរុញដោយក្រសួងផ្សេងៗទៀតក្រៅពីក្រសួងមហាផ្ទៃផងដែរ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាក្រសួងដែលមានភារកិច្ចក្នុងការការពារ និងផ្តល់សេវាដល់កុមារ និងប្រជាជនងាយរងគ្រោះ។ នៅថ្នាក់ជាតិ MoSVY ដឹកនាំក្រុមប្រឹក្សា និងក្រុមការងារពិសេសមួយចំនួន ដែលតាក់តែងគោលនយោបាយ និងសម្របសម្រួលសេវានានាដែលផ្តល់ដោយអង្គការ មិនមែនរដ្ឋាភិបាល នៅក្នុងវិស័យការថែទាំតាមផ្ទះ សមាហរណកម្ម កុមារអនាថា ជនពិការ និងកុមារងាយរងគ្រោះទូទៅ។

នៅថ្នាក់ក្រោមជាតិ នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងឲ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ស្រុក។ នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្តល់សេវាការពារកុមារមួយភាគធំ តាមរយៈការថែទាំជាលក្ខណៈស្ថាប័ន ដោយគ្រប់គ្រងមណ្ឌលថែទាំ និងមណ្ឌលស្តារយុវនីតិសម្បទាជនញៀនគ្រឿងញៀន ចំនួន ២១កន្លែង ។ នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កម្រនឹងចូលរួមនៅក្នុងការផ្តល់សេវាសង្គមកិច្ច ដោយផ្ទាល់ដល់ក្រុមគ្រួសារនៅក្នុងសហគមន៍ណាស់។ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាយការណ៍អំពីគ្រួសារ និងកុមារងាយរងគ្រោះជូននាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាពីថ្នាក់ឃុំសង្កាត់ ក្រុង ឬខណ្ឌ។ យោងតាមប្រកាសលេខ ៣៥៩ នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនមានភារកិច្ចផ្តល់សេវាសង្គមកិច្ចដោយផ្ទាល់ឡើយ។

**គេមិនដឹងច្បាស់ទេថាតើនាយកដ្ឋាន សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានទំនាក់ទំនងជាមួយ គ.ក.ន.ក ឬអត់នោះទ**

Harachi (ឆ្នាំ២០១៤) នៅក្នុងរបាយការណ៍ពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ច បានកត់សម្គាល់ថា ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ មានបុគ្គលិកថ្នាក់ក្រោមជាតិចំនួនតែ ១.០១៧នាក់ប៉ុណ្ណោះ នៅក្នុងនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ ការិយាល័យសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងនោះរាប់បញ្ចូលទាំងអ្នកមិនមែនផ្តល់សេវា ដែលចំនួននេះត្រូវគេរំពឹងថា គ្របដណ្តប់បាន ១.៦៣៣ឃុំសង្កាត់។ អ្នកនិពន្ធរបាយការណ៍ដដែលនេះ កត់សម្គាល់ថា ភាគច្រើននៃពេលវេលារបស់បុគ្គលិកទាំងនេះ ត្រូវបានចំណាយទៅលើការបើកប្រាក់សោធននិវត្តន៍ដល់អតីតយុទ្ធជន មន្ត្រីរាជការដែលចូលនិវត្តន៍ និងជនពិការ។ អ្នកនិពន្ធបន្តទៀតថា កម្រិតបុគ្គលិកនៅក្នុង នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថយចុះជារៀងរាល់ឆ្នាំ។ ចំណុចចុងក្រោយ អ្នកនិពន្ធរកឃើញនូវបញ្ហាកង្វះមូលនិធិ សមត្ថភាព និងការផ្តល់សេវាការពារកុមារនៅថ្នាក់មូលដ្ឋាន។ គេមិនដឹងច្បាស់ទេថាតើនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានទំនាក់ទំនងជាមួយ គ.ក.ន.ក ឬអត់នោះទេ។

---

[2] ឯកសារស្តីពីការប្រព្រឹត្តទៅរបស់ គ.ក.ន.ក រៀបរាប់មិនលម្អិតគ្រប់គ្រាន់អំពីការគាំទ្ររបស់ WCCC ចំពោះ គ.ក.ន.ក និងរបៀបគប្បីអនុវត្ត ចំណែកឯប្រកាសស្តីពីការបង្កើត និងការប្រព្រឹត្តិទៅរបស់ WCCC ក៏មិនបាន បញ្ជាក់លម្អិតអំពីទម្រង់គាំទ្រសម្រាប់ គ.ក.ន.ក ដែរ។

**ទាំងក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងការងារ និងក្រសួងយុត្តិធម៌ សុទ្ធតែគ្មានបុគ្គលិក សង្គមកិច្ច**

ការផ្តល់សេវាការពារកុមារមិនគួររឹតត្បិតតែចំពោះអ្នកផ្តល់សេវាសង្គមកិច្ចប៉ុណ្ណោះនោះទេ ប៉ុន្តែគួរតែរួមបញ្ចូលភាគីពាក់ព័ន្ធជាច្រើនទៀត ដូចជា ភាគីពាក់ព័ន្ធមកពីសំណាក់វិស័យសុខាភិបាល អប់រំ ការងារ និងយុត្តិធម៌។ Harachi (ឆ្នាំ២០១៥) កត់សម្គាល់បន្ថែមទៀតថា បុគ្គលិកសង្គមកិច្ចគឺជាមនុស្សសំខាន់នៅក្នុងការផ្តល់ការថែទាំផ្លូវចិត្តក្នុងវិស័យសុខាភិបាល ការទប់ស្កាត់ការបោះបង់ការសិក្សានៅក្នុងវិស័យអប់រំ ការទប់ស្កាត់ពលកម្មកុមារ និងការជួយកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌។ ប៉ុន្តែ នៅក្នុងប្រទេសកម្ពុជា ការងារសង្គមកិច្ច មិនត្រូវបានទទួលស្គាល់ថា ជាសមាសធាតុសំខាន់នៃការផ្តល់សេវានៅក្នុងវិស័យទាំងនេះឡើយ។ ទាំងក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងការងារ និងក្រសួងយុត្តិធម៌ សុទ្ធតែគ្មានបុគ្គលិកសង្គមកិច្ច។ ប៉ុន្តែ គ.ក.ន.ក ធ្វើការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការកំណត់រកបញ្ហាពលកម្មកុមារនៅក្នុងសហគមន៍ ហើយត្រូវបានស្នើឲ្យធ្វើការជាមួយមន្ទីរការងារខេត្ត ដែលមានភារកិច្ចតាមដាន និងលុបបំបាត់ពលកម្មកុមារ ដោយសហការជាមួយ CWCC សាលារៀន និងតាមរយៈការចុះធ្វើអធិការកិច្ចកន្លែងការងារផ្លូវការនានា។

បច្ចុប្បន្ន ពុំទាន់មានការស្រាវជ្រាវ ឬគោលនយោបាយណាមួយដែលផ្តោតលើទំនាក់ទំនងគ្នាទៅវិញទៅមករវាងសមាជិករបស់ គ.ក.ន.ក នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ប៉ុន្តែ ប្រធានបទនេះ ត្រូវបានលើកឡើងនៅក្នុងការសិក្សាមួយចំនួនដែលទាក់ទងនឹងប្រធានបទផ្សេង។ ការសិក្សាស្រាវជ្រាវបង្ហាញថានៅថ្នាក់ឃុំសង្កាត់ គ.ក.ន.ក នឹងស្វែងរកជំនួយពីសមាជិករបស់នាយកដ្ឋាន សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងករណីពិសេសៗ ដែល គ.ក.ន.ក គិតថា អំណាចរបស់អង្គភាពនេះអាចជួយបាន និងថា ជារឿយៗ សមាជិក នាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានអញ្ជើញឲ្យធ្វើជាហត្ថលេខា ក្នុងករណីបញ្ជូនកុមារ ឬដើម្បីបំពេញតួនាទីជាអធិបតីនៅក្នុងពិធីធ្វើសមាហរណកម្ម (Jordanwood ឆ្នាំ២០១៥, Harachi ឆ្នាំ២០១៥)។

[2] DOSVY សម្រាប់ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក៏គ្រប់គ្រងមណ្ឌលសំចតសម្រាប់កុមារដែលវិលត្រលប់មកពីចំណាកស្រុក ឬការជួញដូរទៅកាន់ប្រទេសថៃ និងមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនផងដែរ។

## ២.១ ហេតុផលសម្រាប់ការស្រាវជ្រាវ និងសំណួរស្រាវជ្រាវ

សិទ្ធិរបស់កុមារក្នុងការទទួលបានការការពារនៅក្នុងប្រទេសកម្ពុជា មិនទាន់ឆ្លើយតបបាននៅឡើយទេ ដូចដែលយើងបានលើកឡើងរួចមកហើយនៅចំណុចខាងលើ (នៅក្នុងចំណុចស្តីពី បរិបទ)។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាខ្វះនូវយន្តការការពារកុមារថ្នាក់ជាតិ ដើម្បីផ្តល់សេវាដល់កុមារងាយរងគ្រោះ។ ជាផ្នែកមួយនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ គ.ក.ន.ក ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសនៅឆ្នាំ២០០៤។ តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក ផ្តោតសំខាន់លើការធ្វើផែនការ ការសម្របសម្រួល ការតស៊ូមតិ ការលើកកម្ពស់ការយល់ដឹង និងការតាមដាន។ អង្គការមិនមែនរដ្ឋាភិបាលនានាបាននឹងកំពុងធ្វើការជាមួយ គ.ក.ន.ក ដើម្បីកសាងសមត្ថភាពសម្រាប់បំពេញតួនាទីទាំងនេះ។ ការស្រាវជ្រាវមានច្រើនគួរឲ្យកត់សម្គាល់ស្តីពីរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដូចជា ក្រុមប្រឹក្សាឃុំសង្កាត់ (Plummer និង Tritt ឆ្នាំ២០១១, Plummer ឆ្នាំ២០១២, Conferal ឆ្នាំ២០១២) ប៉ុន្តែទន្ទឹមនឹងនេះ មានការស្រាវជ្រាវតិចតួចណាស់អំពីប្រព័ន្ធការពារកុមារក្រៅផ្លូវការ និង គ.ក.ន.ក ដូចអ្វីដែលយើងនឹងពិភាក្សានៅខាងក្រោម (ត្រង់ចំណុចស្តីពីការពិនិត្យមើលឯកសារនានា)។

ការសិក្សានេះមានបំណងចូលរួមចំណែកក្នុងការសិក្សាស្វែងយល់ និងការកែលម្អប្រព័ន្ធការពារកុមារនៅក្នុងប្រទេសកម្ពុជា ដោយផ្តល់ព័ត៌មានស៊ីជម្រៅបន្ថែមទៀតស្តីពីការអនុវត្តមុខងាររបស់ គ.ក.ន.ក ភាពជាដៃគូរបស់ពួកគេជាមួយអង្គការមិនមែនរដ្ឋាភិបាល ទំនាក់ទំនង ជាមួយយន្តការការពារកុមារក្រៅផ្លូវការនៅថ្នាក់ភូមិ កត្តានានាដែលជំរុញ ឬរាំងរាំងជោគជ័យរបស់ គ.ក.ន.ក ព្រមទាំងអាកប្បកិរិយា និងឥរិយាបថរបស់ពួកគេចំពោះកុមារ និងការការពារកុមារ។

ការសិក្សាស្រាវជ្រាវនេះពិនិត្យលើកម្មវិធីចំនួន ១៤ របស់អង្គការចំនួន ៥ (អង្គការទស្សនៈពិភពលោក (World Vision) មូលនិធិកុមារ (Childfund) អង្គការសង្គ្រោះ កុមារ (Save the Children) អង្គការភ្លែន (Plan) មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) ដែលផ្តោតការងារលើការពង្រឹងប្រព័ន្ធសម្រាប់ការការពារកុមារនៅកម្ពុជា។ អង្គការទាំងនេះ ទទួលខុសត្រូវលើការតាក់តែងនូវវត្ថុបំណង នៃការស្រាវជ្រាវ ការកំណត់រកអ្នកចូលរួមសម្រាប់ការស្រាវជ្រាវ និងមតិយោបល់ស្តីពីសេចក្តីព្រាងបឋម នៃការសិក្សា ក្នុងគោលដៅធ្វើយ៉ាងណាឲ្យការស្រាវជ្រាវនេះ មានសារប្រយោជន៍ចំពោះកម្មវិធីការពារកុមារដែលកំពុងអនុវត្ត។

ការសិក្សានេះ ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដូចខាងក្រោម ដែលបានចោទសួរដោយគណៈកម្មាធិការដឹកនាំការសិក្សា៖

១. តើតួអង្គរដ្ឋអំណាចមូលដ្ឋាន និងសមាជិកសហគមន៍ មានអាកប្បកិរិយា និងឥរិយាបថយ៉ាងដូចម្តេចខ្លះ ចំពោះកុមារ និងការការពារកុមារ?

២. តើទម្លាប់អនុវត្តន៍ការពារកុមារតាមសហគមន៍ ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (CBCPPs) មានអ្វីខ្លះ ដែលពាក់ព័ន្ធជាមួយ គ.ក.ន.ក និងបណ្តាញការពារកុមារក្រៅផ្លូវការដទៃទៀត? តើទម្លាប់ណាខ្លះក្នុងចំណោមទម្លាប់ទាំងនេះ ដែលទទួលបានជោគជ័យបំផុត? មូលហេតុអ្វី?

៣. តើកត្តាសំខាន់ៗអ្វីខ្លះ ដែលរារាំង និងជំរុញការអនុវត្តមុខងារ និងប្រសិទ្ធភាពរបស់ គ.ក.ន.ក ពាក់ព័ន្ធនឹងបញ្ហាការការពារកុមារ?

## ការស្រាវជ្រាវបែបចូលរួម

ការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងភាពជាដៃគូ រវាងក្រុមស្រាវជ្រាវ និងគណៈកម្មាធិការអចិន្ត្រៃយ៍ស្ទូល។ អង្គការទាំងនេះ សហការជាមួយក្រុមស្រាវជ្រាវនៅគ្រប់ដំណាក់កាលនៃការបង្កើតការសិក្សានេះ។ ដំណើរការនេះ បានអនុញ្ញាតឲ្យអ្នកស្រាវជ្រាវអាចរកឃើញកង្វះខាតផ្សេងៗនៅក្នុងការស្រាវជ្រាវ និងធ្វើឲ្យការសិក្សានេះមានទម្រង់មួយ ដែលកាន់តែមានប្រយោជន៍ថែមទៀតដល់អ្នកអនុវត្ត និងអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការងារនេះនាពេលអនាគត។ ភាពជាដៃគូរវាងក្រុមស្រាវជ្រាវ និង អង្គការមិនមែនរដ្ឋាភិបាល បានបង្កើតនូវលទ្ធភាពនៃការលម្អៀងនៅក្នុងការជ្រើសរើសសំណាក ដូចដែលយើងនឹងពិភាក្សានៅផ្នែកខាងក្រោម (នៅក្នុងចំណុចស្តីពីសំណាក)។ ទោះជាយ៉ាងណា ក្រុមស្រាវជ្រាវបានខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពលម្អៀងនេះ ជាពិសេសតាមរយៈការបញ្ជាក់ឲ្យច្បាស់លាស់អំពីដំណើរការ និងដែនកំណត់របស់ការសិក្សា។

## ក្រុមស្រាវជ្រាវ

សមាសភាពក្រុមស្រាវជ្រាវ រួមមាន ប្រធានអ្នកស្រាវជ្រាវមួយរូបជាជនបរទេស ដែលមានបទពិសោធន៍ជាង ១០ឆ្នាំនៅក្នុងការងារទាក់ទងនឹងការការពារកុមារនៅកម្ពុជា និងជំនួយការអ្នក ស្រាវជ្រាវកម្ពុជា ដែលមានបទពិសោធន៍៨នាក់ផ្សេងទៀត។

## ការពិនិត្យឯកសារ

ឯកសារចំនួន ៦៥ ត្រូវបានពិនិត្យឡើងវិញជាផ្នែកមួយនៃការស្រាវជ្រាវនេះ ដែលរួមមាន ៤ ប្រភេទធំៗសម្រាប់ជាមូលដ្ឋានព័ត៌មាននៃផ្នែកផ្សេងៗនៅក្នុងរបាយការណ៍នេះ ដូចដែលបានកត់សម្គាល់នៅក្នុងតារាង ១។ ដើម្បីរក្សាការសម្ងាត់របស់កម្មវិធីទាំង ១៤ ដែលបានដាក់បញ្ចូលនៅក្នុងការសិក្សានេះ យើងមិនបានរាយបញ្ជីឈ្មោះឯកសារកម្មវិធីទាំងនោះ នៅក្នុងរបាយការណ៍នេះទេ។

### តារាង ១. ឯកសារដែលត្រូវពិនិត្យមើល និងដកស្រង់យក មកយោង សម្រាប់ផ្នែកមួយចំនួននៃរបាយការណ៍នេះ

| ផ្នែកនៃការសិក្សាស្រាវជ្រាវ | ឯកសារដែលបានពិនិត្យនិងដកស្រង់យកមកយោងសម្រាប់ផ្នែកនេះ |
|---|---|
| បរិបទនៃការការពារកុមារកម្ពុជា | ការសិក្សាដែលទាក់ទងនឹងអំពើហិង្សាលើកុមារ ពលកម្មកុមារ កុមារដែលស្ថិតក្នុង RCIs អំពើរំលោភសេពសន្ថវៈ ផលប៉ះពាល់នៃចំណាកស្រុកទៅលើកុមារ។ |
| ការធ្វើផែនទីគំរូ CBCPMs ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | សំណើ និងរបាយការណ៍គម្រោងពីកម្មវិធីសហប្រតិបត្តិការទាំង១៥។ |
| រំព្ញកទ្រឹស្តី | ការសិក្សានានាស្តីពីប្រសិទ្ធភាពរបស់ គ.ក.ន.ក<br>ការសិក្សានានាស្តីពីអាកប្បកិរិយាចំពោះកុមារ |

# ការប្រមូលទិន្នន័យ

## ឧបករណ៍

ការសិក្សានេះ ធ្វើឡើងតាមរយៈវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ដោយសារផ្អែកលើមូលហេតុពីរ។ ទី១ ដោយសារកង្វះរបាយការណ៍ស្រាវជ្រាវស្តីពី គ.ក.ន.ក ពីមុនមក ការស្រាវជ្រាវមួយនេះ មានលក្ខណៈជាការសិក្សាស្វែងយល់ប៉ុណ្ណោះ។ ហេតុនេះហើយទើបយើងចាំបាច់ត្រូវប្រើសំណួរបើកដែលអនុញ្ញាតឲ្យយើងទទួលបានព័ត៌មានថ្មីៗបន្ថែមទៀត។ ទី២ ការសិក្សានេះ មានគោលបំណងពិនិត្យមើលទៅលើកត្តាសង្គមដែល មានស្មុគស្មាញទាក់ទងនឹងអាកប្បកិរិយា ឥរិយាបថ និងការឆ្លើយតបចំពោះការការពារកុមារ។ ការស្រាវជ្រាវបែបគុណភាព អនុញ្ញាតឲ្យយើងស្វែងយល់អំពីបញ្ហាទាំងនេះកាន់តែលម្អិតថែមទៀត។

កិច្ចសម្ភាសន៍បុគ្គល

កិច្ចសម្ភាសន៍បុគ្គល (semi-structured interviews) ត្រូវបានធ្វើឡើងជាមួយមន្ត្រីរដ្ឋអំណាចនៅថ្នាក់ឃុំសង្កាត់ និងស្រុកខណ្ឌ បុគ្គលទទួលខុសត្រូវ គ.ក.ន.ក កុមារ នាយកសាលា និងអ្នកផ្តល់ព័ត៌មានសំខាន់ៗមកពីអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ (ចូរមើលប្រអប់ ២)។

### កិច្ចពិភាក្សាក្រុមគោលដៅ

កិច្ចពិភាក្សាក្រុមគោលដៅ (Focus group discussion or FGD) ធ្វើឡើងជាមួយក្រុមផ្សេងៗគ្នាចំនួន ១១ប្រភេទ ដូចដែលបានរាយនៅក្នុងប្រអប់ ៣។ កិច្ចពិភាក្សាក្រុម អនុញ្ញាតឲ្យអ្នកស្រាវជ្រាវអាចវាយតម្លៃទៅលើអាកប្បកិរិយា និងឥរិយាបថទូទៅជាច្រើន។ FGD សមស្របបំផុតដើម្បីជំរុញកិច្ចពិភាក្សាក្នុងចំណោមសមាជិកសហគមន៍ អំពីតួនាទីមុខងារបច្ចុប្បន្ន និងប្រសិទ្ធភាពរបស់ គ.ក.ន.ក និងបណ្តាញក្រៅផ្លូវការដទៃទៀត។ FGD ធ្វើឡើងដោយប្រើកម្រងការណែនាំសំណួរ ក្នុងនោះរួមទាំងសំណួរបើកផងដែរ។

កម្រងការណែនាំសំណួរនេះ ក៏រួមបញ្ចូលនូវសំណួរមួយចំនួនដែលក្រុមនេះត្រូវតម្រូវឲ្យជ្រើសរើសចេញពីបញ្ជីចម្លើយផងដែរ។ អ្នកសម្របសម្រួលស្នើឲ្យក្រុមទាំងមូលមូលមតិគ្នាជាឯកច្ឆន្ទអំពីចម្លើយនីមួយៗ ហើយប្រសិនបើមិនមានការមូលមតិគ្នាទេ អ្នកស្រាវជ្រាវកត់សម្គាល់សំណួរនោះថា “គ្មានចម្លើយ”។ ស្ទើរតែគ្រប់ក្រុមទាំងអស់តែងតែមានការមូលមតិគ្នាជាឯកច្ឆន្ទ ហើយជារឿយៗមានភាព ស្រដៀងគ្នារវាងចម្លើយពីក្រុមផ្សេងៗគ្នា នៅក្នុងតំបន់ដូចគ្នា (ឧទាហរណ៍៖ រវាងគ្រួសារ និងសមាជិក គ.ក.ន.ក នៅក្នុងឃុំសង្កាត់តែមួយ) ដែលកិច្ចសម្ភាសន៍បែបនេះ អនុញ្ញាតឲ្យអ្នកស្រាវជ្រាវអាចស៊ើបអង្កេត លើ ប្រធានបទជាច្រើនដែលបានកំណត់ជាមុន ទន្ទឹមនឹងការផ្តល់ភាពអាចបត់បែនបានសម្រាប់ការសួរបន្តទាក់ទងនឹងចម្លើយដែលមិនបានរំពឹងទុក។

**ប្រអប់ ២៖ អ្នកចូលរួមក្នុងកិច្ចសម្ភាសន៍**

- បុគ្គលទទួលបន្ទុក គ.ក.ន.ក
- បុគ្គលិកសង្គមកិច្ចស្រុកខណ្ឌ
- បុគ្គលិកគម្រោងមូលដ្ឋាន
- មេឃុំ/ចៅសង្កាត់
- WCCC
- នាយកសាលា
- កុមារ (ទាំងស្រីទាំងប្រុស) អាយុពី១៥ ដល់ ១៧ឆ្នាំ
- អ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីបុគ្គលិកជាតិរបស់អង្គការក្រៅរដ្ឋាភិបាល ដែលផ្តោតលើការការពារកុមារ
- អ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីបុគ្គលិកជាតិរបស់អង្គការក្រៅរដ្ឋាភិបាល ដែលផ្តោតលើអភិបាលកិច្ច
- អ្នកផ្តល់ព័ត៌មានសំខាន់ៗ ពីបុគ្គលិកដែលផ្តោតលើអភិបាលកិច្ច និងការការពារកុមារ នៅក្នុងទីភ្នាក់ងារពហុភាគី

នាំឲ្យអ្នកស្រាវជ្រាវមានទំនុកចិត្តកាន់តែច្រើនឡើងទៅលើសុពលភាព នៃឧបករណ៍សំណួរនេះ។ ក្រុមស្រាវជ្រាវត្រូវបានរៀបចំកាលវិភាគឲ្យជួបជាមួយ គ.ក.ន.ក នៅក្នុងឃុំសង្កាត់ទាំង ៣២។ គ.ក.ន.ក ពីរដែលមិនបានមកតាម ពេលវេលាកំណត់ ដូច្នេះសំណាកគឺមាន គ.ក.ន.ក ត្រឹមតែ ៣០ប៉ុណ្ណោះ។ ក្នុងករណីខ្លះ សមាជិក គ.ក.ន.ក បានសម្រេចចិត្តមិនឆ្លើយ សំណួរដោយសារហេតុផលផ្សេងៗ។ ក្នុងករណីបែបនេះ ភាគបែងគឺ មានចំនួនទាប ឧទាហរណ៍៖ x/២៩។

**ប្រអប់ ៣: អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុម**

- គ.ក.ន.ក
- កុមារ (ស្រី និងប្រុស) អាយុពី ៩ ដល់ ១៥ឆ្នាំ
- ក្រុមគាំទ្រភូមិ
- បណ្តាញការពារគ្រួសារភូមិ
- ប្រជាការពារភូមិ
- គណៈកម្មាធិការទ្រទ្រង់សាលា
- គណៈកម្មាធិការការពារកុមារ
- គ.ក.ន.ក និងគណៈកម្មាធិការតាមដានពលកម្មកុមារ
- គ្រួសារដែលមានកូននៅក្នុងពលកម្មកុមារ
- គ្រួសារដែលគ្មានកូននៅក្នុងពលកម្មកុមារ
- ក្រុមការងារសហគមន៍

## ការប្រមូលទិន្នន័យ

យើងបានធ្វើការយ៉ាងហ្មត់ចត់ដើម្បីធានាឲ្យបានថាអ្នកតបចម្លើយត្រូវបានការពារពីគ្រោះថ្នាក់ផ្សេងៗ។ ជាពិសេស ការស្រាវជ្រាវនេះបានធ្វើកិច្ចប្រឹងប្រែង ដើម្បី៖

១. ធានាថាអ្នកចូលរួមទាំងអស់បានផ្តល់ការយល់ព្រមដោយស្ម័គ្រចិត្ត

២. គោរពតាមក្រមសីលធម៌ស្តីពីការការពារកុមារតាមឯកសារដែលមានចំណងជើងថា The Right to be Properly Researched, Knowing Children (ឆ្នាំ២០១២) និងធានាថាការស្រាវជ្រាវ ធ្វើឡើងក្នុងលក្ខណៈមួយកុំឲ្យប៉ះពាល់ដល់កុមារ។

៣. គោរពតាមគោលការណ៍ណែនាំដើម្បីទប់ស្កាត់ការមិនសប្បាយចិត្តរបស់អ្នកចូលរួម ធានាថាការស្រាវជ្រាវធ្វើឡើងក្នុងលក្ខណៈមួយដែលមិនប៉ះពាល់ដល់យេនឌ័រ។

៤. ធានាការការពារទាំង ទិន្នន័យ ដើម្បីការពារការសម្ងាត់ និងសិទ្ធិរបស់អ្នកចូលរួម។

## សំណាក

ការស្រាវជ្រាវបានធ្វើឡើងនៅក្នុងឃុំសង្កាត់ចំនួន ៣២ នៅក្នុងខេត្តចំនួន ១០ និងរាជធានីភ្នំពេញ ដែលបានជ្រើសរើសចេញពីតំបន់គោលដៅរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិទាំង៤ និងអង្គការពហុភាគីមួយដែលជាអ្នកឧបត្ថម្ភការសិក្សានេះ (សូមមើលផែនទី ១)។ ការពិភាក្សា ក្រុមគោលដៅចំនួន ១២៧លើក និងកិច្ចសម្ភាសន៍ ១២៩លើក ត្រូវបានធ្វើឡើងនៅតាមតំបន់នានានៅក្នុងឃុំសង្កាត់។ កិច្ចសម្ភាសន៍ចំនួន ១២ ត្រូវបានធ្វើឡើងជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ។ ឯកសារចំនួន ៦៥ ត្រូវបានពិនិត្យឡើងវិញ។




៣២ឃុំ/សង្កាត់ នៅក្នុងខេត្តទាំង ១០ និងរាជធានីភ្នំពេញ
ខេត្តទាំង ១០ រួមមាន **បាត់ដំបង, បន្ទាយមានជ័យ, ត្បូងឃ្មុំ, កំពង់ឆ្នាំង, ក្រចេះ, ព្រៃវែង, ព្រះសីហនុ,**
**សៀមរាប, ស្វាយរៀង, តាកែវ**

## ការកំណត់សំណាកដោយចេតនា

ការកំណត់សំណាកដោយចេតនា ត្រូវបានធ្វើឡើងសម្រាប់ការសិក្សានេះទាំងមូល។ ការកំណត់សំណាកដោយចេតនា អនុញ្ញាតឲ្យក្រុមស្រាវជ្រាវអាចកំណត់រកអ្នកចូលរួម ដែលមានមតិយោបល់ពាក់ព័ន្ធនឹងសំណួរជាក់លាក់ និងកំណត់បាននូវបុគ្គលឬក្រុមដែលជះឥទ្ធិពលជាវិជ្ជមាន និងអវិជ្ជមាន (ដូចដែលនឹងលើកឡើងនៅខាងក្រោម) ហើយផលប្រយោជន៍នេះ ត្រូវគេជឿជាក់ថាមានទម្ងន់ធ្ងន់ជាងការលម្អៀងដែលអាចមាន។ វាក៏អនុញ្ញាតឲ្យអ្នកស្រាវជ្រាវអាចធានាថា ទស្សនៈរបស់អ្នកមានសិទ្ធិអំណាចត្រូវបានដាក់បញ្ចូលក្នុងការស្រាវជ្រាវ។

## ការជ្រើសរើសសំណាក

សំណាកត្រូវបានជ្រើសរើសទៅតាមឧទាហរណ៍នៃការជះឥទ្ធិពលជាវិជ្ជមាន និងអវិជ្ជមាន។ បុគ្គល ឬក្រុមដែលជះឥទ្ធិពលជាវិជ្ជមាន គឺជាអ្នកដែលអាចជំនះឧបសគ្គក្នុងការទទួលបានជោគជ័យ ក្នុងការងាររបស់គេ (positive deviant) រីឯបុគ្គលឬក្រុមដែលជះឥទ្ធិពលជាអវិជ្ជមាន គឺជាអ្នកដែលជួបប្រទះឧបសគ្គក្នុងការសម្រេចការងារ (negative deviant)។ គណៈកម្មាធិការអចិន្ត្រៃយ៍ទទួលខុសត្រូវក្នុងការកំណត់រក គ.ក.ន.ក ដែលជះឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាន ដោយផ្អែកតាមការអនុវត្តមុខងាររបស់ គ.ក.ន.ក។ នៅក្នុងខេត្តនីមួយៗ ដៃគូដឹកនាំបានកំណត់ឃុំពីរ គឺឃុំមួយមាន គ.ក.ន.ក ដែលជះឥទ្ធិពលវិជ្ជមាន (មានន័យថា ជា គ.ក.ន.ក ដែលបាន នឹងងកំពុងធ្វើការប្រកបដោយប្រសិទ្ធភាពដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជាដៃគូ) និងឃុំមួយដែលមាន គ.ក.ន.ក ដែលជះឥទ្ធិពលអវិជ្ជមាន (មានន័យថា ជា គ.ក.ន.ក ដែលបាន នឹងកំពុងធ្វើការដោយមិនមានប្រសិទ្ធភាព)។ ដើម្បីទប់ស្កាត់កុំឲ្យមានភាពលម្អៀង ក្រុមស្រាវជ្រាវមិនបានដឹងថា តើ គ.ក.ន.ក មួយណាត្រូវបានកំណត់ថាក្រុមវិជ្ជមាន ឬអវិជ្ជមាននោះទេ នៅមុនការប្រមូលព័ត៌មាន។ ប៉ុន្តែនៅពេលវិភាគទិន្នន័យ គេមើលឃើញយ៉ាងច្បាស់ថា ការបែងចែកបុគ្គល ឬក្រុមដែលជះឥទ្ធិពលវិជ្ជមាន/អវិជ្ជមាន មិនអាចវិភាគប្រកបដោយអត្ថន័យបានឡើយ ដោយសារតែកត្តាផ្សេងៗទៀតនៅក្នុងសំណាក (ដូចដែលនឹងត្រូវពិភាក្សានៅផ្នែកខាងក្រោម នៅក្នុងចំណុចស្តីពីការវិភាគបុគ្គលឬក្រុមដែលជះឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន)។

## ការវិភាគទិន្នន័យ

**ទិន្នន័យបែបគុណភាព**

**ទិន្នន័យបែបគុណភាព** ត្រូវបានបកស្រាយ រួចហើយដាក់កូដទៅតាមប្រធានបទ ដោយផ្អែកតាមប្រេវ៉ាឡង់ចម្លើយ។ បន្ទាប់មកទៀត ប្រធានបទត្រូវបានញែកទៅតាមសំណួរស្រាវជ្រាវចំនួន ០៣៖ អាកប្បកិរិយា និងឥរិយាបថចំពោះកុមារ CBCPPs ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងកត្តានានាដែលជំរុញ ឬរាំងប្រសិទ្ធភាពរបស់ គ.ក.ន.ក។ សំណួរស្រាវជ្រាវនីមួយៗ មានប្រធានបទអនុប្រភេទជាច្រើន។ បន្ទាប់មក អ្នកស្រាវជ្រាវត្រឡប់ទៅពិនិត្យមើលទិន្នន័យឡើងវិញ ហើយអត្ថបទដែលទាក់ទងទៅនឹងប្រធានបទនានា ត្រូវបានញែកដាច់ដោយឡែក និងចងក្រង។ បន្ទាប់មកទៀត អត្ថបទដែលចងក្រងនោះ ត្រូវបានសង្ខេបបន្ថែមទៀត ដើម្បីឈានទៅដល់ការរកឃើញលទ្ធផលសំខាន់ៗ។

**ទិន្នន័យបែបបរិមាណ**

**ទិន្នន័យបែបបរិមាណ** ត្រូវបានរាប់ដើម្បីផ្តល់ន័យជាប្រេវ៉ាឡង់នៅតាមស្រុក/ខណ្ឌខុសៗគ្នា ហើយនៅក្នុងករណីខ្លះ ត្រូវបានចាត់ចំណាត់ថ្នាក់យោងទៅតាមភាពញឹកញាប់នៃចម្លើយ។ បន្ទាប់មក លទ្ធផលរកឃើញបែបគុណភាព និងបរិមាណត្រូវបានប្រៀបធៀបគ្នា ហើយការរកឃើញទូទៅ ត្រូវបានប្រៀបធៀបទៅនឹងរបាយការណ៍ស្រាវជ្រាវដែលមានស្រាប់ដើម្បីផ្ទៀងផ្ទាត់ថាតើការរកឃើញទាំងនេះបន្ថែម លើចំណេះដឹង ដែលមានស្រាប់ ឬយ៉ាងណា។ គួរកត់សម្គាល់ថា ការសិក្សានេះគ្មានគោលបំណងផ្តល់សារសំខាន់ផ្នែកស្ថិតិ អនុញ្ញាតឲ្យធ្វើការទាញសន្និដ្ឋានទូទៅ ឬបង្កើតសម្មតិកម្ម ឬទំនាក់ទំនងគ្នាទៅវិញទៅមកនោះទេ។ ការសិក្សានេះ គ្រាន់តែជាការស្វែងយល់ប៉ុណ្ណោះ ហើយផ្តោតទៅលើតែអាកប្បកិរិយា និងឥរិយាបថប៉ុណ្ណោះ ដូច្នេះហើយវាជាការល្អបំផុត ដែលការសិក្សានេះត្រូវធ្វើឡើងជាចម្បងតាមរយៈការស្រាវជ្រាវបែបគុណភាព។

ការវិភាគបុគ្គលឬក្រុមដែលជះឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន

នីតិវិធីស្រាវជ្រាវដំបូងតម្រូវឲ្យធ្វើការប្រៀបធៀបគ្នា រវាងបុគ្គលឬក្រុមដែលជះឥទ្ធិពលវិជ្ជមាន ជាមួយនឹងបុគ្គលឬក្រុមដែលជះឥទ្ធិពលអវិជ្ជមាន ប៉ុន្តែនៅពេលវិភាគទិន្នន័យយើងបានឃើញច្បាស់ថា ការប្រៀបធៀបគ្នាបែបនេះមិនអាចធ្វើបានឡើយ។ គ.ក.ន.ក ភាគច្រើនបំផុត បានរាយការណ៍ (ទាំងនៅ ក្នុងសំណួរបើក និងទាំងនៅក្នុងសំណួរជាលំដាប់លំដោយនៅក្នុងការស្ទង់មតិ) ថាបានអនុវត្តភារកិច្ចភាគច្រើនដែលបានដាក់ឲ្យ គ.ក.ន.ក តាមរយៈគោលនយោបាយរដ្ឋាភិបាល (RGC ឆ្នាំ២០០៨)។ ដូច្នេះវាជាការលំបាកក្នុងការញែកដាច់ពីគ្នារវាងបុគ្គល ឬក្រុមដែលទទួលបានជោគជ័យ និងមិនទទួលបាន ជោគជ័យណាស់។ ជាងនេះទៅទៀត អង្គការមិនមែនរដ្ឋាភិបាលដែលជាគណៈ កម្មាធិការអចិន្ត្រៃយ៍មួយ ចំនួន បានផ្តល់ការគាំទ្រច្រើនគួរសម រួមជាមួយនឹងការចូលរួមសកម្មដល់ គ.ក.ន.ក ផងដែរ។ នៅក្នុង បណ្តាឃុំសង្កាត់ដែលទទួលបានការគាំទ្រប្រភេទនេះ ពីអង្គការក្រៅរដ្ឋាភិបាលទាំងបុគ្គល ឬក្រុមដែលទទួលបានជោគជ័យ និងមិនទទួលបានជោគជ័យ បានបង្ហាញនូវការអនុវត្តមុខងារ កម្រិតខ្ពស់ជាងនៅ តាមបណ្តាឃុំសង្កាត់ដែលមិនបានទទួលកម្រិតនៃការគាំទ្រទាំងនេះ។

អ្វីដែលជាមេរៀនសម្រាប់ការដកពិសោធន៍ នោះ គឺថា បុគ្គលឬក្រុមដែលជះឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាន គួរតែត្រូវបានកំណត់នៅក្រោយការផ្តល់ការ គាំទ្រជុំទីមួយ បន្ទាប់មក ការធ្វើរបាយការណ៍ស៊ីជម្រៅនៅជុំទី២ គួរតែបំពេញតាមក្រោយ។

## ២.៣ ដែនកំណត់នៃការសិក្សា

គ្រប់ចម្លើយទាំងអស់របស់ គ.ក.ន.ក គឺក្នុងទម្រង់ជាការរាយការណ៍ដោយខ្លួនឯង ដូច្នេះហើយអាចមានភាពលម្អៀង។ ជាងនេះទៅទៀត សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលផ្តល់មូលនិធិដល់គម្រោងនានាដែលធ្វើការជាមួយ គ.ក.ន.ក ជាអ្នកទទួលខុសត្រូវក្នុងការទាក់ទងអ្នកចូលរួម ដែលអាចនឹងធ្លាប់មានការចូលរួមពីមុនមក និងធ្លាប់ស្គាល់ គ.ក.ន.ក។ ប៉ុន្តែ អ្នកចូលរួមមួយចំនួនធំបានរាយការណ៍ថាមិនធ្លាប់បានឮអំពី គ.ក.ន.ក ទេ ហើយអ្នកចូលរួមចម្រុះគ្នាក្នុងចំនួនច្រើនគួរសម ត្រូវបានជឿជាក់ថាបានកាត់បន្ថយភាពលម្អៀងនៃសំណាក។ លើសពីនេះទៅទៀត កិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីបង្កើនសុពលភាពនៃការរកឃើញ តាមរយៈការធ្វើត្រីកោណវិធី ដោយប្រៀបធៀបចម្លើយពីក្រុមផ្សេងៗគ្នានៅក្នុងសហគមន៍មួយ។ ចម្លើយនៅក្នុងសហគមន៍នានា ដែលទាក់ទងនឹងចម្លើយស្តីពីការការពារកុមារនាពេលមុនៗ ត្រូវគេរកឃើញថាមានលក្ខណៈស្រដៀងគ្នា ដោយបង្ហាញនូវភាពស៊ីសង្វាក់គ្នានៅក្នុងទិន្នន័យដែលនាំឲ្យក្រុមស្រាវជ្រាវជឿជាក់ថាទិន្នន័យនេះមានសុពលភាពត្រឹមត្រូវ។

ការវាយតម្លៃភាពជោគជ័យរបស់ CBCPP តាមរយៈការពិនិត្យមើលឯកសារ គឺធ្វើបានតិចតួចប៉ុណ្ណោះ។ មានឯកសារគម្រោងតិចតួចប៉ុណ្ណោះ ដែលបានវាយតម្លៃសហគមន៍ នៅមុនពេលគម្រោងចាប់ផ្តើម ហើយភស្តុតាងនៅក្នុងឯកសារ ផ្តោតទៅលើលទ្ធផលជាជាងទៅលើផលប៉ះពាល់នៃគម្រោង។ ការវាយតម្លៃអន្តរទីភ្នាក់ងារទៅលើបណ្តាញការពារកុមារតាមសហគមន៍ បានជួបប្រទះនឹងបញ្ហាស្រដៀងគ្នានេះ ជុំវិញការវាស់វែងផលប៉ះពាល់នៃកិច្ចអន្តរាគមន៍នានា (Wessells ឆ្នាំ២០០៩)។ កង្វះការវាស់វែងជាមុនបានធ្វើឲ្យគេពិបាកក្នុងការវាយតម្លៃថាតើគំរូនានាបានផ្តល់លទ្ធផលវិជ្ជមានសម្រាប់កុមារ ឬអត់ដោយផ្អែកតាមឯកសាររបស់អង្គការ។ ដូច្នេះហើយជោគជ័យរបស់ CBCPPs គឺផ្អែកទៅលើទិន្នន័យបែបគុណភាពដែលប្រមូលបានពីកិច្ចសម្ភាសន៍ និងការពិភាក្សាក្រុមគោលដៅ ជាមួយអ្នកចូលរួមមួយក្រុមធំដែលបានចូលរួមនៅក្នុងការសិក្សានេះ។

អ្នកចូលរួមខ្លះមិនទាំងយល់ពាក្យ គ.ក.ន.ក ផងទេ។ ខណៈដែលការចុះស្រាវជ្រាវតាមមូលដ្ឋាន បានបន្តអ្នកស្រាវជ្រាវកាន់តែស្ទាត់ជំនាញក្នុងការជួយអ្នកចូលរួមឲ្យយល់អំពីអត្ថន័យនៃពាក្យ គ.ក.ន.ក។ កង្វះការយល់ដឹងនេះគឺជាការរកឃើញថ្មីផង និងជាលក្ខខណ្ឌរឹតត្បិតផង។

វិសាលភាពរបស់គម្រោងបានពង្រីកដល់ទៅ ៩ដងនៃទំហំរបស់សំណើដើម។ វិធានការនានាដើម្បីកែសម្រួលទៅតាមការពង្រីកនេះ មិនបានធ្វើឡើងគ្រប់គ្រាន់ទេ ហើយពេលវេលាតិចតួចណាស់ដែលបានផ្តល់សម្រាប់ការធ្វើវិភាគទិន្នន័យ។ អាស្រ័យហេតុនេះ ការវិភាគទិន្នន័យធ្វើឡើងដោយបង្ខំ។

ការមិនអើពើ គឺជាបញ្ហាមួយនៃការការពារកុមារ ប៉ុន្តែការសិក្សានេះមិនបានគ្របដណ្តប់លើប្រធានបទនេះទេ ហើយបញ្ហានេះក៏មិនត្រូវបានបង្ហាញឲ្យឃើញថាជាបញ្ហា នៅក្នុងចម្លើយរបស់ គ.ក.ន.ក ផងដែរ។

## ៣.១ ប្រសិទ្ធភាពរបស់ គ.ក.ន.ក

**ការពិភាក្សាខាងក្រោមនេះ ត្រូវបានរៀបចំរចនាសម្ព័ន្ធផ្តោតទៅលើកត្តាមួយ ចំនួនដែលគេបានរកឃើញថាជះឥទ្ធិពលទៅលើភាពជោគជ័យ**

គ.ក.ន.ក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ដើម្បីជារចនាសម្ព័ន្ធឃុំសង្កាត់ថ្មី ហើយការស្រាវជ្រាវមានតិចតួចប៉ុណ្ណោះ ដែលទាក់ទងនឹងកត្តានានាដែលរាំង ឬលើកកម្ពស់ប្រសិទ្ធភាពរបស់គណៈកម្មាធិការនេះ។ មានរបាយការណ៍ស្រាវជ្រាវសំខាន់ចំនួន ៣ ដែលត្រូវបានពិនិត្យឡើងវិញខាងក្រោមនេះ។ នៅក្នុងឆ្នាំ២០០៦ អង្គការ UNICEF បានបោះពុម្ពផ្សាយរបាយការណ៍ មួយដែលមានចំណងជើងថា An Assessment of CCWC and Commune Focal Points ដែលផ្អែកលើព័ត៌មានដែលប្រមូលនៅក្នុងខេត្តចំនួន ៣ ដែលគាំទ្រដោយអង្គការUNICEF។ នៅក្នុងឆ្នាំ២០០៨ អង្គការUNICEF បានធ្វើការស្ទង់មតិមួយ Knowledge, Attitudes and Practices Survey of CCWCs and Focal Points នៅក្នុងឃុំសង្កាត់ចំនួន៧០។ នៅក្នុងឆ្នាំ២០១០ វិទ្យាស្ថានបណ្តុះបណ្តាលអ្នកគ្រប់គ្រងការងារ (VBNK) បានធ្វើការសិក្សាមួយដែលមានចំណងជើងថា Capacity of Assessment of the CCWC តាមរយៈការពិនិត្យឯកសារជាច្រើន។ **ការពិភាក្សាខាងក្រោមនេះ ត្រូវបានរៀបចំរចនាសម្ព័ន្ធផ្តោតទៅលើកត្តាមួយចំនួនដែលគេបានរកឃើញថាជះឥទ្ធិពលទៅលើភាពជោគជ័យ។**

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់គឺជាតំណាងរបស់ គ.ក.ន.ក នៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់។ អ្នកទទួលបន្ទុកនេះ គឺជាសមាជិកតែម្នាក់គត់របស់គណៈកម្មាធិការ ដែលជាអ្នកទទួលខុសត្រូវចម្បងលើកិច្ចការនារី និងកុមារឃុំសង្កាត់។ សមាជិកដទៃទៀត ត្រូវបានចាត់តាំងក្នុងនាមជាតំណាងរបស់ស្ថាប័នផ្សេងទៀត ដូចជា សាលារៀន និងមណ្ឌលសុខភាពក្នុងមូលដ្ឋាន ត្រូវបានតម្រូវឲ្យបញ្ជូនតំណាងមួយរូបមកអង្គុយនៅក្នុងគណៈកម្មាធិការ។ អ្នកទទួលបន្ទុក គឺជាសមាជិកដែលទទួលបានការចាត់តាំង និងទទួលបានប្រាក់បៀវត្សរ៍សម្រាប់បំពេញការងារនេះ ចំណែកឯសមាជិកដទៃទៀតមិនទទួលបានប្រាក់បៀវត្សរ៍ទេ។ មុខតំណែងជាអ្នកទទួលបន្ទុកបានមកតាមរយៈការតែងតាំង ហើយជារឿយៗ អ្នកទទួលបន្ទុកត្រូវមានបទពិសោធន៍ការងារលើវិស័យដែលទាក់ទងនឹងស្ត្រី និងកុមារ ដូចជា ជំនាញឆ្មបជាដើម។

គ.ក.ន.ក ទទួលរងឥទ្ធិពលពីបុគ្គលិកលក្ខណៈខុសៗគ្នារបស់អ្នកទទួលបន្ទុក និងសមាជិកដទៃទៀតរបស់ គ.ក.ន.ក (UNICEF ឆ្នាំ២០០៨)។ គ.ក.ន.ក មានមូលនិធិតិចតួចប៉ុណ្ណោះ។ គេពុំទាន់មានព័ត៌មានអំពីកម្រិតប្រាក់បៀវត្សរ៍របស់អ្នកទទួលបន្ទុកនៅឡើយទេ ប៉ុន្តែ សមាជិកបានពណ៌នាថា ប្រាក់បៀវត្សរ៍មានកម្រិតតិចតួចណាស់ និងថាពួកគេត្រូវចំណាយប្រាក់កាស និងពេលវេលាផ្ទាល់ខ្លួន ដើម្បីបំពេញតួនាទីនេះថែមទៀតផង។ ដោយសារតែលក្ខខណ្ឌរឹតត្បិតនេះ វាមិនគួរឲ្យភ្ញាក់ផ្អើលទេដែលគេនិយាយថា ការលះបង់របស់សមាជិក គ.ក.ន.ក ជាពិសេសអ្នកទទួលបន្ទុកត្រូវបានចាត់ទុកថា ជាកត្តាកំណត់ដែលជះឥទ្ធិពលលើជោគជ័យរបស់គណៈកម្មាធិការ។ ទំនុកចិត្តរបស់អ្នកទទួលបន្ទុក និងសមាជិកដទៃទៀតក៏ត្រូវបានបង្ហាញថា ក៏ជះឥទ្ធិពលលើការអនុវត្តមុខងារ និងប្រសិទ្ធភាពរបស់ គ.ក.ន.ក (UNICEF ឆ្នាំ២០០៦, UNICEF ឆ្នាំ២០០៨, VBNK ឆ្នាំ២០១០)។ បន្ថែមលើនេះទៅទៀតទំនុកចិត្តរបស់អ្នកទទួលបន្ទុកអាចនឹងអន្តរាយដោយសារតែការរើសអើងផ្នែកយេនឌ័រ។ ស្ត្រីខ្លះមានអារម្មណ៍ថា នៅពេលដែលអ្នកទទួលបន្ទុកជាស្ត្រី ចែករំលែកមតិយោបល់ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ មតិយោបល់ទាំងនោះជារឿយៗច្រើនតែបដិសេធដោយសមាជិកជាបុរស (VBNK ឆ្នាំ២០១០)។ អ្នកទទួលបន្ទុក គ.ក.ន.ក បានពណ៌នាអំពីកង្វះទំនុកចិត្តថាជាឧបសគ្គរាំងលទ្ធភាពរបស់ពួកគេក្នុងការអនុវត្តភារកិច្ចរបស់ គ.ក.ន.ក (UNICEF ឆ្នាំ២០០៨)។

សមាជិក គ.ក.ន.ក បានរកឃើញថា កង្វះជំនាញ គឺជាកត្តាដែលរាំងដល់ជោគជ័យរបស់ពួកគេ (UNICEF ឆ្នាំ២០០៦, UNICEF ឆ្នាំ២០០៨)។ ជំនាញទាំងនេះបែងចែកជាបីប្រភេទ៖ ជំនាញភាពជាអ្នកដឹកនាំ (ក្នុងនោះរាប់ទាំងជំនាញការប្រាស្រ័យទាក់ទង និងការសម្របសម្រួល) ជំនាញប្រតិបត្តិការ (ការរៀបចំថវិកាមូលនិធិវិនិយោគឃុំសង្កាត់) និងជំនាញលើវិស័យជាក់លាក់ (ចំណេះដឹងអំពីបញ្ហាទាក់ទងនឹងការការពារកុមារជាក់លាក់តាមករណី)។ (VBNK ឆ្នាំ២០១០)។ នៅពេលដែលកង្វះជំនាញភាពជាអ្នកដឹកនាំ ធ្វើឲ្យប៉ះពាល់ដល់ការចូលរួម និងកិច្ចប្រជុំ គ.ក.ន.ក និងរឹតត្បិតការចូលរួមពីសំណាក់សហគមន៍មូលដ្ឋាន (UNICEF ឆ្នាំ២០០៨)។ ខណៈដែលការសិក្សាអំពីទាំងក្រុមប្រឹក្សាឃុំសង្កាត់ និងទាំង គ.ក.ន.ក បានរកឃើញថា

នៅពេលដែលកង្វះជំនាញ ភាពជាអ្នកដឹកនាំ ធ្វើឲ្យប៉ះពាល់ដល់ការចូលរួម និងកិច្ចប្រជុំ គ.ក.ន.ក និងរឹតត្បិតការចូលរួមពីសំណាក់សហគមន៍មូលដ្ឋាន (UNICEF ឆ្នាំ២០០៨)។ ខណៈដែលការសិក្សាអំពីទាំងក្រុមប្រឹក្សាឃុំសង្កាត់ និងទាំង គ.ក.ន.ក បានរកឃើញថា

កង្វះចំណេះដឹងបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការអនុវត្តការងារតាមវិស័យផ្សេងៗ ក៏ត្រូវបានកំណត់ថាជាកត្តាឧបសគ្គមួយផងដែរ (UNICEF ឆ្នាំ២០០៨)។ តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក តម្រូវឲ្យសមាជិកអនុវត្តការងារពាក់ព័ន្ធនឹងវិស័យសុខាភិបាល អប់រំ និងការតស៊ូមតិសម្រាប់ការការពារកុមារការតាមដាន និងការលើកកម្ពស់ការយល់ដឹង។ បើទោះបីជាសមាជិក គ.ក.ន.ក ជាធម្មតាត្រូវបានតែងតាំងចេញពីសមាជិកសហគមន៍ដែលមានជំនាញពាក់ព័ន្ធ (គណៈកម្មាធិការនីមួយៗ មានគោលដៅដាក់បញ្ចូលសមាជិកមកពីមណ្ឌលសុខភាព និងគ្រូបង្រៀន) ប៉ុន្តែ ជារឿយៗ សមាជិក គ.ក.ន.ក មិនមានបទពិសោធន៍នៅក្នុងវិស័យនានាដែលខ្លួនត្រូវធ្វើការនោះទេ។ ជាងនេះទៅទៀត សមត្ថភាពផ្នែកការការពារកុមារ និងការងារសង្គមកិច្ចមានកម្រិតទាបនៅថ្នាក់ជាតិ (Harachi ឆ្នាំ២០១៤)។ ប្រការនេះអាចជះឥទ្ធិពលអវិជ្ជមានទៅលើលទ្ធភាពរបស់ពួកគេ ក្នុងការកំណត់រកភាពងាយរងគ្រោះ និងការអនុវត្តសកម្មភាពនានាស្របទៅតាមគោលដៅរបស់ គ.ក.ន.ក (VBNK ឆ្នាំ២០១០)។

ខណៈដែល គ.ក.ន.ក ត្រូវបានផ្តល់នូវការបណ្តុះបណ្តាល ទាំងតាមរយៈកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល និងជាញឹកញាប់ តាមរយៈភាពជាដៃគូអង្គការសង្គមស៊ីវិល។ អង្គការ Unicef (ឆ្នាំ២០០៦) បានរកឃើញថា ការបណ្តុះបណ្តាលបានធ្វើឲ្យកម្រិតសមត្ថភាពសមាជិកគណៈ កម្មាធិការមានភាពប្រសើរឡើង និងបានធ្វើឲ្យតួនាទីរបស់ គ.ក.ន.ក មានភាពច្បាស់លាស់ជាងមុន។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី VBNK បានរកឃើញថា ការបណ្តុះបណ្តាលសមាជិក គ.ក.ន.ក កម្រត្រូវគេវាយតម្លៃតាមរយៈការធ្វើតេស្តមុន និងក្រោយពេលបណ្តុះបណ្តាលណាស់ (VBNK ឆ្នាំ២០១០) ដូច្នេះហើយ គេមិនដឹងច្បាស់លាស់ទេថា តើចំណេះដឹងច្រើនប៉ុណ្ណាដែលត្រូវបានផ្ទេរក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល។

ប្រសិទ្ធភាពរបស់ គ.ក.ន.ក ត្រូវបានរារាំងបន្ថែមទៀតដោយសារកង្វះយន្តការប្រមូលទិន្នន័យ ឲ្យបានគ្រប់គ្រាន់នៅក្នុង គ.ក.ន.ក ដែលនាំឲ្យមានការលំបាកក្នុងការប្រមូលទិន្នន័យ (VBNK ឆ្នាំ២០១០)។ គ.ក.ន.ក មួយចំនួនបានធ្វើការប្រមូលទិន្នន័យក៏ពិតមែន ប៉ុន្តែទិន្នន័យទាំងនោះ មិនត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ជាព័ត៌មានដល់ការធ្វើកម្មវិធីនានាឡើយ (VBNK ឆ្នាំ២០១០)។

ទំនាក់ទំនងការងារសហប្រតិបត្តិការរឹងមាំត្រូវបានគេរកឃើញថា លើកកម្ពស់ការអនុវត្តមុខងារ និងប្រសិទ្ធភាពរបស់ គ.ក.ន.ក (UNICEF ឆ្នាំ២០០៨)។ គ.ក.ន.ក ត្រូវបានរកឃើញថាបានបង្កើតទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំសង្កាត់ មេភូមិ និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ព្រមទាំងជាមួយអង្គការក្រៅរដ្ឋាភិបាល (UNICEF ឆ្នាំ២០០៦, UNICEF ឆ្នាំ២០០៨, VBNK ឆ្នាំ២០១០)។ ទំនាក់ទំនងការងារជាមួយអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់នូវឱកាសដល់ គ.ក.ន.ក ដើម្បីផ្សារភ្ជាប់សមាជិកសហគមន៍ជាមួយនឹងសេវានានា។ កិច្ចសហប្រតិបត្តិការរវាង គ.ក.ន.ក និងអង្គការមិនមែនរដ្ឋាភិបាល ជាទូទៅ ត្រូវគេរកឃើញថាបានបង្កើនលទ្ធភាពរបស់ គ.ក.ន.ក ក្នុងការបំពេញអាណត្តិរបស់ខ្លួន (UNICEF ឆ្នាំ២០០៦, UNICEF ឆ្នាំ២០០៨, VBNK ឆ្នាំ២០១០)។

នៅពេលដែល គ.ក.ន.ក ផ្តល់សេវាដោយផ្ទាល់ដល់សមាជិកសហគមន៍ វាបង្កើនការជឿទុកចិត្តមកលើពួកគេពីសំណាក់សហគមន៍ (VBNK ឆ្នាំ២០១០)។ ជារឿយៗ “តម្លៃពិត” នេះសម្រេចបានតាមរយៈភាពជាដៃគូសហប្រតិបត្តិការ ដែលផ្សារភ្ជាប់ គ.ក.ន.ក ជាមួយនឹងសេវានានារបស់អង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី គេក៏គួរប្រយ័ត្នប្រយែងផងដែរថា ក្នុងករណីខ្លះភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើឲ្យ គ.ក.ន.ក មានភាពអន់ខ្សោយ។ ក្នុងករណីដែល គ.ក.ន.ក ធ្វើជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលច្រើន វាបានបណ្តាលឲ្យសមាជិក គ.ក.ន.ក ទទួលនូវបន្ទុកការងារច្រើនហួស (UNICEF ឆ្នាំ២០០៦)។ ការសិក្សារបស់ Plummer និង Tritt នាឆ្នាំ២០១១ ទៅលើក្រុមប្រឹក្សាឃុំសង្កាត់បានរកឃើញថា ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលច្រើន បានបណ្តាលឲ្យអាទិភាពទាំងឡាយត្រូវបានកំណត់ដោយអង្គការមិនមែនរដ្ឋាភិបាល ជាជាងកំណត់ដោយក្រុមប្រឹក្សា និងសហគមន៍។ ទោះបីជាបញ្ហានេះមិនត្រូវបានលើកឡើងនៅក្នុងការសិក្សាអំពី គ.ក.ន.ក ក៏ពិតមែន ប៉ុន្តែវាអាចទៅរួចដែលថា បញ្ហាស្រដៀងគ្នានេះកើតមាននៅក្នុង គ.ក.ន.ក ដែរ។

## ៣.២ របាយការណ៍ស្រាវជ្រាវដែលទាក់ទងនឹងអាកប្បកិរិយារបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋានចំពោះកុមារ និងការការពារកុមារ

**មានឯកសារតិចតួចប៉ុណ្ណោះ ស្តីពីអាកប្បកិរិយាចំពោះកុមារក្នុងបរិបទនៃការអភិវឌ្ឍនៅក្នុងប្រទេស កម្ពុជា**

**មានឯកសារតិចតួចប៉ុណ្ណោះ ស្តីពីអាកប្បកិរិយាចំពោះកុមារក្នុងបរិបទនៃការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា**។ ការសិក្សារបស់ O' Leary និង Nee កាលពីឆ្នាំ២០០១ Learning for Transformation បានពិនិត្យមើលទៅលើអាកប្បកិរិយាចំពោះការអភិវឌ្ឍក្នុងចំណោមអ្នកអនុវត្តគម្រោងអភិវឌ្ឍន៍ចំនួន ៤៣។ បើទោះបីការសិក្សានេះមិនបានផ្តោតលើកុមារក្តី ប៉ុន្តែបានលម្អិតអំពីអាកប្បកិរិយាវប្បធម៌ ចំពោះឋានានុក្រមដែលអនុវត្តចំពោះទំនាក់ទំនងរវាងមនុស្សពេញវ័យ និងកុមារ។ Jordanwood (ឆ្នាំ២០១០) បានវាយតម្លៃអាកប្បកិរិយាចំពោះការចូលរួមរបស់កុមារ នៅក្នុងការស្ទង់មតិកុមារចំនួន ២.០០០នាក់ នៅទូទាំងប្រទេស។ នៅឆ្នាំ២០០៩ Gourley បានសរសេរការសិក្សាដែលមានចំណងជើងថា the Middle Way ដោយផ្អែកលើកិច្ចសម្ភាសន៍ និងការស្ទង់មតិជាមួយអ្នកចូលរួមចំនួន ២.៣៤០នាក់។ ការសិក្សានេះ បានធ្វើការស៊ើបអង្កេតទៅលើអាកប្បកិរិយាចំពោះសិទ្ធិកុមារ។ កិច្ចពិភាក្សាខាងក្រោម ពិនិត្យមើលទៅលើគុណតម្លៃសំខាន់ៗចំនួន ៣ ដែលបានរកឃើញនៅក្នុងការសិក្សាទាំងនេះ ដែលប្រាប់ឲ្យដឹងអំពីអាកប្បកិរិយាចំពោះកុមារ។

### អាកប្បកិរិយាចំពោះតួនាទីរបស់កុមារនៅក្នុងសង្គម

ការសិក្សាទាំងបីនេះបានរកឃើញថា ឋានានុក្រមនៅក្នុងសង្គម ត្រូវបានឲ្យតម្លៃខ្ពស់នៅក្នុងវប្បធម៌ប្រពៃណីខ្មែរ។ នៅក្នុងឋានានុក្រមនេះ កុមារមានឋានៈទាបជាងមនុស្សពេញវ័យ និងត្រូវគិតថា មានសិទ្ធិតិចជាងឪពុកម្តាយ។ Jordanwood (ឆ្នាំ២០១០) បានរកឃើញថា កុមារត្រូវគេរំពឹងថា ត្រូវតែគោរពចំពោះឪពុកម្តាយ និងបានកត់សម្គាល់ពាក្យសុភាសិតទូទៅមួយដែលថា "កុមារត្រូវតែគោរពឪពុកម្តាយ និងស្តាប់ដំបូន្មានគ្រូ" ត្រូវបានផ្តល់ដោយការពិភាក្សាក្រុមគោលដៅ ទាំងអស់ជាការពិពណ៌នាដ៏សំខាន់អំពីតួនាទីរបស់កុមារ។ ខណៈដែល UNCRC ផ្តោតសំខាន់ទៅលើសិទ្ធិកុមារ Gourley បានរកឃើញថា កុមារនៅក្នុងប្រទេសកម្ពុជាត្រូវបានគេមានទស្សនៈយល់ឃើញថា មានទំនួលខុសត្រូវជាជាងមានសិទ្ធិ។ Gourley និង Jordanwood បានភ្ជាប់ទំនួលខុសត្រូវទាំងនេះទៅនឹងទស្សនៈរបស់កុមារ ដែលពួកគេយល់ឃើញថា ពួកគេជំពាក់ គុណឪពុកម្តាយរបស់ពួកគេចាប់តាំងពីពេលចាប់កំណើតមកម្ល៉េះ។ Jordanwood (ឆ្នាំ២០១០) បានរកឃើញថា ជំនឿដែលថាកុមារត្រូវគោរពដំបូន្មានឪពុកម្តាយ គឺមានលក្ខណៈយ៉ាងមុតមាំ រហូតដល់ថា កុមារជឿជាក់ថា វាជាទំនួលខុសត្រូវរបស់ពួកគេ ដែលត្រូវតែស្តាប់ដំបូន្មានរបស់ឪពុកម្តាយ បើទោះបីជាលទ្ធផលអាចនឹងប៉ះពាល់ដល់កុមារក្តី។

### អាកប្បកិរិយាចំពោះការចូលរួមរបស់កុមារ

ការគោរពដែលកុមារត្រូវតបស្នងចំពោះឪពុកម្តាយត្រូវបានរកឃើញថា ជាកត្តាបន្ទប់បង្អាក់ទឹកចិត្ត ដល់ការចូលរួមរបស់កុមារនៅក្នុងកិច្ចអភិវឌ្ឍន៍។ O' Leary និង Nee (ឆ្នាំ២០០១) កត់សម្គាល់ថា នៅក្នុងរចនាសម្ព័ន្ធឋានានុក្រមជាប្រពៃណី អ្នកដែលមានអំណាចក៏ត្រូវគេសន្មតថា ជាមនុស្សមានចំណេះដឹង ហើយតួនាទីរបស់អ្នកនៅខាងក្រោម គឺត្រូវទទួលចំណេះដឹងនេះដោយគ្មានការសួរនាំ។ Jordanwood (ឆ្នាំ២០១០) បានរកឃើញថា នៅក្នុងគ្រួសារ និងសាលារៀន គេកម្រលើកទឹកចិត្តឲ្យកុមារសួរសំណួរ ឬបញ្ចេញមតិយោបល់ណាស់។ Gourley (ឆ្នាំ២០០៩) និង Jordanwood (ឆ្នាំ២០១០) បានរកឃើញថា ទោះបីជាអាកប្បកិរិយា ហាក់មានការផ្លាស់ប្តូរក៏ពិតមែន ប៉ុន្តែអាកប្បកិរិយា ដែលជាប្រពៃណីរបស់ប្រជាជនកម្ពុជា បានរារាំងកុមារមិនឲ្យចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ និងនៅក្នុងសកម្មភាពនានា ដើម្បីធ្វើឲ្យជីវិតរបស់ពួកគេមានភាពប្រសើរឡើង។ ការចូលរួមត្រូវបានគេរកឃើញថា គឺជាបញ្ហាប្រឈមជាពិសេសនៅក្នុងការមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងវិស័យសាធារណៈ (O' Leary និង Nee, Plummer ឆ្នាំ២០១២)។

### អាកប្បកិរិយាចំពោះកុមារម្នាក់ៗ និងផលប្រយោជន៍រួម

Gourley (ឆ្នាំ២០០៩) ពិភាក្សាអំពីទំនាស់រវាងគុណតម្លៃដែលផ្តល់ដល់កុមារជាបុគ្គល នៅក្នុង UNCRC និងគុណតម្លៃ ដែលផ្តល់ទៅលើផលប្រយោជន៍រួមនៅក្នុងសង្គមប្រពៃណីខ្មែរ។ ការសិក្សាទាំងបីកត់សម្គាល់ថា អាកប្បកិរិយាជាប្រពៃណីរបស់ប្រជាជនខ្មែរលើកកម្ពស់ផលប្រយោជន៍រួម ទន្ទឹមគ្នានឹងសិទ្ធិរបស់បុគ្គល និងកត់សម្គាល់នូវតួនាទីនៃគុណតម្លៃទាំងនេះ នៅក្នុងការដោះស្រាយករណីរំលោភបំពាន។ Gourley បង្ហាញអំពីផលប៉ះពាល់នៃគុណតម្លៃប្រទាំងប្រទើសគ្នានេះ តាមរយៈការរៀបរាប់របស់ឪពុកមួយរូប អំពីដំណោះស្រាយចំពោះករណីរំលោភសេពសន្ថវៈមួយ៖

> “អ្នកត្រូវតែយល់ថា៖ ព្រហ្មចារី (ភាពបរិសុទ្ធរបស់មនុស្សស្រី) គឺសំខាន់ខ្លាំងណាស់នៅក្នុងសង្គមកម្ពុជា ហើយប្រសិនបើអ្នកផងទាំងពួងដឹងថា កូនស្រីខ្ញុំត្រូវបានគេរំលោភសេពសន្ថវៈ (យើងទាំងអស់គ្នា) នឹងបាត់បង់កិត្តិយស ហើយប្រសិនបើកើតរឿងបែបនេះមែន នោះគ្មានអ្នកណាម្នាក់នឹងរៀបការជាមួយកូនស្រីរបស់ខ្ញុំទេ។ ហើយបើគ្មានអ្នកណាដណ្តឹងនាងធ្វើជាប្រពន្ធទេ នោះនៅពេលដែលខ្ញុំ និងប្រពន្ធខ្ញុំស្លាប់ទៅបាត់ តើបាននរណាមើលថែទាំនាង?” ទំព័រ ២៥។

Gourley (ឆ្នាំ២០០៩) និង Jordanwood (ឆ្នាំ២០១០) បានរកឃើញដូចគ្នាថា នៅក្នុងវប្បធម៌ប្រពៃណីខ្មែរ កុមារជារឿយៗត្រូវគេរំពឹងថា ត្រូវលះបង់សិទ្ធិបុគ្គលរបស់ខ្លួនដើម្បីភាពសុខដុមរមនារបស់សហគមន៍។ អ្វីដែលសំខាន់ គឺគួរកត់សម្គាល់ថា ក្នុងករណីក្រីក្របំផុត ការរស់រានជីវិតរបស់បុគ្គលម្នាក់ អាចនឹងអាស្រ័យទៅលើផលប្រយោជន៍រួម។ ឧទាហរណ៍ នៅក្នុងករណីដែលសមាជិកគ្រួសារនៅតែបន្តរស់នៅជាមួយប្តីដែលប្រើអំពើហិង្សា គឺដោយសារតែពួកគេត្រូវការប្រាក់ចំណូលបន្ថែមសម្រាប់ម្ហូបអាហារ។ ក្នុងករណីបែបនេះ សិទ្ធិរបស់កុមារក្នុងការទទួលបានការការពារ (មិនត្រូវគេវាយ) ត្រូវបានលះបង់ដើម្បីសិទ្ធិរស់រានមានជីវិត (សិទ្ធិទទួលបានអាហារ)។

**ឯកសារស្រាវជ្រាវបង្ហាញថា អាកប្បកិរិយាជាប្រពៃណីរបស់ប្រជាជនកម្ពុជាចំពោះកុមារ អាចបន្ទច់បង្អាក់ ទឹកចិត្តចូលរួមរបស់កុមារនៅក្នុងទម្លាប់អនុវត្តន៍អភិបាលកិច្ចមូលដ្ឋាន**

**ឯកសារស្រាវជ្រាវបង្ហាញថា អាកប្បកិរិយាជាប្រពៃណីរបស់ប្រជាជនកម្ពុជាចំពោះកុមារ អាចបន្ទច់បង្អាក់ទឹកចិត្តចូលរួមរបស់កុមារនៅក្នុងទម្លាប់អនុវត្តន៍អភិបាលកិច្ចមូលដ្ឋាន។** គុណតម្លៃជាប្រពៃណី ដែលផ្តល់ដល់ឋានានុក្រម និងជំនឿដែលថា កុមារត្រូវតែគោរព និងស្តាប់ដំបូន្មាន ប៉ុន្តែមិនត្រូវបញ្ចេញមតិយោបល់ អាចជាឧបសគ្គរាំងដល់ការចូលរួម។ ជាប្រពៃណី សិទ្ធិបុគ្គលមិនសំខាន់ជាងភាពសុខដុមរមនាឡើយ ហើយប្រការនេះ ក៏អាចជារបាំងមិនមែនចំពោះតែការចូលរួមប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ចំពោះការរាយការណ៍ករណីរំលោភបំពានផងដែរ។ ជំនឿដែលថា កុមារជំពាក់គុណ និងបំណុលឪពុកម្តាយ អាចរាំងដល់ការសម្រេចបានសិទ្ធិរបស់កុមារ ប៉ុន្តែ គេក៏អាចបង្វែរសិទ្ធិទាំងនេះបានផងដែរ។ ប្រសិនបើការចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន អាចត្រូវគេចាត់ទុកថាជាទំនួលខុសត្រូវរបស់កុមារ នោះឪពុកម្តាយរបស់ពួកគេអាចនឹងគាំទ្រដល់ពួកគេកាន់តែខ្លាំងក្លាជាងនេះ។

# លទ្ធផល

## ការអនុវត្តមុខងាររបស់ គ.ក.ន.ក. ពាក់ព័ន្ធបញ្ហាការពារកុមារ

ផ្នែកនេះ ពិនិត្យមើលជាបឋមទៅលើការអនុវត្តមុខងាររបស់ គ.ក.ន.ក. ដោយបង្ហាញថាភារកិច្ចរបស់ គ.ក.ន.ក. មានអ្វីខ្លះ ហើយបន្ទាប់មកពិនិត្យទៅលើប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចទាំងនេះ។ ផ្នែកនេះផ្តោតទៅលើប្រសិទ្ធភាពរបស់ គ.ក.ន.ក. ក្នុងការបំពេញភារកិច្ចទូទៅបំផុតក្នុងការការពារកុមារ ដែលរួមមាន ការលើកកម្ពស់ការយល់ដឹង ការប្រមូលព័ត៌មានពាក់ព័ន្ធនឹងស្ត្រី និងកុមារ និងការបញ្ជូនទៅរកសេវា ឬការផ្តល់សេវា។ បន្ទាប់មក ផ្នែកនេះ នឹងបន្តវាយតម្លៃកិច្ចប្រឹងប្រែងរបស់ គ.ក.ន.ក. ថាជាភារកិច្ចដ៏ទៃទៀត ដែល គ.ក.ន.ក. ត្រូវបានតម្រូវឲ្យធ្វើទៅតាមគោលនយោបាយ ប៉ុន្តែមិនបានរាយពីភារកិច្ចសំខាន់ៗនៅក្នុងការប្រមូលទិន្នន័យ ឡើយ។

ដើម្បីស្វែងយល់អំពីកិច្ចការដែល គ.ក.ន.ក. កំពុងធ្វើ ក្រុមស្រាវជ្រាវ ជាដំបូង បានស្នើសុំសមាជិក គ.ក.ន.ក. ឲ្យរៀបរាប់អំពីភារកិច្ចរបស់ពួកគេជាការឆ្លើយតបនឹងសំណួរបើក ហើយបន្ទាប់មក ឲ្យពួកគេជ្រើសរើសភារកិច្ចសំខាន់ៗពីបញ្ជី ភារកិច្ចការងារ ដែលត្រូវបំពេញដោយគណៈកម្មាធិការ។ បន្ទាប់មក ការឆ្លើយតបទៅនឹងសំណួរបើកដំបូង ត្រូវបានយកទៅវិភាគ ចាត់ប្រភេទ និងចាត់ថ្នាក់។

សកម្មភាពចំនួន ៩ ខាងក្រោមនេះ គឺហាក់ដូចជាសកម្មភាពស្នូលរបស់ គ.ក.ន.ក. ជាច្រើន។
អ្វីដែលបានបង្ហាញនៅកម្រិតទី១ គឺជាចម្លើយដែលលើកឡើងញឹកញាប់បំផុត ដែលទទួលបានពិន្ទុច្រើនជាងចំណុចដទៃទៀត។ កម្រិតទី២គឺជាចម្លើយដែលលើកឡើងញឹកញាប់បន្ទាប់ ចំណែកឯសកម្មភាព ៥ ចុងក្រោយ មានចម្លើយដែលលើកឡើងតិចជាងគេ។ ចម្លើយដែលមានចំណាត់ថ្នាក់កំពូលទាំង ៩ នេះ ត្រូវបានលើកឡើងជាថ្មីម្តងទៀតពេល ឆ្លើយតបទៅនឹងសំណួរក្រោយផ្សេងៗគ្នាស្ថិតក្នុង FGD តែមួយ ហើយក៏ត្រូវបានលើកឡើងជាថ្មីម្តងទៀតនៅក្នុង FGD ជាមួយក្រុម និង និងកិច្ចសម្ភាសន៍ដទៃទៀតដែរ។




**ក្រាហ្វ ១. ភារកិច្ចស្នូលរបស់ គ.ក.ន.ក. ដែលបានរាយការណ៍**

**ក្នុងចំណោមភារកិច្ចទាំង ៩ របស់ គ.ក.ន.ក. ដែលមានចំណាត់ថ្នាក់ខ្ពស់រួមមាន៖**

- ៥/៩ ទាក់ទងផ្ទាល់ទៅនឹងការការពារកុមារ (ជួយស្វែងរកដំណោះស្រាយសម្រាប់អំពើហិង្សាក្នុងគ្រួសារ ដោះស្រាយបញ្ហារបស់មាតា និងកុមារងាយរងគ្រោះ បង្ការការរំលោភបំពានផ្លូវភេទ ការលើកកម្ពស់ការ យល់ដឹងទាក់ទងនឹងចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ពលកម្មកុមារ និង ការរើសអើងយេនឌ័រ ការប្រមូលព័ត៌មានពាក់ព័ន្ធនឹងស្ត្រី និងកុមារ ងាយរងគ្រោះ)
- ១/៩ ពាក់ព័ន្ធនឹងការអប់រំ (ការគាំទ្រ/ការជំរុញកុមារឲ្យចូលសាលារៀន) ប៉ុន្តែដូចដែលភាគីពាក់ព័ន្ធជាច្រើន បានលើកឡើងភារកិច្ចនេះពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការការពារកុមារដោយសារការចូលសាលារៀន អាចជួយ ទប់ស្កាត់កុមារមិនឲ្យធ្លាក់ចូលទៅក្នុង ពលកម្មកុមារ ហើយអាចកាត់បន្ថយឱកាសចំណាកស្រុករបស់ពួកគេ។
- ២/៩ ពាក់ព័ន្ធនឹងសុខាភិបាល (ការផ្តល់ការគាំទ្រផ្នែកសុខាភិបាលដល់ស្ត្រីមានគភ៌ ការផ្តល់អាហារូបត្ថម្ភ និងព័ត៌មានផ្នែកអនាម័យ) និងភារកិច្ចចុងក្រោយ។
- ការបណ្តុះបណ្តាលក្រុមយុវជន អាចមានជាប់ពាក់ព័ន្ធទៅនឹងវិស័យជាច្រើនផ្សេងៗគ្នា។

**ចំណាត់ថ្នាក់នេះបង្ហាញថា គ.ក.ន.ក. យល់ឃើញថា ភារកិច្ចរបស់ពួកគេគឺផ្តោតទៅលើតម្រូវការការពារកុមារនៅក្នុងសហគមន៍។**
ប្រៀបធៀបទៅនឹងអាណត្តិរបស់ពួកគេ ចំណាត់ថ្នាក់ភារកិច្ចរបស់ គ.ក.ន.ក. ចែកចេញជា ៣ ស្ថានភាព៖ ស្របតាម ពាក់ព័ន្ធតិចតួច និងមិនបានលើកឡើង ដូចដែលបង្ហាញនៅក្នុងតារាង ១ខាងក្រោមនេះ។

**តារាង ១**

| ការប្រៀបធៀបនឹងគោលនយោបាយ | ភារកិច្ចកំណត់ដោយអាណត្តិ | ភារកិច្ចដែលបានរាយការណ៍ |
|---|---|---|
| ស្របនឹងគោលនយោបាយ | ការលើកកម្ពស់ការយល់ដឹងពីច្បាប់ និងគោលនយោបាយ ដទៃទៀតពាក់ព័ន្ធនឹងសិទ្ធិស្ត្រី និងកុមារនៅក្នុងចំណោម ប្រជាជនក្នុងឃុំ/សង្កាត់ | កាការលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងចំណាកស្រុកដោយសុវត្ថិភាព និងការបង្ការ ការជួញដូរមនុស្ស ពលកម្មកុមារ និងការរើសអើងយេនឌ័រ |
| | ផ្តល់ជំនួយដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ដើម្បីប្រមូល វិភាគ ព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងបញ្ហា និងតម្រូវការរបស់ ស្ត្រី និងកុមារ និងធ្វើសមាហរណកម្មព័ត៌មាននេះទៅក្នុង CDP និង CIP | ប្រមូលព័ត៌មានពាក់ព័ន្ធនឹងស្ត្រី និងកុមារងាយរងគ្រោះ |
| ពាក់ព័ន្ធតិចតួចនឹងគោលនយោបាយ | ប្រមែប្រមូលសហគមន៍ទៅលើសុខភាព ការអប់រំ ការការពារ និងការអភិវឌ្ឍកុមារ រួមទាំងការចុះបញ្ជីទារកកើតថ្មី និងកុមារ<br><br>ការចូលរួមក្នុងការអនុវត្ត តាមដាន និងវាយតម្លៃផែនការឃុំ/សង្កាត់ពាក់ព័ន្ធនឹងស្ត្រី និងកុមារ | ផ្តល់ការគាំទ្រ ផ្នែកសុខមាលភាព ដល់ស្ត្រីមានផ្ទៃពោះ<br>ផ្តល់អាហារូបត្ថម្ភ និងព័ត៌មានអនាម័យ<br>ជួយស្វែងរកដំណោះស្រាយសម្រាប់អំពើហិង្សាក្នុងគ្រួសារ<br>គាំទ្រ/ជំរុញកុមារឲ្យចូលសាលារៀន<br>ដោះស្រាយបញ្ហាមាតា និងកុមារងាយរងគ្រោះ<br>បង្ការការរំលោភបំពានផ្លូវភេទ<br>បណ្តុះបណ្តាលក្រុមយុវជន |
| មិនបានលើកឡើងនៅក្នុងចំណាត់ថ្នាក់ | រៀបចំផែនការការងារប្រចាំឆ្នាំ និងកញ្ចប់ថវិកាសម្រាប់គណៈកម្មាធិការ និងបញ្ជូនទៅឲ្យក្រុមប្រឹក្សាឃុំ/សង្កាត់អនុម័ត | មិនបានបញ្ជាក់ |
| | តស៊ូមតិឲ្យស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ/សង្កាត់ | |

**៥/៩ រាយការណ៍ថា សកម្មភាព គ.ក.ន.ក. អាចត្រូវបានគេយល់ឃើញថា ជាអ្នកផ្ដល់សេវា**

ចុងបញ្ចប់ចំណាត់ថ្នាក់នេះក៏បានបង្ហាញថា គ.ក.ន.ក. យល់ឃើញថា ភារកិច្ចរបស់ពួកគេ មានលើសពីការតស៊ូមតិ ការលើកកម្ពស់ការយល់ដឹង និងការតាមដានទៅទៀត ដោយរួមបញ្ចូលទាំងការអនុវត្តការផ្ដល់សេវាផងដែរ។ ៥/៩ រាយការណ៍ថា សកម្មភាព គ.ក.ន.ក. អាចត្រូវបានគេយល់ឃើញថា ជាអ្នកផ្ដល់សេវា៖

- ផ្ដល់ការគាំទ្រផ្នែកសុខាភិបាលដល់ស្ត្រីមានផ្ទៃពោះ
- ជួយស្វែងយកដំណោះស្រាយដល់អំពើហិង្សាក្នុងគ្រួសារ
- ជួយគាំទ្រ/ជំរុញកុមារឲ្យចូលសាលារៀន
- បណ្ដុះបណ្ដាលក្រុមយុវជនទៅលើបញ្ហាជាច្រើន
- ដោះស្រាយបញ្ហាមាតា និងកុមារងាយរងគ្រោះ

បន្ទាប់ពីការចាត់ចំណាត់ថ្នាក់ សមាជិក គ.ក.ន.ក. នៅក្នុង FGD ត្រូវបានស្នើឲ្យជ្រើសរើសការងារដែល គ.ក.ន.ក. របស់ពួកគេបានធ្វើ ដោយជ្រើសរើសចេញពីបញ្ជីជាលាយលក្ខណ៍អក្សរ។ ការងារទាំងនេះឆ្លើយតបយ៉ាងជិតដិតទៅនឹងភារកិច្ចរបស់ គ.ក.ន.ក. ដូចដែលបានកំណត់នៅក្នុងគោលនយោបាយ (RGC)។ ការស្នើសុំអ្នកចូលរួមឲ្យជ្រើសរើសបញ្ជីនៃភារកិច្ចដែលមានចែងនៅក្នុងគោលនយោបាយ អាចឈានទៅរកភាពលម្អៀងនៅក្នុងការផ្ដល់ចម្លើយ ដោយសារអ្នកចូលរួមអាចមានអារម្មណ៍ថា ពួកគេគួរតែធ្វើសកម្មភាពនីមួយៗ។ ក្រុមអ្នកស្រាវជ្រាវជឿថា សំណួរបើកកាលពីដំបូងពាក់ព័ន្ធនឹងភារកិច្ចរបស់ គ.ក.ន.ក. មានសុពលភាពជាងបញ្ជីនៃការស្ទង់មតិទៅទៀត។

គ.ក.ន.ក. ភាគច្រើនបំផុត បានរាយការណ៍ថា បានបំពេញការងារស្ទើរតែទាំងអស់ដូចមាននៅក្នុងបញ្ជី។ នេះបង្ហាញថា សមាជិក គ.ក.ន.ក. បានដឹងអំពីការងារដែលពួកគេមានកាតព្វកិច្ចត្រូវបំពេញ។ រឿងនេះគួរឲ្យភ្ញាក់ផ្អើលផងដែរ ដោយសារមានពាក់កណ្ដាលនៃ គ.ក.ន.ក. ត្រូវបានគេជ្រើសរើសជាសំណាកដោយចេតនា ពីព្រោះគេជឿថា សមាជិក គ.ក.ន.ក. ជាជនអសកម្ម។ ទោះជាយ៉ាងណាក៏ដោយ នៅពេលក្រុមស្រាវជ្រាវសិក្សាបន្ថែម មានការបង្ហាញយ៉ាងច្បាស់ថា ភារកិច្ចជាច្រើន ត្រូវបានគេបំពេញយកតែនាមប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងប្រសិទ្ធភាពរបស់ គ.ក.ន.ក. នៅក្នុងការបំពេញភារកិច្ចទៅតាមភារកិច្ចដែលមានចែងនៅក្នុងគោលនយោបាយ នឹងមានការពិភាក្សានៅក្នុងផ្នែកខាងក្រោមនេះ។

## ៤.២ ការវាយតម្លៃទំនួលខុសត្រូវរបស់ គ.ក.ន.ក

### ៤.២.១ ការលើកកម្ពស់ការយល់ដឹងអំពីចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរ កុមារ និងពលកម្មកុមារ

**សមាជិក គ.ក.ន.ក ជាច្រើនមាន ចំណេះដឹងកម្រិតខ្ពស់ អំពីបញ្ហាសិទ្ធិភាគច្រើនបំផុត ដែលទាក់ទងនឹងការការពារកុមារ ជាពិសេស សិទ្ធិកុមារ និងពលកម្មកុមារ**

យោងតាមគោលនយោបាយ (RGC ឆ្នាំ២០០៨) គ.ក.ន.ក មានភារកិច្ចលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយដែលទាក់ទងនឹងសិទ្ធិនារី និងសិទ្ធិកុមារ។ ការធ្វើការពិភាក្សាក្រុមគោលដៅជាមួយ គ.ក.ន.ក និងសម្ភាសន៍ជាមួយបុគ្គលទទួលបន្ទុក បានរកឃើញថា សមាជិក គ.ក.ន.ក ជាច្រើនមានចំណេះដឹងកម្រិតខ្ពស់ អំពីបញ្ហាសិទ្ធិភាគច្រើនបំផុត ដែលទាក់ទងនឹងការការពារកុមារ ជាពិសេសសិទ្ធិកុមារ និងពលកម្មកុមារ។ ឪពុកម្ដាយ និងកុមារភាគច្រើនបំផុត ក៏មានចំណេះដឹងច្រើន អំពីបញ្ហាការការពារកុមារទាំងនេះផងដែរ។ ប្រការនេះ ត្រូវបានគាំទ្រដោយភស្តុតាងនៅក្នុងឯកសារកម្មវិធីមួយ គឺការស្ទង់មតិមួយ ដែលបានរាយការណ៍ថា កុមារី ៧៨,៨ភាគរយ និងកុមារា ៦៦,៥ភាគរយ ដែលមានអាយុចាប់ពី ៨ ដល់ ១៨ឆ្នាំ បានរាយការណ៍ថា យល់ដឹងអំពីសិទ្ធិកុមារ។

**ប៉ុន្តែអ្នកចូលរួមមានការយល់ដឹងកម្រិតទាប អំពីការរំលោភបំពានផ្លូវភេទ ដែលជាបញ្ហាជាប់ទាក់ទង យ៉ាងជិតស្និទ្ធ ទៅនឹងសិទ្ធិកុមារ**

ប៉ុន្តែអ្នកចូលរួមមានការយល់ដឹងកម្រិតទាប អំពីការរំលោភបំពានផ្លូវភេទ ដែលជាបញ្ហាជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិកុមារ។ សមាជិក គ.ក.ន.ក និងក្រុមគ្រួសារ ផ្ដោតទៅលើតែការរំលោភសេពសន្ថវៈ ខណៈដែលទម្រង់ផ្សេងទៀតនៃការរំលោភបំពានមិនត្រូវបានលើកឡើងឡើយ។ ប្រការនេះដូចគ្នាទៅនឹងការវាយតម្លៃមួយដែលបានធ្វើឡើងនាពេលថ្មីៗ ទៅលើកម្មវិធីដែលធ្វើការលើ បញ្ហារំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ច ដែលបានរកឃើញកម្រិតទាបនៃការយល់ដឹងអំពីទម្រង់ និងវិធីនានានៃការរំលោភបំពានផ្លូវភេទ (Embode ឆ្នាំ២០១៥)។

[៩] ចម្លើយដែលឆ្លើយតបសំណួរផ្សេងៗនៅពេលក្រោយបានបញ្ជាក់ពីភារកិច្ចនេះបន្តិចបន្តួចដែរ ហើយចម្លើយទាំងនេះក៏ត្រូវបានពិភាក្សាខាងក្រោមដែរ។

ក្រុមស្រាវជ្រាវមិនអាចធ្វើការវាយតម្លៃបានទេថាតើចំណេះដឹងអំពីសិទ្ធិកុមារ ពលកម្មកុមារ និងការការពារ កុមារកើតចេញពីលទ្ធផលនៃការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល ឬយ៉ាងណានោះទេ ដោយសារតែកង្វះនៃការធ្វើតេស្តនៅមុន និងក្រោយពេលបណ្តុះបណ្តាល អំពីចំណេះដឹងរបស់អ្នកចូលរួម។ Gourley នៅក្នុងការសិក្សាថ្នាក់ជាតិមួយនៅក្នុងឆ្នាំ២០០៩ បានរកឃើញថា ឪពុកម្តាយមានចំណេះដឹងកម្រិតខ្ពស់អំពីសិទ្ធិកុមារ និងពលកម្មកុមារ ដូច្នេះវាអាចទៅរួចដែលថាចំណេះដឹងនោះមានតាំងពីមុនពេលបណ្តុះបណ្តាលទៅទៀត។

**ការលើកកម្ពស់ការយល់ដឹងត្រូវបានសមាជិក គ.ក.ន.ក ឲ្យនិយមន័យមិនច្បាស់លាស់**

ការលើកកម្ពស់ការយល់ដឹងត្រូវបានសមាជិក គ.ក.ន.ក ឲ្យនិយមន័យមិនច្បាស់លាស់។ នៅពេលស្នើឲ្យពណ៌នាអំពីសកម្មភាពលើកកម្ពស់ការយល់ដឹង សមាជិក គ.ក.ន.ក ជាច្រើន បានពណ៌នាថាអំពីវេទិកា និងព្រឹត្តិការណ៍នានា។ ឧទាហរណ៍ដែលបានលើកឡើង ផ្តោតជុំវិញបញ្ហាសុខភាព ដូចជាការពន្យល់ដល់អ្នកកាន់ប័ណ្ណមូលនិធិសមធម៌សុខភាព អំពីរបៀបប្រើប័ណ្ណនេះ ឬការជម្រាបដល់អ្នកចូលរួមអំពីសារសំខាន់នៃការធ្វើសំបុត្រកំណើតឲ្យកូនជាដើម។ បញ្ហាមួយចំនួនដែលលើកឡើងថា ទាក់ទងនឹងការការពារកុមារ គឺសារៈសំខាន់នៃការទៅរៀន និងចំណាកស្រុកដោយប្រសិទ្ធភាព។ សមាជិក គ.ក.ន.ក ខ្លះ បានពណ៌នាស្ទើរតែគ្រប់សកម្មភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់ដូចជា ការប្រជុំប្រចាំខែ ជាដើមថាជាទម្រង់មួយនៃការលើកកម្ពស់ការយល់ដឹង។
ទាំងការស្រាវជ្រាវ ទាំងឯកសារដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល មិនបានលើកឡើងអំពីការធ្វើតេស្តនៅមុន និងក្រោយព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងទេ ប៉ុន្តែ អ្នកចូលរួមជាច្រើន បានសំដែងនូវការជឿជាក់ថា សកម្មភាពរបស់ពួកគេមានឥទ្ធិពល ដូចរៀបរាប់ខាងក្រោមនេះ។

សមាជិក
គ.ក.ន.ក

ចំនួនករណីអំពើហិង្សាក្នុងគ្រួសារបានថយចុះ។ ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ យើងមានករណីហឹង្សាក្នុងគ្រួសារតិចតួចបំផុត។ នេះគឺដោយសារតែ គ.ក.ន.ក បានធ្វើការពន្យល់ណែនាំឪពុកម្តាយអំពីច្បាប់។

ខ្ញុំបានដឹងថា ការវាយកូនចៅ គឺមិនល្អទេ ដូច្នេះ ឥឡូវនេះ ខ្ញុំមិនវាយកូនដូចមុនទៀតទេ។

ឪពុកម្តាយ

### ៤.២.២ ការប្រមូលព័ត៌មានអំពីស្ត្រី និងកុមារ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការបែងចែកសេវា

**អ្នកចូលរួមជាច្រើននៅក្នុង FGDs ជាមួយ គ.ក.ន.ក និងនៅក្នុងកិច្ចសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន បានពណ៌នាអំពីដំណើរការនានានៃការ ប្រមូលព័ត៌មានអំពីស្ត្រី និងកុមារ ដើម្បី ផ្តល់ជាព័ត៌មានសម្រាប់ការអនុវត្ត**

គ.ក.ន.ក មានភារកិច្ចតាមដានស្ថានភាពស្ត្រី និងកុមារនៅក្នុងឃុំសង្កាត់ និងធ្វើរបាយការណ៍ទៀងទាត់ (RGC ឆ្នាំ២០០៨)។ អ្នកចូលរួមជាច្រើននៅក្នុង FGDs ជាមួយ គ.ក.ន.ក និងនៅក្នុងកិច្ចសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន បានពណ៌នាអំពីដំណើរការនានានៃការប្រមូលព័ត៌មានអំពីស្ត្រី និងកុមារ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការអនុវត្ត។ នៅក្នុងករណីខ្លះ ពាក់ព័ន្ធនឹងដំណើរការប្រមូលព័ត៌មានផ្លូវការដែលធ្វើឡើងដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ដូចដែលមានរៀបរាប់នៅខាងក្រោម (ត្រង់ផ្នែកស្តីពីការគាំទ្រសម្រាប់ការធ្វើផែនទី និងការតាមដាន គ.ក.ន.ក)។ ភាគច្រើនបំផុតនៃអង្គការទាំងនេះបានពន្យល់ថា ដំណើរការប្រមូលព័ត៌មានពាក់កណ្តាលផ្លូវការ គឺមានជាទូទៅ និងធ្វើឡើងនៅពេលមានកិច្ចប្រជុំរបស់ គ.ក.ន.ក។ នៅក្នុង គ.ក.ន.ក មួយចំនួន សមាជិកនឹងធ្វើរបាយការណ៍ជាផ្លូវការ អំពីចំនួនស្ត្រី និងកុមារងាយរងគ្រោះដែលមាននៅក្នុងភូមិរបស់ពួកគេ។ នៅក្នុង គ.ក.ន.ក ជាច្រើន កិច្ចប្រជុំប្រចាំខែបានផ្តល់ជាកន្លែងមួយសម្រាប់សមាជិករាយការណ៍អំពីករណីស្ត្រី និងកុមារ ដែលពួកគេជឿជាក់ថាត្រូវការជំនួយជាចាំបាច់។ សមាជិក គ.ក.ន.ក និយាយថា ជាធម្មតា ករណីទាំងនេះត្រូវបានលើកឡើងដោយមេភូមិ ដែលបានទទួលព័ត៌មានពីសហគមន៍។

ខណៈដែលសមាជិក គ.ក.ន.ក មួយចំនួនបាននិយាយថា ពួកគេត្រូវបានក្រុមគ្រួសារ ឬកុមារមករកដោយផ្ទាល់ ប៉ុន្តែប្រការនេះ មិនមែនជាទម្លាប់អនុវត្តន៍ទូទៅនោះទេ។ ក្រុមគ្រួសារជាច្រើនបំផុតនៅក្នុងការពិភាក្សាក្រុមគោលដៅ បាននិយាយថា ពួកគេដឹងថា គ.ក.ន.ក គឺជាអ្វី។ នេះប្រហែលបណ្តាលមកពីភាពលម្អៀងនៃការជ្រើសរើសសំណាក ពីព្រោះឯកសារតាមដានពីអង្គការមិនមែនរដ្ឋាភិបាលមួយដែលជាសមាជិករបស់គណៈកម្មាធិការដឹកនាំ បានរកឃើញថា គ្រួសារភាគច្រើនបំផុតមិនដឹងថា គ.ក.ន.ក ជាអ្វីនោះទេ ប៉ុន្តែ បានស្គាល់សមាជិករបស់ គ.ក.ន.ក ដោយមិនទាំងដឹងអំពីតួនាទីរបស់សមាជិកនោះនៅក្នុងគណៈកម្មាធិការផង។ កុមារមានការយល់ដឹងអំពី គ.ក.ន.ក កម្រិតទាប។

> កុមារមិនដែលសុំជំនួយពី គ.ក.ន.ក ទេ ពីព្រោះពួកគេមិនស្គាល់ គ.ក.ន.ក ឡើយ។
>
> សមាជិក គ.ក.ន.ក

**កុមារតិចជាង ៥០ភាគរយ ដែលបានចូលរួមនៅក្នុង FGDs បានរាយការណ៍ថាបានស្គាល់ គ.ក.ន.ក។**

កុមារតិចជាង ៥០ភាគរយ ដែលបានចូលរួមនៅក្នុង FGDs បានរាយការណ៍ថាបានស្គាល់ គ.ក.ន.ក។ ១០/២២ FGDs ជាមួយកុមារ បានបង្ហាញថា កុមារស្គាល់អ្វីទៅជា គ.ក.ន.ក ៩/២២ ធ្លាប់បានជួបជាមួយ គ.ក.ន.ក និង ២/២២ បានរាយការណ៍ថា បានទទួលជំនួយពីគ.ក.ន.ក ដូចដែលបង្ហាញនៅក្នុងក្រាហ្វ ២។ អ្នកចូលរួមបានពន្យល់ថា តាមប្រពៃណីវប្បធម៌ ឪពុកម្តាយត្រូវគេរំពឹងថា នឹងបំពេញតួនាទីក្នុងការទាក់ទងជាមួយអាជ្ញាធរ និងថា កុមារមានការខ្មាស់អៀនមិនហ៊ានទាក់ទងទៅ គ.ក.ន.ក ដោយខ្លួនឯងឡើយ។

**ចំណេះដឹងអំពី គ.ក.ន.ក ដែលបានរាយការណ៍ដោ**




**ក្រាហ្វ ២៖ ចំណេះដឹងរបស់កុមារអំពី គ.ក.ន.ក ដែលបានរាយការណ៍**

[៥] ពាក់កណ្តាលផ្លូវការ ក្នុងន័យថាវាផ្តោតទៅលើកិច្ចប្រជុំផ្លូវការរបស់ គ.ក.ន.ក ប៉ុន្តែ វាមិនបានពាក់ព័ន្ធនឹងដំណើរការតាមដានផ្លូវការនោះទេ។

ខណៈដែល ២៧/២៨ នៃក្រុមសមាជិក គ.ក.ន.ក បាននិយាយថា ពួកគេបានធ្វើសកម្មភាពផ្សព្វផ្សាយ អប់រំសកម្មភាពនេះ ត្រូវបានពណ៌នាថាជាការចុះទៅជួបគ្រួសារក្រីក្រ ដែលត្រូវបានកំណត់រកឃើញកាលពីពេលមុន។ គ.ក.ន.ក តិចតួចប៉ុណ្ណោះ ដែលបានពណ៌នាអំពីដំណើរការជាប្រព័ន្ធ សម្រាប់ការកំណត់រកស្ត្រី និងកុមារងាយរងគ្រោះ ដែលធ្វើឡើងជារៀងរាល់ខែ ហើយវាអាចទៅរួចដែលថា សេចក្តីត្រូវការរបស់គ្រួសាររងគ្រោះជាច្រើនមិនបានដឹងដល់ គ.ក.ន.ក។ ទម្រង់នៃការតាមដានដែលកំពុងអនុវត្តសម្រាប់ គ.ក.ន.ក ជាច្រើន ទំនងជាផ្អែកទៅលើការវាយតម្លៃផ្លូវការទៅលើករណីនានា ដែលមេភូមិបានរាយការណ៍ជូន គ.ក.ន.ក។ ឥទ្ធិពលនៃការប្រមូលព័ត៌មាននេះទៅលើ CIP ត្រូវបានលើកយកមកពិភាក្សានៅខាងក្រោមនេះ (ត្រង់ចំណុចស្តីពីការរៀបចំផែនការការងារ និងថវិកា)។

### ៤.២.៣ ការបញ្ជូនទៅរក និងការផ្តល់សេវាការពារកុមារពីសំណាក់ គ.ក.ន.ក

គ.ក.ន.ក មានភារកិច្ចធ្វើផែនការ តស៊ូមតិ លើកកម្ពស់ការយល់ដឹង និងតាមដានបញ្ហាស្ត្រី និងកុមារ។ គណៈកម្មាធិការនេះ ក៏ទទួលខុសត្រូវផងដែរ ក្នុងការពង្រឹងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំសង្កាត់ អ្នកផ្តល់សេវា និងអ្នកភូមិ ព្រមទាំងជួយក្រុមប្រឹក្សាឃុំសង្កាត់លើកិច្ចការនានាដែលទាក់ទងនឹងស្ត្រី និងកុមារ (RGC ឆ្នាំ២០០៨)។ ប៉ុន្តែ ដូចដែលបានកត់សម្គាល់ខាងដើមរួចមកហើយ **គ.ក.ន.ក មិនមានភារកិច្ចផ្តល់សេវាទេ។ ប៉ុន្តែ ការសិក្សានេះបានរកឃើញថា សមាជិក គ.ក.ន.ក ជាច្រើនជឿជាក់ថាការផ្តល់សេវាសង្គមកិច្ច ក៏ជាភារកិច្ចរបស់ពួកគេដែរ ហើយពួកគេចាត់វិធានការនានាដើម្បីសម្រេចភារកិច្ចនេះ។**

អ្នកចូលរួមបានកំណត់មូលហេតុចម្បង ៣យ៉ាង ដែលនាំឲ្យ គ.ក.ន.ក ចាប់ផ្តើមផ្តល់សេវាសង្គមកិច្ច។ ទី១ កង្វះស្ថាប័នជាតិដែលផ្តល់សេវាការពារកុមារ មានន័យថា សេចក្តីត្រូវការរបស់កុមារមិនត្រូវបានឆ្លើយតបឡើយ។ តាមរយៈការងាររបស់ខ្លួនក្នុងការតាមដាន ការតស៊ូមតិ និងការលើកកម្ពស់ការយល់ដឹង គ.ក.ន.ក បានរកឃើញបញ្ហាជាច្រើន ដែលសមាជិកសហគមន៍ជួបប្រទះ ហើយនៅពេលរកឃើញបញ្ហាយ៉ាងដូច្នេះ សមាជិក គ.ក.ន.ក ចង់ជួយដោះស្រាយបញ្ហាទាំងនេះ។ ទី២ សមាជិកសហគមន៍ដែលស្គាល់ គ.ក.ន.ក មិនដឹងអំពីការរឹតត្បិតនៃតួនាទីរបស់គណៈកម្មាធិការនេះទេ ហើយជឿជាក់ថា គ.ក.ន.ក ក៏មានភារកិច្ចផ្តល់សេវាផងដែរ។ សមាជិកសហគមន៍ស្នើសុំការផ្តល់សេវាពី គ.ក.ន.ក។ **សមាជិកគ្រួសារជាច្រើននៅក្នុងការសិក្សានេះ មិនបានយល់ដឹងច្បាស់លាស់អំពីតួនាទីរបស់ គ.ក.ន.ក ហើយជឿជាក់ថា គណៈកម្មាធិការនេះ ទទួលខុសត្រូវក្នុងការថែទាំស្ត្រី និងកុមារទូទៅ។** ទី៣ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុករបស់ខ្លួន ផ្តល់ការគាំទ្រដល់ គ.ក.ន.ក សម្រាប់ផ្តល់សេវាការពារកុមារ។

ការផ្តល់សេវាគឺជារឿងធម្មតានៅក្នុងចំណោម គ.ក.ន.ក ដែលចូលរួមនៅក្នុងការសិក្សានេះ។ នៅក្នុងការពិភាក្សាក្រុមគោលដៅ ២៨/៣០ នៃ គ.ក.ន.ក បានរាយការណ៍ថា បានផ្តល់សេវា និង ២៧/៣០ អាចផ្តល់ឧទាហរណ៍អំពីករណីដែលកុមារម្នាក់ត្រូវបានគេជួយ ដូចដែលបង្ហាញនៅខាងក្រោមនេះ។




**ក្រាហ្វ ៣៖ ចំនួន គ.ក.ន.ក ដែលបានជួយកុមារ តាមអ្វីដែល គ.ក.ន.ក បានរាយការណ៍**

**អ្នកចូលរួម គ.ក.ន.ក បានរាយការណ៍ថា បានទទួលថវិកាតិចតួចពីក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់សេវាសង្គមកិច្ច។**

សេវាដែល គ.ក.ន.ក ដែលបានផ្តល់ទទួលមូលនិធិ ឬប្រើប្រាស់ដោយប្រភពផ្សេងៗជាច្រើន។ អ្នកចូលរួម គ.ក.ន.ក បានរាយការណ៍ថា បានទទួលថវិកាតិចតួចពីក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់សេវាសង្គមកិច្ច។ យោងតាមការសិក្សាមួយទៅលើ CIP មានតែ ៣-៤ភាគរយនៃ CIP ប៉ុណ្ណោះ ដែលត្រូវបានធ្វើការបែងចែកសម្រាប់សេវាសង្គមកិច្ច (Ramage ឆ្នាំ២០១៥)។ ខណៈដែលថវិកាសម្រាប់ឃុំសង្កាត់ផ្សេងៗគ្នាមានចំនួនខុសៗគ្នាទៅតាមការពិចារណាលើកត្តាភូមិសាស្ត្រ នៅពេលស្នើឲ្យធ្វើការប៉ាន់ស្មានចំនួនថវិកាដែលត្រូវបានបែងចែកសម្រាប់សេវាកុមារ គ.ក.ន.ក ជាច្រើនបានប៉ាន់ស្មានថាមានចំនួនប្រហែលជារាប់ពាន់ដុល្លារ។ គ.ក.ន.ក ដែលចូលរួម ក៏បានរាយការណ៍ផងដែរ អំពីការទទួលបានមូលនិធិសម្រាប់ផ្តល់សេវាតាមរយៈការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល។ ចុងក្រោយ គ.ក.ន.ក ក៏បានរាយការណ៍អំពីការបញ្ជូនសមាជិកសហគមន៍ទៅរកសេវានានា ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

**ពុំមានឧទាហរណ៍ដែលបង្ហាញពីកិច្ចអន្តរាគមន៍សេវាសង្គមកិច្ច ដែលមានលក្ខណៈស្មុគស្មាញដូចជា ការគាំទ្រផ្នែកព្យាបាល ឬផ្នែកចិត្តសង្គមដល់ជនរងគ្រោះនៃអំពើ ហិង្សា ឬការរំលោភបំពានផ្លូវភេទ ដែលផ្តល់ដោយ គ.ក.ន.ក តាមរយៈមូលនិធិឃុំសង្កាត់ទេ**

សមាជិក គ.ក.ន.ក បានពណ៌នាអំពីការផ្តល់សេវាមួយចំនួនតូច តាមរយៈមូលនិធិឃុំសង្កាត់។ ឧទាហរណ៍ដែលរាយនៅក្នុងទិន្នន័យ ស្ទើរតែទាំងអស់គឺសម្រាប់ការទូទាត់ថ្លៃធ្វើដំណើរទៅមន្ទីរពេទ្យ ឬថ្លៃចំណាយលើការទិញសម្ភារៈសិក្សា។ ពុំមានឧទាហរណ៍ដែលបង្ហាញពីកិច្ចអន្តរាគមន៍សេវាសង្គមកិច្ច ដែលមានលក្ខណៈស្មុគស្មាញដូចជា ការគាំទ្រផ្នែកព្យាបាល ឬផ្នែកចិត្តសង្គមដល់ជនរងគ្រោះ នៃអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទ ដែលផ្តល់ដោយ គ.ក.ន.ក តាមរយៈមូលនិធិឃុំសង្កាត់ទេ។ ប្រការនេះមិនមែនជាអ្វីដែលគួរឲ្យភ្ញាក់ផ្អើលឡើយ ដោយសារតែ គ.ក.ន.ក ជាច្រើនបានពណ៌នាថាខ្លួនខ្វះជំនាញបច្ចេកទេស ហើយកិច្ចអន្តរាគមន៍ប្រភេទទាំងនេះ គឺមានលក្ខណៈស្មុគស្មាញ។

គ.ក.ន.ក បានរាយការណ៍អំពីកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ដើម្បីជួយឲ្យសហគមន៍នានាអាចទទួលបានការគាំទ្រ។ ក្នុងករណីទាំងនេះ គ.ក.ន.ក ផ្តល់សេវាដោយប្រើមូលនិធិអង្គការមិនមែនរដ្ឋាភិបាល ដែលមិនសូវទូទៅទេ ឬបញ្ជូនគ្រួសារប្រជាពលរដ្ឋទៅរកសេវានានា ដែលផ្តល់ឲ្យដោយអង្គការមិនមែនរដ្ឋាភិបាល ដែលលំនាំនេះកើតមានជាទូទៅជាង។ ជារឿយៗ អ្នកចូលរួមមិនបានញែកដាច់ពីគ្នារវាងភាពខុសគ្នានៃការផ្តល់សេវាទាំងពីរប្រភេទនេះឡើយ ហើយតែងនិយាយថា គ.ក.ន.ក ជាអ្នកផ្តល់សេវា នៅពេលតាមពិតទៅពួកគេគ្រាន់តែជួយណែនាំប្រជាពលរដ្ឋឲ្យទៅរកសេវារបស់អង្គការមិនមែនរដ្ឋាភិបាលប៉ុណ្ណោះ។

សមាជិក គ.ក.ន.ក បានរាយការណ៍អំពីការផ្សារភ្ជាប់ជាមួយនឹងកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាល មិនមែនចំនួនត្រឹមតែ ១៤អង្គការដែលចូលរួមនៅក្នុងការសិក្សានេះទេ ប៉ុន្តែគឺមានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនផ្សេងទៀត ក្នុងនោះរាប់បញ្ចូលទាំងអង្គការដែលផ្តល់សេវាសុខភាព និងការគាំទ្រផ្នែកច្បាប់ផងដែរ។ កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការគាំទ្រ បានលេចឡើងជាប្រធានបទមួយនៅក្នុងការពិភាក្សាក្រុមគោលដៅ។ អង្គការមិនមែនរដ្ឋាភិបាល ដែលគេបានលើកឡើង រួមមានទាំងអង្គការនានាដែលមានសេវាគ្របដណ្តប់ទូទាំងប្រទេស និងទាំងអង្គការតូចៗ ដែលធ្វើការត្រឹមតែនៅក្នុងតំបន់មូលដ្ឋាន ប៉ុណ្ណោះ។

**សមាជិក គ.ក.ន.ក លើកឡើងជាទូទៅបំផុតអំពីការផ្តល់សេវា ឬការបញ្ជូនទៅរកសេវាលើវិស័យដូចខាងក្រោម៖**

- ការទប់ស្កាត់ការបោះបង់ការសិក្សា និងពលកម្មកុមារ
- ការគាំទ្រគ្រួសារដែលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ
- ការគាំទ្រដល់កុមារដែលប៉ះពាល់ដោយការរំលោភបំពានផ្លូវភេទ
- ការទប់ស្កាត់ចំណាកស្រុក និងការគាំទ្រដល់កុមារដែលទុកចោល ដោយឪពុកម្តាយធ្វើចំណាកស្រុក។

**ច្បាស់ណាស់ គឺ គ.ក.ន.ក បាននឹងកំពុងផ្តល់សេវា ឬបញ្ជូនប្រជាពលរដ្ឋទៅរកសេវាជាច្រើនសម្បូរបែប។**

ច្បាស់ណាស់ គឺ គ.ក.ន.ក បាននឹងកំពុងផ្តល់សេវា ឬបញ្ជូនប្រជាពលរដ្ឋទៅរកសេវាជាច្រើនសម្បូរបែប។ រដ្ឋាភិបាលដើរតួនាទីសំខាន់មួយក្នុងការផ្តល់ការការពារដល់កុមារ។ ដូចដែលបានកត់សម្គាល់ពីខាងដើម MoSVY គឺជាក្រសួងដែលមានភារកិច្ចការពារកុមារ ប៉ុន្តែ ក្រសួងនេះនៅខ្វះខាតទាំងមូលនិធិសម្រាប់សេវា និងខ្វះខាតទាំងយន្តការសម្រាប់ផ្តល់សេវាការពារកុមារនៅតាមសហគមន៍។ **គ.ក.ន.ក បានបំពេញតួនាទីនេះដោយគ្មានការបណ្តុះបណ្តាលបទពិសោធន៍ និងការគាំទ្រគ្រប់គ្រាន់ពីរាជរដ្ឋាភិបាល**។ ដូចដែលយើងនឹងពិភាក្សានៅខាងក្រោម គ.ក.ន.ក ភាគច្រើន គឺមិនបានផ្តល់សេវាការពារកុមារគ្រប់គ្រាន់ដល់ក្រុមគ្រួសារប្រជាពលរដ្ឋនៅតាមសហគមន៍ទេ។

## ការឆ្លើយតបរបស់ គ.ក.ន.ក ចំពោះបញ្ហាបោះបង់ការសិក្សា និងពលកម្មកុមារ

ការស្ទង់មតិអំពីកម្លាំងពលកម្ម និងពលកម្មកុមារនៅកម្ពុជា ឆ្នាំ២០១២ រកឃើញថា ១៩,១ភាគរយ នៃកុមារអាយុពី ៥ឆ្នាំ ដល់ ១៧ឆ្នាំ មានសកម្មភាពនៅក្នុងវិស័យសេដ្ឋកិច្ច ហើយភាគច្រើនបំផុតនៃកុមារទាំងនេះ (៨៧,៣ភាគរយ) រស់នៅក្នុងតំបន់ជនបទ។ ៥៦,៩ភាគរយ នៃកុមារដែលសកម្មនៅក្នុងវិស័យសេដ្ឋកិច្ចត្រូវបានចាត់ថ្នាក់ថាជាពលករកុមារ និង ៣១,៣ភាគរយត្រូវបានចាត់ថ្នាក់ថា ធ្វើការងារដែលគ្រោះថ្នាក់។ កុមារភាគច្រើនលើសលប់ ធ្វើការនៅក្នុងវិស័យកសិកម្ម ព្រៃឈើ ឬនេសាទ ឬបម្រើការងារតាមផ្ទះ។ ជាងពាក់កណ្ដាលនៃពលករកុមារ បានបោះបង់ការសិក្សា ឬមិនធ្លាប់បានសិក្សាទាល់តែសោះ។

**ទម្រង់ទូទៅបំផុតនៃការគាំទ្រដែលផ្ដល់ដោយ គ.ក.ន.ក គឺការគាំទ្រផ្នែកសិក្សា។**

ទម្រង់ទូទៅបំផុតនៃការគាំទ្រដែលផ្ដល់ដោយ គ.ក.ន.ក គឺការគាំទ្រផ្នែកសិក្សា។ យោងតាមគោលនយោបាយ ការអប់រំថ្នាក់បឋមសិក្សានៅកម្ពុជា គឺឥតគិតថ្លៃទេ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្ដែង សិស្សត្រូវគេតម្រូវឲ្យបង់ថ្លៃសាលាក្រៅផ្លូវការច្រើនមុខច្រើនបែបទៅឲ្យគ្រូ។ កត្តាទាំងនេះដើរតួនាទីដ៏ធំហួតដល់ប្រព័ន្ធអប់រំកម្ពុជាត្រូវបានគេឲ្យឈ្មោះថា ប្រព័ន្ធកូនកាត់រដ្ឋ-ឯកជន (Bremh ឆ្នាំ២០១២)។ វាជាការលំបាកសម្រាប់កុមារឆ្លងកាត់ប្រព័ន្ធអប់រំកម្ពុជា ដោយមិនបង់ប្រាក់សោះនោះ។ ការបង់ថ្លៃទាំងនេះបង្កជាឧបសគ្គចំពោះការអប់រំសម្រាប់គ្រួសារក្រីក្រ ហើយនៅពេលដែលកុមារឈប់រៀនទៅធ្វើការងារពួកគេអាចរួមចំណែករកប្រាក់ចំណូលជួយទ្រទ្រង់គ្រួសារបាន។ ដូច្នេះហើយ កុមារប្រឈមនឹងការលើកទឹកចិត្តខ្លាំងឲ្យបោះបង់ការសិក្សា។ អ្នកចូលរួមបានពន្យល់ថា វាជាក្លាយជារឿងទូទៅទៅហើយ ដែលកុមារបោះបង់ការសិក្សាដោយសារបញ្ហាថ្លៃសាលា ឬដើម្បីរកចំណូលជួយទ្រទ្រង់គ្រួសារ ឬនៅក្នុងករណីជាច្រើនគឺដោយសារមូលហេតុទាំងពីរយ៉ាងនេះរួមគ្នាតែម្ដង។

> **សមាជិក គ.ក.ន.ក**
>
> ក្មេងស្រីម្នាក់រស់នៅក្នុងភាពក្រីក្រជាមួយបងស្រីរបស់នាង។ នាងរកប្រាក់បានបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែ ថ្លៃរៀនគួរ និងថ្លៃប្រលងត្រូវចំណាយអស់លុយច្រើនពេក នាងក៏ឈប់រៀន និងទៅធ្វើការនៅប្រទេសថៃដើម្បីរកប្រាក់ដោះបំណុលគ្រួសារ។

អ្នកចូលរួមជា គ.ក.ន.ក ម្នាក់បានពន្យល់ថា ការបោះបង់ការសិក្សា គឺស្ទើរតែជាជំហានដែលមិនអាចត្រលប់ក្រោយវិញបាន ពីព្រោះអ្នកដែលបោះបង់ការសិក្សាកម្រនឹងត្រលប់មកចូលសាលាវិញណាស់។ ជម្រើសសម្រាប់អនាគតរបស់កុមារដែលបោះបង់ការសិក្សា ត្រូវបានពណ៌នាថា មានតិចតួចណាស់។

ឧទាហរណ៍ជាច្រើនត្រូវបានផ្ដល់ឲ្យនៅក្នុងទិន្នន័យ ដែលបង្ហាញអំពីករណីនានា នៃកុមារបោះបង់ការសិក្សាដើម្បីទៅធ្វើការ។ អ្នកចូលរួមជាច្រើន ទាំងសមាជិក គ.ក.ន.ក ទាំងឪពុកម្ដាយ និងកុមារ បង្ហាញថា ការបោះបង់ការសិក្សា និងពលកម្មកុមារ គឺមានទំនាក់ទំនងជាមួយគ្នា៖ តម្រូវការលុយកាក់ពីការធ្វើពលកម្មនាំទៅរកការបោះបង់ការសិក្សា ហើយការបោះបង់ការសិក្សាគឺនាំទៅរកស្ថានភាពពលកម្មកុមារស្ទើរតែជៀសមិនផុត។

> ក្មេងស្រី និងគ្រួសាររបស់នាងរស់នៅក្នុងជីវភាពក្រីក្រ ហើយនាងគ្មានលុយទៅរៀនទេ។ ដូច្នេះយើងបាន ផ្ដល់លុយឲ្យនាងទៅរៀន ពីព្រោះថា បើយើងមិនផ្ដល់លុយឲ្យទេ នាងនឹងឈប់រៀន ហើយទៅធ្វើការ។ នាងនៅក្មេងណាស់ មិនទាន់គ្រប់អាយុធ្វើការនៅឡើយទេ។
>
> **សមាជិក គ.ក.ន.ក**

នៅក្នុង គ.ក.ន.ក ដែលគាំទ្រដោយអង្គការដែលអនុវត្តកម្មវិធីពលកម្មកុមារ ការគាំទ្រផ្នែកការសិក្សា ត្រូវបានផ្តល់ឲ្យជាវិធានការជាក់លាក់មួយ ដើម្បីទប់ស្កាត់ពលកម្មកុមារ។ គ.ក.ន.ក មួយចំនួនតូច បានផ្តល់មូលនិធិសម្រាប់បង់ថ្លៃសាលាក្រៅផ្លូវការ ឯកសណ្ឋាន និងកង់ដើម្បីឲ្យកុមារទៅរៀន ប៉ុន្តែអ្វីដែលទូទៅជាងគឺ គ.ក.ន.ក បញ្ជូនសមាជិកសហគមន៍ទៅរកអង្គការមិនមែនរដ្ឋាភិបាលនានា ដែលផ្តល់មូលនិធិទាំងនេះ។ គ.ក.ន.ក ខ្លះបានសហការជាមួយកម្មវិធីអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការគាំទ្រដល់ការបង្រៀន ការបំពាក់បំប៉ន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ទន្ទឹមគ្នានឹងការលើកកម្ពស់ ការយល់ដឹងអំពីសារសំខាន់ នៃការឲ្យកុមារបន្តសិក្សានៅសាលា។ គ.ក.ន.ក ភាគច្រើនបំផុតបានពិពណ៌នាអំពីសារៈសំខាន់នៃការឲ្យកុមារបន្តការសិក្សានៅសាលា។ នៅតាមតំបន់នានា ដែលគ្មានការគាំទ្រខ្លាំងក្លាពីអង្គការមិនមែនរដ្ឋាភិបាល ប្រការនេះត្រូវគេមើលឃើញថាជាការល្អ ហើយនៅតាមតំបន់នានាដែលមាន ការគាំទ្រខ្លាំងក្លាពីអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសតំបន់ដែលគាំទ្រឲ្យដោះស្រាយបញ្ហាពលកម្មកុមារ ការគាំទ្រផ្នែកការសិក្សាត្រូវបានពណ៌នាថាជាកត្តាសំខាន់នៅក្នុងការការពារកុមារ។

**អាចនឹងទៅរួចដែលថា សមាជិក គ.ក.ន.ក ចូលចិត្តផ្តល់ការគាំទ្រផ្នែកសិក្សា ពីព្រោះតែវាជាទម្រង់នៃការគាំទ្រដែលងាយស្រួលបំផុតក្នុងការផ្តល់ឲ្យ។**

ទន្ទឹមនឹងនេះដែរ អាចនឹងទៅរួចដែលថា សមាជិក គ.ក.ន.ក ចូលចិត្តផ្តល់ការគាំទ្រផ្នែកសិក្សា ពីព្រោះតែវាជាទម្រង់នៃការគាំទ្រដែលងាយស្រួលបំផុតក្នុងការផ្តល់ឲ្យ។ ការផ្តល់មូលនិធិ ឬសម្ភារៈ គឺជាកិច្ចការសាមញ្ញ បើប្រៀបធៀបនឹងអន្តរាគមន៍ការពារកុមារដទៃទៀត។ ជាងនេះទៅទៀត តាមបទពិសោធន៍របស់អ្នកស្រាវជ្រាវក្រុមគ្រួសារ គឺភាគច្រើនជាអ្នកស្នើសុំជំនួយប្រភេទនេះ ហើយសមាជិកសហគមន៍ភាគច្រើនបំផុត យល់ដឹងអំពីផលប្រយោជន៍នៃជំនួយនេះ។ អ្វីដែលពិបាកខ្លាំងជាង គឺការស្វែងរកដំណោះស្រាយចំពោះបញ្ហាស្មុគស្មាញនានាដូចជា អំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពានផ្លូវភេទ តាមអ្វីដែលកត់សម្គាល់ដោយ Gamer និង Mauney (ឆ្នាំ២០០៩) និងដូចដែលយើងនឹងពិភាក្សានៅខាងក្រោម។

## ការឆ្លើយតបរបស់ គ.ក.ន.ក ចំពោះអំពើហិង្សាក្នុងគ្រួសារ

**ប្រេវ៉ាឡង់អំពើហិង្សាក្នុងគ្រួសារ គឺជាប្រធានបទទូទៅមួយនៅក្នុងការសិក្សានេះ ហើយភាគច្រើននៃសមាជិក គ.ក.ន.ក បាននិយាយថាវាជាបញ្ហាដែលធ្វើឲ្យពួកគេចំណាយពេលវេលា ច្រើនបំផុត។**

អំពើហិង្សាក្នុងគ្រួសារ កើតមានច្រើននៅក្នុងប្រទេសកម្ពុជា ដោយ ២០ភាគរយនៃស្ត្រីបានជួបប្រទះអំពើហិង្សាលើរាងកាយតាំងពីអាយុ ១៥ឆ្នាំ និង ៨ភាគរយ ធ្លាប់ជួបប្រទះក្នុងរយៈពេល ១២ខែចុងក្រោយ (CDHS ឆ្នាំ២០១៤)។ ប្រេវ៉ាឡង់អំពើហិង្សាក្នុងគ្រួសារ គឺជាប្រធានបទទូទៅមួយនៅក្នុងការសិក្សានេះ ហើយភាគច្រើននៃសមាជិក គ.ក.ន.ក បាននិយាយថា វាជាបញ្ហាដែលធ្វើឲ្យពួកគេចំណាយពេលវេលាច្រើនបំផុត។ កុមារអាចនឹងជាជនរងគ្រោះនៃអំពើហិង្សាដែលបង្កដោយឪពុកម្តាយរបស់ពួកគេ ឬជាជនរងគ្រោះដោយប្រយោល ដែលបានឃើញផ្ទាល់ភ្នែកនូវការប្រើប្រាស់អំពើហិង្សាដោយឪពុកទៅលើម្តាយ ឬដៃគូដទៃទៀត។ ទាំងការធ្លាប់ទទួលរងអំពើហិង្សាដោយផ្ទាល់ ទាំងការធ្លាប់ឃើញអំពើហិង្សាដោយផ្ទាល់ភ្នែក អាចមានផលប៉ះពាល់អវិជ្ជមានផ្លូវកាយ និងផ្លូវចិត្តរយៈពេលវែង ទៅលើកុមារ (Kitzman et al. ឆ្នាំ២០០៣, Unicef ឆ្នាំ២០០៤)។ អំពើហិង្សាក្នុងគ្រួសារ គឺតជំនាន់ (CDHS ឆ្នាំ២០១៤) ហើយដំណោះស្រាយចំពោះអំពើហិង្សាក្នុងគ្រួសារ ជារឿយៗ មានភាពស្មុគស្មាញ និងពិបាកក្នុងការអនុវត្ត។

សមាជិក គ.ក.ន.ក សមាជិកគ្រួសារ និងកុមារភាគច្រើនបំផុត ដែលបានចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅ មិនគាំទ្រអំពើហិង្សាក្នុងគ្រួសារទេ ហើយជឿជាក់ថាគេគួរតែរាយការណ៍ករណីបែបនេះទៅអាជ្ញាធរមូលដ្ឋាន។ អំពើហឹង្សាក្នុងគ្រួសារត្រូវបានពណ៌នាថា មានផលប៉ះពាល់អវិជ្ជមាន ទៅលើទាំងជនរងគ្រោះ និងទាំងសហគមន៍ទាំងមូល។ នៅពេលសុំឲ្យពិចារណាស្ថានភាពសម្មតិកម្មមួយ ដែលកុមារជាជនរងគ្រោះនៃអំពើហឹង្សាបង្កដោយម្តាយ ២៧/៣០ នៃសមាជិក គ.ក.ន.ក និង ២០/២២ នៃកុមារបាននិយាយថា ករណីនេះគួរតែរាយការណ៍ទៅ គ.ក.ន.ក។ ក្នុងចំណោមសមាជិក គ.ក.ន.ក និងគ្រួសារភាគច្រើនបំផុត ដែលចូលរួមក្នុងការពិភាក្សាក្រុមគោលដៅ ទំនងជាមានការផ្លាស់ប្តូរអាកប្បកិរិយា ចំពោះអំពើហិង្សាក្នុងគ្រួសារ។ នៅក្នុងការសិក្សាមួយកាលពីឆ្នាំ២០០៨ ៥៤ភាគរយនៃបុរស និង ៩៧ភាគរយនៃស្ត្រីប៉ុណ្ណោះដែលជឿជាក់ថា បុរសវាយប្រពន្ធគឺមិនអាចទទួលយកបានទេ ហើយជាង ៥០ភាគរយនៃអ្នកឆ្លើយតបទាំងអស់ និយាយថា អំពើហិង្សាគឺសមហេតុផល ប្រសិនបើប្រពន្ធជាអ្នកពន្យុះប្តី (Morrison ឆ្នាំ២០០៩)។ ការរកឃើញនេះ ផ្ទុយគ្នាស្រលះពីការស្រាវជ្រាវនេះ ដែលអ្នកចូលរួមភាគច្រើនបង្ហាញការមិនគាំទ្រចំពោះអំពើហិង្សាក្នុងគ្រួសារឡើយ។

នៅពេលពិភាក្សាអំពីអំពើហិង្សាក្នុងគ្រួសារ ជារឿយៗ អ្នកចូលរួមមិនបានញែកឲ្យដាច់ពីគ្នា រវាងអំពើហិង្សា លើមនុស្សធំ និងអំពើហិង្សាលើកុមារនោះទេ។ ប៉ុន្តែ **ឧទាហរណ៍នៃកិច្ចអន្តរាគមន៍ ស្ទើរតែ**

**ទាំងអស់ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ គឺផ្តោតទៅលើម្តាយ**

ទាំងអស់ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ គឺផ្តោតទៅលើម្តាយ។ វាអាចមានករណីខ្លះដែលកុមារត្រូវបានបំពានរាងកាយ ហើយក្នុងនោះម្តាយក៏ជាជនរងគ្រោះដែរ។ ប៉ុន្តែដោយសារកុមារអាចជាជនរងគ្រោះនៃអំពើហិង្សាដែលបង្កដោយទាំងឪពុក ឬទាំងម្តាយ ភាពចាំបាច់នៅតែមានសម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើកុមារ ជាបញ្ហាចំពោះកិច្ចអន្តរាគមន៍ ដែលមិនពាក់ព័ន្ធនឹងស្ថានភាពរបស់ម្តាយ។

**សមាជិក គ.ក.ន.ក បានរាយការណ៍ញឹកញាប់ថាពួកគេបានឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ ដោយណែនាំឲ្យជនប្រព្រឹត្តបញ្ឈប់អំពើបែបនេះ**

សមាជិក គ.ក.ន.ក បានរាយការណ៍ញឹកញាប់ថា ពួកគេបានឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ ដោយណែនាំឲ្យជនប្រព្រឹត្តបញ្ឈប់អំពើបែបនេះ។ ពាក្យណែនាំជាភាសាខ្មែរ មានអត្ថន័យថា ដាស់តឿន ឬប្រដៅ។ នៅពេលដែល គ.ក.ន.ក ពណ៌នាថា បានណែនាំដល់ជនប្រព្រឹត្ត ពួកគេសំដៅទៅលើអន្តរាគមន៍ដោយពាក្យសម្តីខ្លាំងៗ។ ប៉ុន្តែ នៅពេលដែល គ.ក.ន.ក ត្រូវបានសួរដេញដោលបន្ថែមទៀតជុំវិញចម្លើយនេះ គេបានឃើញច្បាស់ថា សមាជិក គ.ក.ន.ក ជាច្រើន មិនជឿថា ការឆ្លើយតបនេះជាការគ្រប់គ្រាន់នោះទេ ប៉ុន្តែ ពួកគេប្រើប្រាស់វិធីនេះ នៅពេលដែលគេជឿថា វាគ្មានជម្រើសអ្វីឡើយផ្សេងពីនេះ។ មានភ័ស្តុតាងតិចតួចប៉ុណ្ណោះ ដែលបង្ហាញថា ការណែនាំឲ្យជនប្រើអំពីហិង្សាឈប់ប្រើទង្វើរបស់ខ្លួន ជះឥទ្ធិពលទៅលើកម្រិតនៃអំពើហិង្សាក្នុងគ្រួសារ។

**ការឆ្លើយតបទូទៅទីពីរចំពោះអំពើហិង្សាក្នុងគ្រួសារ គឺការព្យាយាមសម្របសម្រួល ឲ្យមានការផ្សះផ្សាគ្នា រវាងគូភាគី។**

ការឆ្លើយតបទូទៅទីពីរចំពោះអំពើហិង្សាក្នុងគ្រួសារ គឺការព្យាយាមសម្របសម្រួល ឲ្យមានការផ្សះផ្សាគ្នារវាងគូភាគី។ ក្នុងករណីទាំងនេះ សមាជិក គ.ក.ន.ក រួមជាមួយនឹងមេភូមិ នឹងចុះទៅជួបសមាជិកគ្រួសារ ហើយព្យាយាមសម្របសម្រួលជម្លោះក្នុងន័យផ្សះផ្សាគ្នា។ នៅក្នុងករណីជាច្រើន ការឆ្លើយតបនេះក៏ពាក់ព័ន្ធនឹង "ការណែនាំ" ជនប្រព្រឹត្តអំពីហិង្សាឲ្យឈប់ប្រើអំពើហិង្សា និងការពិភាក្សារិះរកវិធីដែលជនរងគ្រោះអាចផ្លាស់ប្តូរឥរិយាបថដើម្បីជៀសវាងការបញ្ឆេះឲ្យមានអំពើហិង្សា។ ការមិនរៀបចំបាយទឹក ការនិយាយជាមួយអ្នកក្រៅ ឬរអ៊ូរទាំដល់ប្តី ត្រូវបានរៀបរាប់ថាជាទម្រង់នៃការពន្យុះឲ្យមានអំពើហិង្សា។ វាជាការគួរឲ្យបារម្ភដែលសមាជិក គ.ក.ន.ក ជាច្រើន បានព្យាយាមដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ដោយភ្ជាប់ការស្តីបន្ទោសទៅលើជនរងគ្រោះ និងដោយព្យាយាមផ្សះផ្សាប្តីប្រពន្ធដែលឲ្យសះជានឹងគ្នាវិញ។ អ្វីដែលគួរឲ្យសោកស្តាយ គឺការផ្តោតសំខាន់ទៅលើការផ្សះផ្សា ជាជាងការនាំជនប្រព្រឹត្តទៅផ្តន្ទាទោស គឺមិនធ្វើឲ្យជនប្រើអំពើហិង្សារាងចាលឡើយ ហើយដាក់ស្ត្រី និងកុមារឲ្យស្ថិតក្នុងហានិភ័យនៃអំពើហិង្សាបន្តទៀត។

**ការឆ្លើយតបទូទៅទីបី គឺព្យាយាមរកកន្លែងសុវត្ថិភាពបណ្តោះអាសន្នឲ្យកុមារស្នាក់នៅ នៅពេលដែល ឪពុក ឬម្តាយកំពុងមានរឿងអំពើហិង្សា។**

ការឆ្លើយតបទូទៅទីបី គឺព្យាយាមរកកន្លែងសុវត្ថិភាពបណ្តោះអាសន្នឲ្យកុមារស្នាក់នៅ នៅពេលដែល ឪពុក ឬម្តាយកំពុងមានរឿងអំពើហិង្សា។ ស្ត្រីម្នាក់បានពន្យល់ថា គាត់នាំកូនទៅដេកក្នុងព្រៃ។ ច្បាស់ណាស់ នេះមិនមែនជាដំណោះស្រាយដែលមានសុវត្ថិភាពស្ថិតស្ថេរសម្រាប់កុមារឡើយ។ ប៉ុន្តែ សមាជិក គ.ក.ន.ក និងសមាជិកក្រុមគ្រួសារជាច្រើន បានពណ៌នាពីការគាំទ្រឲ្យកុមារដេកនៅផ្ទះអ្នកជិតខាង ក្នុងពេលដែលឪពុកម្តាយកើតមានរឿងអំពើហិង្សា។ ទាំងនេះត្រូវបានចាត់ទុកថា ជាការផ្តល់សុវត្ថិភាពបណ្តោះអាសន្នដល់កុមារ។ ការឲ្យកុមារស្នាក់បណ្តោះអាសន្ននៅផ្ទះអ្នកជិតខាង គឺជា CBCPP បែបប្រពៃណី។ គេត្រូវការការស្រាវជ្រាវច្រើនបន្ថែមទៀត ដើម្បីធ្វើការវាយតម្លៃថាតើទម្លាប់នេះគ្រប់គ្រាន់ ឬអត់ ក្នុងការធានាសុវត្ថិភាពរបស់កុមារ ហើយចាំបាច់គេត្រូវមានគោលការណ៍ណែនាំដើម្បីធានាថាកុមារមិនត្រូវបានដាក់ឲ្យប្រឈមនឹងហានិភ័យបន្ថែមទៀត នៅពេលស្នាក់នៅឯផ្ទះរបស់អ្នកជិតខាង។ លើសពីនេះ គេមិនត្រូវប្រើជម្រកសហគមន៍រយៈពេលខ្លី ជាវិធីជំនួសការកសាងសំណុំរឿងប្តឹងជនល្មើសទៅតុលាការឡើយ។

ដូចដែលយើងនឹងពិភាក្សានៅខាងក្រោម នៅក្នុងឃុំសង្កាត់មួយចំនួន គ.ក.ន.ក សហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានរៀបចំចងក្រងក្រុមបិទ (closed group) សម្រាប់គ្រួសារ ដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ។ ក្រុមទាំងនេះ រួមមានក្រុមដាច់ដោយឡែកសម្រាប់កុមារ ប្តីប្រពន្ធដែលជាជនរងគ្រោះ និងជាជនដៃដល់។ បន្ទាប់ពីការផ្សះផ្សា ពីសំណាក់ គ.ក.ន.ក ជនដៃដល់នឹងត្រូវតម្រូវឲ្យចូលរួមក្នុងក្រុមបិទជារៀងរាល់ខែ ដោយក្រុមទាំងនេះនឹងដើរតួនាទីជាវិធានការទប់ស្កាត់។ ក្រុមសម្រាប់កុមារ និងប្តីប្រពន្ធ ទំនងជាបំពេញតួនាទីព្យាបាលសម្រាប់ជនរងគ្រោះ។ ប៉ុន្តែ ការសិក្សាយល់ស្របតាមការរកឃើញរបស់ Mauney (ឆ្នាំ២០១៣) ដែលកត់សម្គាល់ថា ជាលទ្ធផលនៃការចូលរួមជាប់លាប់របស់ជនដៃដល់ ក្រុមបិទបាននាំមកនូវអាកប្បកិរិយាចម្រុះចំពោះការចូលរួម។ Mauney រាយការណ៍ថា

ការចូល រួមនៅក្នុងក្រុមបិទ ដែលរួមមានអ្នកចូលរួមរាប់តាំងពីប្ដីដែលមកដល់ទាំងស្រវឹង រហូតដល់អ្នកដែលប្រឆាំងនឹងការចូលរួមដាច់ខាតតែម្ដង និងអ្នកដែលនិយាយថាក្រុមនេះបានជួយពួកគេឲ្យផ្លាស់ប្ដូរឥរិយាបថរបស់ខ្លួន។ គេមិនអាចវាយតម្លៃបានទេថាតើកម្រិតនៃអំពើហិង្សាក្នុងគ្រួសារមានការថយចុះរដ្ឋាភិបាលនៅក្នុងគណៈកម្មាធិការដឹកនាំ មិនបានវាស់ វែងកម្រិតអំពើហិង្សានៅមុនការចាប់ផ្ដើមគម្រោងដើម្បីជាមូលដ្ឋានសម្រាប់ការវាស់វែងការថយចុះនោះទេ។ មានភ័ស្ដុតាងជាដំណើររឿងខ្លះ នៅក្នុងការសិក្សានេះ ដែលបង្ហាញថា ក្រុមបិទ និងការផ្សះផ្សាមានឥទ្ធិពលទៅលើអំពើហិង្សាក្នុងគ្រួសារ ដោយសមាជិក គ.ក.ន.ក មួយចំនួន និយាយថា អន្ដរាគមន៍ទាំងនេះ បាននាំឲ្យចំនួននៃករណីអំពើហិង្សាក្នុងគ្រួសារថយចុះ។ លើសពីនេះទៀត អ្នកចូលរួមមួយចំនួនតូចនៅក្នុងការពិភាក្សាក្រុមគោលដៅជាមួយឪពុកម្ដាយ បាននិយាយថា អន្ដរាគមន៍ទាំងនេះបានជួយឲ្យពួកគេផ្លាស់ប្ដូរឥរិយាបថ ហើយពួកគេគិតថាវាមានប្រយោជន៍ច្រើន។ ដូចដែល Mauney បានធ្វើការកត់សម្គាល់ថា អំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាមិនអាចផ្លាស់ប្ដូរបាននៅក្នុងសង្គមជាច្រើន ហើយការផ្លាស់ប្ដូរនៃគំរូអំពើហិង្សាក្នុងគ្រួសារ ជាធម្មតាទាមទារនូវកិច្ចអន្ដរាគមន៍រយៈពេលវែង។

> **ប៉ុន្ដែ នៅ ពេលសួរថាតើអ្វីដែលបានកើតឡើងពិតប្រាកដ នៅក្នុងករណីទាំងនេះនៅក្នុងឃុំសង្កាត់របស់ខ្លួន គ.ក.ន.ក ភាគច្រើនបំផុតនិយាយថា ករណីអំពើហិង្សាត្រូវបានដោះស្រាយតាមរយៈការផ្សះផ្សា និងការសម្របសម្រួល។**

នៅពេលសួរអំពីស្ថានភាពសម្មតិកម្មមួយ ដែលពាក់ព័ន្ធនឹងឪពុកម្ដាយហិង្សា គ.ក.ន.ក បានគាំទ្រការរាយការណ៍ករណីបែបនេះទៅអាជ្ញាធរ និងប្ដឹងទៅតុលាការ នៅក្នុងករណីភាគច្រើនបំផុត។ ប៉ុន្ដែ នៅពេលសួរថាតើអ្វីដែលបានកើតឡើងពិតប្រាកដ នៅក្នុងករណីទាំងនេះ នៅក្នុងឃុំសង្កាត់របស់ខ្លួន គ.ក.ន.ក ភាគច្រើនបំផុត និយាយថា ករណីអំពើហិង្សាត្រូវបានដោះស្រាយតាមរយៈការផ្សះផ្សា និងការសម្របសម្រួល។ មូលហេតុជាច្រើនត្រូវបានគេលើកឡើងពាក់ព័ន្ធនឹងគោលជំហរផ្ទុយគ្នាស្រលះទាំងនេះ។ ទីមួយ ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ មានបទប្បញ្ញត្ដិខ្សោយស្ដីពីការផ្ដន្ទាទោសជនល្មើស។ ទីពីរ គ្រួសារពឹងផ្អែកទៅលើទាំងឪពុកទាំងម្ដាយដើម្បីរស់រានផ្នែកសេដ្ឋកិច្ច ដែលនេះជាមូលហេតុមិនលើកទឹកចិត្ដដល់ការផ្ដន្ទាទោសប្ដីដែលប្រព្រឹត្ដអំពើហិង្សា។ ទីបី ប្រព័ន្ធច្បាប់ត្រូវបានគេយល់ឃើញថាមានអំពើពុករលួយ ដូច្នេះហើយគេត្រូវចំណាយប្រាក់អស់ច្រើនណាស់ទើបអាចផ្ដន្ទាទោសជនល្មើសតាមប្រព័ន្ធតុលាការបាន។ ចំណុចនេះ នឹងលើកយកមកពិភាក្សាបន្ថែមទៀត (នៅក្នុងចំណុចស្ដីពីកង្វះការទុកចិត្ដលើប្រព័ន្ធយុត្ដិធម៌)។ ជាទីបញ្ចប់ ដូចដែលបានលើកយកមកពិភាក្សានៅខាងដើម (នៅក្នុងចំណុចស្ដីពីអាកប្បកិរិយាចំពោះបុគ្គល) អាកប្បកិរិយាផ្នែកវប្បធម៌ជំរុញឲ្យមានភាពសុខដុម និងសមូហភាពនិយម ជាជាងយុត្ដិធម៌សម្រាប់បុគ្គល (Gourley ឆ្នាំ២០០៩)។ ដូច្នេះ ខណៈដែលមានការផ្លាស់ប្ដូរអាកប្បកិរិយាទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ការសិក្សានេះមិនរកឃើញភ័ស្ដុតាងដែលបង្ហាញថា ការផ្លាស់ប្ដូរនេះត្រូវបានប្រែក្លាយទៅជាការឆ្លើយតបគ្រប់គ្រាន់ដើម្បីការពារកុមារឡើយ។

## ការឆ្លើយតបរបស់ គ.ក.ន.ក ចំពោះការរំលោភបំពានផ្លូវភេទ

និយមន័យទូលំទូលាយ នៃការរំលោភបំពានផ្លូវភេទ មាននៅក្នុងផ្នែកស្ដីពីវាក្យសព្ទ នៅខាងដើម នៃរបាយការណ៍ស្រាវជ្រាវនេះ។ អង្គការ Unicef (ឆ្នាំ២០១៥) បានរកឃើញថា ជាង ៦ភាគរយនៃនារី និង ៥ភាគរយនៃបុរស ដែលមានអាយុពី ១៣ឆ្នាំ ដល់ ១៧ឆ្នាំ បានរាយការណ៍ថា ធ្លាប់មានបទពិសោធន៍នៃការរំលោភបំពានផ្លូវភេទយ៉ាងហោចណាស់មួយលើក។ ការរំលោភបំពានបានកើតឡើងទាំងនៅផ្ទះ និងទាំងនៅក្នុងសហគមន៍។ នៅក្នុងការសិក្សានេះ ការរំលោភបំពានផ្លូវភេទដែលគេបានលើកឡើង គឺការរំលោភសេពសន្ថវៈ។ នេះប្រហែលមកពីការរំលោភសេពសន្ថវៈ គឺជាទម្រង់មួយ ក្នុងចំណោមទម្រង់តែពីរបីប៉ុណ្ណោះ នៃការរំលោភបំពានផ្លូវភេទ ដែលត្រូវបានគេស្គាល់ និងយល់ដឹងជាទូទៅនៅក្នុងសហគមន៍។ ការរំលោភបំពានផ្លូវភេទលើកុមារា មិនត្រូវបានគេលើកឡើងឡើយ។ ទោះបីជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈទាំងពីរភេទ អាចនឹងមិននិយាយប្រាប់អ្នកណាម្នាក់ បុរសទំនងជាប្រាប់ឲ្យគេដឹងតិចជាងស្ដ្រី (UNICEF ឆ្នាំ២០១៤)។ ជាថ្មីម្ដងទៀត កង្វះការយល់ដឹងអំពីការរំលោភបំពានផ្លូវភេទលើកុមារា បូកផ្សំនឹងកង្វះចំណេះដឹងអំពីករណីទាំងនេះ អាចជាមូលហេតុដែលគ្មានអ្នកណាលើកឡើងអំពីការរំលោភបំពានផ្លូវភេទលើកុមារា។

ការរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជាបទល្មើសធ្ងន់ធ្ងរ។ ការស្រាវជ្រាវមុនៗ បានរកឃើញថា ការរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជារឿងអាម៉ាស់ ហើយអ្នកខ្លះយល់ឃើញថា គេគួរតែលាក់បាំងរឿងនេះដើម្បីការពារជនរងគ្រោះ (Gourley ឆ្នាំ២០០៩)។ ប៉ុន្ដែ អ្នកចូលរួមភាគច្រើនបំផុតនៅក្នុង

**នៅពេលពណ៌នាអំពីអ្វីដែលបានកើតឡើងចំពោះជនរងគ្រោះ ៣/៨ បានលើកឡើងថាក្មេងស្រីត្រូវបានបញ្ជូនទៅមណ្ឌលថែទាំដើម្បីអន្តរាគមន៍ វិបត្តិនេះ**

ការសិក្សានេះ មិនបានចែករំលែកទស្សនៈទាំងនេះទេ។ សមាជិក គ.ក.ន.ក ត្រូវបានស្នើឲ្យពិចារណាលើសេណារីយ៉ូសម្មតិកម្មមួយនៃការរំលោភសេពសន្ថវៈលើក្មេងស្រីអាយុ ១៦ឆ្នាំមួយរូប។ ភាគច្រើននៃ គ.ក.ន.ក បានគាំទ្រការរាយការណ៍អំពីករណីនេះ និងកសាងសំណុំរឿងប្តឹងទៅតុលាការ។ នៅពេលសួរថាតើពួកគេធ្លាប់ជួបស្ថានភាពបែបនេះនៅក្នុងសហគមន៍របស់ពួកគេ ឬអត់សមាជិក គ.ក.ន.ក ៨/៣០ ដែលបានឆ្លើយតប និយាយថា ធ្លាប់មាន។ នៅពេលពិចារណាទៅលើចំនួននេះ ជាការសំខាន់ គឺត្រូវចងចាំថា ៨/៣០ តំណាងឲ្យចំនួន គ.ក.ន.ក ដែលមានសមាជិកយ៉ាងហោចម្នាក់ បាននឹកឃើញករណីមួយ។ ចំនួននេះមិនតំណាងឲ្យប្រេវ៉ាឡង់នៃការរំលោភសេពសន្ថវៈជាទូទៅនោះទេ។ ទោះយ៉ាងណាក៏ដោយ វាគួរឲ្យបារម្ភដែលចំនួននេះខ្ពស់ពេក។ គ.ក.ន.ក ដែលរាយការណ៍ថាមានករណីស្រដៀងគ្នានេះ នៅក្នុងសហគមន៍របស់ពួកគេ ត្រូវស្នើឲ្យរៀបរាប់ថា តើពួកគេឆ្លើយតបយ៉ាងដូចម្តេច។ ភាគច្រើនបំផុតនិយាយថា គ.ក.ន.ក បានជួយរាយការណ៍ករណីនេះទៅសមត្ថកិច្ចនគរបាល និងថា បន្ទាប់មកទៀតករណីនេះ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ នៅពេលពណ៌នាអំពីអ្វីដែលបានកើតឡើងចំពោះជនរងគ្រោះ ៣/៨ បានលើកឡើងថាក្មេងស្រីត្រូវបានបញ្ជូនទៅមណ្ឌលថែទាំ ដើម្បីអន្តរាគមន៍វិបត្តិនេះ។ ការដាក់ជនរងគ្រោះឲ្យស្ថិតនៅក្នុងមណ្ឌលថែទាំគឺមានភាពចម្រូងចម្រាស។ វាផ្តល់លទ្ធភាពឲ្យជនរងគ្រោះទទួលបានសេវា ប៉ុន្តែវាក៏អាចជាទណ្ឌកម្មចំពោះជនរងគ្រោះដោយសារពួកគេត្រូវបានកាត់ផ្តាច់ ពីប្រព័ន្ធគាំទ្ររបស់គ្រួសារ និងសហគមន៍របស់ពួកគេនៅក្នុងអំឡុងពេលមានវិបត្តិ។ ការវាយតម្លៃកាលពីពេលថ្មីៗនេះទៅលើកម្មវិធីមួយរបស់គណៈកម្មាធិការដឹកនាំ ក៏បានរកឃើញថា ជនរងគ្រោះត្រូវបានដាក់នៅក្នុងមណ្ឌល ដោយគ្មានការវាយតម្លៃសុវត្ថិភាពជាមុនជំនួសមុខឲ្យកុមារ និងថា ក្នុងករណីខ្លះ ក្រុមគ្រួសារមិនបានដឹងអំពីទីកន្លែង ដែលកុមារត្រូវបានដាក់ឲ្យស្នាក់នៅឡើយ (Embode ឆ្នាំ២០១៦)។

ខណៈដែលគ្មានកម្មវិធីគាំទ្រ តាមសហគមន៍សម្រាប់ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ត្រូវបានលើកឡើង ដោយអ្នកចូលរួមក្តី ការវាយតម្លៃមួយបានកំណត់អត្តសញ្ញាណអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងផ្តល់សេវាទាំងនេះនៅតាមសហគមន៍ លើវិស័យមួយចំនួន ដូចដែលបានកត់សម្គាល់នៅក្នុងការស្រាវជ្រាវនេះ។ ជាងនេះទៅទៀត ដូចដែលយើងនឹងពិភាក្សានៅខាងក្រោម (នៅត្រង់ចំណុចការផ្តល់បុគ្គលិកសង្គមកិច្ចដែលមានការបណ្តុះបណ្តាល ឲ្យធ្វើការជាមួយ គ.ក.ន.ក) កម្មវិធីសហការគ្នារវាង គ.ក.ន.ក និងអង្គការមិនមែនរដ្ឋាភិបាលមួយ បានផ្តល់ការគាំទ្រដល់បុគ្គលិកសង្គមកិច្ច ដែលសហការជិតស្និទ្ធជាមួយ គ.ក.ន.ក ដើម្បីផ្តល់សេវាព្យាបាលដល់កុមារ។

**ខណៈដែលសមាជិក គ.ក.ន.ក ភាគច្រើនបំផុត គាំទ្រការប្តឹងជនល្មើសទៅតុលាការ គ.ក.ន.ក ម្នាក់បាន ឆ្លើយតបក្នុងលក្ខណៈមួយដែលនាំឲ្យមានការព្រួយបារម្ភ**

ខណៈដែលសមាជិក គ.ក.ន.ក ភាគច្រើនបំផុត គាំទ្រការប្តឹងជនល្មើសទៅតុលាការ គ.ក.ន.ក ម្នាក់បានឆ្លើយតបក្នុងលក្ខណៈមួយដែលនាំឲ្យមានការព្រួយបារម្ភ។ គ.ក.ន.ក នោះបានធ្វើការពណ៌នា អំពីការឆ្លើយតបចំពោះករណីរំលោភសេពសន្ថវៈ ដែលត្រូវបានរាយការណ៍ទៅសមត្ថកិច្ច នគរបាល។ នគរបាលបានធ្វើការជាមួយ គ.ក.ន.ក និងឪពុកម្តាយរបស់ភាគីទាំងពីរ ដើម្បីបង្ខំជនល្មើសឲ្យរៀបការជាមួយជនរងគ្រោះ។ **ជនល្មើសត្រូវបានផ្តល់ជម្រើសមួយ គឺរៀបការជាមួយជនរងគ្រោះ ឬជាប់ពន្ធនាគារ។** គ.ក.ន.ក នោះបានចាត់ទុកករណីនេះថា ត្រូវបានដោះស្រាយដោយជោគជ័យ។ ដំណោះស្រាយប្រភេទនេះ ត្រូវបានលើកឡើងនៅក្នុងការស្រាវជ្រាវមុនៗ (Gourley ឆ្នាំ២០០៩)។ ភាគីពាក់ព័ន្ធម្នាក់ បាន



**ដំណោះស្រាយ បែបនេះ អាចលើកទឹកចិត្តឲ្យមានអំពើរំលោភសេពសន្ថវៈកាន់តែច្រើនឡើង ដោយសារតែជនល្មើសអាច ប្រើប្រាស់វាជាវិធីបង្ខំឲ្យរៀបការក្នុងករណីដែលនារីស្ទាក់ស្ទើរមិនចង់រៀបការជាមួយខ្លួន**

ទោះបីជាដំណោះស្រាយនេះ អាចទទួលយកបាន តាមប្រពៃណីវប្បធម៌នៅតាមសហគមន៍មួយចំនួនក៏ដោយ ប៉ុន្តែដំណោះស្រាយនេះដាក់ជនរងគ្រោះឲ្យប្រឈមនឹងហានិភ័យនៃអំពើហិង្សាបន្តទៀត និងផ្តល់ភាពស្របច្បាប់ ចំពោះអំពើហិង្សាដែលនារីរងគ្រោះបានទទួលរងរួចមកហើយ។ ដំណោះស្រាយបែបនេះ អាចលើកទឹកចិត្តឲ្យមានអំពើរំលោភសេពសន្ថវៈកាន់តែច្រើនឡើង ដោយសារតែជនល្មើសអាចប្រើប្រាស់វាជាវិធីបង្ខំឲ្យរៀបការក្នុងករណីដែលនារីស្ទាក់ស្ទើរមិនចង់រៀបការជាមួយខ្លួន។

## ការឆ្លើយតបរបស់ គ.ក.ន.ក ចំពោះការរំលោភបំពានផ្លូវភេទ

**បញ្ហាចំណាកស្រុក គឺជាប្រធានបទដែលលើកឡើងញឹកញាប់ក្នុងចំណោមអ្នកចូលរួម**

បញ្ហាចំណាកស្រុក គឺជាប្រធានបទដែលលើកឡើងញឹកញាប់ក្នុងចំណោមអ្នកចូលរួម។ ការស្ទង់មតិថ្នាក់ជាតិស្តីពីចំណាកស្រុក នាឆ្នាំ២០១២ បានរកឃើញថា ប្រហែល ៨០ភាគរយនៃជនចំណាកស្រុកមានអាយុក្រោម ៣០ឆ្នាំ (MOP ឆ្នាំ២០១២)។ ការសិក្សានេះ មិនបានកត់ត្រាចំនួនជនចំណាកស្រុកទាំងនេះ ដែលមានអាយុក្រោម ១៨ឆ្នាំទេ ប៉ុន្តែភ័ស្តុតាងជាដំណើររឿងពីអង្គការមិនមែនរដ្ឋាភិបាលបង្ហាញថា កុមារក៏ធ្វើចំណាកស្រុកដែរ ជាពិសេសកុមារអាយុលើស ១៥ឆ្នាំ ដែលជាអាយុស្របច្បាប់សម្រាប់ការធ្វើការងារនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្នុងប្រទេស ទាំងទៅក្រៅប្រទេស ដើម្បីធ្វើការងារនៅក្នុងវិស័យកសិកម្ម បម្រើតាមផ្ទះ និងសំណង់។ ការសិក្សាដាច់ដោយឡែកមួយផ្សេងទៀត បានរកឃើញថា ភាគច្រើននៃកុមារ និងយុវជនដែលធ្វើចំណាកស្រុក គឺធ្វើដំណើរទៅប្រទេសក្រៅ (អង្គការទស្សនៈពិភពលោក ឆ្នាំ២០១៥)។ កុមារក៏ធ្វើចំណាកស្រុកដែរ នៅពេលធ្វើដំណើរតាមឪពុកម្តាយរបស់ពួកគេ។ ការស្ទង់មតិថ្នាក់ជាតិឆ្នាំ២០១២ បានរកឃើញថា ២,៣ភាគរយ នៃជនចំណាកស្រុកធ្វើដំណើរជាមួយប្តី ឬប្រពន្ធ ហើយជាង ៥០ភាគរយនៃពួកគេ នាំកូនអាយុក្រោម ១៥ឆ្នាំទៅជាមួយផងដែរ។ ៨ភាគរយទៀត ទុកកូនៗឲ្យនៅស្រុកកំណើត (MOP ឆ្នាំ២០១២)។

សមាជិក គ.ក.ន.ក គ្រួសារ និងកុមារ បានពណ៌នាអំពីការលំបាកជាច្រើនដែលកុមារទាំងនេះបានជួបប្រទះ។ កុមារត្រូវបានគេពណ៌នាថា ធ្វើចំណាកស្រុកក្នុងអំឡុងពេលឈប់សម្រាកពីការសិក្សាដើម្បីទៅធ្វើការនៅតាមការដ្ឋានសំណង់ ដែលជាទម្រង់ការងារមួយមានគ្រោះថ្នាក់។ កុមារត្រូវបានគេពណ៌នាថា ធ្វើចំណាកស្រុកតាមរដូវកាល ដោយអវត្តមានពីសាលារៀនក្នុងអំឡុងឆ្នាំសិក្សា ទៅធ្វើការនៅតាមស្រែចម្ការ។ កុមារដែលធ្វើចំណាកស្រុកតាមរដូវកាល ជារឿយៗ ច្រើនរៀនមិនទាន់គេ ឬរៀនត្រួតថ្នាក់ ហើយមិនសូវរៀនចប់ទេ (EMC នៅក្នុងសារព័ត៌មាន)។ ករណីជាច្រើនត្រូវបានពណ៌នាអំពីកុមារដែលបោះបង់ការសិក្សាជាអចិន្ត្រៃយ៍ ដើម្បីទៅធ្វើការ ទាំងនៅក្នុងប្រទេសកម្ពុជា និងទាំងនៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី។

**សមាជិក គ.ក.ន.ក ក៏បានពណ៌នាអំពីការលំបាកដែលប្រឈមមុខដោយកុមារដែលត្រូវបានទុកចោលដោយឪពុកម្តាយធ្វើចំណាកស្រុកផងដែរ**

សមាជិក គ.ក.ន.ក ក៏បានពណ៌នាអំពីការលំបាកដែលប្រឈមមុខដោយកុមារដែលត្រូវបានទុកចោលដោយឪពុកម្តាយធ្វើចំណាកស្រុកផងដែរ។ នៅក្នុងគ្រប់ករណីទាំងអស់ដែលបានពណ៌នា ជនចំណាកស្រុកចាកចេញពីស្រុកកំណើតដោយសារភាពក្រីក្រ ហើយកូនៗត្រូវបានទុកឲ្យនៅចាំផ្ទះ ជាមួយនឹងមធ្យោបាយ ហិរញ្ញវត្ថុតិចតួចប៉ុណ្ណោះ។ ៨០ភាគរយនៃកុមារដែលឪពុកម្តាយធ្វើចំណាកស្រុក បានទុកចោល គឺត្រូវបានទុកឲ្យរស់នៅជាមួយជីដូនជីតា (MOP ឆ្នាំ២០១២) ដែលនៅក្នុងការសិក្សានេះ ត្រូវបានពណ៌នាថា មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថែទាំកុមារ ដោយសារពួកគាត់មានវ័យចាស់ជរា។

**ការឆ្លើយតបចម្បងរបស់ គ.ក.ន.ក ចំពោះបញ្ហាចំណាកស្រុក គឺការទប់ស្កាត់ចំណាកស្រុក ដោយគ្មាន សុវត្ថិភាព**

ការឆ្លើយតបចម្បងរបស់ គ.ក.ន.ក ចំពោះបញ្ហាចំណាកស្រុក គឺការទប់ស្កាត់ចំណាកស្រុក ដោយគ្មានសុវត្ថិភាព។ គ.ក.ន.ក បានធ្វើសកម្មភាពលើកកម្ពស់ការយល់ដឹង ដើម្បីលើកទឹកចិត្តកុមារឲ្យពន្យារពេលក្នុងការធ្វើចំណាកស្រុក និងធ្វើចំណាកស្រុកដោយសុវត្ថិភាព។ គ.ក.ន.ក មួយចំនួនតូច បានធ្វើការងារដើម្បីកំណត់រកឪពុកម្តាយ ដែលមានផែនការធ្វើចំណាកស្រុក និងបានលើកទឹកចិត្តពួកគេឲ្យទុកកូនៗនៅជាមួយគ្រួសារនៅក្នុងភូមិ ជាជាងយកពួកគេទៅជាមួយ។ គ.ក.ន.ក ក៏បានផ្តល់សេវាផងដែរ។ អ្នកចូលរួមជាច្រើន បានពណ៌នាអំពីរបៀបដែល គ.ក.ន.ក កំណត់រកកុមារដែលត្រូវបានទុកចោលដោយឪពុកម្តាយធ្វើចំណាកស្រុក និងបានផ្តល់សេវាដល់កុមារទាំងនេះ ក្នុងនោះរាប់បញ្ចូលទាំងការគាំទ្រផ្នែកការសិក្សា ឬការផ្គត់ផ្គង់ផ្សេងៗទៀតផង។

## ការឆ្លើយតបរបស់ គ.ក.ន.ក ចំពោះការរំលោភបំពានផ្លូវភេទ

**បើទោះបីជាសមាជិក គ.ក.ន.ក ភាគច្រើនបំផុត មិនបានលើកឡើងអំពីការធ្វើផែនការការងារ ឬថវិកា រួចរាល់ក្តី នៅក្នុងការបរិយាយដំបូងអំពីតួនាទីរបស់ គ.ក.ន.ក ប៉ុន្តែកិច្ចការទាំងនេះ ត្រូវបានលើកឡើងជារឿយៗនៅក្នុងកិច្ចសម្ភាសន៍ពេលក្រោយមកទៀតពោលគឺនៅពេលសាកសួរផ្ទាល់អំពីមុខងារទាំងនេះ។**

បើទោះបីជាសមាជិក គ.ក.ន.ក ភាគច្រើនបំផុតមិនបានលើកឡើងអំពីការធ្វើផែនការការងារ ឬថវិការួចរាល់ក្តី នៅក្នុងការបរិយាយដំបូងអំពីតួនាទីរបស់ គ.ក.ន.ក ប៉ុន្តែកិច្ចការទាំងនេះ ត្រូវបានលើកឡើងជារឿយៗនៅក្នុងកិច្ចសម្ភាសន៍ពេលក្រោយមកទៀតពោលគឺនៅពេលសាកសួរផ្ទាល់អំពីមុខងារទាំងនេះ។ ការស្រាវជ្រាវមុនៗ បានរកឃើញថា គ.ក.ន.ក ស្ទាត់ជំនាញក្នុងការបំពេញតួនាទីពិធីការ (Plummer ឆ្នាំ២០១២)។ ក្រុមស្រាវជ្រាវមិនអាចរកបានឯកសារទាំងនេះ ដើម្បីវាយតម្លៃកម្រិតនៃការឆ្លុះបញ្ចាំងអំពីកង្វល់ពាក់ព័ន្ធទៅនឹងការការពារកុមារបានឡើយ។ Ramage (ឆ្នាំ២០១៥) បានរកឃើញថា មានតែ ៣-៩ភាគរយ នៃ CIP ប៉ុណ្ណោះ ដែលត្រូវបានបែងចែកសម្រាប់សេវាសង្គមកិច្ច ហើយដោយសារតែចំនួននេះ រួមបញ្ចូលនូវសេវាជាច្រើនប្រភេទផ្សេងៗគ្នា ថវិកាជាក់ស្តែងដែលបានបែងចែកសម្រាប់សេវាការពារកុមារអាចនឹងមានកម្រិតទាបជាងនេះ។ **២៨/៣០ នៃសមាជិក គ.ក.ន.ក បាននិយាយថា ពួកគេបានចំណាយថវិកាទាំងអស់ដែលបានបែងចែកកាលពីឆ្នាំទៅមិញ ដែលបង្ហាញថា នៅក្នុងខ្ទង់ទាំងនេះ មិនមានការចំណាយថវិកាមិនអស់នោះទេ។** សមាជិក គ.ក.ន.ក នៅក្នុងការសិក្សានេះ ត្រូវបានសួរអំពីចំនួនបញ្ហាដែលទាក់ទងនឹងការការពារកុមារ ដែលត្រូវបានដាក់បញ្ចូលនៅក្នុង CIP អ្នកខ្លះនិយាយថា ពួកគេមិនបានដឹងទេ ឬមិនចាំទេ ចំណែកអ្នកខ្លះទៀត ប្រាប់អំពីការចំណាយគិតជាប្រាក់រៀលដោយមិនផ្តល់ព័ត៌មានលម្អិតថាតើប្រាក់នេះត្រូវបានចាយយ៉ាងដូចម្តេចខ្លះឡើយ។ **ទិន្នន័យពី គ.ក.ន.ក ស្តីពីបញ្ហានេះ មិនមានលក្ខណៈរឹងមាំទេ។** ការស្រាវជ្រាវមុនៗ រកឃើញថា មានព័ត៌មានតិចតួចបំផុតដែលប្រមូលពីសហគមន៍ដោយ គ.ក.ន.ក និងការដាក់បញ្ចូលតិចតួចនូវព័ត៌មាននេះនៅក្នុងដំណើរការធ្វើផែនការ (VBNK ឆ្នាំ២០១០)។ ប៉ុន្តែ ការសិក្សាកាលពីពេលថ្មីៗ បានបង្ហាញនូវការផ្លាស់ប្តូរខុសពីពេលមុន។ ផលប៉ះពាល់វិជ្ជមាននៃការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលទៅលើការបែងចែកថវិកាសម្រាប់សេវាសង្គមកិច្ចនៅក្នុង CIP នឹងពិភាក្សានៅផ្នែកខាងក្រោម (នៅក្នុងចំណុចការគាំទ្រសម្រាប់ការធ្វើផែនទី និងការតាមដាន គ.ក.ន.ក)។

ដំណើរការនៃការធ្វើ CDP និង CIP ត្រូវបានពណ៌នាថាមានលក្ខណៈចូលរួម និងមានការចូលរួមគួរសមពីសហគមន៍។ ដំណើរការនេះ គឺជាភារកិច្ចទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ហើយ គ.ក.ន.ក ចូលរួមចំណែកមួយភាគធំក្នុងសមត្ថភាពជាទីប្រឹក្សា។ ការគាំទ្រពីអង្គការ មិនមែនរដ្ឋាភិបាលសម្រាប់ដំណើរការនេះ ត្រូវបានរាយការណ៍នៅក្នុងករណីជាច្រើន។ ដំណើរការធ្វើផែនការត្រូវគេពណ៌នាថា បានឆ្លុះបញ្ចាំងនូវសំណើនានារបស់សមាជិកសហគមន៍។

ការសិក្សាជាច្រើនបានរកឃើញថា នៅពេលជ្រើសរើសសេវានានា សម្រាប់ឃុំសង្កាត់របស់ខ្លួន គណៈកម្មាធិការច្រើនតែជ្រើសរើសគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដោយសារហេតុផលមួយចំនួន (Ramage ឆ្នាំ២០១៥, UNICEF ឆ្នាំ២០០៨, VBNK ឆ្នាំ២០១០)។ គម្រោងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ មានលទ្ធផលដែលអាចមើលឃើញជាក់ស្តែងបាន និងផ្តល់ផលប្រយោជន៍ដល់សហគមន៍មួយភាគធំ។ម្យ៉ាងវិញទៀត គម្រោងបែបនេះ ក៏ងាយស្រួលយល់ផងដែរ។ គម្រោងសេវាសង្គមកិច្ចមានភាពស្មុគស្មាញជាង ហើយសមាជិកសហគមន៍អាចនឹងមិនបានដឹងថា CIP អាចផ្តល់ថវិកាសម្រាប់ការគាំទ្រផ្នែកការសិក្សា ឬការគាំទ្រផ្នែកជីវភាពឡើយ។ ជាងនេះទៅទៀត គម្រោងសេវាសង្គមកិច្ចមានភាពស្មុគស្មាញខ្លាំងជាងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ក្នុងការទទួលបានមូលនិធិពី CDP។

ជាដំបូង អ្នកស្នើបុរេប្រទានពីរតនាគារ បន្ទាប់មក អ្នកទទួលបានលុយ រួចហើយធ្វើសកម្មភាព បន្ទាប់មកទៀត ធ្វើរបាយការណ៍សកម្មភាព ចំនួនអ្នកទទួលផល (ឲ្យបានលម្អិត) បន្ទាប់មកអ្នកត្រូវទៅជួបរតនាគារម្តងទៀតពេលនោះ អាចនឹងមានបញ្ហាពួកគេនិយាយថា អ្នកត្រូវការត្រា និងហត្ថលេខារបស់អ្នកលក់ ប៉ុន្តែប្រហែលជាអ្នកលក់គ្មានត្រាទេ ដូច្នេះ អ្នកត្រលប់ទៅត្រលប់មក ម្តងហើយម្តងទៀត។ ហើយលុយគម្រោងតិចតួចប៉ុណ្ណោះ។ ជាមួយនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធវិញ អ្នកគ្រាន់តែដេញថ្លៃធ្វើកិច្ចសន្យា រួចហើយតាមដានការអនុវត្តជាការស្រេច។

ភាគីពាក់ព័ន្ធមកពីអង្គការមិនមែនរដ្ឋាភិបាល

ខ្លឹមសារអត្ថាធិប្បាយខាងលើបង្ហាញអំពីដំណើរការនៃការស្នើសុំមូលនិធិ សម្រាប់គម្រោងសេវាសង្គមកិច្ច តែមួយ ដែលរួមមានដំណើរការស្នើសុំមូលនិធិ រាយការណ៍អំពីសកម្មភាព និងផ្តល់វិក្កយបត្រ ដែលមានត្រា និងហត្ថលេខា។ សេវានីមួយៗដែលបានផ្តល់ទាមទារឲ្យធ្វើតាមនីតិវិធីជាក់លាក់ ទាមទារការធ្វើដំណើរទៅមកការិយាល័យពាក់ព័ន្ធ ដែល គ.ក.ន.ក អាចនឹងគ្មានប្រេងឥន្ធនៈ ឬពេលវេលាក្នុងការធ្វើដំណើរទៅមកនេះទេ។ រៀងរាល់ពេល ដែលធ្វើតាមដំណើរការនេះ ក៏លេចឡើងនូវឱកាសដែលអ្នកបើកថវិកាឲ្យឆ្លៀតប្រព្រឹត្តនូវអំពើពុករលួយ។ ជាងនេះទៅទៀត អ្នកផ្គត់ផ្គង់គម្រោងហេដ្ឋារចនាសម្ព័ន្ធ អាចនឹងធ្លាប់បានបំពេញនីតិវិធីទាំងនេះពីមុនរួចមកហើយ ខុសពីអ្នកផ្គត់ផ្គង់សេវាសង្គមកិច្ច ដែលធ្លាប់មានបទពិសោធន៍បំពេញតាម នីតិវិធីនេះតិចតួចប៉ុណ្ណោះ។

## ៤.២.៥ ការចូលរួមរបស់កុមារនៅក្នុង គ.ក.ន.ក

**ខណៈដែលគោលនយោបាយ (RGC ឆ្នាំ២០០៨) ចែងថា គ.ក.ន.ក មានភារកិច្ចតស៊ូមតិជំរុញឲ្យស្ត្រី ចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ទាក់ទងនឹងការអភិវឌ្ឍឃុំសង្កាត់ ប៉ុន្តែគោលនយោបាយមិនបានលើកឡើងអំពីការតស៊ូមតិ ជំរុញឲ្យមានការចូលរួមរបស់កុមារឡើយ**

ខណៈដែលគោលនយោបាយ (RGC ឆ្នាំ២០០៨) ចែងថា គ.ក.ន.ក មានភារកិច្ចតស៊ូមតិជំរុញឲ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ទាក់ទងនឹងការអភិវឌ្ឍឃុំសង្កាត់ ប៉ុន្តែគោលនយោបាយមិនបានលើកឡើងអំពីការតស៊ូមតិ ជំរុញឲ្យមានការចូលរួមរបស់កុមារឡើយ។ ចំណុចនេះ ត្រូវបានកត់សម្គាល់ដោយសមាជិក គ.ក.ន.ក មួយចំនួនឆ្លើយតបទៅនឹងសំណួរស្តីពីការចូលរួមរបស់កុមារ និងត្រូវបានលើកឡើងថាជាមូលហេតុនៃកង្វះការចូលរួមជាមួយកុមារ។ កុមារមួយរូបបានភ្ជាប់កង្វះនៃការចូលរួមទៅនឹងអាកប្បកិរិយារបស់មនុស្សពេញវ័យចំពោះកុមារ។

> មនុស្សចាស់និយាយថា កុមារមិនសូវដឹងអីទេ កុមារនៅក្មេង និងត្រូវរៀនសូត្រច្រើន បន្ថែមទៀត ប៉ុន្តែ ទោះបីកុមារមានអាយុតិចក្តី គេដឹងរឿងជាច្រើន ប៉ុន្តែ មនុស្សចាស់មិនព្រមស្តាប់ពួកគេឡើយ។

**នៅក្នុងករណីជាច្រើន គ.ក.ន.ក បានឲ្យកុមារចូលរួម ប៉ុន្តែ ការចូលរួមនេះហាក់ដូចជាមិនសូវមានអត្ថន័យចំពោះកុមារទេ។** ឧទាហរណ៍ នៅពេលស្នើឲ្យពណ៌នាការចូលរួមរបស់កុមារ ប្រធាន គ.ក.ន.ក មួយរូបបាននិយាយថា៖

> កុមារមកចូលរួមព្រឹត្តិការណ៍របស់យើង ហើយយើងណែនាំឲ្យពួកគេដើរផ្លូវល្អ។

**នៅក្នុងករណីនេះ កុមារគ្រាន់តែជាអ្នកស្តាប់ប៉ុណ្ណោះ មិនមែនជាអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាទេ។** សមាជិក គ.ក.ន.ក នេះ មិនទំនងជាយល់ច្បាស់អំពីអត្ថន័យនៃការចូលរួមរបស់កុមារទេ។ វាស្រដៀងគ្នាទៅនឹងការរកឃើញរបស់ការសិក្សា ដែលបានលើកឡើងនៅខាងលើ ដែលរកឃើញថា កុមារតែ ២ភាគរយប៉ុណ្ណោះ ដែលធ្លាប់ត្រូវបានសួរសំណួរអំពីមតិយោបល់នៅក្នុងសាលារៀន (Jordanwood ឆ្នាំ២០០៥)។

នៅក្នុងករណីផ្សេងទៀត សមាជិក គ.ក.ន.ក បានពន្យល់ថា កុមារមិនអាចចូលរួមបានទេ។

> យើងអញ្ជើញកុមារ យើងផ្តល់ឱកាសដល់កុមារ ប៉ុន្តែ ពួកគេមិននិយាយច្រើនទេ ពីព្រោះពួកគេអៀនពេក។

ប៉ុន្តែ ជាពិសេស នៅក្នុងវិស័យដែលក្រុមកុមារ (ដែលពណ៌នាខាងក្រោមនេះ នៅក្នុងចំណុចស្តីពីក្រុមរបស់កុមារ) ចូលរួមសកម្ម ការចូលរួមរបស់កុមារមានអត្ថន័យច្រើនជាងនេះ ដោយចូលរួមនៅក្នុងដំណើរការធ្វើផែនការប្រចាំឆ្នាំ និងព្រឹត្តិការណ៍តស៊ូមតិនានា។ កុមារទំនងជាបានរៀនសូត្រជំនាញទាំងនេះតាមរយៈក្រុមរបស់កុមារ។

**ប៉ុន្តែ ជាពិសេស នៅក្នុងវិស័យដែលក្រុមកុមារ (ដែលពណ៌នាខាងក្រោមនេះ នៅក្នុងចំណុចស្តីពីក្រុម របស់កុមារ) ចូលរួមសកម្ម ការចូលរួមរបស់កុមារមានអត្ថន័យច្រើនជាងនេះ ដោយចូលរួមនៅក្នុង ដំណើរការធ្វើផែនការប្រចាំឆ្នាំ និងព្រឹត្តិការណ៍តស៊ូមតិនានា**

ជាចុងក្រោយ គ.ក.ន.ក មួយចំនួន បានពណ៌នាអំពីការចូលរួមរបស់កុមារមានកម្រិតខ្ពស់ ដោយកុមារចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក និងបញ្ចេញមតិយោបល់នៅក្នុងកិច្ចប្រជុំទាំងនេះ។ អ្នកចូលរួមខ្លះនៃការពិភាក្សាក្រុមគោលដៅ ជាមួយសមាជិក គ.ក.ន.ក និងជាមួយកុមារ បាននិយាយថាការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលតាមរយៈក្រុមកុមារ បានជួយសម្រួលដល់ការចូលរួមរបស់កុមារនៅក្នុង គ.ក.ន.ក។ ប្រការនេះ ត្រូវបានចាត់ទុកថាជាសមិទ្ធផលមួយ ដោយសារតែអាកប្បកិរិយាជាប្រពៃណីមិនគាំទ្រការចូលរួមរបស់កុមារ ហើយកុមារទទួលបានការបណ្តុះបណ្តាល ស្តីពីការចូលរួមតិចតួចណាស់នៅក្នុងសាលារៀន។

# ទម្លាប់នៃការការពារកុមារតាមសហគមន៍ (CBCPP)

## ៥.១ CBCPP ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹង គ.ក.ន.ក

**អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ផ្តល់កម្មវិធីការពារកុមារជាច្រើន នៅក្នុងប្រទេស កម្ពុជា**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ផ្តល់កម្មវិធីការពារកុមារជាច្រើន នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងករណីជាច្រើន អង្គការមិនមែនរដ្ឋាភិបាល បានបំពេញគម្លាតដែលបង្កឡើងដោយសារកង្វះនៃការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់សេវាការពារកុមារ នៅថ្នាក់ឃុំសង្កាត់ និងថ្នាក់ភូមិ។ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ មិនផ្តល់សេវាគ្របដណ្តប់ដល់ថ្នាក់ជាតិឡើយ ហើយជារឿយៗ ផ្តោតសំខាន់ទៅលើក្រុមប្រជាជន និងប្រភេទសេវាជាក់លាក់តែប៉ុណ្ណោះ។ ពុំមានប្រព័ន្ធថ្នាក់ជាតិណាមួយដែលផ្តល់សេវាការពារកុមារតាមស្តង់ដារត្រឹមត្រូវ ឬទូលំទូលាយនៅទូទាំងប្រទេសកម្ពុជាឡើយ។




ក្រាហ្វ ៤៖ ដៃគូរបស់ គ.ក.ន.ក ដូចដែលរាយការណ៍ដោយសមាជិក គ.ក.ន.ក

**នៅគ្រប់ទីកន្លែង និងគ្រប់ក្រុមទាំងអស់ អ្នកចូលរួមបានរាយឈ្មោះអង្គការមិនមែនរដ្ឋាភិបាល ដែល គ.ក.ន.ក បានសហការជាមួយដើម្បីផ្តល់សេវា**

នៅគ្រប់ទីកន្លែង និងគ្រប់ក្រុមទាំងអស់ អ្នកចូលរួមបានរាយឈ្មោះអង្គការមិនមែនរដ្ឋាភិបាល ដែល គ.ក.ន.ក បានសហការជាមួយដើម្បីផ្តល់សេវា។ ប្រេវ៉ាឡង់នៃអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានកត់សម្គាល់នៅខាងលើ (នៅក្នុងចំណុចស្តីពីការបញ្ជូនទៅរក និងការផ្តល់សេវាការពារកុមាររបស់ គ.ក.ន.ក)។ ភាគច្រើននៃអង្គការមិនមែនរដ្ឋាភិបាលដែលបានរាយឈ្មោះ មិនមែនជាផ្នែកនៃគណៈកម្មាធិការដឹកនាំទេ។ កម្មវិធីដែលអង្គការទាំងនេះគ្រប់គ្រង ផ្តោតទៅលើតែការផ្តល់សេវាប៉ុណ្ណោះ ដែលក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលបានបង្កើតគម្រោង និងក្រុមគោលដៅរួចជាស្រេចហើយ បង្កើតភាពជាដៃគូជាមួយ គ.ក.ន.ក ដើម្បីផ្តល់សេវា និងផលប្រយោជន៍ជាក់លាក់ទាំងអស់នេះ។ អង្គការជាច្រើនក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលទាំងនេះបានចាត់ទុកភាពជាដៃគូជាមួយរដ្ឋាភិបាលថាជាការសំខាន់ ប៉ុន្តែ គោលបំណងរបស់ពួកគេគឺដើម្បីផ្តល់សេវាដល់អ្នកទទួលផលប្រយោជន៍ មិនមែនដើម្បីពង្រឹងប្រព័ន្ធការពារកុមាររបស់រដ្ឋាភិបាលនោះទេ។

គំរូនេះមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ ការផ្តល់សេវា ត្រូវបានពណ៌នាថាជាការផ្តល់ដល់ គ.ក.ន.ក នូវភាពជឿទុកចិត្ត និងផ្តល់កេរ្តិ៍ឈ្មោះល្អនៅក្នុងសហគមន៍។ **ប៉ុន្តែ ការផ្តល់សេវារបស់ខ្លួន រឹតត្បិតការចូលរួមរបស់សមាជិកសហគមន៍ និងសមាជិក គ.ក.ន.ក ដោយសារតែការសម្រេចចិត្តអំពីសេវាខ្លះដែលត្រូវផ្តល់ មិនមែនធ្វើឡើងនៅថ្នាក់មូលដ្ឋានទេ ប៉ុន្តែធ្វើឡើងដោយថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិរបស់អង្គការនោះតែម្តង។**

## ៥.២ ការពង្រឹងប្រព័ន្ធ CBCPPs ដែលពាក់ព័ន្ធនឹង គ.ក.ន.ក

កម្មវិធីទាំង១៤ របស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ៩ និងអង្គការពហុភាគីមួយ នៅក្នុងគណៈកម្មាធិការដឹកនាំ សុទ្ធតែផ្តោតទៅលើការផ្តល់ការគាំទ្រដែលទូលំទូលាយជាងការផ្តល់សេវាតាមគោលដៅ។ **កម្មវិធីទាំងនេះបានធ្វើការដើម្បីពង្រឹងប្រព័ន្ធការពារកុមារថ្នាក់ជាតិ** ដោយអនុវត្តកម្មវិធីដោយផ្ទាល់ ឬតាមរយៈភាពជាដៃគូ ឬកិច្ចសន្យាបន្តជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

**កម្មវិធីនានាបានផ្តល់ការគាំទ្រជាច្រើនទម្រង់ដល់ គ.ក.ន.ក**

ខណៈដែលគំរូទាំងនេះពាក់ព័ន្ធនឹងការងារនៅថ្នាក់ជាតិ និងថ្នាក់ស្រុក វិសាលភាពនៃការសិក្សានេះគឺផ្តោតទៅលើត្រឹមតែកិច្ចអន្តរាគមន៍នៅតាមសហគមន៍ប៉ុណ្ណោះ ហើយមានតែកិច្ចអន្តរាគមន៍នៅថ្នាក់ភូមិ និងថ្នាក់ឃុំប៉ុណ្ណោះ ដែលត្រូវបានលើកយកមកពិភាក្សានៅក្នុងចំណុចនេះ។ នៅថ្នាក់នេះ កម្មវិធីទាំង១៤ មានគោលដៅពង្រឹង គ.ក.ន.ក។ កម្មវិធីនានាបានផ្តល់ការគាំទ្រជាច្រើនទម្រង់ដល់ គ.ក.ន.ក។ កម្មវិធីទាំងនេះធ្វើការដើម្បីជះឥទ្ធិពលមិនត្រឹមតែទៅលើសមាជិកគ.ក.ន.ក ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងសមាជិកសហគមន៍ និងអ្នកការពារសហគមន៍ (gatekeepers) ដែលធ្វើការងារប្រសព្វគ្នាជាមួយ គ.ក.ន.ក។ កិច្ចអន្តរាគមន៍បឋមដែលផ្តល់ដោយកម្មវិធីទាំង១៤នេះ រួមមាន **ការគាំទ្រដល់សមត្ថភាពចាត់ចែងការងារ និងសមត្ថភាពបច្ចេកទេស ការគាំទ្រសម្រាប់ការតាមដាន ការគាំទ្រសម្រាប់ការផ្តល់សេវាសង្គមកិច្ច និងការសម្របសម្រួលក្រុមកុមារ និងក្រុមសហគមន៍។** ដោយសារតែកម្មវិធីជាច្រើន ក្នុងចំណោមកម្មវិធីទាំងនេះជាន់គ្នា ដើម្បីទប់ស្កាត់ការជាន់គ្នាដដែលៗ កិច្ចអន្តរាគមន៍របស់កម្មវិធី ត្រូវបានសង្ខេបជាគំរូនៅក្នុងកិច្ចពិភាក្សាខាងក្រោមនេះ។

### ៥.២.១ ការគាំទ្រសមត្ថភាពចាត់ចែង

កម្មវិធីទាំង១៤ បានធ្វើការដើម្បីគាំទ្រដល់ការអនុវត្តមុខងាររបស់ គ.ក.ន.ក ប៉ុន្តែកម្រិតនៃការគាំទ្រមានភាពខុសៗគ្នា។ ចំពោះ គ.ក.ន.ក ខ្លះ ការគាំទ្រនេះមានកម្រិតទាប ចំណែកឯសម្រាប់ គ.ក.ន.ក ខ្លះទៀត ការគាំទ្រនេះមានច្រើន ដូចជា ការបណ្តុះបណ្តាល ការគាំទ្រសម្រាប់ការអនុវត្តមុខងាររបស់ គ.ក.ន.ក ក្នុងនោះរាប់បញ្ចូលទាំងការផ្សារភ្ជាប់ទៅនឹងសេវានានា និងការធ្វើផែនទីសេវា ដើម្បីគាំទ្រដល់ការធ្វើផែនការឃុំសង្កាត់។ ទម្លាប់អនុវត្តន៍នីមួយៗ ត្រូវបានពណ៌នាលម្អិតដូចតទៅ៖

## ការបណ្តុះបណ្តាលលើផ្នែកសមត្ថភាពចាត់ចែង

**សមាជិក គ.ក.ន.ក ត្រូវការការបណ្តុះបណ្តាលជាចាំបាច់ ដើម្បីអាចបំពេញភារកិច្ចការរដ្ឋបាលទាំងនេះបាន**

មានមូលហេតុជាច្រើន ដែលការបណ្តុះបណ្តាលលើផ្នែកសមត្ថភាពចាត់ចែង មានភាពសំខាន់ចាំបាច់។ សមាជិក គ.ក.ន.ក ជាច្រើន មានសមត្ថភាពរដ្ឋបាលកម្រិតទាប ដូចដែលគេរកឃើញទាំងនៅក្នុងការសិក្សានេះ និងទាំងនៅក្នុងរបាយការណ៍មុនៗ (Gamer និង Mauney ឆ្នាំ២០១៣)។ ការចាត់ចែង គ.ក.ន.ក ដ៏សកម្មមួយ អាចពាក់ព័ន្ធនឹងបែបបទឯកសារស្មុគស្មាញ ជាពិសេស ប្រសិនបើ គ.ក.ន.ក ជាប់ពាក់ព័ន្ធនឹងការផ្តល់មូលនិធិ CIP ដល់សមាជិកសហគមន៍ (ដូចបានពណ៌នានៅក្នុងចំណុចស្តីពីការរៀបចំផែនការការងារ និងថវិកាប្រចាំឆ្នាំ) ឬត្រូវតម្រូវឲ្យរក្សាទុកបង្កាន់ដៃរដ្ឋបាលជាផ្នែកនៃភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល។ សមាជិក គ.ក.ន.ក ត្រូវការការបណ្តុះបណ្តាលជាចាំបាច់ ដើម្បីអាចបំពេញភារកិច្ចការរដ្ឋបាលទាំងនេះបាន។

ជាងនេះទៅទៀត សមាជិក គ.ក.ន.ក មួយចំនួន ក៏ត្រូវការការបណ្តុះបណ្តាលផងដែរ ដើម្បីអាចចូលរួមសកម្មនៅក្នុងកិច្ចប្រជុំនានា។ នៅក្នុងការសិក្សាមួយស្តីពីក្រុមប្រឹក្សាឃុំសង្កាត់ កង្វះជំនាញផ្នែកការប្រាស្រ័យទាក់ទង ត្រូវបានកំណត់ថាជាមូលហេតុដែលរឹតត្បិតដល់ការចូលរួមនៅក្នុង គ.ក.ន.ក (Plummer ឆ្នាំ២០១២)។ អ្នកទទួលបន្ទុក គ.ក.ន.ក គឺជាស្ត្រី ហើយភាពលម្អៀងផ្នែកយេនឌ័រក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រុស ត្រូវបានកំណត់ថាជាឧបសគ្គដែលរារាំងការចូលរួមនៅក្នុង គ.ក.ន.ក (VBNK ឆ្នាំ២០១០)។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ការបណ្តុះបណ្តាលផ្នែកការចូលរួម។ ឯកសារវាយតម្លៃការចូលរួមដែលត្រូវបានពិនិត្យឡើងវិញ បានពណ៌នាកត្តាទាំងនេះ ថាមានឥទ្ធិពលវិជ្ជមានទៅលើការអនុវត្តមុខងាររបស់ គ.ក.ន.ក។

## ការបណ្តុះបណ្តាលអំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការការពារកុមារ

**ក្នុងអំឡុងពេលនៃការ ពិភាក្សាក្រុមគោលដៅ គ.ក.ន.ក បានបង្ហាញនូវចំណេះដឹងកម្រិតខ្ពស់អំពីបញ្ហាការពារកុមារ។**

អង្គការមិនមែនរដ្ឋាភិបាលដែលពង្រឹងប្រព័ន្ធ ក៏បានផ្តល់ការបណ្តុះបណ្តាលលើបញ្ហានានា ដែលទាក់ទងនឹងការការពារកុមារផងដែរ។ ប្រធានបទនៃការបណ្តុះបណ្តាលដែលគេលើកឡើងជាទូទៅបំផុត រួមមានការកំណត់រក និងឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ (ទាំងអំពើហិង្សាប្តីប្រពន្ធ និងអំពើហិង្សាលើកុមារ) ការរំលោភបំពានផ្លូវភេទ និងពលកម្មកុមារ។ ការសិក្សាមួយចំនួនបានរកឃើញថា ចំណេះដឹងអំពីបញ្ហាការការពារកុមារនៅក្នុងចំណោម គ.ក.ន.ក ដែលបានទទួលការបណ្តុះបណ្តាល គឺមានកម្រិតខ្ពស់ (Gamer និង Mauney ឆ្នាំ២០១៤, Moore ឆ្នាំ២០១៤, អង្គការសង្គ្រោះកុមារ ឆ្នាំ២០១៤, Bowen ឆ្នាំ២០១៥)។ ក្នុងអំឡុងពេលនៃការ ពិភាក្សាក្រុមគោលដៅ គ.ក.ន.ក បានបង្ហាញនូវចំណេះដឹងកម្រិតខ្ពស់អំពីបញ្ហាការពារកុមារ។ ចំណេះដឹងនេះ មិនទំនងជាត្រូវបានគេប្រែក្លាយទៅជាការរាយការណ៍កើនឡើងគ្រប់គ្រាន់នោះទេ (Gamer និង Mauney ឆ្នាំ២០១៤, Moore ឆ្នាំ២០១៤, អង្គការសង្គ្រោះកុមារ ឆ្នាំ២០១៤)។ ជាងនេះទៅទៀត ដូចដែលយើងនឹងពិភាក្សានៅខាងក្រោមនេះ (នៅក្នុងចំណុចស្តីពីមណ្ឌលថែទាំបែបគ្រួសារ) និងដូចដែលមានបង្ហាញភ័ស្តុតាងនៅក្នុងការសិក្សាដទៃទៀត (Embode ឆ្នាំ២០១៥) គ.ក.ន.ក បានបន្តបញ្ជូនកុមារទៅកាន់ RCIs ដែលត្រូវបានបង្ហាញថាមានផលប៉ះពាល់អវិជ្ជមានជាច្រើនបែបយ៉ាងទៅលើកុមារ ដែលនេះបង្ហាញថា គ.ក.ន.ក ជួបនូវឧបសគ្គក្នុងការយកចំណេះដឹងពីការបណ្តុះបណ្តាលទៅអនុវត្តជាក់ស្តែង។

### ៥.២.២ ការគាំទ្រសម្រាប់ការអនុវត្តមុខងាររបស់ គ.ក.ន.ក

**កង្វះមូលនិធិសម្រាប់ការអនុវត្តមុខងារសំខាន់ៗបំផុត គឺជាប្រធានបទដែលលើកឡើងដដែលៗ ទាំងនៅក្នុងទិន្នន័យសម្រាប់ការសិក្សានេះ និងទាំងនៅក្នុង ឯកសារស្រាវជ្រាវពីមុន**

អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានផ្តល់ការគាំទ្រដោយផ្ទាល់ សម្រាប់ការអនុវត្តមុខងាររបស់ គ.ក.ន.ក។ ដូចដែលយើងនឹងពិភាក្សាខាងក្រោម កង្វះមូលនិធិសម្រាប់ការអនុវត្តមុខងារសំខាន់ៗបំផុត គឺជាប្រធានបទដែលលើកឡើងដដែលៗ ទាំងនៅក្នុងទិន្នន័យសម្រាប់ការសិក្សានេះ និងទាំងនៅក្នុងឯកសារស្រាវជ្រាវពីមុន (UNICEF ឆ្នាំ២០០៦ UNICEF ឆ្នាំ២០០៨ VBNK ឆ្នាំ២០១០)។ មូលនិធិដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល រួមមាន សម្រាប់អាហារសម្រន់នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក ដែលត្រូវបានគេរកឃើញថា ជាការលើកទឹកចិត្តដល់ការចូលរួម និងក្នុងករណីខ្លះ សម្រាប់ថ្លៃប្រេងឥន្ធនៈឲ្យសមាជិក គ.ក.ន.ក ប្រើប្រាស់ក្នុងការធ្វើសកម្មភាពផ្លូវការនានា។ គ្មានកម្មវិធីណាមួយក្នុងចំណោមកម្មវិធីទាំង១៤នេះ ដែលផ្តល់ប្រាក់ខែបន្ថែមនោះឡើយ។

**ប៉ុន្តែក្រុមប្រឹក្សាឃុំសង្កាត់ មិនបានទទួលយកភារកិច្ចផ្តល់មូលនិធិនេះឡើយ ហើយ អ្នកផ្តល់ព័ត៌មានសំខាន់ បានពន្យល់ថា ផលប៉ះពាល់នៃកង្វះមូលនិធិនេះគឺបានធ្វើឲ្យមានការផ្លាស់ប្តូរ កាលវិភាគប្រជុំចំពោះ គ.ក.ន.ក ជាច្រើន។**

អ្នកផ្តល់ព័ត៌មានសំខាន់ៗជាច្រើនបានកត់សម្គាល់ថាពីមុនមានអង្គការមួយបានផ្តល់មូលនិធិ ២០០ដុល្លារក្នុងមួយឆ្នាំដល់ គ.ក.ន.ក ដើម្បីគាំទ្រដល់ការអនុវត្តមុខងាររបស់គណៈកម្មាធិការ។ អ្នកចូលរួមបានរំឭកអំពីការផ្តល់មូលនិធិបន្ថែមនេះ និងបានកត់សម្គាល់ថា មូលនិធិនេះមានប្រយោជន៍ណាស់។ ក្នុងកិច្ចប្រឹងប្រែងដើម្បីឲ្យក្រុមប្រឹក្សាឃុំសង្កាត់ទទួលយកតួនាទីផ្តល់មូលនិធិនេះ អង្គការនោះបានបញ្ចប់ការផ្តល់មូលនិធិ។ ប៉ុន្តែក្រុមប្រឹក្សាឃុំសង្កាត់ មិនបានទទួលយកភារកិច្ចផ្តល់មូលនិធិនេះឡើយ ហើយអ្នកផ្តល់ព័ត៌មានសំខាន់ បានពន្យល់ថា ផលប៉ះពាល់នៃកង្វះមូលនិធិនេះគឺបានធ្វើឲ្យមានការផ្លាស់ប្តូរកាលវិភាគប្រជុំចំពោះ គ.ក.ន.ក ជាច្រើន។ នៅក្នុងករណីទាំងនេះ កិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ និងកិច្ចប្រជុំរបស់ គ.ក.ន.ក ត្រូវបានច្របាច់បញ្ចូលគ្នា ដែលធ្វើឲ្យពេលវេលាសម្រាប់កិច្ចពិភាក្សាមានតិចនៅក្នុងកិច្ចប្រជុំរបស់ គ.ក.ន.ក។ នៅក្នុងករណីផ្សេងទៀត អ្នកផ្តល់ព័ត៌មានសំខាន់ៗ បានរាយការណ៍ថា សមាជិករបស់ក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក នឹងជ្រើសរើសឲ្យចូលរួមនៅក្នុងកិច្ចប្រជុំតែមួយប៉ុណ្ណោះ ដែលទំនងជាកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ពីព្រោះក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានគេគិតថាជាក្រុមប្រឹក្សាដែលមានសារៈសំខាន់ជាង។

## ៥.២.៣ ការគាំទ្រដល់ គ.ក.ន.ក ដើម្បីផ្សារភ្ជាប់ទៅរកសេវា

គ.ក.ន.ក បានធ្វើលើសពីតួនាទីរបស់ខ្លួនដែលកំណត់ដោយច្បាប់ ដែលរួមមានការលើកកម្ពស់ការយល់ដឹង ការតស៊ូមតិ និងការតាមដាន ដោយថែមទាំងផ្តល់សេវាខ្លួនឯងទៀតផង (នៅក្នុងចំណុចស្តីពីការបញ្ជូនទៅរក និងការផ្តល់សេវាការពារកុមាររបស់ គ.ក.ន.ក)។ **ជាញឹកញយ ពួកគេបានធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងបានផ្តល់ការគាំទ្រផ្នែកការសិក្សា។** ពួកគេក៏បានផ្សារភ្ជាប់សមាជិកសហគមន៍ទៅនឹងសេវានានារបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអាចលើកហេតុផលថា ស្ថិតនៅក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួន ដើម្បីបង្កើតការប្រាស្រ័យទាក់ទង កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល រវាងអង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសហគមន៍។ សមាជិក គ.ក.ន.ក កម្រនឹងបានញែកឲ្យដាច់ពីគ្នារវាងតួនាទីទាំងពីរនេះណាស់ ដោយផ្តល់សេវាផង និងបញ្ជូនទៅរកសេវាផង ហើយជាទូទៅ ទំនងជាចាត់ទុកថាតួនាទីរបស់ពួកគេគឺត្រូវធ្វើឲ្យជីវិតរបស់កុមារងាយរងគ្រោះ នៅក្នុងសហគមន៍មានភាពល្អប្រសើរឡើង។

**ការសិក្សានេះ បានរកឃើញថា ជារឿយៗ អាទិភាពរបស់អង្គការមិនមែនរដ្ឋាភិបាលមានអាទិភាពលប់លើអាទិភាពរបស់ គ.ក.ន.ក**

អង្គការមិនមែនរដ្ឋាភិបាលបានធ្វើកិច្ចសហប្រតិបត្តិការជាមួយ គ.ក.ន.ក ទាំងដើម្បីផ្តល់សេវា និងទាំងដើម្បីផ្តល់លទ្ធភាពទៅរកមូលនិធិសម្រាប់សមាជិក គ.ក.ន.ក ប្រើប្រាស់ដើម្បីផ្តល់សេវាដោយខ្លួនឯង។ ការសិក្សានេះ បានរកឃើញថា ជារឿយៗ អាទិភាពរបស់អង្គការមិនមែន រដ្ឋាភិបាលមានអាទិភាពលប់លើអាទិភាពរបស់ គ.ក.ន.ក។ គ.ក.ន.ក ត្រូវបានស្នើឲ្យពណ៌នាអំពីតួនាទីរបស់គណៈកម្មាធិការ។ បន្ទាប់មក ចម្លើយទាំងនេះ ត្រូវបានយកទៅប្រៀបធៀបជាមួយនឹងសកម្មភាព ដែលបានរាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ដែល គ.ក.ន.ក ធ្វើកិច្ចសហប្រតិបត្តិការជាមួយ។ ប្រសិនបើ គ.ក.ន.ក ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រដល់ការសម្រាលកូនដោយសុវត្ថិភាព នោះការសម្រាលកូនដោយសុវត្ថិភាព ជារឿយៗ ត្រូវបានរៀបរាប់ថាជាការងារមួយក្នុងចំណោមការងារទាំងឡាយរបស់ គ.ក.ន.ក។ ម្យ៉ាងវិញទៀត គ.ក.ន.ក បានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការផ្តល់សេវា និងផលប្រយោជន៍នានា ដែលអង្គការមិនមែនរដ្ឋាភិបាលបានគាំទ្រឲ្យពួកគេផ្តល់។ នៅក្នុងការសិក្សាពីមុន Plummer (ឆ្នាំ២០១២) បានរកឃើញថា សកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន អាចនឹងត្រូវកំណត់ដោយរបៀបវារៈរបស់អង្គការមិនមែនរដ្ឋាភិបាល។ **នៅក្នុងការសិក្សានេះ ឥទ្ធិពលនៃបញ្ហានេះ ត្រូវបានរកឃើញថាមានទាំងគុណប្រយោជន៍ និងគុណវិបត្តិ។** គ.ក.ន.ក បានប្តេជ្ញាចិត្តជួយផ្តល់សេវា និងផលប្រយោជន៍នានាដែលអង្គការមិនមែនរដ្ឋាភិបាល ជាដៃគូផ្តល់ ហើយទាំងនេះត្រូវបានគេជឿជាក់ថា មានផលប៉ះពាល់វិជ្ជមានទៅលើកុមារនៅក្នុងសហគមន៍។ ប៉ុន្តែ ការអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលកំណត់របៀបវារៈ មិនបានបង្កើនភាពអង់អាចដល់សមាជិក គ.ក.ន.ក ដើម្បីធ្វើការសម្រេចចិត្តដោយផ្អែកទៅតាមតម្រូវការជាក់ស្តែងរបស់សហគមន៍ឡើយ។ គេយល់ឃើញថា វាបែរជាធ្វើឲ្យប៉ះពាល់ដល់ការចូលរួមពិតប្រាកដរបស់សហគមន៍នៅក្នុងអភិបាលកិច្ចមូលដ្ឋានទៅវិញទេ។

Gourley (ឆ្នាំ២០០៩) ដោយបានពិភាក្សាអំពីអាកប្បកិរិយា និងគុណតម្លៃជាប្រពៃណីខ្មែរ បានកត់សម្គាល់ថា គំរូនៃសប្បុរសធម៌នៅក្នុងប្រទេសកម្ពុជា គឺជាប្រព័ន្ធគាំទ្រដែលមានយូរអង្វែងមកហើយ។ នៅក្នុងរចនាសម្ព័ន្ធនេះ សប្បុរសជនផ្តល់ជំនួយសប្បុរសធម៌ដល់អ្នកទាំងឡាយណាដែលខ្វះខាត។ អ្នកទទួលអំណោយសប្បុរសធម៌នេះ ត្រូវដឹងគុណគេ ប៉ុន្តែ មិនមែនត្រូវបានពង្រឹងសមត្ថភាព ឬភាពអង់អាចឡើយ។ “អំណាច ឬឥទ្ធិពលក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរ នៅតែស្ថិតនៅជាមួយសប្បុរសជនជាម្ចាស់ជំនួយ” ទំព័រ ១៧។ ក្នុងករណីខ្លះ ទំនាក់ទំនងរវាង គ.ក.ន.ក និងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវា និងផលប្រយោជន៍ដល់ក្រុមគោលដៅ បង្កើតជាឱណាមិចនៃគំរូគាំទ្របែបប្រពៃណី។

**នៅពេលដែល គ.ក.ន.ក ពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់សេវា និងផលប្រយោជន៍ដល់ក្រុមគោលដៅ វាអាចនឹងរឹតត្បិតសមត្ថភាព របស់ពួកគេក្នុងការកំណត់សេវាការពារកុមារដែលត្រូវផ្តល់**

កត្តារួមចំណែកបន្ថែមទៀតទៅលើភាពសកម្មនៃអំណាច ឬឥទ្ធិពលទាំងនេះ ក៏អាចបណ្តាលមកពីកង្វះមូលនិធិដែលអាចរកបានសម្រាប់ គ.ក.ន.ក ផងដែរ។ នៅពេលដែល គ.ក.ន.ក ពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់សេវានិងផលប្រយោជន៍ដល់ក្រុមគោលដៅ វាអាចនឹងរឹតត្បិតសមត្ថភាពរបស់ពួកគេ ក្នុងការកំណត់សេវាការពារកុមារដែលត្រូវផ្តល់។ ការផ្តល់សេវាតាមរយៈភាពជាដៃគូរវាង គ.ក.ន.ក និងអង្គការមិនមែនរដ្ឋាភិបាល ទំនងជាពឹងផ្អែកទៅលើការបន្តផ្តល់មូលនិធិដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមស្រាវជ្រាវ មិនបានជួបប្រទះកម្មវិធីផ្តល់សេវាណាមួយតាមរយៈភាពជាដៃគូរវាង គ.ក.ន.ក និងអង្គការមិនមែនរដ្ឋាភិបាល ដែលគេគិតថា អាចបន្តនិរន្តរភាពដោយ គ.ក.ន.ក តែម្នាក់ឯងឡើយ។ រាជរដ្ឋាភិបាលកម្ពុជា មិនបានផ្តល់សេវាការពារកុមារគ្រប់គ្រាន់ឡើយនៅថ្នាក់ឃុំសង្កាត់ ហើយដោយសារតែអង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកផ្តល់សេវាដ៏សំខាន់ ដូច្នេះរបៀបវារៈរបស់ពួកគេអាចនឹងមានអាទិភាពខ្ពស់។

**គ.ក.ន.ក ស្ទើរតែទាំងអស់ បានសម្តែងនូវការជឿជាក់ថា ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ និងសេវាដែលពួកគេបានផ្តល់ឲ្យ គឺពិតជាមានផលប្រយោជន៍ដល់សហគមន៍**

គ.ក.ន.ក ស្ទើរតែទាំងអស់ បានសម្តែងនូវការជឿជាក់ថា ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ និងសេវាដែលពួកគេបានផ្តល់ឲ្យ គឺពិតជាមានផលប្រយោជន៍ដល់សហគមន៍។ គ.ក.ន.ក ជាច្រើន បានស្នើសុំសេវាបន្ថែមទៀត ហើយគ្មាន គ.ក.ន.ក ណាមួយ ត្អូញត្អែរអំពីប្រភេទនៃសេវាដែលបានផ្តល់ឡើយ (ប៉ុន្តែ មានការត្អូញត្អែរពីសមាជិកអំពីការខ្វះជំនាញ និងមូលនិធិដើម្បីផ្តល់សេវាឲ្យបានត្រឹមត្រូវ)។ គេរំពឹងថា គ.ក.ន.ក អាចនឹងគិតថា ពួកគេត្រូវបានស្នើឲ្យធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលច្រើនពេក ប៉ុន្តែ នៅពេលសួរសំណួរ មាន គ.ក.ន.ក ចំនួន ៦/២៨ ប៉ុណ្ណោះ ដែលនិយាយថា នេះជាបញ្ហា។ **កិច្ចពិភាក្សាជាមួយអ្នកទទួលបន្ទុក បានរកឃើញថា គ.ក.ន.ក ជាច្រើន ទទួលសំណើសុំជំនួយដ៏ច្រើនលើសលប់ពីគ្រួសារប្រជាជនក្រីក្រ ដូច្នេះហើយពួកគេមានអារម្មណ៍គិតថា ជំនួយអ្វីក៏មានសារប្រយោជន៍ដែរ។**

## ៥.២.៤ ការគាំទ្រសម្រាប់ការធ្វើផែនទី និងការតាមដានដោយ

**កម្មវិធីពង្រឹងប្រព័ន្ធ មួយចំនួននៅក្នុងការសិក្សានេះ បានផ្តល់ការគាំទ្រដោយផ្ទាល់ដល់ គ.ក.ន.ក ដើម្បីបំពេញដំណើរការនេះ ដោយជាវៀយៗធ្វើការតាមរយៈអ្នកស្ម័គ្រចិត្តសហគមន៍។**

គោលនយោបាយ (RGC ឆ្នាំ២០០៨) កត់សម្គាល់ឃើញថា គ.ក.ន.ក គួរតែ "ជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងបញ្ហា ព្រមទាំងតម្រូវការនានារបស់ស្ត្រី និងកុមារ បន្ទាប់មកដាក់បញ្ចូលព័ត៌មានទាំងនោះទៅក្នុង CDP និង CIP"។ VBNK (ឆ្នាំ២០១០) បានរកឃើញថា នេះជាចំណុចខ្សោយសម្រាប់ គ.ក.ន.ក និងថានៅពេលដែលទិន្នន័យត្រូវបានប្រមូលបានហើយ គេមិនសូវប្រើប្រាស់ព័ត៌មានទាំងនោះសម្រាប់ការធ្វើផែនការទេ។ កម្មវិធីពង្រឹងប្រព័ន្ធមួយចំនួននៅក្នុងការសិក្សានេះ បានផ្តល់ការគាំទ្រដោយផ្ទាល់ដល់ គ.ក.ន.ក ដើម្បីបំពេញដំណើរការនេះ ដោយជារឿយៗធ្វើការតាមរយៈអ្នកស្ម័គ្រចិត្តសហគមន៍។ គម្រោងមួយបានគាំទ្រដល់ គ.ក.ន.ក ក្នុងការប្រមូលភ័ស្តុតាងលម្អិតនៃស្ថានភាពពលកម្មកុមារនៅក្នុងឃុំ។ លទ្ធផលនៃការវាយតម្លៃទាំងនេះ បន្ទាប់មក ត្រូវបានចែករំលែកនៅក្នុងវេទិកា ដើម្បីដាក់បញ្ចូលការរកឃើញនេះ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ (CDP) និងផែនការវិនិយោគឃុំសង្កាត់ (CIP)។ **សមាជិក គ.ក.ន.ក នៅក្នុងឃុំដែលបានទទួលការគាំទ្រ បានរាយការណ៍ថា ខ្លួនបានជួយកសាងជំនាញ និងបានធានាថា តម្រូវការរបស់សហគមន៍ត្រូវបានតំណាងនៅក្នុងដំណើរការធ្វើផែនការ។**

**អ្នកចូលរួម (ទាំងនៅក្នុងឃុំដែលបានទទួលការគាំទ្រ និងទាំងនៅក្នុងឃុំដែលមិនបានទទួលគាំទ្រ) បានពណ៌នាអំពីការលំបាកក្នុងការធ្វើ CDP និង CIP។** ដំណើរការនេះ មានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ហើយនៅដំណាក់កាលនេះ ការលំបាកក៏កើតមាន ដែលរឹតត្បិតការដាក់បញ្ចូលលទ្ធផលនៃការប្រមូលទិន្នន័យ។

**ទោះជាយ៉ាងណាក៏ដោយ ការពិនិត្យឯកសារបានរកឃើញភ័ស្តុតាងថា ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការធ្វើផែនការទាំងនេះ ជះឥទ្ធិពលវិជ្ជមានទៅលើការបែងចែកមូលនិធិ របស់ឃុំសង្កាត់សម្រាប់សេវាសង្គមកិច្ចនៅក្នុង CIP។**

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ការពិនិត្យឯកសារបានរកឃើញភ័ស្តុតាងថា ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការធ្វើផែនការទាំងនេះ ជះឥទ្ធិពលវិជ្ជមានទៅលើការបែងចែកមូលនិធិរបស់ឃុំសង្កាត់សម្រាប់សេវាសង្គមកិច្ចនៅក្នុង CIP។ សេចក្តីសង្ខេបគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ បានកត់ត្រាកំណើននៃការបែងចែកថវិកាក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់សេវាសង្គមកិច្ច ពី៣ភាគរយ ដល់ ៦ភាគរយ នៅក្នុងឃុំសង្កាត់នានាដែលអង្គការមិនមែនរដ្ឋាភិបាលនោះគាំទ្រសកម្មដល់ គ.ក.ន.ក។ Ramage (ឆ្នាំ២០១៥) បានរកឃើញថាការបែងចែកថវិកាសម្រាប់សេវាសង្គមកិច្ច នៅក្នុងឃុំសង្កាត់ដែលគាំទ្រដោយអង្គការ UNICEF បានកើនឡើង៣ដង ដែលនេះបង្ហាញថា ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល អាចជះឥទ្ធិពលវិជ្ជមានទៅលើចំណាយ CIP សម្រាប់សេវាសង្គមកិច្ច។ ជាងនេះទៅទៀត Ramage ក៏បានរកឃើញទំនាក់ទំនងវិជ្ជមានរវាងភាពងាយរងគ្រោះ និងការផ្តល់សេវាសង្គមកិច្ច ដែលនេះបង្ហាញថា CIP ពិតជាឆ្លុះបញ្ចាំងតម្រូវការរបស់ជនងាយរងគ្រោះ។

## ៥.២.៥ ការបង្កើតក្រុមកុមារ

អង្គការមិនមែនរដ្ឋាភិបាលពង្រឹងប្រព័ន្ធភាគច្រើនបំផុត នៅក្នុងការសិក្សានេះ បានផ្តល់ការគាំទ្រដល់កម្មវិធីនានា ដែលរៀបចំបង្កើតក្រុមកុមារ ឬក្រុមយុវជន នៅក្នុងសហគមន៍ ជាផ្នែកមួយនៃវដ្តថៃទាំនៃសេវាការពារកុមារ។ ក្រុមទាំងនេះ បានបង្កើនចំណេះដឹងជុំវិញបញ្ហានានានៃការការពារកុមារ និងការអភិវឌ្ឍជំនាញចូលរួមរបស់កុមារ។

**គ.ក.ន.ក ជាច្រើន មានទំនាក់ទំនងរឹងមាំជាមួយក្រុមកុមារ**

គ.ក.ន.ក ជាច្រើន មានទំនាក់ទំនងរឹងមាំជាមួយក្រុមកុមារ។ កុមារមកពីក្រុមទាំងនេះ បានចូលរួមនៅក្នុងសកម្មភាពរបស់ គ.ក.ន.ក។ នៅតាមតំបន់មួយចំនួន សមាជិកក្រុមកុមារ និងក្រុមយុវជន បានចូលរួមនៅក្នុងព្រឹត្តិការណ៍ម្តងម្កាល ឬព្រឹត្តិការណ៍ប្រចាំឆ្នាំ ប៉ុន្តែ នៅតំបន់ផ្សេងទៀត សមាជិកក្រុម គឺជាសមាជិករបស់ គ.ក.ន.ក។ ឯកសារពីសមាជិកគណៈកម្មាធិការដឹកនាំ បានរកឃើញថា នៅពេលទទួលបានការគាំទ្រ កុមារមានទំនុកចិត្តលើខ្លួនឯងដើម្បីចូលរួមចំណែកជាមួយ គ.ក.ន.ក។

**ក្រុមកុមារអាច លើកទឹកចិត្តកុមារគ្នាឯងដើម្បីលើកកម្ពស់ការយល់ដឹង និងធ្វើរបាយការណ៍ ប៉ុន្តែអាចមានគ្រោះថ្នាក់ ចំពោះកុមារ ប្រសិនបើពួកគេចូលរួមអន្តរាគមន៍នៅក្នុងករណីការពារកុមារ**

ឯកសារនានា ក៏បានបង្ហាញផងដែរថា ក្រុមរបស់កុមារអាចនាំទៅរកការកើនឡើង នៃការធ្វើរបាយការណ៍អំពីការរំលោភបំពានលើកុមារ (Gamer និង Mauney ឆ្នាំ២០១៣, អង្គការ សង្គ្រោះកុមារ ឆ្នាំ២០១៤)។ ជារឿយៗ របាយការណ៍ទាំងនេះត្រូវបានធ្វើឡើងដោយសមាជិក ដែលជាមិត្តភក្តិរបស់កុមារ ដែលទទួលរងការរំលោភបំពាន។ ប៉ុន្តែ ឯកសារដដែលក៏បានក្រើនរំឭកផងដែរថា ក្រុមកុមារ និងយុវជនត្រូវតែតាមដានដោយយកចិត្តទុកដាក់ ដើម្បីធានាថា កុមារមិនធ្វើអ្វីលើសពីតួនាទីរបស់ខ្លួន។ ក្រុមកុមារអាចលើកទឹកចិត្តកុមារគ្នាឯងដើម្បីលើកកម្ពស់ការយល់ដឹង និងធ្វើរបាយការណ៍ ប៉ុន្តែអាចមានគ្រោះថ្នាក់ចំពោះកុមារ ប្រសិនបើពួកគេចូលរួមអន្តរាគមន៍នៅក្នុងករណីការពារកុមារ។

## ៥.២.៦ ការបង្កើតក្រុមឪពុកម្តាយ

**ឪពុកម្តាយ ខ្លះ ដែលបានចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅសម្រាប់ការសិក្សានេះ បានរាយការណ៍ថា ពួកគភាគច្រើនប្រើវិធីចិញ្ចឹមកូនបែបវិជ្ជមាន ជាជាងប្រើប្រាស់ការរំលោភបំពានរាងកាយ**

អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានបង្កើតក្រុមឪពុកម្តាយ ដែលផ្សារភ្ជាប់ជាមួយនឹងគ.ក.ន.ក។ ក្រុមទាំងនេះ បង្កើតឡើងក្នុងគោលបំណងបង្កើនការយល់ដឹង ជំរុញវិធីចិញ្ចឹមកូនប្រកបដោយភាពវិជ្ជមាន នៅក្នុងចំណោមគ្រួសារជាសមាជិក ហើយក្នុងករណីខ្លះ ក្រុមទាំងនេះដើរតួនាទីជាគំរូមិត្តអប់រំមិត្ត។ ក្រុមឪពុកម្តាយនាំទៅរកកំណើននៃកម្រិតចំណេះដឹងក្នុងចំណោមអ្នកចូលរួម។ ឪពុកម្តាយខ្លះ ដែលបានចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅសម្រាប់ការសិក្សានេះ បានរាយការណ៍ថា ពួកគភាគច្រើនប្រើវិធីចិញ្ចឹមកូនបែបវិជ្ជមាន ជាជាងប្រើប្រាស់ការរំលោភបំពានរាងកាយ។ ឯកសារនានាពីអង្គការមិនមែនរដ្ឋាភិបាលពង្រឹងប្រព័ន្ធ បានរកឃើញលទ្ធផលស្រដៀងគ្នា (Gamer និង Mauney ឆ្នាំ២០១៤, អង្គការសង្គ្រោះកុមារ ឆ្នាំ២០១៤)។ **ក្រុមកុមារ និងក្រុមឪពុកម្តាយ ក៏បានកសាងទំនាក់ទំនងរវាងក្រុមទាំងនេះ និង គ.ក.ន.ក ផងដែរ ហើយអ្នកចូលរួមជាច្រើនបានផ្តល់ឧទាហរណ៍អំពីរបៀបដែលទំនាក់ទំនងទាំងនេះដែលបានជួយសម្រួលដល់ការអនុវត្តមុខងាររបស់ គ.ក.ន.ក។**

## ៥.២.៧ ការបង្កើតក្រុមសម្រាប់គ្រួសារដែលមានប្រវត្តិមានអំពើហិង្សា

**ក្រុមទាំងនេះ បង្កើតបានជាសហគមន៍គាំទ្រ ហើយសមាជិកភាគច្រើនបំផុត បានសម្តែងមតិក្លៀវក្លាប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ។ ឥទ្ធិពលនៃ ក្រុមសម្រាប់ជនដៃដល់ មានភាពចម្រុះ**

អង្គការមិនមែនរដ្ឋាភិបាលមួយ បានបង្កើតក្រុមសម្រាប់ជនរងគ្រោះ និងជនដៃដល់នៃអំពើរំលោភបំពានរាងកាយ។ ជនដៃដល់បានចុះហត្ថលេខាលើកិច្ចសន្យា ដែលកំណត់ឲ្យត្រូវតែចូលខ្លួនមកជួបអាជ្ញាធរមូលដ្ឋាននៅក្នុងដំណើរការនីតិវិធីផ្សះផ្សា។ ក្រុមទាំងពីរនេះ ទាមទារឲ្យមានអ្នកសម្របសម្រួលដែលមានការបណ្តុះបណ្តាលកម្រិតខ្ពស់ និងទាមទារឲ្យមាននូវជំនាញ និងកិច្ចប្រឹងប្រែងខ្លាំងក្លាដើម្បីដឹកនាំ។ ក្រុមសម្រាប់ជនរងគ្រោះត្រូវបានពណ៌នាថាមានភាពជោគជ័យជាង ទាំងនៅក្នុងការសិក្សានេះ និងទាំងនៅក្នុងឯកសារនានា (Gamer និង Mauney ឆ្នាំ២០១៣)។ ក្រុមទាំងនេះ បង្កើតបានជាសហគមន៍គាំទ្រ ហើយសមាជិកភាគច្រើនបំផុត បានសម្តែងមតិក្លៀវក្លាប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ។ ឥទ្ធិពលនៃក្រុមសម្រាប់ជនដៃដល់ មានភាពចម្រុះ។ វត្តមានរបស់ជនដៃដល់ គឺមិនមែនជាការចូលរួមដោយស្ម័គ្រចិត្តនោះទេ។ សមាជិកក្រុមខ្លះបានប្តេជ្ញាប្រើប្រាស់ក្រុមនេះជាយានសម្រាប់ការកែលម្អ ប៉ុន្តែ សមាជិកក្រុមផ្សេងទៀតមានការខ្មាស់អៀនក្នុងការចូលរួម ឬមិនសប្បាយចិត្តនឹងក្រុមនេះឡើយ។ មានទំនាក់ទំនងទៅវិញទៅមករវាងការសេពគ្រឿងស្រវឹងច្រើនហួសកម្រិត និងអំពើហិង្សាក្នុងគ្រួសារ (CDHS ឆ្នាំ២០១៤) និង Mauney រាយការណ៍ថា បានចុះទៅជួបក្រុមទាំងនេះ ដោយបានឃើញសមាជិកខ្លះស្រវឹងស្រា ឬនៅសល់អាការៈស្រវឹងនៅឡើយ។ Mauney បានលើកឡើងនូវកង្វល់ថា សមាជិកដែលអន់ចិត្តនឹងការចូលរួម អាចនឹងជះកំហឹងរបស់ខ្លួនទៅលើប្រពន្ធបន្ទាប់ពីការចូលរួមនេះ។ ប៉ុន្តែ សមាជិកខ្លះនៃក្រុមជនដៃដល់ បានរាយការណ៍ ទាំងនៅក្នុងការសិក្សានេះ និងទាំងនៅក្នុងឯកសារអង្គការមិនមែនរដ្ឋាភិបាល បានថ្លែងថា ក្រុមទាំងនេះ បានជួយពួកគេកាត់បន្ថយឥរិយាបថអំពើហិង្សា។ អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាចាក់ឫសគល់យ៉ាងជ្រៅ ដែលជារឿយៗ បន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត ហើយការថយចុះមានសភាពយឺត។ **ការថយចុះរយៈពេលខ្លី នៃអំពើហិង្សាក្នុងគ្រួសារដោយសារការចូលរួមនៅក្នុងក្រុមជាប្រការដ៏គួរឲ្យមានសង្ឃឹម ប៉ុន្តែទាមទារនូវមានការស្រាវជ្រាវបន្ថែមទៀត។**

### ៥.២.៨ ការផ្តល់បុគ្គលិកសង្គមកិច្ចដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីធ្វើការជាមួយគ.ក.ន.ក

អង្គការមិនមែនរដ្ឋាភិបាលមួយ បានគាំទ្រដល់ការផ្តល់បុគ្គលិកសង្គមកិច្ចនៅក្នុងសហគមន៍។ បុគ្គលិកសង្គមកិច្ចទាំងនេះ បានទទួលការបណ្តុះបណ្តាលពីសំណាក់អង្គការមួយដ៏មានបទពិសោធន៍ ដែលផ្តោតទៅលើសេវាសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា។ បុគ្គលិកសង្គមកិច្ចទាំងនេះក៏ទទួលបានការគាំទ្របន្ត តាមរយៈការជួបប្រជុំគ្នាប្រចាំខែផងដែរ ដែលក្នុងនោះ អ្នកអនុវត្តជួបជុំគ្នាដើម្បីចែករំលែកធនធាន ពិភាក្សាករណីនានាដោយរក្សាការសម្ងាត់ និងទទួលបានការបណ្តុះបណ្តាលរំឭកឡើងវិញ។ គម្រោងនេះបានបង្កើតភាពជាដៃគូជាមួយ គ.ក.ន.ក និងមេភូមិ ដើម្បីសម្របសម្រួលការបញ្ជូនទៅរកសេវា និងបានអនុវត្តការអប់រំផ្សព្វផ្សាយនៅក្នុងសហគមន៍ ដើម្បីឲ្យគ្រួសារប្រជាពលរដ្ឋអាចទំនាក់ទំនងជាមួយបុគ្គលិកសង្គមកិច្ច តាមទូរសព្ទក្តី ឬដោយជួបផ្ទាល់ក្តី។

**បុគ្គលិកសង្គមកិច្ចបានផ្តល់នូវការគាំទផ្នែកព្យាបាលដល់កុមារ**

បុគ្គលិកសង្គមកិច្ចបានផ្តល់នូវការគាំទ្រផ្នែកព្យាបាលដល់កុមារ។ កុមារបានជួបជាមួយបុគ្គលិកសង្គមកិច្ចនៅឯផ្ទះ ឬនៅកន្លែងផ្សេងទៀតដែលមានសុវត្ថិភាព និងពិភាក្សាអំពីបញ្ហារបស់ពួកគេ។ បន្ទាប់មកបុគ្គលិកសង្គមកិច្ច និងកុមារ រួមគ្នាធ្វើផែនការផ្តល់សេវា។ ផែនការខ្លះត្រូវបានអនុវត្តនៅក្នុងសហគមន៍ ខ្លះទៀតពាក់ព័ន្ធនឹងការបញ្ជូនទៅរកសេវាដទៃទៀត ដូចជា សេវាវេជ្ជសាស្ត្រ សេវាផ្នែកច្បាប់ ឬសេវាផ្តល់ជម្រកនៅក្នុងសហគមន៍។ កុមារអាចជួបជាមួយបុគ្គលិកសង្គមកិច្ចច្រើនលើកច្រើនសា ទៅតាមការចាំបាច់ ដើម្បីបង្កើតយន្តការដោះស្រាយ ឬស្វែងរកដំណោះស្រាយ។

គំរូនេះត្រូវបានពណ៌នាថា ទទួលបានភាពជោគជ័យដោយសារមូលហេតុមួយចំនួន។ គ.ក.ន.ក មិនមែនជាបុគ្គលិកសង្គមកិច្ចដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវនោះទេ។ ពួកគេគ្មានជំនាញ ហើយក៏គ្មានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់ការគាំទ្របន្តបន្ទាប់សម្រាប់បញ្ហាការពារកុមារដែលមានភាពស្មុគស្មាញឡើយ។ គំរូបនេះ ផ្សារភ្ជាប់ គ.ក.ន.ក ជាមួយនឹងបុគ្គលិកសង្គមកិច្ច ដែលមិនត្រឹមតែទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានទាំងការតាមដាន និងការគាំទ្រទៀតផង។ ពួកគេក៏អាចផ្តល់ការគាំទ្រជាលក្ខណៈឯកជន ដោយផ្អែកតាមទម្លាប់ព្យាបាលល្អបំផុតផងដែរ។

CBCPPs **និង** Non-CBCPPs

## ៦.១ ទម្លាប់ការពារកុមារនៅតាមសហគមន៍បែបប្រពៃណី

ទម្លាប់ការពារកុមារនៅតាមសហគមន៍ក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងអន្តរាគមន៍ផ្លូវការ តាមរយៈ គ.ក.ន.ក. និងអន្តរាគមន៍ក្រៅផ្លូវការតាមរយៈអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូរបស់ គ.ក.ន.ក.។ ទោះជាយ៉ាងណា ក៏មានទម្លាប់ការពារកុមារនៅតាមសហគមន៍ ដែលត្រូវបានបង្កើតឡើងជាផ្នែកមួយនៃវប្បធម៌ប្រពៃណីរបស់សហគមន៍ផងដែរ។ មានការសិក្សាស្រាវជ្រាវតិចតួចប៉ុណ្ណោះ បានធ្វើឡើងលើតួនាទីនៃទម្លាប់ទាំងនេះនៅក្នុងការការពារកុមារ។ ខណៈដែលការសាវជ្រាវនេះផ្តោតទៅលើ គ.ក.ន.ក. និងអង្គការមិនមែនរដ្ឋាភិបាល ទំនាក់ទំនងរវាង គ.ក.ន.ក. និងទម្លាប់ការពារកុមារនៅតាមសហគមន៍តាមបែបប្រពៃណី ត្រូវបានសិក្សាស្វែងយល់។

### ៦.១.១ ការថែទាំតាមវត្តអារាម

**វត្តអារាម គឺជាទម្រង់សាមញ្ញមួយនៃការថែទាំកុមារ**

វត្តអារាម គឺជាទម្រង់សាមញ្ញមួយនៃការថែទាំកុមារ ប៉ុន្តែមានការសិក្សាតិចតួចប៉ុណ្ណោះ ទៅលើសេវាការពារកុមារដែលវត្តអារាមផ្តល់ដល់កុមារ។ សមាជិកសហគមន៍ដែលមិនមានផ្ទះសម្បែង ត្រូវបានគេអនុញ្ញាតឲ្យរស់នៅក្នុងវត្តអារាម ហើយកុមារជាច្រើនរស់នៅក្នុងវត្តអារាម។ រដ្ឋាភិបាលកម្ពុជា ពុំបានកត់ត្រាចំនួនផ្លូវការ នៃកុមាររស់នៅក្នុងវត្តអារាមឡើយ។ ការសិក្សាទ្រង់ទ្រាយតូចមួយទៅលើវត្តអារាមនៅខេត្តកណ្តាលកាលពីឆ្នាំ២០០៩ បានរកឃើញថា **វត្តអារាមនីមួយៗ មានកុមាររស់នៅចំនួន ៥ ទៅ ៧នាក់ (ICC HOSEA)។ ប្រសិនបើចំនួនកុមាររស់នៅក្នុងវត្តអារាមមានប្រហែល ៣.០០០នាក់នៅទូទាំងប្រទេសកម្ពុជា នោះចំនួនកុមារដែលរស់នៅក្រោមការថែទាំបែបនេះ អាចមានចំនួនខ្ពស់ជាងនេះ។** នេះគឺជាផ្នែកមួយដែលទាមទារឲ្យមានការស្រាវជ្រាវបន្ថែម។ តាមប្រពៃណី កុមារីមិនត្រូវបានគេអនុញ្ញាត

ឲ្យរស់នៅក្នុងវត្តអារាមជាច្រើននោះឡើយ។ ចំណែកវត្តអារាមទាំងឡាយដែលទទួលកុមារី បានកំណត់ឲ្យពួកគេចាកចេញពី វត្តអារាមវិញនៅពេលពួកគេដល់វ័យមានរដូវ (Ramage ២០០៥)។ ហេតុនេះចំនួនកុមាររស់នៅក្នុងវត្តអារាមត្រូវបានគេគិតថាភាគច្រើនលើសលប់គឺជាក្មេងប្រុស។

**ទម្រង់សំខាន់នៃការគាំទ្រដែលវត្តអារាមផ្ដល់ឲ្យ ហាក់ដូចគ្នាទៅនឹងការថែទាំបែបគ្រួសារផងដែរ ប៉ុន្តែការ ថែទាំបែបគ្រួសារនៅតាមវត្តអារាម មិនអនុលោមទៅតាមស្តង់ដារអប្បរមាស្តីពីការថែទាំកុមារបែបជំនួស (MSACC) និងការគ្រប់គ្រងពីសំណាក់ MoSVY ឡើយ។**

ទម្រង់សំខាន់នៃការគាំទ្រដែលវត្តអារាមផ្ដល់ឲ្យ ហាក់ដូចគ្នាទៅនឹងការថែទាំបែបគ្រួសារផងដែរ ប៉ុន្តែការថែទាំបែបគ្រួសារនៅតាមវត្តអារាម មិនអនុលោមទៅតាមស្តង់ដារអប្បរមាស្តីពីការថែទាំកុមារបែបជំនួស (MSACC) និងការគ្រប់គ្រងពីសំណាក់ MoSVY ឡើយ។ នៅក្នុងសិក្សានេះ គ្មានរបាយការណ៍ណាបង្ហាញថាវត្តអារាមផ្ដល់សេវាសង្គមកិច្ច លើសពីការថែទាំបែបគ្រួសារនោះឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានសហការជាមួយវត្តអារាម ដើម្បីផ្ដល់សេវាសង្គមកិច្ច ប៉ុន្តែកិច្ចសហការជាដៃគូជាមួយវត្តអារាមពុំត្រូវបានគេរកឃើញឡើយនៅក្នុងដំណើរការប្រមូលទិន្នន័យ។ អ្នកចូលរួមជាកុមារតិចតួចណាស់ ដែលបានបញ្ជាក់ថា ព្រះសង្ឃគឺជាមនុស្សដែលពួកគេអាចពឹងពាក់នៅពេលពួកគេជួបប្រទះបញ្ហា។ ការសិក្សាមួយអំពីទម្រង់នៃការថែទាំសម្រាប់សមាហរណកម្មជនរងគ្រោះដោយសារការជួញដូរមនុស្ស ក៏បានរកឃើញផងដែរថា នេះគឺជាករណីផងដែរ (Smith-brake ឆ្នាំ២០១៤)។

**គុណភាពនៃការថែទាំផ្ដល់ដល់កុមារនៅតាមវត្តអារាម ត្រូវបានគេរកឃើញថា មានលក្ខណៈទន់ខ្សោយ។**

គុណភាពនៃការថែទាំផ្ដល់ដល់កុមារនៅតាមវត្តអារាម ត្រូវបានគេរកឃើញថា មានលក្ខណៈទន់ខ្សោយ។ ការសិក្សាមួយកាលពីឆ្នាំ២០០៤ (ICC HOSEA) បានរកឃើញថាកុមារនៅតាមវត្តអារាម មិនត្រូវបានព្រះសង្ឃមើលថែទាំត្រឹមត្រូវនោះឡើយ ដោយហេតុថា ការផ្តោតសំខាន់របស់ព្រះសង្ឃ គឺសេវាពុទ្ធចក្រមិនមែនការថែទាំកុមារឡើយ។ វាហាក់បង្ហាញថា ព្រះសង្ឃមិនទទួលបានការបណ្តុះបណ្តាលខាងថែទាំកុមារឡើយ។ កុមារនៅតាមវត្តអារាម តែងតែទទួលបានការរើសអើងពីសមាជិកសហគមន៍ ដោយសារតែភាពក្រីក្ររបស់ពួកគេ (ICC)។ វត្តអារាមជាច្រើន គឺជាទីតាំងប្រារព្ធពិធីបុណ្យ និងរៀបមង្គលការតាមប្រពៃណី ដែលមានការចូលរួមពីយុវជន។ មានសេចក្តីរាយការណ៍នានាពីកុមាររស់នៅក្នុងវត្តថា ពួកគេបានឃើញអំពើហិង្សារវាងក្រុមយុវជននៅក្នុងកម្មវិធីទាំងនេះ (Jordanwood ឆ្នាំ២០១៤)។ ថ្មីៗនេះ ករណីរំលោភបំពានផ្លូវភេទធំៗ បានកើតឡើងនៅវត្តអារាមផងដែរ (Elliot និង Chanyda ឆ្នាំ២០១៦, Hilton ឆ្នាំ២០០៨)។ ជារួមមានការសិក្សាតិចតួចទៅលើស្ថានភាពកុមាររស់នៅក្នុងវត្តអារាម ហើយការសិក្សានោះបានកន្លងហួសយូរមកហើយ។ **ការសិក្សាកាន់តែច្រើន នឹងទាមទារឲ្យធ្វើឡើងមុននឹងអង្គការមិនមែនរដ្ឋាភិបាលពិចារណាលើការកសាងភាពជាដៃគូជាមួយវត្តអារាម ដើម្បីផ្ដល់យន្ត ការការពារកុមារនៅតាមមូលដ្ឋាន។**

### ៦.១.២ ការថែទាំដោយញាតិសន្តាន

ការថែទាំដោយញាតិសន្តាន គឺជាទម្រង់ថែទាំមានចំនួនច្រើនបំផុត សម្រាប់កុមារដែលបានបែកចេញពីឪពុកម្ដាយរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ CDHS (ឆ្នាំ២០១៤) បានរកឃើញថា ១៧ភាគរយ នៃគ្រួសារ មានកូនដែលត្រូវបានចិញ្ចឹម ឬកូនកំព្រា។ ការថែទាំប្រភេទនេះ ជាញឹកញាប់ត្រូវបានគេរៀបចំឡើងក្រៅផ្លូវការ។ នៅក្នុងការសិក្សានេះ គ.ក.ន.ក. និងក្រុមគ្រួសារ ត្រូវបានគេរកឃើញថា បានចាត់ទុកការថែទាំដោយញាតិសន្តាននេះ គឺជាជម្រើសមួយសម្រាប់កុមារងាយរងគ្រោះ។ សមាជិកមួយចំនួនរបស់ គ.ក.ន.ក. បានរៀបរាប់អំពីការសម្របសម្រួលការទុកដាក់កុមារដែលរងការរំលោភបំពាន ទៅក្នុងគ្រួសារញាតិសន្តាន។ អ្នកដទៃទៀត បានរៀបរាប់អំពីការបញ្ចុះបញ្ចូលក្រុមគ្រួសារចំណាកស្រុកនៅរដូវច្រូតកាត់ឲ្យទុកដាក់កូនចៅរបស់ពួកគេជាមួយសាច់ញាតិ ដើម្បីកុំឲ្យកុមារទាំងនោះគេចវេសពីការសិក្សា។

ការសិក្សាអន្តរជាតិ បានរកឃើញថា ការថែទាំដោយញាតិសន្តាន អាចផ្ដល់អត្ថប្រយោជន៍យ៉ាងពិសេសទាក់ទងនឹងសុខមាលភាព និងការវិវត្តផ្លូវចិត្ត។ ទោះជាយ៉ាងណា ការថែទាំបែបនេះ មិនមែនសុទ្ធតែល្អនោះទេ ហើយកុមារស្ថិតនៅក្រោមការថែទាំពីញាតិសន្តាន អាចរងគ្រោះបើប្រៀបធៀបទៅនឹងកុមារនៅ RCI។ ដោយសារកង្វះការស្រាវជ្រាវទៅលើវិស័យនៅក្នុងប្រទេសកម្ពុជា គេមិនបានដឹងអំពីផលប៉ះពាល់នៃការទុកដាក់កុមារឲ្យស្ថិតក្រោមការថែទាំរបស់ញាតិសន្តានឡើយ។ នេះគឺជាផ្នែកមួយដែលទាមទារឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀត។

## ៦.២ ទម្លាប់ការពារកុមារមិនមែននៅតាមសហគមន៍
(Non-CBCPPs)

### ៦.២.១ មណ្ឌលថែទាំ (RCIs)

**នៅក្នុងការសិក្សា គ.ក.ន.ក. ២២/៣០ បានរាយការណ៍ថា គ.ក.ន.ក. បាន បញ្ជាឲ្យទុកដាក់កុមារនៅ RCI ហើយ គ.ក.ន.ក. ១៧/៣០ អាចរំលឹកឡើងវិញនូវករណីមួយនៅពេលដែលកុមារម្នាក់មកពីសហគមន៍របស់ពួកគេ ត្រូវបានទុកដាក់នៅ RCI**

ការស្រាវជ្រាវបានរកឃើញថា ដោយសារពុំមានការគាំទ្រផ្នែកសង្គមដល់កុមារងាយរងគ្រោះ នៅក្នុងសហគមន៍ ក្រុមគ្រួសារនឹងបញ្ជូនកូនៗរបស់ពួកគេទៅក្នុងការថែទាំបែបគ្រួសារ ដើម្បីធានាថា តម្រូវការរបស់ពួកគេត្រូវបានផ្តល់ឲ្យ (Jordanwood ឆ្នាំ២០១២)។ គោលនយោបាយជាតិនៅកម្ពុជា បានចែងថា ការថែទាំបែបគ្រួសារ គួរត្រូវបានគេទុកជាជម្រើសចុងក្រោយ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៩)។ ទោះជាយ៉ាងណា ការសិក្សានេះបានរកឃើញថា អាជ្ញាធរមូលដ្ឋាន កម្រដើរតាមគោលនយោបាយណាស់ ហើយមនុស្សជាច្រើនបានណែនាំឲ្យជ្រើសរើសយកការដាក់ទុកកុមារនៅ RCI ធ្វើជាការឆ្លើយតបដំបូង (Jordanwood ឆ្នាំ២០១២)។ **នៅក្នុងការសិក្សា គ.ក.ន.ក. ២២/៣០ បានរាយការណ៍ថា គ.ក.ន.ក. បានបញ្ជាឲ្យទុកដាក់កុមារនៅ RCI ហើយ គ.ក.ន.ក. ១៧/៣០ អាចរំលឹកឡើងវិញនូវករណីមួយ នៅពេលដែលកុមារម្នាក់មកពីសហគមន៍របស់ពួកគេ ត្រូវបានទុកដាក់នៅ RCI។** នៅពេលគេស្នើឲ្យពិចារណាលើសេណារីយ៉ូសម្មតិកម្មមួយ ដែលកុមារម្នាក់ត្រូវបានគេទុកដាក់នៅ RCI គ.ក.ន.ក. ២២/៣០ បាននិយាយថា នេះគឺជាការសម្រេចចិត្តដ៏ល្អ។ ដោយហេតុថា ការស្រាវជ្រាវថ្មីៗ (NIS, MoSVY, Columbia University, MLT Consulting ឆ្នាំ២០១៦) បានរកឃើញថា មានកុមារជាង ៤៨.០០០នាក់រស់នៅក្នុង RCI នៅក្នុងប្រទេសកម្ពុជា ហើយចំនួននេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ។ RCI អាចជាការអន្តរាគមន៍ការពារកុមារជាផ្លូវការធំបំផុតនៅក្នុងប្រទេសកម្ពុជា។

**ការស្រាវជ្រាវបង្ហាញថា នៅក្នុងករណីជាច្រើន សមាជិក គ.ក.ន.ក. បានផ្តល់សេចក្តីណែនាំដល់កុមារ ទៅខាង RCI**

ការស្រាវជ្រាវបង្ហាញថា នៅក្នុងករណីជាច្រើន សមាជិក គ.ក.ន.ក. បានផ្តល់សេចក្តីណែនាំដល់កុមារទៅខាង RCI។ សមាជិក គ.ក.ន.ក. ខ្លះ បានរៀបរាប់អំពីទំនាក់ទំនងនោះថា បានវិវត្តរវាង គ.ក.ន.ក. និង RCI។ គ.ក.ន.ក. នឹងណែនាំគ្រួសារ និងកុមារទៅ RCI ដើម្បីសម្របសម្រួលការទុកដាក់កុមារ ដូចរៀបរាប់ខាងក្រោម

> យើងពិគ្រោះជាមួយកុមារ និងទូន្មានពួកគេ ហើយណែនាំឲ្យពួកគេទៅរក មណ្ឌលកុមារកំព្រាដើម្បីដោះស្រាយបញ្ហា។
>
> សមាជិក គ.ក.ន.ក.

ទំនាក់ទំនងទាំងនេះ អាចធ្វើឲ្យវាកាន់តែឃើញថា គ.ក.ន.ក. នឹងណែនាំឲ្យទុកដាក់នៅ RCI ជាជាងជម្រើសសហគមន៍មូលដ្ឋាន។

ការទុកដាក់នៅ RCI មានផលប៉ះពាល់អវិជ្ជមានក្នុងរយៈពេលវែងជាច្រើន ចំពោះការវិវត្តផ្នែករាងកាយ និងសង្គម (Nelso et al ឆ្នាំ២០០៧, Parket et al. ឆ្នាំ២០១៧, Project Sky ឆ្នាំ២០០៧, Zeanah et al. ឆ្នាំ២០០៥)។ ទោះជាយ៉ាងណា ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា បានរកឃើញថា នៅពេលគ្មានសេវាដទៃទៀតនៅសហគមន៍ផ្តល់ទៅកុមារ RCI អាចផ្តល់ច្រកដ៏ប្រសើរសម្រាប់ទទួលបានការអប់រំ (Whetten ឆ្នាំ២០១៣)។ លទ្ធផលដ៏គួរឲ្យភ្ញាក់ផ្អើលមួយនៃការសិក្សានេះ គឺថា សមាជិក គ.ក.ន.ក. ជាច្រើនក្រុមគ្រួសារ និងកុមារ បានដឹងអំពីផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាននៃការទុកដាក់កុមារនៅ RCI។ ខណៈមានការគាំទ្រយ៉ាងច្រើនចំពោះការទុកដាក់កុមារនៅ RCI អ្នកចូលរួមជាច្រើន ពន្យល់ថា កុមារស្ថិតនៅក្រោមការថែទាំបែបគ្រួសារនេះ នឹងទទួលរងផលប៉ះពាល់ខាងផ្លូវចិត្តកើតចេញពីការបំបែកពួកគេ ពីក្រុមគ្រួសារ និងសហគមន៍។

> យើងពិគ្រោះជាមួយកុមារ និងទូន្មានពួកគេ ហើយណែនាំឲ្យពួកគេទៅប្រសិនបើយើងដាក់កុមារម្នាក់នៅមណ្ឌលកុមារកំព្រា កុមារម្នាក់នោះនឹងអាចសិក្សារៀនសូត្រ។ ប្រសិនបើកុមារម្នាក់នោះរស់នៅជាមួយឪពុកម្តាយ កុមារម្នាក់នោះនឹងមិនបានសិក្សារៀនសូត្រឡើយ។ នៅមណ្ឌលកុមារកំព្រា កុមារម្នាក់នឹងក្លាយជាមនុស្សមានចំណេះដឹង នឹងមានសម្ភារៈសិក្សាគ្រប់គ្រាន់ មានម្ហូបអាហារគ្រប់គ្រាន់...ប៉ុន្តែនៅមណ្ឌលកុមារកំព្រា កុមារម្នាក់នោះមានអារម្មណ៍ថាអស់សង្ឃឹម។ កុមារម្នាក់នោះនឹងខ្លាចថាការថែទាំនៅមណ្ឌលកុមារកំព្រាមិនល្អដូចជាការមើលថែទាំរបស់ឪពុកម្តាយរបស់ពួកគេទេ។ កុមារម្នាក់នោះ នឹងចង់ជួបឪពុកម្តាយរបស់ពួកគេជាថ្មី។
>
> សមាជិក គ.ក.ន.ក

ជារួម គ.ក.ន.ក. បង្ហាញនូវឥរិយាបថទោរទន់ទៅរក RCI និងចាត់ទុក RCI ជាជម្រើសសមរម្យសម្រាប់ការថែទាំកុមារ។ នៅក្នុងករណីខ្លះ គ.ក.ន.ក. ហាក់ដូចជាជំរុញ RCI យ៉ាងសកម្ម។ ជួនកាល ពួកគេដឹងថាការដាក់កុមារនៅ RCI អាចធ្វើឲ្យកុមារមានទុក្ខកង្វល់ច្រើន។ ខណៈការពង្រឹងប្រព័ន្ធដែលអង្គការមិនមែនរដ្ឋាភិបាលបង្ហាញថាទទួលបានភាពជោគជ័យ កំពុងផ្លាស់ប្តូរឥរិយាបថពាក់ព័ន្ធនឹងវិស័យជាច្រើន នៅផ្នែកការពារកុមារនោះ ឥរិយាបថពាក់ព័ន្ធនឹង RCI ហាក់ដូចជានៅដដែលមិនផ្លាស់ប្តូរនោះឡើយ ចាប់តាំងពី Jordanwood (ឆ្នាំ២០១១) បានរកឃើញថា អាជ្ញាធរមូលដ្ឋានភាគច្រើនបានគាំទ្រ RCI។ ការកំណត់សេវានាពេលថ្មីៗពាក់ព័ន្ធនឹងការថែទាំបែបគ្រួសារ បានរកឃើញថា អាជ្ញាធរមូលដ្ឋាន ចាត់ទុកការថែទាំបែបគ្រួសារនេះ ជាជម្រើសសម្រាប់ការថែទាំកុមារ (Fiss និង Matthews ឆ្នាំ២០១៦)។ នេះគឺជាក្តីកង្វល់ពិសេសដែល គ.ក.ន.ក. គាំទ្រការទុកដាក់កុមារនៅ RCI ដោយសារអាជ្ញាធរមូលដ្ឋាន គឺជាអ្នកកម្លាំងសំខាន់សម្រាប់កុមារដែលត្រូវការការពារ។

## កត្តារាំងស្ទះ ឬជំរុញដល់មុខងារ និងប្រសិទ្ធភាពរបស់ គ.ក.ន.ក.

**ទាំងសមាជិក គ.ក.ន.ក. និងភាគីពាក់ព័ន្ធសំខាន់ៗ បានកំណត់កត្តាមួយចំនួន ដែលជះឥទ្ធិពលដល់ មុខងារ និងភាពជោគជ័យរបស់ គ.ក.ន.ក.។**

ទាំងសមាជិក គ.ក.ន.ក. និងភាគីពាក់ព័ន្ធសំខាន់ៗ បានកំណត់កត្តាមួយចំនួន ដែលជះឥទ្ធិពលដល់មុខងារ និងភាពជោគជ័យរបស់ គ.ក.ន.ក.។ កត្តាទាំងនោះ មានក្រិតក្រមស្មុគស្មាញ ពាក់ព័ន្ធនឹងគណនេយ្យភាព និងកង្វះខាតមូលនិធិ។ បុគ្គលិកលក្ខណៈរបស់សមាជិក គ.ក.ន.ក. ជាពិសេសជនបង្គោល ក៏មានសារៈសំខាន់ផងដែរ ហើយកង្វះខាតជំនាញក្នុងចំណោមសមាជិក បានធ្វើឲ្យរាំងស្ទះដល់ប្រសិទ្ធភាពរបស់ គ.ក.ន.ក.។ ប្រសិទ្ធភាពរបស់ គ.ក.ន.ក. បានរាំងស្ទះបន្ថែមទៀតដោយសារតែកង្វះខាត បណ្តាញដ៏ទូលំទូលាយនៃសេវាបង្អែក និងត្រូវបានកម្រិតដោយសារតែទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌។ ទោះជាយ៉ាងណា អន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល ដូចជាការបង្កើតក្រុមកុមារ និងឪពុកម្តាយ ជាមួយនឹងការផ្សារភ្ជាប់យ៉ាងរឹងមាំជាមួយ គ.ក.ន.ក. និងការផ្តល់បុគ្គលិកសង្គមកិច្ចសម្រាប់ធ្វើជាដៃគូជាមួយ គ.ក.ន.ក. បានកែលម្អប្រសិទ្ធិភាព ដូចដែលពិភាក្សាខាងក្រោម។

### ភាពប្រឈមរបស់ គ.ក.ន.ក ក្នុងការបំពេញការងារ ដូចដែលរាយការណ៍ដោយសមាជិក គ.ក.ន.ក




ក្រាហ្វ ៥៖ ភាពប្រឈមរបស់ គ.ក.ន.ក ក្នុងការបំពេញការងារ ដូចដែលរាយការណ៍ដោយសមាជិក គ.ក.ន.ក

## ៧.១ ឥទ្ធិពលនៃគណនេយ្យភាពសាំញ៉ាំ

សមាជិក គ.ក.ន.ក. ត្រូវមានទំនួលខុសត្រូវចំពោះក្រសួងនានា ហើយកត្តាធ្វើឲ្យរាំងស្ទះដល់ប្រសិទ្ធភាពនៃគណៈកម្មាធិការ។ នៅក្នុងឃុំ/សង្កាត់មួយចំនួន គ.ក.ន.ក. ពិនិត្យមើលពលកម្មកុមារ ដែលត្រូវរាយការណ៍ទៅក្រសួង MoLVT។ សមាជិក គ.ក.ន.ក. ត្រូវបានជ្រើសរើសពីក្រុមប្រឹក្សាឃុំ សង្កាត់ នគរបាល សាលារៀន និងមណ្ឌលសុខភាព។ សមាជិកទាំងនេះ មានទំនួលខុសត្រូវចំពោះក្រសួងមហាផ្ទៃ ក្រសួងអប់រំ និងក្រសួងសុខាភិបាល។ អ្នកចូលរួម បានរាយការណ៍ថា សមាជិកទាំងនេះ តែងតែចាត់ទុកការចូលរួមក្នុង គ.ក.ន.ក. ជាភារកិច្ចបំពេញបន្ថែម ហើយមិនបានវិនិយោគទៅក្នុងការជំរុញការការពារកុមារឡើយ។ ជនបង្គោល គឺជាសមាជិកសំខាន់ នៃគណៈកម្មាធិការដែលធ្វើការសម្រាប់ គ.ក.ន.ក. នោះ គឺជាភារកិច្ចសំខាន់របស់ពួកគេ ហើយជនបង្គោលមួយចំនួនដែលបានសម្ភាស បានពន្យល់ថា ពួកគេមានអារម្មណ៍ទទួលខុសត្រូវខ្លាំងលើការអនុវត្តសកម្មភាព ហើយថាសមាជិកដទៃទៀតអនុវត្តតិចតួចលើសពីការចូលរួមប្រជុំ។ បញ្ហាមួយផ្សេងទៀត គឺថា គ.ក.ន.ក. រាយការណ៍ទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលនឹងរាយការណ៍បន្តទៅក្រសួងមហាផ្ទៃ។ ក្រសួងមហាផ្ទៃ មានភារកិច្ចខាងរដ្ឋបាលអភិបាលកិច្ច និងការការពារថ្នាក់ជាតិ ហើយមិនបានផ្តោតលើការការពារកុមារនោះឡើយ។ MoSVY ទទួលខុសត្រូវសម្រាប់ការការពារកុមារ ប៉ុន្តែ មិនមែនជាស្ថាប័នអនុវត្តនៅថ្នាក់ឃុំ/សង្កាត់នោះឡើយ។ ខណៈដែល គ.ក.ន.ក. ជាច្រើនកត់សម្គាល់ពីកិច្ចសហការជាមួយមន្ត្រី DOSVY កិច្ចសហការទាំងនេះត្រូវបានកំណត់ត្រឹមការផ្តល់ជំនួយសម្រាប់ករណីដាច់ដោយឡែក។ ក្រុមមន្ត្រី DOSVY ហាក់មិនបានដើរតួនាទីសកម្មនៅក្នុងការការពារកុមារតាមរយៈ គ.ក.ន.ក. នោះឡើយ ហើយ គ.ក.ន.ក. ហាក់ដូចជាមិនទទួលបានអត្ថប្រយោជន៍ពីជំនាញរបស់ DOSVY ឡើយ។

វាគឺជាបញ្ហាធម្មតាសម្រាប់ប្រព័ន្ធការពារកុមារ ក្នុងការចូលពាក់ព័ន្ធក្នុងកម្រិតទូលាយលើភាគីពាក់ព័ន្ធ។ ប្រព័ន្ធការពារកុមារប្រកបដោយប្រសិទ្ធិភាពមួយ អាស្រ័យលើវិសាលភាពនៃភាគីពាក់ព័ន្ធ ដែលតែងតែមានភាគីមកពីវិស័យអប់រំ យុត្តិធម៌ និងសុខាភិបាល (Wessells ឆ្នាំ២០០៩)។ ឧបសគ្គដែល គ.ក.ន.ក. ជួបប្រទះ គឺថា បុគ្គលិកមកពីវិស័យដទៃទៀត ត្រូវបានចាត់តាំងមក គ.ក.ន.ក. ខណៈភារកិច្ចបន្ថែមមិនត្រូវបានថ្នាក់លើរបស់ពួកគេ ត្រួតពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពនោះឡើយ។ ភាពស្មុគស្មាញនៃក្រឹតក្រមគណនេយ្យភាពដែលសមាជិក គ.ក.ន.ក. ត្រូវតែមាន គឺជាបញ្ហាដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការមុខងារ។

## ៧.២ ឥទ្ធិពលនៃមូលនិធិ

កង្វះខាតមូលនិធិសម្រាប់ គ.ក.ន.ក. បានកើតឡើងជាថ្មីនៅក្នុងទិន្នន័យ។ ៣០/៣០ គ.ក.ន.ក. បានលើកឡើងអំពីការខ្វះខាតថវិកា។ អ្នកចូលរួមមួយចំនួន កត់សម្គាល់ថា កង្វះខាតប្រាក់បៀវត្សរ៍សមរម្យសម្រាប់បំពេញការងារពេញលេញសម្រាប់ គ.ក.ន.ក. បានធ្វើឲ្យរាំងស្ទះដល់ប្រសិទ្ធភាពការងារ។ ជនបង្គោលរបស់ គ.ក.ន.ក. គឺសមាជិកមួយរូបនៅក្រុមប្រឹក្សាឃុំ/សង្កាត់ ហើយស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាតរូបនោះ ទទួលប្រាក់បៀវត្សរ៍តាមរយៈគណៈកម្មាធិការ នោះ។ សមាជិកដទៃទៀតនៃ គ.ក.ន.ក. ត្រូវបានតែងតាំងចេញពីមណ្ឌលសុខាភិបាល សាលារៀន និងមន្ទីរពេទ្យ ហើយពួកគេទទួលបានប្រាក់ខែតាមរយៈស្ថាប័នរបស់ពួកគេ។ ពុំមានសមាជិក គ.ក.ន.ក. ណាម្នាក់ ដែលទទួលប្រាក់បៀវត្សរ៍ដាច់ដោយឡែកសម្រាប់បំពេញការងារឲ្យ គ.ក.ន.ក. នោះឡើយ ហើយអ្នកចូលរួមជាច្រើន និយាយថា ជាលទ្ធផលការងាររបស់ គ.ក.ន.ក.ត្រូវបានចាត់ទុកជាការងារស្ម័គ្រចិត្ត ឬការងារបន្ថែម។ ជាងនេះទៅទៀត ជនបង្គោលជាច្រើនរបស់ គ.ក.ន.ក. និយាយថា ប្រាក់ខែរបស់ពួកគាត់ មិនគ្រប់គ្រាន់សម្រាប់ការផ្គត់ផ្គង់លើការចំណាយរស់នៅរបស់ពួកគាត់ឡើយ។

បញ្ហាទីពីរដែលទាក់ទងនឹងមូលនិធិ គឺកង្វះខាតថវិកាគ្រប់គ្រាន់សម្រាប់ការចំណាយលើប្រតិបត្តិការ។ គ.ក.ន.ក. ទទួលបានថវិកាប្រចាំឆ្នាំតិចតួចសម្រាប់ចំណាយផ្នែករដ្ឋបាល ប៉ុន្តែ គ.ក.ន.ក. ភាគច្រើនត្អូញត្អែថា ពួកគេខ្វះខាតមូលនិធិគ្រប់គ្រាន់សម្រាប់អនុវត្តភារកិច្ចរបស់ពួកគេ។ សមាជិក គ.ក.ន.ក. និយាយថា ពួកគេខ្វះខាតកុំព្យូទ័រ ថវិកាសម្រាប់អាហារសម្រន់ និងថវិកាសម្រាប់ទិញសម្ភារៈការិយាល័យ។ បញ្ហាដែលគេលើកឡើងញឹកញាប់បំផុត គឺកង្វះខាតថវិកាសម្រាប់ថ្លៃប្រេងឥន្ធនៈ។ គ.ក.ន.ក. បច្ចុប្បន្ននេះ កំពុងធ្វើការផ្នែកតស៊ូមតិ ឃ្លាំមើល និងផ្តល់សេវា ហើយកិច្ចការនីមួយៗ ទាមទារ

ឲ្យសមាជិក គ.ក.ន.ក. ធ្វើដំណើរទៅចូលរួមប្រជុំ និងជួបគ្រួសារងាយរងគ្រោះ។ ដោយសារពុំមានមូលនិធិគ្រប់គ្រាន់សម្រាប់ចំណាយលើមធ្យោបាយ ធ្វើដំណើរ សមាជិក គ.ក.ន.ក. ពុំអាចបំពេញភារកិច្ចរបស់ពួកគេបាននោះឡើយ។

បញ្ហាទីបីទាក់ទងនឹងមូលនិធិ គឺកង្វះខាតថវិកាសម្រាប់ផ្តល់សេវា។ នៅក្នុងគោលនយោបាយ (RGC ឆ្នាំ២០០៨) គ.ក.ន.ក. មិនមានភារកិច្ចអនុវត្តសេវាទាំងនោះទេ។ ដូចបានកត់សម្គាល់ពីខាងលើ (នៅក្នុង គ.ក.ន.ក. ផ្ញើទៅ និងថវិកានៃសេវាការពារកុមារ) សមាជិកបាន និងកំពុងចាប់ផ្តើមអនុវត្តការផ្តល់សេវាដល់គ្រួសារងាយរងគ្រោះ ជាការឆ្លើយតបទៅនឹងការជំរុញតាមរយៈដៃគូអង្គការមិនមែនរដ្ឋាភិបាល និងសំណើសុំជំនួយពីសមាជិកសហគមន៍។ ដោយសារ MoSVY ពុំមានភ្នាក់ងារអនុវត្តនៅថ្នាក់ឃុំ/សង្កាត់ គ.ក.ន.ក. បាន និងកំពុងមានបំណងបំពេញកង្វះចន្លោះនេះ។ គ.ក.ន.ក. ទទួលបានមូលនិធិខ្លះពីកញ្ចប់ថវិកាក្រុមប្រឹក្សាឃុំ/សង្កាត់ ប៉ុន្តែ ដោយសារតែមូលនិធិនេះត្រឹម ៣-៤ភាគរយប៉ុណ្ណោះ ត្រូវបានចំណាយលើសេវាសង្គមនោះ គ.ក.ន.ក. នៅតែមានកង្វះចន្លោះដ៏សំខាន់នេះ (Ramage ឆ្នាំ២០១៤)។ បើទោះបីជាមានមូលនិធិ ឬមូលនិធិត្រូវបានផ្តល់ឲ្យតាមរយៈអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ក៏កង្វះខាតមូលនិធិសម្រាប់ការផ្តល់សេវាបានកើតឡើងដដែលៗ។

## ៧.៣ ឥទ្ធិពលនៃការទទួលសេវាការពារកុមារ

**ខណៈដែល គ.ក.ន.ក. មួយចំនួន ជាអ្នកចូលរួមក្នុងការកំណត់សេវាសំខាន់ៗនោះ ភាគច្រើន ការសម្រេចនានាពាក់ព័ន្ធនឹងការផ្តល់សេវារបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានធ្វើឡើងដោយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ សមាជិក គ.ក.ន.ក. មានការចូលរួមតិចតួចពាក់ព័ន្ធនឹងសេវាដែលផ្តល់នៅសហគមន៍របស់ពួកគេ។**

ការស្រាវជ្រាវនេះ រកឃើញថា គ.ក.ន.ក. តែងតែពឹងផ្អែកលើកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្សារភ្ជាប់គ្រួសារទៅនឹងការផ្តល់សេវា។ ដូចបានកត់សម្គាល់ខាងលើ ប្រទេសកម្ពុជាពុំមានបណ្តាញសេវារដ្ឋាភិបាលថ្នាក់ជាតិសម្រាប់ផ្តល់សេវាសង្គមកិច្ចនោះឡើយ ហើយអង្គការមិនមែនរដ្ឋាភិបាល តែងតែធ្វើជាអ្នកផ្តល់សេវាសង្គមសំខាន់នៅថ្នាក់ឃុំ/សង្កាត់ និងថ្នាក់ភូមិ។ ខណៈដែល គ.ក.ន.ក. មួយចំនួនជាអ្នកចូលរួមក្នុងការកំណត់សេវាសំខាន់ៗនោះ ភាគច្រើន ការសម្រេចនានាពាក់ព័ន្ធនឹងការផ្តល់សេវារបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានធ្វើឡើងដោយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ សមាជិក គ.ក.ន.ក. មានការចូលរួមតិចតួចពាក់ព័ន្ធនឹងសេវាដែលផ្តល់នៅសហគមន៍របស់ពួកគេ។ នៅពេលសមាជិកសហគមន៍ទៅស្នើសុំសេវាពី គ.ក.ន.ក. សមាជិក គ.ក.ន.ក. បានត្រឹមផ្សារភ្ជាប់ពួកគេទៅទទួលសេវាដែលអង្គការមិនមែនរដ្ឋាភិបាល ជ្រើសរើសផ្តល់ឲ្យប៉ុណ្ណោះ។ អង្គការមិន មែនរដ្ឋាភិបាលភាគច្រើន ធ្វើការនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ និងក្រុមគោលដៅជាក់លាក់។ នេះមានន័យថា ប្រសិនបើបញ្ហាការការពារកុមារត្រូវបាននាំយកទៅ គ.ក.ន.ក. ហើយពុំមានអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាទាំងនេះនៅក្នុងសហគមន៍នោះទេ គ.ក.ន.ក. អាចមិនមានលទ្ធភាពជួយបាននោះឡើយ។

**ការឆ្លើយតបរបស់ គ.ក.ន.ក. ឬជនបង្គោល នៅមានកម្រិតមិនត្រឹមតែដោយសារតែលទ្ធភាពនៃការផ្តល់សេវានោះឡើយ ប៉ុន្តែ វាក៏ដោយសារតែចំណេះដឹងផ្នែកសេវារបស់សមាជិក គ.ក.ន.ក. ផ្ទាល់ផងដែរ។**

ការឆ្លើយតបរបស់ គ.ក.ន.ក. ឬជនបង្គោល នៅមានកម្រិតមិនត្រឹមតែដោយសារតែលទ្ធភាព នៃការផ្តល់សេវានោះឡើយ ប៉ុន្តែ វាក៏ដោយសារតែចំណេះដឹងផ្នែកសេវារបស់សមាជិក គ.ក.ន.ក. ផ្ទាល់ផងដែរ។ សមាជិក គ.ក.ន.ក. ហាក់មិនមានច្រកទទួលបានទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាលទេ ប៉ុន្តែផ្ទុយទៅវិញ ពួកគេពឹងផ្អែកទៅលើទំនាក់ទំនងផ្ទាល់ដែលមានស្រាប់ជាមួយអង្គការមិនមែនរដ្ឋាភិបាល។ ប្រសិទ្ធភាពរបស់ គ.ក.ន.ក. ក្នុងការផ្សារភ្ជាប់ស្ត្រី និងគ្រួសារឲ្យទទួលបានសេវានៅមានកម្រិតដោយសារបញ្ហាទាំងអស់នេះ។

## ៧.៤ ឥទ្ធិពលនៃសមត្ថភាពសមាជិក គ.ក.ន.ក.

**សមត្ថភាពរបស់សមាជិក រាំងស្ទះដល់ប្រសិទ្ធភាពនៃ គ.ក.ន.ក.។**

សមត្ថភាពរបស់សមាជិក រាំងស្ទះដល់ប្រសិទ្ធភាពនៃ គ.ក.ន.ក.។ ទោះបីជា ២៨/៣០ បានទទួលការបណ្តុះបណ្តាលក៏ដោយ ក៏ គ.ក.ន.ក. ២៨/៣០ បាននិយាយថា ពួកគេនៅខ្វះជំនាញដែរ។ កម្រិតជំនាញទាបក្នុងចំណោមសមាជិក គ.ក.ន.ក. ត្រូវបានកត់សម្គាល់នៅក្នុងការសិក្សាមុនៗ (Gamer និង Mauney ឆ្នាំ២០០៩, VBNK ឆ្នាំ២០១០) ហើយនៅក្នុងកិច្ចសម្ភាស អ្នកផ្តល់ព័ត៌មានសំខាន់ៗ បានកត់សម្គាល់ថា សមាជិក គ.ក.ន.ក. មួយចំនួន គឺជាអនក្ខរជន។ សមាជិក គ.ក.ន.ក. ទាំងអស់ដែលចូលរួមក្នុងការពិភាក្សាក្រុមគោលដៅ អាចចេះអក្សរ ប៉ុន្តែសមាជិកជាច្រើនខ្វះជំនាញដទៃទៀត ជាពិសេសជំនាញសង្គមកិច្ច។

**សមត្ថភាពកំណត់អត្តសញ្ញាណការរំលោភបំពានការការពារកុមារ និងយល់ដឹងអំពីវិធីឆ្លើយតបនឹងការរំលោភបំពាននេះ គឺចាំបាច់សម្រាប់ការបំពេញតួនាទីទាំងនេះដោយប្រសិទ្ធភាព។**

**សមាជិក គ.ក.ន.ក. មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីការរំលោភបំពាន ប៉ុន្តែពុំមានជំនាញគ្រប់គ្រាន់ក្នុងការយល់ដឹងអំពីវិធីឆ្លើយតបប្រកបដោយភាពសមរម្យនោះឡើយ។**

នៅក្នុងគោលនយោបាយ គ.ក.ន.ក. មានភារកិច្ចផ្តល់ការលើកកម្ពស់ការយល់ដឹង និងតស៊ូមតិ ព្រមទាំងធ្វើការដើម្បីកែលម្អទំនាក់ទំនង ធ្វើការសម្របសម្រួល និងសហការគ្នារវាងក្រុមប្រឹក្សាឃុំ/សង្កាត់ អ្នកផ្តល់សេវា និងសមាជិកសហគមន៍ ដើម្បីគាំទ្រស្ត្រី និងកុមារ។ សមត្ថភាពកំណត់អត្តសញ្ញាណការរំលោភបំពានការការពារកុមារ និងយល់ដឹងអំពីវិធីឆ្លើយតបនឹងការរំលោភបំពាននេះ គឺចាំបាច់សម្រាប់ការបំពេញតួនាទីទាំងនេះ ដោយប្រសិទ្ធភាព។ សមាជិក គ.ក.ន.ក. ភាគច្រើន បានរៀបរាប់អំពីតួនាទីរបស់ គ.ក.ន.ក. ប្រកបទៅដោយសមត្ថភាព ហើយនៅពេលគេសាកសួរអំពីសេណារីយ៉ូសម្មតិកម្ម ដូចបានរៀបរាប់ ការឆ្លើយតប បានផ្តោតទៅលើការផ្តល់សេវា ឬការកាត់ទោសជនល្មើស។ ទោះជាយ៉ាងណាស្ទើរតែគ្មានសមាជិក គ.ក.ន.ក. ណាម្នាក់ រៀបរាប់អំពីកិច្ចអន្តរាគមន៍សង្គមកិច្ចដ៏ស្មុគស្មាញនោះឡើយ ដូចជា ការព្យាបាល ជាដើម ហើយដូចបានកត់សម្គាល់ពីចំណុចខាងលើហើយថា សមាជិក គ.ក.ន.ក. បានជ្រើសរើសយកការផ្សះផ្សារ ដោយមិនបានពិចារណាពេញលេញ លើការការពារជនរងគ្រោះនោះឡើយ។ សមាជិក គ.ក.ន.ក. មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីការរំលោភបំពាន ប៉ុន្តែពុំមានជំនាញគ្រប់គ្រាន់ក្នុងការយល់ដឹងអំពីវិធីឆ្លើយតបប្រកបដោយភាពសមរម្យនោះឡើយ។

**គ.ក.ន.ក. មិនមានភារកិច្ចផ្តល់សេវាសង្គមកិច្ចនោះឡើយ ប៉ុន្តែ បានចូលអន្តរាគមន៍ជាបន្តបន្ទាប់ក្នុងករណីរំលោភបំពានក្នុងគ្រួសារ ជាផ្នែកមួយដែលពួកគេពុំមានជំនាញ។**

**ប្រសិនបើ អង្គការមិនមែនរដ្ឋាភិបាល បន្តពង្រឹងប្រព័ន្ធការពារកុមារតាមរយៈ គ.ក.ន.ក. ពួកគេគួរតែដោះស្រាយកង្វះខាតសមត្ថភាពការការពារកុមារនៅ គ.ក.ន.ក. និងពិចារណាការពង្រីកគំរូ ដែលជួលមូលនិធិដល់បុគ្គលិកសង្គមនៅក្នុងសហគមន៍ដែលគាំទ្រ គ.ក.ន.ក.។**

គ.ក.ន.ក. មិនមានភារកិច្ចផ្តល់សេវាសង្គមកិច្ចនោះឡើយ ប៉ុន្តែបានចូលអន្តរាគមន៍ជាបន្តបន្ទាប់ ក្នុងករណីរំលោភបំពានក្នុងគ្រួសារ ជាផ្នែកមួយដែលពួកគេពុំមានជំនាញ។ នៅក្នុងប្រទេសកម្ពុជាទាំងមូលពុំមានបុគ្គលិកសង្គម ដែលទទួលបានការបណ្តុះបណ្តាលនោះឡើយ ហើយមនុស្សភាគច្រើនដែលជ្រើសរើសឲ្យធ្វើជាបុគ្គលិកសង្គមកិច្ច មិនទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនោះឡើយ (Harachi ឆ្នាំ២០១៤)។ ហេតុនេះ វាមិនគួរឲ្យភ្ញាក់ផ្អើលនោះឡើយនៅពេលរកឃើញថា ជំនាញផ្នែកសង្គមកិច្ចរបស់សមាជិក គ.ក.ន.ក. នៅមានកម្រិតនោះ ជាពិសេសដោយសារតែការផ្តល់សេវា មិនស្ថិតក្នុងអាណត្តិរបស់រដ្ឋាភិបាលពួកគេ។ ជាងនេះទៅទៀត គេត្រូវតែកត់សម្គាល់ផងដែរថា ការការពារសង្គមគឺជាវិស័យមួយដែលមានលក្ខណៈស្មុគស្មាញ ហើយអ្នកប្រតិបត្តិជាទូទៅ ប្រឈមទៅនឹងការស្វែងរកដំណោះស្រាយ។ ទោះជាយ៉ាងណា គ.ក.ន.ក. កំពុងទទួលយកតួនាទីផ្តល់ការគាំទ្រ នៅក្នុងករណីស្មុគស្មាញ ជាមួយការបណ្តុះបណ្តាលកម្រិតអប្បរមា។ ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលបន្តពង្រឹងប្រព័ន្ធការពារកុមារតាមរយៈ គ.ក.ន.ក. ពួកគេគួរតែដោះស្រាយកង្វះខាតសមត្ថភាពការការពារកុមារនៅ គ.ក.ន.ក. និងពិចារណាការពង្រីកគំរូដែលជួលមូលនិធិដល់បុគ្គលិកសង្គមនៅក្នុងសហគមន៍ដែលគាំទ្រ គ.ក.ន.ក.។

## ៧.៥ ឥទ្ធិពលនៃកង្វះខាតការជឿជាក់លើប្រព័ន្ធយុត្តិធម៌

**ការឆ្លើយតបទៅតាមការគិត និងការឆ្លើយតបជាក់ស្តែង នៅមានគម្លាតនៅឡើយ។ អ្នកចូលរួមជាច្រើន បានដាក់បន្ទុកថាគម្លាតនេះ ដោយសារតែកង្វះការជឿជាក់លើប្រព័ន្ធយុត្តិធម៌។**

នៅពេលសាកសួរឲ្យធ្វើការពិចារណាលើស្ថានការណ៍សម្មតិកម្មពាក់ព័ន្ធនឹងការរំលោភបំពានរាងកាយ និងផ្លូវភេទកុមារ សមាជិក គ.ក.ន.ក. ភាគច្រើន គ្រួសារ និងដៃគូអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់អនុសាសន៍ឲ្យរាយការណ៍ករណីនោះទៅអាជ្ញាធរមូលដ្ឋាន និងកាត់ទោសជនដៃដល់។ ទោះជាយ៉ាងណា អ្នកទាំងឡាយដែលរាយការណ៍ស្ថានការណ៍ស្រដៀងគ្នានេះ នៅក្នុងសហគមន៍របស់ពួកគេ បានពន្យល់ថា ករណីទាំងនេះ តែងតែមិនត្រូវបានគេរាយការណ៍ និងកាត់ទោសនោះឡើយ។ ការឆ្លើយតបទៅតាមការគិត និងការឆ្លើយតបជាក់ស្តែង នៅមានគម្លាតនៅឡើយ។ អ្នកចូលរួមជាច្រើន បានដាក់បន្ទុកថាគម្លាតនេះដោយសារតែកង្វះការជឿជាក់លើប្រព័ន្ធយុត្តិធម៌។ អ្នកចូលរួមកត់សម្គាល់ថា ការវិនិច្ឆ័យករណីមួយ ចំណាយលុយច្រើន។ អ្នកចូលរួមម្នាក់ បានចាត់ទុកនគរបាលជាបុគ្គលគ្មានឆន្ទៈ ចំពោះការធ្វើដំណើរទៅមើលគ្រួសារក្រីក្រងាយរងគ្រោះ ហើយបានកត់សម្គាល់នូវអារម្មណ៍ពេញចិត្ត ចំពោះអំពើហិង្សាក្នុងគ្រួសារ។ អ្នកចូលរួមម្នាក់ទៀត បានកត់សម្គាល់ថា នគរបាលពុំមានជំនាញ និងឧបករណ៍សម្ភារៈសម្រាប់ប្រមូលភស្តុតាងវិទ្យាសាស្ត្រនៅក្នុងករណីរំលោភសេពសន្ថវៈ ឬករណីរំលោភបំពានផ្លូវភេទនោះឡើយ។ ការសិក្សាមុនៗ បានរកឃើញថា នគរបាលមិនត្រឹមតែខ្វះជំនាញសម្រាប់អនុវត្តការស៊ើបអង្កេតបែបនេះប៉ុណ្ណោះទេ ប៉ុន្តែនគរបាលក៏មិនបានការពារភាពសម្ងាត់របស់ជនរងគ្រោះផងដែរ (Rosas ឆ្នាំ២០១២)។ អ្នកចូលរួមម្នាក់ បានគាំទ្រការរាយការណ៍ករណីរំលោភបំពានក្នុងគ្រួសារ ប៉ុន្តែនៅពេលសាកសួរថា ហេតុអ្វីបានជាករណីមួយ មិនត្រូវបានគេរាយការណ៍នោះ អ្នកចូលរួមនោះបានពន្យល់ថា ជនរងគ្រោះរស់នៅដាច់ឆ្ងាយពី គ.ក.ន.ក. និងនគរបាលដែលអាចទាក់ទងពួកគេឲ្យស៊ើបអង្កេត។ ចុងក្រោយ អ្នកចូលរួមមួយចំនួនជឿថា បើទោះបីជាករណីមួយត្រូវបាននាំទៅតុលាការក៏ដោយ ក៏ជនដៃដល់ នឹងមិនត្រូវគេកាត់ទោសដែរដោយសារតែអំពើពុករលួយ។ ចំណុចសំខាន់ដែលគួរឲ្យ

កត់សម្គាល់គឺថា សមាជិក គ.ក.ន.ក. បានចែករំលែករឿងរ៉ាវនានា ដែលក្នុងនោះជនល្មើសត្រូវបាន និន្ទ័យទោស និងកាត់ទោសទាំងពីបទរំលោភ និងការរំលោភបំពានរាងកាយកម្រិតស្រាល។ ទោះជាយ៉ាងណា ជារួមកង្វះជំនឿលើប្រព័ន្ធយុត្តិធម៌ បានធ្វើឲ្យរាំងស្ទះដល់ប្រសិទ្ធភាពរបស់ គ.ក.ន.ក. ក្នុងការជំរុញការវិនិច្ឆ័យទោស។

## ៧.៦ ឥទ្ធិពលនៃវត្តមាន និងការចូលរួមនៅ គ.ក.ន.ក.

**ការប្រមូលទិន្នន័យ បានរកឃើញថា គ.ក.ន.ក. មិនត្រូវបានប្រជាជនទូទៅស្គាល់ច្បាស់នោះឡើយ។**

**ខណៈដែល គ.ក.ន.ក. អាចកំណត់អត្តសញ្ញាណគ្រួសារងាយរងគ្រោះតាមរយៈការចុះជួបផ្ទាល់នោះ សមាជិកសហគមន៍នានា ហាក់មិនជួបនឹង គ.ក.ន.ក. ដោយខ្លួនគេផ្ទាល់ឡើយ។**

ការប្រមូលទិន្នន័យ បានរកឃើញថា គ.ក.ន.ក. មិនត្រូវបានប្រជាជនទូទៅស្គាល់ច្បាស់នោះឡើយ។ អ្នកស្រាវជ្រាវបានរកឃើញថា នៅក្នុងការប្រមូលទិន្នន័យ ពួកគេតែងតែតម្រូវឲ្យពន្យល់ថា តើ គ.ក.ន.ក. ធ្វើអ្វីសម្រាប់កុមារ និងគ្រួសារនៅក្នុងការពិភាក្សាក្រុមគោលដៅ។ ដូចបានកត់សម្គាល់ពីចំណុចខាងលើហើយថា (នៅក្នុងការប្រមូលព័ត៌មានអំពីស្ត្រី និងកុមារដែលបានដឹងពីការបែងចែកសេវា)នោះ កុមារពីរបីនាក់បានស្គាល់ គ.ក.ន.ក.។ ការរកឃើញនេះអាចឲ្យគេពន្យល់បានថា ខណៈដែល គ.ក.ន.ក. អាចកំណត់អត្តសញ្ញាណគ្រួសារងាយរងគ្រោះតាមរយៈការចុះជួបផ្ទាល់នោះ សមាជិកសហគមន៍នានា ហាក់មិនជួបនឹង គ.ក.ន.ក. ដោយខ្លួនគេផ្ទាល់ឡើយ។

**សមាជិក គ.ក.ន.ក. ជាច្រើន បានកត់សម្គាល់ឃើញថា កិច្ចប្រជុំរបស់ គ.ក.ន.ក. ពុំមានវត្តមានត្រឹមត្រូវនោះឡើយ ហើយបញ្ហានេះបានធ្វើឲ្យ ប្រសិទ្ធិភាពរបស់ គ.ក.ន.ក. នៅមានកម្រិត។**

សមាជិក គ.ក.ន.ក. ជាច្រើន បានកត់សម្គាល់ឃើញថា កិច្ចប្រជុំរបស់ គ.ក.ន.ក. ពុំមានវត្តមានត្រឹមត្រូវនោះឡើយ ហើយបញ្ហានេះបានធ្វើឲ្យប្រសិទ្ធិភាពរបស់ គ.ក.ន.ក. នៅមានកម្រិត។ Ramage (ឆ្នាំ២០១៥) បានរកឃើញថាការចូលរួមរបស់ពលរដ្ឋនៅក្រុមប្រឹក្សាឃុំ/សង្កាត់ មានកម្រិតខ្ពស់ ដោយមានអ្នកចូលរួមប្រហែល ២ភាគ៣នៃសំណាកដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ បានចូលរួមក្នុងកិច្ចប្រជុំម្តងកាលពីឆ្នាំមុន។ ទោះបីជារឿងនេះគឺជាការពិតក្នុងករណីមួយចំនួនក៏ដោយ ក៏អ្នកចូលរួមជាច្រើននៅក្នុងការសិក្សានេះរាយការណ៍ថា កិច្ចប្រជុំរបស់ គ.ក.ន.ក. ជាញឹកញាប់មានការចូលរួមតិចតួច។

ដូចដែលបានកត់សម្គាល់ខាងលើរួចមកហើយថា គ.ក.ន.ក. មិនត្រូវបានគេស្គាល់ទូលំទូលាយនោះឡើយ ហើយរឿងនេះ អាចជាមូលហេតុសំខាន់បំផុតសម្រាប់វត្តមានដ៏តិចតួចនេះ។ បន្ថែមពីនេះទៅទៀតនោះ អ្នកចូលរួមបានកត់សម្គាល់ថា គ្រួសារទាំងនោះមានកម្រិតជីវភាពក្រីក្រ និងត្រូវយ៉ាងលំបាកលំបិនដើម្បីជួយខ្លួនឯង ដូច្នេះពួកគេមិនមានពេលវេលាទំនេរដើម្បីចូលរួមកិច្ចប្រជុំឡើយ។

ការត្អូញត្អែរជាទូទៅមួយទៀត គឺថា ប្រជាជនដែលបានចូលរួមកិច្ចប្រជុំរបស់ គ.ក.ន.ក. នោះមិនមែនជាអ្នកចូលរួមដោយសុទ្ធចិត្តនោះឡើយ។ សមាជិក គ.ក.ន.ក. ជាច្រើន ជនបង្គោល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បានពន្យល់ថា កិច្ចប្រជុំនានា នឹងត្រូវបានគេរៀបចំឡើងដើម្បីធ្វើការតស៊ូមតិ ឬផ្តល់មតិយោបល់ដល់ក្រុមគោលដៅជាក់លាក់ និងថា ក្រុមទាំងនេះ នឹងមិនចូលរួមឡើយ។

**ប្រសិនបើយើងធ្វើការងារអំពើហិង្សាក្នុងគ្រួសារជាក្រុម យើងអញ្ជើញប្តីឲ្យចូលរួម ប៉ុន្តែប្រពន្ធមកជំនួស ហើយប្រសិនបើយើងធ្វើការជាក្រុមអំពីការពន្យារកំណើត យើងអញ្ជើញស្ត្រីជាម្តាយ ប៉ុន្តែដីដូនមកជំនួសទៅវិញ។**

**សមាជិក គ.ក.ន.ក.**

**នៅក្នុងឧទាហរណ៍ជាច្រើន សមាជិក គ.ក.ន.ក. ពន្យល់ថា មនុស្ស ដែលមានពេលទំនេរចូលរួមប្រជុំ គឺកម្រជាមនុស្សដែលក្រុម គ.ក.ន.ក. ចង់គ្របដណ្តប់លើណាស់។**

សមាជិក គ.ក.ន.ក. ដែលបានកំណត់យកគ្រួសារចំណាកស្រុកនោះ នឹងរកឃើញថា ពួកគេមិនអាចទាក់ទងគ្រួសារទាំងនេះបានទេ ដោយសារពួកគេរវល់ធ្វើការងារ ឬក៏បានចាកចេញពីប្រទេសទៅហើយ។ សមាជិក គ.ក.ន.ក. ដែលកំណត់ថាបុរសជាអ្នករំលោភបំពាននោះ នឹងយល់ថា ពួកគេកំពុងធ្វើការងារ ឬគ្មានឆន្ទៈក្នុងការចូលរួមប្រជុំនោះឡើយ។ នៅក្នុងឧទាហរណ៍ជាច្រើន សមាជិក គ.ក.ន.ក. ពន្យល់ថា មនុស្សដែលមានពេលទំនេរចូលរួមប្រជុំ គឺកម្រជាមនុស្សដែលក្រុម គ.ក.ន.ក. ចង់គ្របដណ្តប់លើណាស់។

**អ្នកចូលរួមកត់សម្គាល់ថា កុមារ ជាពិសេស ហាក់មិនចង់ចែករំលែកមតិយោបល់នៅក្នុងកិច្ចប្រជុំឡើយ។**

បន្ថែមលើនេះ សមាជិក គ.ក.ន.ក. មួយចំនួនកត់សម្គាល់ថា ការចូលរួមក្នុងកិច្ចប្រជុំមានកម្រិត។ Ramage (ឆ្នាំ២០១៥) បានរកឃើញថា បើទោះបីជាពីរភាគបីនៃមនុស្ស បានចូលរួមជាប្រក្រតីក្នុងកិច្ចប្រជុំ របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ក៏ដោយ ក៏មានមនុស្សត្រឹមមួយភាគបួនប៉ុណ្ណោះដែលបានចូលរួម ប្រជុំយ៉ាងសកម្ម។ ស្ថានភាពប្រហាក់ប្រហែលគ្នានេះ បានកើតឡើងនៅ គ.ក.ន.ក.។ អ្នកចូលរួមកត់សម្គាល់ថា កុមារ ជាពិសេស ហាក់មិនចង់ចែករំលែកមតិយោបល់នៅក្នុងកិច្ចប្រជុំឡើយ។ ក្នុងកម្រិតខ្លះ រឿងនេះអាចដោយសារតែតម្លៃវប្បធម៌បុរាណរបស់កម្ពុជា ដែលមិនជំរុញឲ្យមនុស្សនិយាយ។ Jordanwood (ឆ្នាំ២០០៥) បានរកឃើញថា កុមារត្រឹមតែពីរភាគរយប៉ុណ្ណោះក្នុងចំណោមសិស្សសាលា ធ្លាប់ត្រូវបានគេប្រាប់ឲ្យបញ្ចេញមតិនៅក្នុងសាលារៀន។ ស្រដៀងគ្នានេះដែរ Gourley (ឆ្នាំ២០០៩) បានរកឃើញថា ប្រព័ន្ធអាណាព្យាបាលបុរាណ មិនស៊ីគ្នានឹងគោលបំណងផ្តល់អំណាចដល់ការចូលរួមរបស់ UNCRC នោះឡើយ។ នេះគឺជាបទពិសោធន៍នៃក្រុមស្រាវជ្រាវ ដែលនៅក្នុងវប្បធម៌បុរាណរបស់កម្ពុជា មនុស្សស្ទាក់ស្ទើរក្នុងការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំផ្លូវការ។ រឿងនេះ អាចចូលរួមចំណែកទៅដល់កម្រិតទាបនៃការចូលរួមយ៉ាងសកម្មរបស់ គ.ក.ន.ក.។

ទោះបីជាយ៉ាងណាក៏ដោយ ក៏មានករណីដាច់ដោយឡែកចំពោះរឿងនេះដែរ។ កម្មវិធីអង្គការមិនមែនរដ្ឋាភិបាលពីរបី បានគាំទ្រក្រុមកុមារ ដែលពង្រឹងការយល់ដឹងពីសិទ្ធិរបស់កុមារ ចំណេះដឹងផ្នែកការរំលោភបំពាន និងជំនាញទំនាក់ទំនង។ កម្មវិធីទាំងនេះ បានធ្វើឲ្យការចូលរួមរបស់កុមារនៅក្នុង គ.ក.ន.ក. កាន់តែមានភាពងាយស្រួល ជាលទ្ធផល ការចូលរួមមានការកើនឡើង ដូចដែលរៀបរាប់ដោយផ្ទាល់នៅខាងក្រោមនេះ (នៅក្នុងផ្នែកឥទ្ធិពលក្រុមកុមារ យុវជន និងក្រុមគ្រួសារ)។

## ៧.៧ ឥទ្ធិពលរបស់កុមារ យុវជន និងក្រុមគ្រួសារ

**រឿងនេះអាចនិយាយបានថា កុមារកំពុងមានការចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋានតាមវិធីនេះ។**

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជាច្រើន និងដៃគូក្នុងស្រុក បានបង្កើតក្រុម ឬក្លឹបនានាសម្រាប់កុមារ និងឪពុកម្តាយ (ពិភាក្សានៅក្នុងផ្នែក CNCPP គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល)។ ក្រុមទាំងនេះបានផ្តល់អត្ថប្រយោជន៍សំខាន់ៗចំនួនបី។ ទីមួយ ពួកគេបានកសាងមូលដ្ឋានចំណេះដឹងសមាជិក ដែលធ្វើឲ្យពួកគេកាន់តែអាចចូលរួមបានច្រើនឡើង។ ទីពីរ ក្រុមទាំងនេះក៏បានជួយកសាងជំនាញទំនាក់ទំនងរបស់សមាជិក និងរៀបចំពួកគេសម្រាប់ការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំរបស់ គ.ក.ន.ក.។ រឿងនេះ គឺជាការសន្និដ្ឋានយ៉ាងសំខាន់ថា បរិបទវប្បធម៌ មិនរំពឹងថាកុមារចូលរួមនៅក្នុងការបញ្ចេញមតិ ឬធ្វើសេចក្តីសម្រេចចិត្តនោះឡើយ។ ទីបី ក្រុមទាំងនេះ បានបង្កើតនូវទំនាក់ទំនងច្បាស់លាស់ រវាងសមាជិកក្រុម និងអាជ្ញាធរមូលដ្ឋាន។ នេះគឺជាបទពិសោធន៍របស់អ្នកស្រាវជ្រាវដែលថា ទំនាក់ទំនងផ្ទាល់ខ្លួនមានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងវប្បធម៌កម្ពុជា ហើយទំនាក់ទំនងផ្ទាល់ខ្លួន ដែលបង្កើតឡើងដោយក្រុមទាំងនេះ ត្រូវបានគេចាត់ទុកជាការកត្តាជំរុញឲ្យមានការចូលរួមក្នុងកិច្ចប្រជុំ។ ក្រុមទាំងនេះបានរៀបចំកុមារឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ គ.ក.ន.ក. ហើយនៅក្នុងករណីពីរបី ក្រុមទាំងនេះក្លាយទៅជាសមាជិកនៃ គ.ក.ន.ក.។ ការវាយតម្លៃកម្មវិធី បានកត់សម្គាល់ថា ក្រុមកុមារ មានកម្រិតចំណេះដឹងកាន់តែច្រើនឡើង និងមានភាពបើកទូលាយពាក់ព័ន្ធនឹងការរំលោភបំពានកុមារ ហើយរឿងនេះ បានធ្វើឲ្យការរាយការណ៍អំពីករណីរំលោភបំពានរាងកាយទាំងនៅសាលារៀន និងនៅផ្ទះមានការកើតឡើង (អង្គការសង្គ្រោះកុមារ ឆ្នាំ២០០៩, Moore ឆ្នាំ២០០៩)។ រឿងនេះអាចនិយាយបានថា កុមារកំពុងមានការចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋានតាមវិធីនេះ។

## ៧.៨ ឥទ្ធិពលនៃបុគ្គលិកសង្គម

ដូចបានកត់សម្គាល់ពីចំណុចខាងលើរួចហើយថា (នៅក្នុងផ្នែកការផ្តល់បុគ្គលិកសង្គម មានការបណ្តុះបណ្តាល) អង្គការមិនមែនរដ្ឋាភិបាលមួយ បានបណ្តុះបណ្តាលបុគ្គលិកសង្គមឲ្យ ផ្តល់សេវាសង្គមនៅថ្នាក់ភូមិ។ បុគ្គលិកសង្គមទាំងនេះ បានទទួលបានបណ្តុះបណ្តាលដំបូងមួយ ដែលត្រូវបានធ្វើបន្តទៀត ជាមួយការបណ្តុះបណ្តាលតាមដំណាក់កាល។ ពួកគេក៏ទទួលបានការគាំទ្រផ្នែកបច្ចេកទេសជាបន្តបន្ទាប់ផងដែរ។ ការបណ្តុះបណ្តាលកម្រិតខ្ពស់បែបនេះ បានជួយឲ្យពួកគេផ្តល់សេវាសង្គម ប្រកបដោយប្រសិទ្ធភាព ទៅដល់សមាជិកសហគមន៍។ បុគ្គលិកសង្គមទាំងនេះ ធ្វើការយ៉ាងជិតស្និទ្ធជាមួយ គ.ក.ន.ក. ដោយទទួលបានការពិនិត្យជាបន្តបន្ទាប់។ គ.ក.ន.ក. នៅក្នុងតំបន់ទាំងនេះ បានរាយការណ៍នូវទំនាក់ទំនងល្អជាមួយបុគ្គលិកសង្គម និងក្រុមគ្រួសារ និងកុមារ នៅក្នុងតំបន់ទាំងនេះ ដែលរាយការណ៍អំពីអត្ថប្រយោជន៍បានមកពីសេវារបស់ពួកគេ។ នៅក្នុងសហគមន៍ បុគ្គលិកសង្គម មិនអាចផ្តល់សេវាព្យាបាលបានទេ ដែលផ្តល់នូវវិធីថ្មីទៅដល់ការឆ្លើយតបជារួមដទៃទៀតរបស់ គ.ក.ន.ក. ក្នុងការផ្សះផ្សារ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារដែលគ្មានការគាំទ្របន្ត ឬផ្ញើរទៅ RCI។

**បុគ្គលិកសង្គមទាំងនេះ ធ្វើការយ៉ាងជិតស្និទ្ធជាមួយ គ.ក.ន.ក. ដោយទទួលបានការពិនិត្យជាបន្តបន្ទាប់។**

**នៅក្នុងសហគមន៍ បុគ្គលិកសង្គម មិនអាចផ្តល់សេវាព្យាបាលបានទេ ដែលផ្តល់នូវវិធីថ្មីទៅដល់ការឆ្លើយតបជារួមដទៃទៀតរបស់ គ.ក.ន.ក. ក្នុងការផ្សះផ្សារ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារដែលគ្មានការគាំទ្របន្ត ឬផ្ញើរទៅ RCI។**

យន្តការការពារកុមារផ្លូវការ និងក្រៅផ្លូវការមួយចំនួន មាននៅកម្រិតឃុំ/សង្កាត់ក្នុងប្រទេសកម្ពុជា។ គ.ក.ន.ក. ផ្តល់តែអង្គភាពការពារកុមារផ្លូវការរបស់រដ្ឋាភិបាលនៅថ្នាក់ឃុំ/សង្កាត់ ប៉ុណ្ណោះ។ អាណត្តិរបស់ពួកគេផ្តោតលើការរៀបចំផែនការ ការលើកកម្ពស់ការយល់ដឹង តស៊ូមតិ និងតាមដាន ព្រមទាំងការបង្កើនទំនាក់ទំនង និងកិច្ចសហការរវាង គ.ក.ន.ក. សេវា និងសមាជិកសហគមន៍។ ទោះជាយ៉ាងណា គ.ក.ន.ក. បានដើរហួសពីអាណត្តិរបស់ពួកគេ ដើម្បីផ្តល់សេវានានា ដូចជា ការដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ។

គ.ក.ន.ក. ក៏បានកសាងភាពជាដៃគូយ៉ាងរឹងមាំ ជាមួយអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន បានផ្តល់សេវានានា ដែលគេអាចទទួលបានតាមរយៈការបញ្ជូនមក គ.ក.ន.ក.។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូច បានផ្តោតលើការការពារកុមារ គាំទ្រមុខងាររបស់ គ.ក.ន.ក. ដើម្បីឲ្យសហគមន៍អាចបំពេញអាណត្តិរដ្ឋាភិបាលរបស់ពួកគេ។ តាមរយៈអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ គ.ក.ន.ក. ទទួលបានការគាំទ្រផ្នែកមុខងារ ការបណ្តុះបណ្តាល ការតាមដាន ការរៀបចំផែនការ និងការផ្តល់សេវានានា។ អង្គការមិនមែនរដ្ឋាភិបាល ក៏បានធ្វើកិច្ចអន្តរាគមន៍នានា ដែលជួយជំរុញឲ្យមានការការពារកុមារនៅក្នុងភូមិ និងបង្កើនការចូលរួមនៅក្នុង គ.ក.ន.ក. ផងដែរ ហើយរាយការណ៍ការរំលោភបំពានទៅ គ.ក.ន.ក.។ ទាំងនេះរួមបញ្ចូលទាំងក្រុមកុមារ និងក្រុមឪពុកម្តាយ បណ្តាញការពារភូមិ និងការផ្តល់ការបុគ្គលិកសង្គមមានការបណ្តុះបណ្តាល ដើម្បីធ្វើការជាមួយករណីនានាដែល គ.ក.ន.ក. រាយការណ៍ (ក្នុងចំណោមអ្នកដទៃ)។

គ.ក.ន.ក. បានរាយការណ៍ថា បញ្ហាជារួមពាក់ព័ន្ធនឹងការការពារកុមារនៅក្នុងសហគមន៍របស់ពួកគេ គឺការបោះបង់ការសិក្សា និងពលកម្មកុមារ អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងចំណាកស្រុក។ គ.ក.ន.ក. បានឆ្លើយតបនឹងបញ្ហាទាំងនេះដោយទទួលបានជោគជ័យតាមកម្រិតផ្សេងៗ។ ការបោះបង់ការសិក្សា មានពាក់ព័ន្ធយ៉ាងជិតដិតទៅនឹងពលកម្មកុមារពីសំណាក់អ្នកចូលរួម ហើយត្រូវបានគេដោះស្រាយភាគច្រើនតាមរយៈការផ្តល់ដំបូន្មានឲ្យបន្តការសិក្សា ផ្តល់ថ្លៃសិក្សា ឬសម្ភារៈ។ នៅក្នុងតំបន់ដែល គ.ក.ន.ក. ទទួលបានការគាំទ្រពីកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ ដើម្បីបង្ការពលកម្មកុមារ ការគាំទ្រការប្រយុទ្ធប្រឆាំងនឹងការបោះបង់ការសិក្សា រឹតតែមានលក្ខណៈទូលំទូលាយ និងរួមបញ្ចូលការគាំទ្រជីវភាព ប៉ុន្តែ ទម្រង់នៃការគាំទ្រនេះ មិនមែនផ្តល់ឲ្យដោយ គ.ក.ន.ក. តែម្នាក់ឯងនោះឡើយ។ អំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេដោះស្រាយតាមរយៈការលើកកម្ពស់ការយល់ដឹង និងការផ្សះផ្សារ។ ឥរិយាបថទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ហាក់មានការផ្លាស់ប្តូរ ហើយភាគច្រើននៃអ្នកចូលរួម បានផ្តល់ដំបូន្មានឲ្យរាយការណ៍អំពីជនល្មើស។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានគម្លាតរវាងឥរិយាបថ និងសកម្មភាព ហើយការឆ្លើយតបជារួមទៅនឹង ហេតុការណ៍ អំពើហិង្សាក្នុងគ្រួសារ មានពាក់ព័ន្ធនឹងការផ្តល់ដំបូន្មានដល់ជនរងគ្រោះ និងជនប្រព្រឹត្តអំពើហិង្សាឲ្យកែប្រែ និងការផ្សះផ្សារក្នុងក្រុមគ្រួសារ។ រឿងនេះគឺជាក្តីបារម្ភ ដោយសារការផ្សះផ្សារបានធ្វើឲ្យស្ត្រី និងកុមារកាន់តែមានហានិភ័យខ្ពស់។ ការរំលោភសេពសន្ថវៈ ត្រូវបានគេជឿថា មិនត្រូវបានគេរាយការណ៍នោះឡើយ ហើយនៅក្នុងការសិក្សា មានតែករណីរំលោភសេពសន្ថវៈប៉ុណ្ណោះដែលត្រូវបានគេរាយការណ៍។ បញ្ហាទាំងនេះ ត្រូវបានដោះស្រាយតាមរយៈការគាំទ្រឲ្យទទួលបានការកាត់ទោសជនល្មើស។ ស្ទើរតែគ្មានសេវាណាមួយផ្តល់ជូនជនរងគ្រោះរំលោភសេពសន្ថវៈ នៅក្នុងសហគមន៍របស់ពួកគេឡើយ ហើយជនរងគ្រោះខ្លះ ត្រូវបានគេបញ្ជូនទៅមណ្ឌលការពារ។ បញ្ហាចំណាកស្រុក ត្រូវបានគេដោះស្រាយតាមរយៈការលើកកម្ពស់ការយល់ដឹងដើម្បីជំរុញការបង្ការ និងជំរុញឲ្យក្រុមគ្រួសារទុកដាក់កូនៗរបស់ពួកគេជាមួយសាច់ញាតិ និងតាមរយៈការផ្តល់សេវាដល់កុមារ ដែលនៅជាមួយសមាជិកក្រុមគ្រួសារ របស់ពួកគេ។

ការងាររបស់ គ.ក.ន.ក. អាចប្រឈមនឹងការព្រួយបារម្ភផ្នែកសមត្ថភាព។ គ.ក.ន.ក. ភាគច្រើន បានទទួលការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ និងខ្វះជំនាញសម្រាប់បំពេញភារកិច្ចរដ្ឋបាល និងភារកិច្ចបច្ចេកទេសរបស់ពួកគេ។ ការផ្តល់មូលនិធិមុនៗសម្រាប់ដំណើរការមុខងារ គ.ក.ន.ក. ត្រូវបានគេដកចេញ ហើយ គ.ក.ន.ក. ខ្វះខាតមូលនិធិសម្រាប់សកម្មភាពមូលដ្ឋាន (ឧទាហរណ៍ ថវិកាសម្រាប់ចំណាយលើប្រេង

ឥន្ទនៈ នៅពេលសមាជិក គ.ក.ន.ក. ចុះទៅសាកសួរសមាជិកសហគមន៍)។ តម្រូវការការពារកុមារ ដែលមិនដែលជួប គ.ក.ន.ក. នៅក្នុងសហគមន៍មានចំនួនច្រើន ហើយ គ.ក.ន.ក. បានស្នើសុំជាបន្តបន្ទាប់ឲ្យដោះស្រាយតម្រូវការទាំងអស់នេះ។ ពុំមានបណ្តាញសេវាសង្គមកិច្ចថ្នាក់ជាតិ នៅក្នុងប្រទេសកម្ពុជានោះឡើយ ហើយការផ្តល់សេវាភាគច្រើន កើតចេញពីអង្គការមិនមែនរដ្ឋាភិបាល។ វិសាលភាពនៃការគ្របដណ្តប់របស់អង្គការមិន មែនរដ្ឋាភិបាល នៅមានកម្រិត ទាំងផ្នែកភូមិសាស្ត្រ និងប្រភេទនៃសេវា។ សមាជិក គ.ក.ន.ក. តែងតែមិនអាចផ្សារភ្ជាប់កុមារទៅនឹងសេវាដែលពួកគេត្រូវការនោះឡើយ។ នៅពេល គ.ក.ន.ក. ផ្តល់សេវាទាំងនេះ សេវាទាំងនេះអាចមិនទៅតាមការអនុវត្តដ៏ល្អផ្អែកលើភស្តុតាងនោះឡើយ ហើយនៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ អាចធ្វើឲ្យជនរងគ្រោះកាន់តែមានហានិភ័យបន្ថែមទៀត។ ការពឹងផ្អែកលើសលប់ទៅលើ RCI និងមណ្ឌលសង្គ្រោះដើម្បីផ្តល់សេវានោះ កើតមានផងដែរនៅក្នុងសហគមន៍ ប្រសិនបើយន្តការការពារកុមារកើតមាន។

ឆ្លើយតបទៅនឹងការរកឃើញនៅក្នុងការសិក្សានេះ ការផ្លាស់ប្តូរខាងក្រោមត្រូវបានគេលើកឡើង។

## មូលនិធិ និងធនធាន

### លទ្ធផលរកឃើញសំខាន់ៗ:

- សេវាការពារកុមារនៅថ្នាក់ភូមិ ពុំមានមូលនិធិគាំទ្រគ្រប់គ្រាន់ ដោយគ្មានមូលនិធិច្បាស់លាស់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងមូលនិធិមិនគ្រប់គ្រាន់សម្រាប់ គ.ក.ន.ក។
- ថវិកាឃុំសង្កាត់ ច្រើនតែផ្តល់អាទិភាពទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ជាជាងសេវាសង្គមកិច្ច ហើយដំណើរការនៃការប្រើប្រាស់មូលនិធិសម្រាប់សេវាសង្គមកិច្ច មានភាពស្មុគស្មាញជាងវិស័យ និងគម្រោងដទៃទៀត។ ប្រការនេះ អាចឆ្លុះបញ្ចាំងនូវកង្វះចំណេះដឹងអំពីសេវា ដែលអាចផ្តល់មូលនិធិ ដោយថវិកាឃុំសង្កាត់។
- នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលគាំទ្រដំណើរការធ្វើផែនការ និងថវិកា លទ្ធផលគឺកំណើននៃការវិភាជថវិកាពីកញ្ចប់ថវិកានៃផែនការអភិវឌ្ឍន៍ឃុំសង្កាត់ (CIP) សម្រាប់សេវាសង្គមកិច្ច។

### អនុសាសន៍សម្រាប់រដ្ឋាភិបាល:

- ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា គួរអនុម័តយុទ្ធសាស្ត្រច្បាស់លាស់ជាងមុន ដើម្បីបង្កើតប្រព័ន្ធផ្តល់សេវាសង្គមកិច្ចទូលំទូលាយមួយ ដែលនឹងបង្កើនសេវាសង្គមកិច្ច ការពារកុមារនៅថ្នាក់ភូមិ និងថ្នាក់ឃុំ សម្រាប់រយៈពេលវែង និងរៀបចំសំណើសុំមូលនិធិច្បាស់លាស់ទៅរាជរដ្ឋាភិបាលកម្ពុជាដើម្បីបានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តប្រព័ន្ធនេះ។
- ជាផ្នែកមួយនៃយុទ្ធសាស្ត្រនេះ ការផ្តល់មូលនិធិដល់ គ.ក.ន.ក តាមរយៈក្រសួងមហាផ្ទៃ គួរត្រូវបានបង្កើនជាមួយនឹងការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើសកម្មភាពទប់ស្កាត់ ការប្រមូលទិន្នន័យ ការចំណាយសម្រាប់ការចុះទៅដល់ផ្ទះ និងការឆ្លើយតបទៅនឹងករណីរំលោភ បំពានកុមារ ព្រមទាំងអំពើហិង្សាក្នុងគ្រួសារ។
- ដំណើរការឃុំសង្កាត់សម្រាប់ការស្នើសុំ និងទទួលបានមូលនិធិសម្រាប់សេវាសង្គមកិច្ច គួរតែពិនិត្យមើលឡើងវិញ និងធ្វើឲ្យមានលក្ខណៈងាយស្រួល។
- គ.ក.ន.ក គួរអប់រំពលរដ្ឋអំពីសេវាសង្គមកិច្ច ដែលអាចផ្តល់មូលនិធិបានតាមរយៈ CIP។

### អនុសាសន៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងដៃគូផ្សេងៗ:

- អង្គការមិនមែនរដ្ឋាភិបាល គួរបន្តផ្តល់ការគាំទ្រដល់ គ.ក.ន.ក ដើម្បីបំពេញតួនាទីអាណត្តិរបស់ខ្លួន ដោយស្របទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងនោះរាប់បញ្ចូលទាំងការគាំទ្រសេវាការពារ កុមារនៅថ្នាក់មូលដ្ឋាន និងផ្តល់មតិយោបល់សម្រាប់ការបង្កើតប្រព័ន្ធជាតិមួយសម្រាប់សេវាសង្គមកិច្ច។
- អង្គការមិនមែនរដ្ឋាភិបាលគួរបន្តពង្រីកការគាំទ្រដល់ គ.ក.ន.ក និងក្រុមប្រឹក្សាឃុំសង្កាត់ នៅក្នុងដំណើរការធ្វើផែនការ និងថវិកា ព្រមទាំងការតស៊ូមតិដើម្បីជំរុញការបង្កើនវិភាជន៍ថវិកាសម្រាប់សេវាសង្គមកិច្ច (នៅថ្នាក់ឃុំ ស្រុក និងខេត្ត)។
- អង្គការមិនមែនរដ្ឋាភិបាល គួរគាំទ្រការចូលរួមរបស់ពលរដ្ឋ ដើម្បីឲ្យមានឥទ្ធិពលទៅលើការរៀបចំថវិកា និងតាមដានថវិកាថ្នាក់ឃុំសង្កាត់។

## លទ្ធផលរកឃើញសំខាន់ៗ:

- គ.ក.ន.ក ជាច្រើនបានធ្វើលើសពីតួនាទីរបស់ខ្លួន ដែលបានកំណត់នៅក្នុងគោលនយោបាយ និងបានផ្តល់សេវាការពារកុមារ។ ជារឿយៗ សេវាទាំងនេះមិនគ្រប់គ្រាន់ឡើយ ហើយក្នុងករណីមួយចំនួន បានដាក់ឲ្យកុមារបន្តប្រឈមនឹងហានិភ័យ។
- សមត្ថភាពបច្ចេកទេសនៅមានកម្រិតរបស់ គ.ក.ន.ក បណ្តាលឲ្យការឆ្លើយតបចំពោះករណីការពារកុមារ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ ឧទាហរណ៍ ការពឹងផ្អែកខ្លាំងពេកទៅលើការផ្សះផ្សា ធ្វើឲ្យជនរងគ្រោះបន្តប្រឈមនឹងហានិភ័យ។ ករណីរំលោភបំពានផ្លូវភេទ ក្រៅពីការរំលោភសេពសន្ថវៈជានិច្ចកាលមិនត្រូវបានកំណត់ និងការពឹងផ្អែកខ្លាំងពេកទៅលើមណ្ឌល និងស្ថាប័នថែទាំតាមផ្ទះជាការឆ្លើយតបបឋមសម្រាប់កុមារ ដែលត្រូវបានរំលោភសេពសន្ថវៈ។
- ការចូលរួមរបស់ក្រុមសង្គមស៊ីវិលនៅមូលដ្ឋាន ជាពិសេសក្រុមឪពុកម្តាយ និងក្រុមកុមារ អាចនាំឲ្យមានកំណើនក្នុងការរាយការណ៍ អំពីការរំលោភបំពានលើកុមារទៅអាជ្ញាធរ ហើយអាចជះឥទ្ធិពលវិជ្ជមានទៅលើការប្រព្រឹត្តទៅរបស់ គ.ក.ន.ក។
- ជារឿយៗ អង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកផ្តល់សេវាការពារកុមារសំខាន់ជាងគេ ប៉ុន្តែកម្មវិធីទាំងនេះត្រូវបានសម្រេចនៅថ្នាក់ជាតិ ដោយមានការចូលរួមមតិយោបល់តិចតួចប៉ុណ្ណោះ ពី គ.ក.ន.ក ហើយមិនគ្របដណ្តប់ប្រជាជនទាំងអស់នោះទេ។
- កង្វះការជឿទុកចិត្តលើប្រព័ន្ធតុលាការ បានបន្ទុចបង្អាក់ដល់កិច្ចប្រឹងប្រែង ដើម្បីបញ្ជូនជនល្មើសទៅផ្តន្ទាទោស ហើយប្រព័ន្ធយុត្តិធម៌នេះទៀតសោត មិនមានលក្ខណៈកុមារមេត្រី ដែលមិនរក្សាការសម្ងាត់ ឬត្រូវអស់កម្រៃច្រើន។
- ការថែទាំមិនផ្លូវការដោយសាច់ញាតិ គឺជាផ្នែកស្នូលនៃការការពារកុមារនៅតាមសហគមន៍។ កម្មវិធីអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលគាំទ្របុគ្គលិកសង្គមកិច្ច ដែលទទួលជនរងគ្រោះពី គ.ក.ន.ក ដំណើរការប្រកបដោយប្រសិទ្ធភាព និងភាពជោគជ័យ។

## អនុសាសន៍សម្រាប់រដ្ឋាភិបាល:

- ក្រសួងមហាផ្ទៃគួរតែពិនិត្យឡើងវិញ និងកែសម្រួលតួនាទីរបស់ គ.ក.ន.ក ដើម្បីឲ្យមានភាពច្បាស់លាស់ជាងនេះ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ពួកគេ ក្នុងនោះរាប់បញ្ចូលទាំងមុខងារតាមដាន និងការចូលរួមរបស់កុមារ នារី បុគ្គលិកសង្គមកិច្ច និងមេដឹកនាំសាសនា នៅក្នុងគណៈកម្មាធិការ។
- មុខងារតាមដានរបស់ គ.ក.ន.ក គួរតែត្រូវពង្រឹងបន្ថែម ដោយគាំទ្រ គ.ក.ន.ក ឲ្យប្រើប្រាស់ព័ត៌មានដែលប្រមូលបាន ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយសេវាអង្គការមិនមែនរដ្ឋាភិបាល និងធានាឲ្យ
- បាននូវការសម្របសម្រួលសេវានានា ជាមួយអ្នកផ្តល់សេវានៅតាមមូលដ្ឋាន។ ការផ្តោតយកចិត្តទុកដាក់បន្ថែមទៀត និងគោលការណ៍ណែនាំស្តីពីការចូលរួមរបស់កុមារ និងយុវជននៅក្នុង គ.ក.ន.ក គឺត្រូវការជាចាំបាច់ដែលត្រូវតែមាន និងធានាថា ការចូលរួមរបស់ពួកគេ ស្របទៅនឹងឧត្តមប្រយោជន៍របស់ពួកគេ។
- គ.ក.ន.ក គួរជំរុញការថែទាំនៅតាមសហគមន៍ និងទប់ស្កាត់ការដាក់កុមារឲ្យស្ថិតក្រោមការថែទាំតាមផ្ទះដែលមិនចាំបាច់។
- ក្រសួងមហាផ្ទៃគួរសហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់ការបណ្តុះបណ្តាលកសាងសមត្ថភាពបន្ថែមទៀតដល់ គ.ក.ន.ក លើប្រធានបទដូច ខាងក្រោម៖
    - ការធ្វើថវិកាសម្រាប់បញ្ហាការពារកុមារ
    - ការកំណត់អត្តសញ្ញាណ និងការតាមដានកុមារងាយរងគ្រោះ
    - ការធានាឲ្យបាននូវសុវត្ថិភាពកុមារ នៅពេលឆ្លើយតបទៅនឹងករណីអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទ
    - អត្ថប្រយោជន៍នៃការផ្សារភ្ជាប់កម្មវិធីថែទាំតាមសហគមន៍ និងផលប៉ះពាល់អវិជ្ជមាន នៃការថែទាំតាមផ្ទះទៅលើការអភិវឌ្ឍកុមារ
    - ដំណើរការបញ្ជូនបន្តទៅរកសេវា (សេវារដ្ឋាភិបាលក្តី ឬសេវាអង្គការមិនមែនរដ្ឋាភិបាល)។
- ពង្រឹងការអនុវត្តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ដើម្បីធានាឲ្យបាននូវការផ្តន្ទាទោស (និងការដាក់ពន្ធនាគារ) ជនល្មើស និងធ្វើការកែលម្អការគាំទ្រដល់ជនរងគ្រោះ។
- ពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ សមាជិក គ.ក.ន.ក និងនគរបាល ដើម្បីធានាថាពលរដ្ឋនឹងមិនត្រូវបានតម្រូវឲ្យបង់ប្រាក់ក្រៅផ្លូវការ សម្រាប់ដំណើរការនីតិវិធីរឿងក្តី និងធានាថាប្រព័ន្ធយុត្តិធម៌ផ្តល់ការរក្សាការសម្ងាត់ និងលទ្ធភាពដល់ កុមារ។

**អនុសាសន៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងដៃគូផ្សេងៗ:**

- ក្នុងរយៈពេលមធ្យម អង្គការមិនមែនរដ្ឋាភិបាលគួរតែពង្រីកកម្មវិធីផ្តល់បុគ្គលិក/សេវាសង្គមកិច្ច (សម្រាប់ជនរងគ្រោះ និងកុមារងាយរងគ្រោះ និងក្រុមគ្រួសារ) ដែល គ.ក.ន.ក អាចបញ្ជូនទៅរក និងគាំទ្រការពង្រឹងយន្តការសម្របសម្រួលរវាង គ.ក.ន.ក និងអ្នកផ្តល់សេវា (ក្នុងនោះរាប់បញ្ចូលទាំងការកំណត់ចន្លោះខ្វះខាត់ផ្អែកភូមិសាស្ត្រនៅក្នុងការផ្តល់សេវា)។
- បន្តតស៊ូមតិជំរុញឲ្យមានវិភាជន៍ថវិកាឃុំសង្កាត់សម្រាប់បុគ្គលិកសង្គមកិច្ច។
- ពង្រឹងចំណេះដឹង និងការយល់ដឹងរបស់បុគ្គលិកអំពីតួនាទីរបស់ គ.ក.ន.ក (ដូចដែលបានកំណត់នៅក្នុងគោលនយោបាយ) ព្រម ទាំងធានាឲ្យបានថាដៃគូនានាគាំទ្រដល់សមត្ថភាពរបស់ គ.ក.ន.ក ក្នុងការកំណត់ និងការបញ្ជូនសំណុំរឿងការពារកុមារ។
- បន្តគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយការថែទាំតាមផ្ទះ ដោយធ្វើផែនទីជម្រើសនានាសម្រាប់ការថែទាំតាមសហគមន៍ និងការផ្សារភ្ជាប់ឱកាសថ្មីៗជាមួយនឹង គ.ក.ន.ក។
- គាំទ្រកម្មវិធី និងយន្តការដែលផ្តល់ឱកាសឲ្យពលរដ្ឋបញ្ចេញ មតិយោបល់អំពីតម្រូវការរបស់ពួកគេទៅកាន់ គ.ក.ន.ក និងជះឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្ត ស្តីពីសេវាការពារកុមារនៅថ្នាក់មូលដ្ឋាន។
- សហប្រតិបត្តិការជាមួយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ នៅថ្នាក់ស្រុក/ខណ្ឌ និងខេត្ត/ក្រុង ដើម្បីធានាឲ្យបានថាការបញ្ជូនទៅរកសេវា និងការផ្សារភ្ជាប់បណ្តាញរវាងអង្គការក្រៅរដ្ឋាភិបាល និង គ.ក.ន.ក ត្រូវបានសម្របសម្រួលបានល្អ។
- បន្តវាយតម្លៃ ស្រាវជ្រាវ និងរិះរកឱកាសសម្រាប់ការថែទាំដោយសាច់ញាតិ នៅក្នុងប្រទេសកម្ពុជា និងបង្កើតគំរូដែលអាចអនុវត្តបានដោយភាពជោគជ័យ។

## របនាសម្ព័ន្ធរដ្ឋបាល និងគណនេយ្យភាព

**លទ្ធផលរកឃើញសំខាន់ៗ:**

- សមាជិក គ.ក.ន.ក មានបន្ទាត់រាយការណ៍ច្របូកច្របល់គ្នាទៅកាន់ក្រសួងខុសៗគ្នា ដែលនាំឲ្យប៉ះពាល់ដល់ការផ្តោតការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តរបស់សមាជិក (ពីនគរបាលមណ្ឌលសុខភាព សាលារៀន និងជូនកាល ពីក្រុមប្រឹក្សាឃុំសង្កាត់)។
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (WCCC) មិនបានចូលរួមជាមួយ គ.ក.ន.ក ឬគាំទ្រ គ.ក.ន.ក ក្នុងលក្ខណៈដ៏មានអត្ថន័យណាមួយឡើយ។

**អនុសាសន៍សម្រាប់រដ្ឋាភិបាល:**

- ក្រសួងមហាផ្ទៃត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវតួនាទី និងទំនួលខុសត្រូវរបស់សមាជិក គ.ក.ន.ក និងកសាងយន្តការដែលមានគណនេយ្យភាព។ បទដ្ឋានថ្មីៗ (ដែលអាចតាមដានបាន) គួរតែកំណត់ឲ្យបានច្បាស់លាស់នៅក្នុងឯកសារគោលនយោបាយ។ បទដ្ឋានថ្មីៗទាំងនេះ ក៏គួរលម្អិតផងដែរអំពីតួនាទី ទំនួលខុសត្រូវ និងការចូលរួមរបស់មន្ត្រីមកពីនគរបាល មណ្ឌលសុខភាព សាលារៀន ក្រុមប្រឹក្សាឃុំសង្កាត់ និងតួអង្គរដ្ឋាភិបាលដទៃទៀត។
- ទំនួលខុសត្រូវសម្រាប់ការចែករំលែកព័ត៌មាន (ដូចជាការចែករំលែកព័ត៌មានរបស់នគរបាល ស្តីពីករណីរំលោភបំពានលើកុមារ ដែលបានរាយការណ៍) គួរតែកំណត់ឲ្យបានច្បាស់លាស់ជាងមុន និងធានាថាសមាជិក គ.ក.ន.ក ដទៃទៀតឆ្លើយតបតាមតួនាទីរបស់ខ្លួន នៅពេលដែលទទួលបានព័ត៌មានចែករំលែក។
- ក្រសួងមហាផ្ទៃគួរបញ្ជាក់ឲ្យបានច្បាស់លាស់អំពីវិធីដែល WCCC អាចសម្របសម្រួល និងគាំទ្រ គ.ក.ន.ក បានប្រសើរជាងមុន ដើម្បីបំពេញអាណត្តិរបស់ខ្លួនសម្រាប់ការការពារកុមារ។ ប្រការនេះនឹងតម្រូវឲ្យមានការធ្វើវិសោធនកម្មទៅលើប្រកាសដែលមានស្រាប់ ឬគោលនយោបាយថ្មី ដើម្បីលម្អិតអំពីពេលវេលានៃការប្រាស្រ័យទាក់ទងគ្នា យន្តការតាមដាន និងគណនេយ្យភាព និងការឆ្លើយតបរបស់ WCCC ចំពោះបញ្ហានានាដែលលើកឡើងដោយ គ.ក.ន.ក ដើម្បីសុំការគាំទ្របន្ថែម។

**អនុសាសន៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងដៃគូផ្សេងៗ:**

- អង្គការមិនមែនរដ្ឋាភិបាលគួរតែធានាថាកម្មវិធីរបស់ខ្លួនគាំទ្រសមាសភាពចម្រុះរបស់ គ.ក.ន.ក និងបង្កើនការផ្សារភ្ជាប់ទៅនឹងវិស័យផ្សេងទៀតឲ្យបានជាអតិបរមា។

Autencio, G., 2013. Community level assessment report on child protection systems Phnom Penh: World Vision Cambodia.

Brehm, W.C., Silova, I. and Mono, T., 2012. Hidden privatization of public education in Cambodia: the impact and implications of private tutoring. New York: Open Society Foundation Education Support Program.

Blagbrough, J. 2015. Work in progress effective approaches to end child labour London: World Vision.

Cambodia National Council for Children, 2015. Decision on the establishment of the national child protection commission. Phnom Penh: Cambodia National Council for Children.

Child Froniters, 2014. National child protection systems in the East Asia and Pacific region. Bangkok: Child Frontiers.

CDRI, 2015. Eliminating Exploitative Child Labour through education and livelihoods. Phnom Penh: CDRI.

Cruz, a. and Rattana, L., 2007. Understanding children's work in Cambodia, mapping and costing current programmes targeting the worst forms of child labour. Phnom Penh: UCW.

EMC, in press. The impact of migration on children in Cambodia Phnom Penh: UNICEF.

Gamer, G., and Mauney, R., 2013. Family protection network. Phnom Penh: Plan

Gourley, S., 2009. The Middle Way. Phnom Penh: NGOCRC.

Harachi, 2014, A review of social work practice: an emphasis on public and child welfare. Phnom Penh: UNICEF.

Hing, V., Lun, P., and Phann, D. 2014. The impacts of adult migration on children's well-being. Phnom Penh: CDRI.

Hilton, A., 2009. I thought it could never happen to boys. Phnom Penh: SSC/Hagar/World Vision Cambodia.

ICC/Hosea, 2001. Pagoda Based Care. Phnom Penh: ICC/Hosea.
ILO, 2013. 2012 Cambodia Labor Force and Child Labor Survey. Phnom Penh: ILO.

ILO, UNICEF and World Bank, 2006. Children's work in Cambodia: a challenge for growth and poverty reduction. Phnom Penh: ILO, UNICEF and World Bank.

Jordanwood, M., 2008. Child participation research. Phnom Penh: Save the Children.

Jordanwood, M., 2011. With the best intentions. Phnom Penh: UNICEF.

Kitzman, K. Gaylord, N.Holt A, Keny E., 2003. Child witness to domestic violence: A meta-analytic review. Journal of Consulting and Clinical Psychology. Vol. 71, No. 2, 339–352.

Licadho, 2015. Getting away with it: the treatment of rape in Cambodia's justice system. Phnom Penh: LICADHO.

Mauney, R., 2013 Family protection manual. Phnom Penh: Plan.

MoP, 2012. Report of the Cambodia Rural Urban Migration Project. Phnom Penh: MoP.

Moore, K., 2014. Evaluating the effectiveness of CBCPMs supported by Plan Cambodia.

MoSVY, 2006. Policy for the alternative care for children. Phnom Penh: MoSVY.
MoSVY, 2008, Minimum standards on alternative care for children. Phnom Penh: MoSVY.

Ministry of Women's Affairs (MoWA), 2008. A Fair Share for Women: Cambodia Gender Assessment. Phnom Penh: MoWA

National Institute of Statisitics, 2015. Cambodia demographic and health survey 2014. Phnom Penh: NIS.

National Institute of Statistics, MoSVY, Columbia University and MLT Consulting, 2016. National Estimation of Children in Residential Care Institutions in Cambodia. Phnom Penh: NIS and MoSVY.

O'Leary and Nee, 2001, Learning for Transformation. Phnom Penh: VBNK.

Ramage, I., 2015. Study on Commune/Sangkat Planning and Budgeting for Social Services: Understanding Expenditure Trend and Factors that promote and hamper Social Service Delivery. Phnom Penh: Angkor Research/UNICEF/MoI
RGC, 2008. Functioning of the Commune Committees on Women and Children. Phnom Penh: RGC.

RGC, 2010. Safe village and commune/sangkhat policy guidelines (and update). Phnom Penh: RGC.

RGC, 2010. National plan of action on the illumination of the worst forms of child labor by 2016. Phnom Penh: RGC.

Roby, J., 2011. Children in informal alternative care. New York: UNICEF.
Rosas, S., 2012. Lessons learned: MoSVY-UNICEF-Project Sky reunification pilot. Phnom Penh: Project Sky.

Smith-Brake, J., 2014. Community-based alternative care options in Cambodia. Phnom Penh: World Vision Cambodia.

Tritt, G., and Plummer, J., 2012. Voice, choice and decision: A study of local governance processes in Cambodia. Phnom Penh: World Bank/Asia Foundation.

UNICEF Cambodia, 2006, Seth Koma's Commune Committees for Women and Children and Commune Focal Points for Women and Children. Phnom Penh: UNICEF.

UNICEF and MoWA, 2008. Commune women and children Focal Point KAP study. Phnom Penh: UNICEF and MOWA.

UNICEF, 2014. Cambodia's violence against children survey 2013. Phnom Penh: UNICEF

---

# អរគុណ!





unicef PLAN INTERNATIONAL Save the Children ChildFund Cambodia World Vision